# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍វាយតម្លៃ
# អំពី
# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា
# ឆ្នាំ២០១៥

ផ្អែកលើក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)

**សម្របសម្រួលនិងរៀបចំដោយ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍វាយតម្លៃ

# អំពី

# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា

# ឆ្នាំ២០១៥

ផ្អែកលើក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)

**សម្របសម្រួលនិងរៀបចំដោយ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# មាតិកានុក្រម

អក្សរកាត់ .................................................................................................. i

អារម្ភកថា...................................................................................................... v

សេចក្តីសង្ខេប ............................................................................................. ១

១. សេចក្តីផ្តើម ........................................................................................... ១

២. និន្នាការទូទៅនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ............................................. ២

៣. ការវាយតម្លៃលើចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ......... ៣

៣.១ វិន័យថវិកា.................................................................................... ៣

៣.២ យុទ្ធសាស្ត្រវិភាជន៍ធនធាន ...................................................................... ៤

៣.៣ ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ........................................................... ៥

៣.៤ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានថវិកា ........................................................... ៥

៤. បម្រែបម្រួលការអនុវត្តធៀបនឹងការវាយតម្លៃ ឆ្នាំ២០១០ ................................................ ៨

៥. ទិសដៅបន្តនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ............................................ ៩

ក. សេចក្តីផ្តើម.............................................................................................. ១៣

ក.១ សាវតារ និងគោលបំណងនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........................ ១៣

ក.២ កិច្ចដំណើរការនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......................................១៤

ក.៣ វិធីសាស្ត្រនៃការវាយតម្លៃ............................................................................. ១៦

ក.៤ វិសាលភាពនៃការវាយតម្លៃ ........................................................................... ១៨

ក.៥ រចនាសម្ព័ន្ធរបាយការណ៍............................................................................... ១៨

ខ. ស្ថានភាពប្រទេសកម្ពុជា............................................................................... ២១

ខ.១ ការពិពណ៌នាអំពីស្ថានភាពសេដ្ឋកិច្ច.................................................................. ២១

ខ.១.១ ទិដ្ឋភាពទូទៅរបស់ប្រទេស.......................................................................... ២១

ខ.១.២ កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល.................................................................. ២២

ខ.១.៣ សមានគតិភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ...................................២៣

ខ.២ ការពិពណ៌នាអំពីការអនុវត្តថវិកា ....................................................................... ២៣

ខ.២.១ ការអនុវត្តថវិកា ..................................................................................... ២៣

ខ.២.២ ការវិភាជថវិកា.........................................................................................២៤

ខ.២.៣ គោលដៅនៃគោលនយោបាយសារពើពន្ធ ២០១៤-២០១៨..........................................២៤

ខ.៣ ក្របខ័ណ្ឌគតិយុត្ត និងក្របខណ្ឌស្ថាប័នសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ..................... ២៧

ខ.៣.១ ក្របខ័ណ្ឌអភិបាលកិច្ច ........................................................................ ២៧

ខ.៣.២ រចនាសម្ព័ន្ធនៃវិស័យសាធារណៈ........................................................................ ២៧

ខ.៣.៣ ក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូល-ចំណាយ........................................ ២៨

ខ.៣.៤ ការរៀបចំផែនការ និងថវិកា........................................................................ ៣០

ខ.៣.៥ ការងារលទ្ធកម្ម........................................................................ ៣០

ខ.៣.៦ ការអនុវត្តថវិកា ការគ្រប់គ្រងបំណុលនិងសាច់ប្រាក់ គណនេយ្យ និងការរៀបចំរបាយការណ៍......៣១

ខ.៣.៧ សវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ........................................................................៣២

ខ.៣.៨ រដ្ឋបាលថ្នាក់ក្រោមជាតិ........................................................................ ៣៣

**គ. ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: កិច្ចដំណើរការ និងស្ថាប័ន** .....៣៥

**គ.១ ភាពជឿទុកចិត្តនៃថវិកា**........................................................................ ៣៥

គ.១.១ ចំណាយសរុបធៀបនឹងច្បាប់ថវិកា (PI-1) ........................................................ ៣៥

គ.១.២ សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកា (PI-2)........................................................៣៧

គ.១.៣ ចំណូលសរុបធៀបនឹងច្បាប់ថវិកា (PI-3) ........................................................៤០

គ.១.៤ សន្និធិ និងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ (PI-4)........................................ ៤៣

**គ.២ ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា**........................................................ ៤៧

គ.២.១ ចំណាត់ថ្នាក់ថវិកា (PI-5) ........................................................................ ៤៧

គ.២.២ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា (PI-6) ..................៥០

គ.២.៣ ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ (PI-7) ............................ ៥២

គ.២.៤ តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) (PI-8) .. ៥៦

គ.២.៥ ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ (PI-9) .. ៥៨

គ.២.៦ លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ (PI-10) ...................... ៦២

**គ.៣ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**........................................................ ៦៥

គ.៣.១ កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ (PI-11) ........................ ៦៥

គ.៣.២ ទស្សនវិស័យពហុឆ្នាំនៅក្នុងការធ្វើផែនការថវិកា គោលនយោបាយចំណាយ និងការរៀបចំថវិកា(PI-12). ៧០

**គ.៤ ភាពអាចប៉ាន់ប្រមាណបាននិងការត្រួតពិនិត្យការអនុវត្តថវិកា**........................................ ៧៥

គ.៤.១ តម្លាភាពនៃកាតព្វកិច្ច និងបំណុលពន្ធ របស់អ្នកជាប់ពន្ធ (PI-13)........................................ ៧៥

គ.៤.២ ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ (PI-14).................. ៨១

គ.៤.៣ ប្រសិទ្ធភាពនៃការប្រមូលពន្ធ (PI-15) ........................................................ ៨៦

គ.៤.៤ ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពនៃថវិកាសម្រាប់ធានាចំណាយ (PI-16)........................៩០

គ.៤.៥ ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់ បំណុល និងការធានា (PI-17).................... ៩៣

គ.៤.៦ ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស (PI-18) .................... ៩៧

គ.៤.៧ តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម (PI-19).......... ១០២

គ.៤.៨ ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស (PI-20) .................... ១០៧

គ.៤.៩ ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង (PI-21).................... ១១១

**គ.៥ គណនេយ្យ ការកត់ត្រា និងរបាយការណ៍**.................... ១១៤

គ.៥.១ ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី (PI-22).................... ១១៤

គ.៥.២ អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា (PI-23).................... ១១៦

គ.៥.៣ គុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ (PI-24).................... ១១៧

គ.៥.៤ គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (PI-25) .................... ១២០

**គ.៦ ការត្រួតពិនិត្យនិងសវនកម្មខាងក្រៅ**.................... ១២៤

គ.៦.១ វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ (PI-26).................... ១២៤

គ.៦.២ ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ (PI-27).................... ១២៦

គ.៦.៣ ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិប្បញ្ញត្តិ(PI-28) .................... ១៣០

**គ.៧ ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍**.................... ១៣២

គ.៧.១ ភាពអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាដោយផ្ទាល់ (D-1).................... ១៣៣

គ.៧.២ ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី (D-2).................... ១៣៥

គ.៧.៣ ទំហំហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ (D-3).................... ១៣៧

## ឃ. បម្រែបម្រួលសមិទ្ធកម្ម ចាប់ពីឆ្នាំ២០១០ .................... ១៤១

**ឃ.១ និដ្ឋភាពរួមនៃលទ្ធផលវាយតម្លៃឆ្នាំ២០១០** .................... ១៤១

**ឃ.២ និដ្ឋភាពរួមនៃលទ្ធផលវាយតម្លៃឆ្នាំ២០១៥**.................... ១៤៣

**ឃ.៣ សង្ខេបបម្រែបម្រួលសមិទ្ធកម្មពីឆ្នាំ២០១០**.................... ១៤៧

## ង. ការវិវត្តនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ១៤៩

**ង.១ វឌ្ឍនភាព និងជំហានបន្ទាប់នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** .................... ១៤៩

**ង.២ កម្មវិធីកែទម្រង់វិស័យរដ្ឋបាល**.................... ១៥១

ង.២.១ ការកែទម្រង់រដ្ឋបាលសាធារណៈ.................... ១៥១

ង.២.២ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ.................... ១៥១

**ង.៣ ការគាំទ្រផ្នែកនយោបាយ និងស្ថាប័ន**.................... ១៥២

**ង.៤ យុទ្ធសាស្ត្រ ការដឹកនាំ និង យន្តការតាមដាននិងត្រួតពិនិត្យ** .................... ១៥៣

**ឧបសម្ព័ន្ធ** ...... ១៥៧
ឧបសម្ព័ន្ធ ១÷ សេចក្តីសង្ខេបស្ទង់បនាករនៃក្របខ័ណ្ឌរង្វាស់សមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ... ១៥៩
ឧបសម្ព័ន្ធ ២÷ សមាសភាពក្រុមការងារវាយតម្លៃ ...... ១៨១
ឧបសម្ព័ន្ធ ៣÷ បញ្ជីរាយនាមភាគីពាក់ព័ន្ធដែលត្រូវបានសម្ភាសន៍ ...... ១៨៣
ឧបសម្ព័ន្ធ ៤÷ បញ្ជីឯកសារយោង ...... ១៨៩
ឧបសម្ព័ន្ធ ៥÷ តារាងទិន្នន័យ ...... ១៩៥
ឧបសម្ព័ន្ធ ៥.១÷ បញ្ជីគ្រឹះស្ថានសាធារណៈរដ្ឋបាល ...... ១៩៥
ឧបសម្ព័ន្ធ ៥.២÷ បញ្ជីសហគ្រាសសាធារណៈ ...... ១៩៧
ឧបសម្ព័ន្ធ ៥.៣÷ ទិន្នន័យលម្អិត សម្រាប់ការគណនាគម្លាត នៃ PI-2 សមាសធាតុ (១) ...... ១៩៨
ឧបសម្ព័ន្ធ ៥.៤÷ កម្ចី និងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ២០១២-២០១៤ ...... ២០១
ឧបសម្ព័ន្ធ ៦÷ អនុសាសន៍កែលម្អកង្វះខាតនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ...... ២០៣
ឧបសម្ព័ន្ធ ៧÷ អង្គការលេខនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ...... ២១១
**យន្តការត្រួតពិនិត្យ និងធានាគុណភាព** ...... ២១៣

# បញ្ជីតារាង

តារាង ក÷ សេចក្តីសង្ខេបរួមអំពីពិន្ទុនៃការវាយតម្លៃសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥....៦
តារាង ខ÷ បម្រែបម្រួលលើលទ្ធផល/សមិទ្ធកម្ម ធៀបនឹងការវាយតម្លៃកន្លងទៅ.................................. ១០
តារាង ខ.១÷ ការអនុវត្តថវិកាទូទៅរបស់រដ្ឋាភិបាល ២០១១-២០១៤ (ពាន់លានរៀល).............................២៥
តារាង ខ.២÷ ការអនុវត្តថវិកាទូទៅរបស់រដ្ឋាភិបាល ២០១១-២០១៤ (% នៃចំណូលក្នុងស្រុកសរុប) ........... ២៦
តារាង គ.១÷ លទ្ធផលចំណាយសរុបនិងថវិកាដែលបានអនុម័ត................................................... ៣៦
តារាង គ.២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១ ......................................................................... ៣៦
តារាង គ.៣÷ គម្លាតជាភាគរយនៃថវិកាដែលបានគ្រោង ធៀបនឹងការអនុវត្តតាមក្រសួង-ស្ថាប័ន.................. ៣៨
តារាង គ.៤÷ ភាគរយនៃចំណាយជាក់ស្តែងដែលជាចំណាយមិនមានមុខសញ្ញា ...................................... ៣៩
តារាង គ.៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២ ......................................................................... ៣៩
តារាង គ.៦÷ ការអនុវត្តចំណូល ២០១១-២០១៣ .......................................................................៤១
តារាង គ.៧÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៣.......................................................................... ៤៣
តារាង គ.៨÷ ការវិភាគចំណាយលើការទូទាត់បំណុលកកស្ទះ..........................................................៤៦
តារាង គ.៩÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៤.............................................................................៤៦
តារាង គ.១០÷ ទិដ្ឋភាពនៃមាតិកាថវិកាឆ្នាំ២០១៤ ..................................................................... ៤៩
តារាង គ.១១÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៥............................................................................ ៤៩
តារាង គ.១២÷ បង្ហាញពីព័ត៌មានគន្លឹះរបស់ឯកសារថវិកាឆ្នាំ២០១៥............................................... ៥០
តារាង គ.១៣÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៦............................................................................៥១
តារាង គ.១៤÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៧ ........................................................................... ៥៥
តារាង គ.១៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៨............................................................................ ៥៨
តារាង គ.១៦÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៩............................................................................ ៦២
តារាង គ.១៧÷ សមាសធាតុនៃព័ត៌មានដែលចាំបាច់សម្រាប់សាធារណជន ....................................... ៦៣
តារាង គ.១៨÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១០.......................................................................... ៦៤
តារាង គ.១៩÷ ការវិភាគថវិកា ផ្អែកលើច្បាប់ហិរញ្ញវត្ថុនិងកាលបរិច្ឆេទជាក់ស្តែងនៃការរៀបចំថវិកាឆ្នាំ២០១៤...៦៦
តារាង គ.២០÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១១ ......................................................................... ៦៩
តារាង គ.២១÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១២.......................................................................... ៧៤
តារាង គ.២២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៣.......................................................................... ៧៩
តារាង គ.២៣÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៤ ......................................................................... ៨៤
តារាង គ.២៤÷ ការប្រមូលបំណុលពន្ធដោយអគ្គនាយកដ្ឋានពន្ធដារ.............................................. ៨៧
តារាង គ.២៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៥.......................................................................... ៨៩
តារាង គ.២៦÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៦ ......................................................................... ៩២
តារាង គ.២៧÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៧ ......................................................................... ៩៦

តារាង គ.២៨÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី១៨........................................................................................ ១០១
តារាង គ.២៩÷ សមាសធាតុគន្លឹះនៃក្របខ័ណ្ឌនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់លទ្ធកម្ម........................ ១០៤
តារាង គ.៣០÷ សមាសធាតុគន្លឹះនៃកិច្ចលទ្ធកម្មដែលត្រូវផ្សព្វផ្សាយជាសាធារណៈ.................................. ១០៥
តារាង គ.៣១÷ សមាសធាតុគន្លឹះសម្រាប់យន្តការដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម.......................... ១០៦
តារាង គ.៣២÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី១៩......................................................................................... ១០៧
តារាង គ.៣៣÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២០........................................................................................ ១១០
តារាង គ.៣៤÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២១ ...................................................................................... ១១៣
តារាង គ.៣៥÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២២ ...................................................................................... ១១៦
តារាង គ.៣៦÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៣........................................................................................ ១១៧
តារាង គ.៣៧÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៤........................................................................................ ១២០
តារាង គ.៣៨÷ ការដាក់របាយការណ៍ហិរញ្ញវត្ថុដើម្បីធ្វើសវនកម្ម ..................................................... ១២១
តារាង គ.៣៩÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៥ ...................................................................................... ១២២
តារាង គ.៤០÷ ភាពទាន់ពេលវេលានៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០១៣.. ១២៥
តារាង គ.៤១÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៦ ...................................................................................... ១២៦
តារាង គ.៤២÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៧ ...................................................................................... ១២៩
តារាង គ.៤៣÷ ភាពទាន់ពេលវេលានៃការពិនិត្យរបាយការណ៍សវនកម្ម.............................................. ១៣១
តារាង គ.៤៤÷ ពិន្ទុស្ទូចនាករសមិទ្ធកម្មទី២៨........................................................................................ ១៣២
តារាង គ.៤៥÷ រាជរដ្ឋាភិបាលកម្ពុជា និងការផ្តល់កញ្ចប់ថវិកា (គិតជាលានដុល្លារអាមេរិក)...................... ១៣៣
តារាង គ.៤៦÷ ការប៉ាន់ប្រមាណ និងការទទួលបានថវិកាគាំទ្រជាក់ស្តែង (គិតជាលានដុល្លារអាមេរិក).......... ១៣៤
តារាង គ.៤៧÷ ពិន្ទុស្ទូចនាករសមិទ្ធកម្ម D-1......................................................................................... ១៣៤
តារាង គ.៤៨÷ ពិន្ទុស្ទូចនាករសមិទ្ធកម្ម D-2......................................................................................... ១៣៧
តារាង គ.៤៩ ÷ ការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍន៍ (ពហុភាគី) ឆ្នាំ២០១៤.................................. ១៣៨
តារាង គ.៥០÷ ពិន្ទុស្ទូចនាករសមិទ្ធកម្ម D-3......................................................................................... ១៣៨

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AusAid | Australian Aid Agency | ភ្នាក់ងារជំនួយអូស្ត្រាលី |
| BS | Budget Support | ការគាំទ្រថវិកាដោយផ្ទាល់ |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CCC | Cambodia Chamber of Commerce | សភាពាណិជ្ជកម្មកម្ពុជា |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CMTC | Cash Management Technical Committee | គណៈកម្មាធិការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ |
| CMU | Cash Management Unit | អង្គភាពគ្រប់គ្រងសាច់ប្រាក់ |
| CoA | Chart of Accounts | ប្លង់គណនី |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| DCDM | Department of Cooperation and Debt Management | នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល |
| DIC | Department of Investment and Cooperation | នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ |
| EC | European Commission | គណៈកម្មការអឺរ៉ុប |
| FAD | Financial Affairs Department | នាយកដ្ឋានហិរញ្ញកិច្ច |
| FMIS | Financial Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FY | Fiscal year | ឆ្នាំសារពើពន្ធ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| GDEPFP | General Department of Economic and Public Finance Policy | អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GDSPNTR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ |

| | | |
|---|---|---|
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) |
| HRMIS | Human Resource Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងធនធានមនុស្ស |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| JICA | Japan International Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KHR | Cambodian Riel | ប្រាក់រៀល |
| KIT | Khmer Information Technology | បច្ចេកវិទ្យាព័ត៌មានខ្មែរ |
| LM | Line ministry | ក្រសួង- ស្ថាប័ន |
| LOT | Law on Taxation | ច្បាប់ពន្ធដារ |
| MAFE | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCS | Ministry of Civil Service | ក្រសួងមុខងារសាធារណៈ |
| MCFA | Ministry of Culture and Fine Arts | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MLVT | Ministry of Labor and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| MOI | Ministry of the Interior | ក្រសួងមហាផ្ទៃ |
| MOP | Ministry of Planning | ក្រសួងផែនការ |
| MND | Ministry of National Defense | ក្រសួងការពារជាតិ |
| MPWT | Ministry of Public Works and Transport | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| MSAVYR | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MTEF | Medium-Term Expenditure Framework | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OCM | Office of the Council of Ministers | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ODA | Official Development Assistance | ហិរញ្ញប្បទានសហប្រតិបត្តិការ |
| O&M | Operations and Maintenance | ប្រតិបត្តិការ និងជួសជុល- ថែទាំ |
| PAE | Public Administrative Entity | គ្រឹះស្ថានសាធារណៈរដ្ឋបាល |

| | | |
|---|---|---|
| PCA | Post Clearance Audit | សវនកម្មក្រោយការទូទាត់ |
| PE | Public Enterprise | សហគ្រាសសាធារណៈ |
| PEFA | Public Expenditure and Financial Accountability | ចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PI | Performance Indicator | សូចនាករសមិទ្ធកម្ម |
| PIP | Public Investment Program | កម្មវិធីវិនិយោគសាធារណៈ |
| PPP | Public-Private Partnership | ភាពជាដៃគូ វិស័យឯកជន និងសាធារណៈ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SIDA | Swedish International Development Agency | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SNA | Sub National Administration | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| TIN | Taxpayer Identification Number | លេខអត្តសញ្ញាណអ្នកជាប់ពន្ធ |
| TOFE | Table of Fiscal and Economic Operations of the Government | តារាងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋាភិបាល |
| TSA | Treasury Single Account | គណនីទោលរតនាគារ |
| UNCTAD | United Nations Conference on Trade and Development | សន្និសីទអង្គការសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ |
| USD | United States Dollar | ដុល្លារអាមេរិក |
| VAT | Value Added Tax | អាករលើតម្លៃបន្ថែម |
| WB | World Bank | ធនាគារពិភពលោក |

# អារម្ភកថា

ការប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃសមិទ្ធកម្ម “**ចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ**” (PEFA) បានផ្តល់លទ្ធភាពឱ្យយើងធ្វើការវាយតម្លៃលើវឌ្ឍនភាព បញ្ហាប្រឈម និងកិច្ចការចាំបាច់សម្រាប់បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការវាយតម្លៃនេះគឺជាវិញ្ញាសាមួយដែលបានគូសបញ្ជាក់អំពីវឌ្ឍនភាពផ្នែកសមត្ថភាពរបស់រាជរដ្ឋាភិបាល ធៀបទៅនឹងលទ្ធផលក្នុងរបាយការណ៍ឆ្នាំ២០១០ ដែលត្រូវបានរៀបចំដោយអ្នកវាយតម្លៃឯករាជ្យ។

លទ្ធផលនៃការវាយតម្លៃ PEFA បានក្លាយជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ PEFA បានជួយកំណត់អំពីលក្ខខណ្ឌ និងកង្វះចន្លោះនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវពិនិត្យឡើងវិញនិងពង្រឹងបន្ថែម ជាពិសេសសម្រាប់អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។ លើសពីនេះ វិញ្ញាសា PEFA បានជួយបង្កើនសមត្ថភាព **អ.គ.ហ.** ដើម្បីកំណត់ទស្សនវិស័យវែងឆ្ងាយ និងយុទ្ធសាស្ត្រអនាគតរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ហេតុដូច្នេះ អគ្គនាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធគួរផ្តោតការយកចិត្តទុកដាក់ខ្ពស់លើលទ្ធផលនៃការវាយតម្លៃ PEFA និងគួរចាត់ទុករបាយការណ៍នេះជាមូលដ្ឋានសម្រាប់ពង្រឹងគុណភាពនៃការរៀបចំផែនការសកម្មភាពរបស់រៀងៗខ្លួន។

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ២០០៤។ ការវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ ឆ្នាំ២០០៩ ដែលត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១០ (របាយការណ៍វាយតម្លៃ PEFA ឆ្នាំ២០១០) បានបង្ហាញនូវសមិទ្ធកម្មសំខាន់ៗក្នុងកិច្ចដំណើរការរៀបចំថវិកា, ការកែលម្អការព្យាករណ៍ថវិកាប្រចាំឆ្នាំ និងការពង្រីកការប្រើប្រាស់គណនីទោលរតនាគារជាតិ។ ទន្ទឹមនេះ ការវាយតម្លៃបានបង្ហាញឱ្យឃើញកិច្ចប្រឈមនានាដែលកើតមានក្នុងដំណាក់កាលដំបូងនៃកម្មវិធីកែទម្រង់ ដើម្បីបន្តកែលម្អ និងពង្រឹងភាពជឿទុកចិត្តនៃថវិកា។

ការវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៥នេះ គឺជាការវាយតម្លៃលើកទី២ សម្រាប់កម្ពុជា។ គោលបំណងចម្បងនៃការវាយតម្លៃនេះ គឺការស្វែងរកធាតុចូលបន្ថែម សម្រាប់ជាមូលដ្ឋាននៃការរៀបចំផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដើម្បីតាមដានវឌ្ឍនភាពការងារកែទម្រង់ ផ្អែកលើរបាយការណ៍នៃការវាយតម្លៃលើកទី១ កន្លងមក។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងផ្អែកតាមវិធីសាស្ត្រវាយតម្លៃនៃក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ដោយយោងតាមគោលការណ៍ណែនាំ និងការកែសម្រួលថ្មីៗនៃក្របខ័ណ្ឌវាយតម្លៃនេះ។

ផ្អែកលើគោលការណ៍នៃក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ របាយការណ៍នេះនឹងមិនបង្ហាញនៅក្នុងខ្លឹមសារនៃរបាយការណ៍ នូវអនុសាសន៍កែលម្អលើគោលនយោបាយ, សមត្ថភាព និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវត្ថុដោយឡែកនោះឡើយ។ ទោះយ៉ាងណា ក្រុមការងារវាយតម្លៃរបស់រាជរដ្ឋាភិបាល បានចងក្រងអនុសាសន៍គន្លឹះទៅតាមសូចនាករនីមួយៗ និងបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៦។

របាយការណ៍នេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងរៀបចំវាយតម្លៃជំហានដំបូង ដោយក្រុមការងារនៃរាជរដ្ឋាភិបាល និងការត្រួតពិនិត្យ, ការផ្តល់សុពលភាព និងការបំពេញបន្ថែមលើការងារវាយតម្លៃនេះ ដោយក្រុមទីប្រឹក្សាបរទេស។ ការវាយតម្លៃនេះ ផ្តោតសំខាន់លើសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុង ឬ ក្រោយឆ្នាំ២០១៤ បើសិនមានទិន្នន័យអាចប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃបាន។ វិសាលភាពនៃការវាយតម្លៃគ្របដណ្តប់រដ្ឋបាលថ្នាក់កណ្តាល ដោយរាប់បញ្ចូលនូវគ្រប់ ១២ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អង្គភាពហិរញ្ញវត្ថុដទៃទៀត, ក្រសួង-ស្ថាប័នគន្លឹះមួយចំនួន ព្រមទាំងបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗមួយចំនួន។ ការវាយតម្លៃ

នេះ ក៏គ្របដណ្តប់លើរដ្ឋបាលថ្នាក់ក្រោមជាតិនៅថ្នាក់ឃុំ-សង្កាត់ និងសហគ្រាសសាធារណៈចំនួន ១៥ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់កណ្តាល។

របាយការណ៍វាយតម្លៃនេះ នឹងបង្ហាញជាបឋមអំពីទិដ្ឋភាពទូទៅនៃចំណុចខ្លាំងនិងចំណុចខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា។ លទ្ធផលនៃការវាយតម្លៃនេះនឹងអាចជះឥទ្ធិពលដល់ការសម្រេចបាននូវគោល-បំណង/ធាតុចេញសំខាន់ៗទាំង៣ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន វិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍ថវិកា និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ របាយការណ៍នេះនឹងបង្ហាញដោយសង្ខេបអំពីបម្រែបម្រួលសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធៀបនឹងការវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ កាលពីឆ្នាំ២០១០ និងបង្ហាញដោយសង្ខេបអំពីការងារកែទម្រង់ដែលកំពុងបន្តអនុវត្ត ព្រមទាំងទស្សនវិស័យរយៈពេលវែងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ២. ទិដ្ឋភាពទូទៅនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

តារាង ក បង្ហាញនូវទិដ្ឋភាពទូទៅនៃការដាក់ពិន្ទុលើសូចនាករសមិទ្ធកម្មចំនួន ២៨ សម្រាប់ការអនុវត្តរបស់រាជរដ្ឋាភិបាល និងសូចនាករសមិទ្ធកម្មចំនួន ៣ សម្រាប់ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ដែលរួមបញ្ចូលទាំងសមាស-ធាតុតូចៗ ចំនួន៧៦ នៃសូចនាករសមិទ្ធកម្មទាំងអស់។ សម្រង់ពិន្ទុត្រូវបានយកចេញពីតារាងដាក់ពិន្ទុតាមសូចនាករនីមួយៗ ក្នុង **ផ្នែក គ** នៃរបាយការណ៍នេះ ដែលតារាងទាំងនេះ មានបង្ហាញទាំងបរិការណ៍, ភស្តុតាង និងទឡ្ហីករណ៍សម្រាប់ការដាក់ពិន្ទុនីមួយៗ។ លំដាប់សូចនាករ ត្រូវបានរៀបចំទៅតាមរចនាសម្ព័ន្ធនៃក្របខ័ណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ។

ជាទូទៅ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា មានចំណុចខ្លាំង (មានន័យថាទទួលបានពិន្ទុ A និង B) លើការអនុវត្តថវិកា ទាំងចំណូលនិងចំណាយ (PI-1 និង PI-3), តម្លាភាពនៃទំនាក់ទំនងថវិកាអន្តររដ្ឋបាល (PI-8) និងលំដាប់លំដោយ និងការចូលរួមរបស់ក្រសួង-ស្ថាប័ន ក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ (PI-11)។ ក្រៅពីនេះ មុខងារនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានវាស់វែងដោយសូចនាករសមិទ្ធកម្មផ្សេងទៀត សម្រាប់ការអនុវត្តរបស់រាជរដ្ឋាភិបាល បានបង្ហាញពីចំណុចខ្វះខាតដោយអន្លើ (តាមរយៈពិន្ទុ C និង D) ទោះបីជាសមាសធាតុ (dimension) មួយចំនួននៃសូចនាករទាំងនេះ (សូចនាករចំនួន ១៥ ក្នុងចំណោម ២៤) ទទួលបានពិន្ទុល្អក៏ដោយ។

ជាទូទៅ សូចនាករសមិទ្ធកម្មសម្រាប់ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ មានចំណុចខ្វះខាតច្រើន មានន័យថាការគាំទ្រ និងការចូលរួមក្នុងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីដៃគូអភិវឌ្ឍន៍ នៅមានកម្រិតទាបនៅឡើយ។

លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងជួយគាំទ្ររាជរដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តថវិកា និងការធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈ ដែលផ្សារភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ និងគោលដៅរបស់រាជរដ្ឋាភិបាល។

# ៣. ការវាយតម្លៃលើចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ៣.១ វិន័យថវិកា

វិន័យថវិកា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈវិសាលភាពគ្របដណ្តប់នៃឯកសារថវិកា និងលទ្ធភាពវិភាជន៍ថវិកាទៅតាមផែនការ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចមានសារៈសំខាន់ណាស់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជួយឱ្យរដ្ឋាភិបាលអាចសម្រេចបានលទ្ធផលនៃវិន័យថវិកា។

កម្ពុជា ទទួលបានសមិទ្ធកម្មល្អ លើការអនុវត្តថវិកា ទាំងចំណូលក្នុងស្រុក (PI-3) និងចំណាយសាធារណៈ (PI-1)។ ដោយឡែក ភាពគ្រប់ជ្រុងជ្រោយនៃថវិកានៅមានភាពទន់ខ្សោយនៅឡើយ ដែលមានដូចជា (ក) ចំនួនច្រើនថ្ងៃនៃបំណុលកកស្ទះ (PI-3 សមាសធាតុ ១), និង (ខ) ភាពមិនពេញលេញនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជាពិសេស ចំណូលពីគ្រឹះស្ថានសាធារណៈរដ្ឋបាល (PI-7 សមាសធាតុ ១)។ ភាពទន់ខ្សោយនេះ បណ្តាលមកពីភាពមិនគ្រប់ជ្រុងជ្រោយនៃព័ត៌មាននិងទិន្នន័យថវិកាដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ថវិកាប្រចាំឆ្នាំ ជាពិសេសសមិទ្ធកម្មពាក់ព័ន្ធនឹងប្រតិបត្តិការថវិការបស់រាជរដ្ឋាភិបាល។

លទ្ធផលល្អនៃការអនុវត្តថវិកា ជាពិសេសចំណូលសារពើពន្ធ នឹងបង្ហាញតាមរយៈការព្យាករណ៍កាន់តែសុក្រឹត, ការគ្រប់គ្រងចំណូលទៅតាមផែនការ និងប្រសិទ្ធភាពបញ្ជូនធនធានទាំងនោះទៅរតនាគារ (PI-5 សមាសធាតុ ៣), ទោះបីនៅមានកង្វះចន្លោះដោយអន្លើក៏ដោយ។ ដំណើរការរៀបចំថវិកាតាមលំដាប់លំដោយ និងបានទាន់ពេលវេលា ទាមទារឱ្យគ្រប់អង្គភាពថវិកាទាំងអស់មានភាពជាម្ចាស់លើថវិការបស់ខ្លួន និងដឹងពីការវិភាជថវិកាចុងក្រោយកាន់តែច្បាស់ មុននឹងចាប់ផ្តើមឆ្នាំសារពើពន្ធថ្មី (PI-11)។ របាយការណ៍អនុវត្តថវិកា ត្រូវធានាភាពទាន់ពេលវេលាជាប្រចាំខែ ប្រកបដោយសុក្រឹតភាព និងសង្គតិភាព សម្រាប់ការតាមដានត្រួតពិនិត្យលើចំណូលនិងចំណាយសាធារណៈសរុប (PI-24)។ ការរៀបចំផែនការសាច់ប្រាក់ ដែលផ្តល់នូវព័ត៌មានអាចទុកចិត្តបានអំពីសាច់ប្រាក់ សម្រាប់ក្រសួង-ស្ថាប័នរៀបចំផែនការដើម្បីស្នើធានាចំណាយ ទទួលបានពិន្ទុល្អ (PI-16 សមាសធាតុ ១ និង ២)។ ការត្រួតពិនិត្យល្អលើសហគ្រាសសាធារណៈ និងរដ្ឋបាលឃុំ/សង្កាត់ បានបង្ហាញថាស្ថាប័នទាំងនោះមិនបានស្នើថវិការរួបន្ថែម ក្រៅពីផែនការឡើយ (PI-9)។

ក្រៅពីនេះ ចំណុចមួយចំនួននៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលនៅមានកង្វះចន្លោះ ក៏មានសារៈសំខាន់ក្នុងការធានាវិន័យថវិកាផងដែរ។ ប្រព័ន្ធគ្រប់គ្រងចំណូល មិនទាន់អាចធានាបាននូវប្រសិទ្ធភាពនៃការចុះបញ្ជីអ្នកជាប់ពន្ធ ឬគ្រប់គ្រងបំណុលពន្ធនៅឡើយ (PI-14) រីឯការកាត់បន្ថយកម្រិតនៃបំណុលពន្ធកកស្ទះមានវឌ្ឍនភាពតិចតួច (PI-15 សមាសធាតុ ១)។ កង្វះប្រព័ន្ធតាមដានវិក្កយបត្រទំនិញនិងសេវាកម្ម ប្រកបដោយប្រសិទ្ធភាព មានន័យថាព័ត៌មានអំពីការទូទាត់វិក្កយបត្រ និងការគ្រប់គ្រងបំណុលកកស្ទះ មិនត្រូវបានដឹងឡើយ (PI-4 សមាសធាតុ ២)។ ទោះបីជាការព្យាករណ៍អំពីការផ្តល់ថវិកាដោយដៃគូអភិវឌ្ឍន៍នៅមានកម្រិត ប៉ុន្តែចំណុចនេះមិនមែនជាបញ្ហាចម្បងនោះទេ ដោយសារមានការថយចុះនៃការគាំទ្រថវិកានេះ ធៀបនឹងការគាំទ្រដោយថវិការដ្ឋ។

ស្ទូចនាករមួយចំនួនទៀត អាចជួយឱ្យរដ្ឋាភិបាលចៀសវាងនូវចំណាយមិនបានគ្រោងទុកក្នុងរយៈពេលមធ្យម។ ក្នុងនោះ ការត្រួតពិនិត្យតាមដានលើបំណុលមានប្រសិទ្ធភាព ក្នុងពេលដែលបំណុលរបស់កម្ពុជាស្ថិតនៅក្នុងកម្រិតអាចគ្រប់គ្រងបាន (PI-17 សមាសធាតុ ៣ និង PI-12 សមាសធាតុ ២)។ ក្របខ័ណ្ឌថវិការយៈពេលមធ្យម ស្ថិតនៅក្នុងដំណាក់កាលរៀបចំបឋម ដែលការផ្សារភ្ជាប់ថវិកាពីវដ្តមួយទៅវដ្តមួយទៀត នៅមានកម្រិតនៅឡើយ (PI-12 សមាសធាតុ ១ និង ៤)។ ការពិនិត្យហានិភ័យថវិកា ដែលមានបង្ហាញពីសំណើថវិកាជាយថាហេតុរបស់សហគ្រាសសាធារណៈ និងប្រតិបត្តិការថវិកាដទៃទៀត មិនទាន់ត្រូវបានរៀបចំនៅឡើយ (PI-9) រីឯការធានារបស់រដ្ឋលើកម្ចី មិនស្ថិតក្នុងដែនកំណត់នៃពិដានថវិកា ឬយន្តការប្រហាក់ប្រហែលឡើយ (PI-17 សមាសធាតុ ៣)។

កង្វះចន្លោះទាំងនេះ បានបង្ហាញឱ្យឃើញថា សមិទ្ធកម្មល្អលើវិន័យថវិកា អាចប្រឈមនឹងហានិភ័យ បើសិនជាការប្រមូលចំណូលក្នុងរយៈពេលខ្លីរបស់រាជរដ្ឋាភិបាល ជួបប្រទះបញ្ហា ឬកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមមានការធ្លាក់ចុះ។

## ៣.២ យុទ្ធសាស្ត្រវិភាជន៍ធនធាន

យុទ្ធសាស្ត្រវិភាជន៍ធនធាន ឆ្លុះបញ្ចាំងនូវលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ធនធានហិរញ្ញវត្ថុសមស្របជូនអង្គភាពផ្តល់សេវាសាធារណៈ និងក្នុងការកៀរគរធនធានហិរញ្ញវត្ថុពីសាធារណជន និងសហគ្រាស ដើម្បីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ និងគោលដៅ។

ប្រព័ន្ធថវិកាដែលខ្លាំង គឺស្ថិតត្រង់ការរៀបចំប្រចាំឆ្នាំ ធ្វើឡើងតាមលំដាប់លំដោយ និងមានការចូលរួមខ្ពស់, ការត្រួតពិនិត្យដោយអង្គនីតិបញ្ញត្តិបានទាន់ពេលវេលា និងតាមនីតិវិធីរៀបរយត្រឹមត្រូវ (PI-11 និង PI-27 សមាសធាតុ ២), និងភាពទាន់ពេលវេលានិងភាពអាចជឿជាក់បាននៃព័ត៌មានអំពីការផ្ទេរធនធានទៅឱ្យឃុំ-សង្កាត់ ដែលមានស្វ័យភាពក្នុងការរៀបចំថវិកា (PI-8 សមាសធាតុ ១ និង ២)។

ដើម្បីសម្រេចបានជាអតិបរមានូវគោលបំណងគោលនយោបាយនៃការផ្តល់សេវាសាធារណៈ គឺទាមទារការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយក្នុងរយៈពេលមធ្យម។ ប៉ុន្តែ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនទាន់អនុវត្តបានល្អនៅឡើយ ដោយសារតែការរៀបចំផែនការថវិកាពហុឆ្នាំសម្រាប់វិស័យអាទិភាពនៅមានភាពទន់ខ្សោយ លើកលែងតែវិស័យសុខាភិបាល និងវិស័យអប់រំ (PI-12 សមាសធាតុ ៣), ដែលនាំឱ្យមានកង្វះចន្លោះក្នុងការជ្រើសរើសគម្រោងវិនិយោគ និងកង្វះការគិតគូរល្អិតល្អន់អំពីផែនការចំណាយថវិកាចរន្តដែលបណ្តាលមកពីការបញ្ចប់គម្រោង (PI-12 សមាសធាតុ ៤)។ លើសពីនេះ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម មិនទាន់ត្រូវបានបង្កើតនិងធ្វើសមាហរណកម្មពេញលេញទៅក្នុងដំណើរការរៀបចំថវិកា ជាមួយការផ្សារភ្ជាប់ថវិកាច្បាស់លាស់ពីវដ្តថវិកាមួយទៅវដ្តថវិកាមួយទៀតនោះទេ លើកលែងតែសម្រាប់ថវិកាសរុប (PI-12 សមាសធាតុ ១)។

លើសពីនេះ ការត្រួតពិនិត្យតាមដានលើការវិភាជនិងការអនុវត្តថវិកា មិនត្រូវបានធ្វើឡើងបានពេញលេញឡើយ ដោយសារកង្វះប្លង់គណនីរួមដែលមានលក្ខណៈឯកភាព ដែលប្លង់គណនីនេះបង្ហាញពីចំណាត់ថ្នាក់ថវិកាទៅតាមវិស័យ, មុខងារ និងតាមកម្មវិធី (PI-5) និងកង្វះរបាយការណ៍លម្អិតអំពីការអនុវត្តគម្រោងដែលប្រើប្រាស់ហិរញ្ញប្បទានខាងក្រៅ ដែលមានប្រមាណ ៣ ភាគ ៤ នៃគម្រោងវិនិយោគសាធារណៈទាំងអស់ (PI-7 សមាសធាតុ ២,

PI-24 និង D-2 សមាសធាតុ ២), ក៏ដូចជាភាពទន់ខ្សោយនៃប្រព័ន្ធតាមដាន ការផ្តល់ធនធានដល់អង្គភាពផ្តល់សេវាសាធារណៈ (PI-23)។

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក៏បានជួបប្រទះនឹងការវិភាជថវិកាឡើងវិញនៅក្នុងឆ្នាំ ជាញឹកញាប់ និងនៅក្នុងទំហំធំ (PI-16 សមាសធាតុ ៣) តាមរយៈសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានកំណត់ក្នុងច្បាប់ (PI-23)។

ជាលទ្ធផល ការវិភាជថវិកាជាក់ស្តែង ច្រើនតែមានភាពខុសគ្នាខ្លាំង បើធៀបនឹងគម្រោងថវិកាដែលត្រូវបានស្នើដោយរដ្ឋាភិបាល (PI-2) ហើយដែលត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិដោយពុំមានការកែប្រែធំដុំឡើយ។

## ៣.៣ ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

ការផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ឆ្លុះបញ្ចាំងឱ្យឃើញពីការប្រើប្រាស់ធនធានហិរញ្ញវត្ថុបានត្រឹមត្រូវ, ចំគោលដៅនៃការផ្តល់សេវាសាធារណៈ និងការកាត់បន្ថយការប្រើប្រាស់ធនធានដោយខ្ជះខ្ជាយ។ នេះជាការងារចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យសមស្របនឹងកំណើនការប្រមូលចំណូល ដែលនឹងនាំមកនូវគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈនៅគ្រប់កម្រិត។

ភាពអាចប៉ាន់ប្រមាណបាននៃអត្ថិភាពថវិកា សម្រាប់ការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ (PI-16 សមាសធាតុ ២) និងរបស់ឃុំ/សង្កាត់ (PI-8 សមាសធាតុ ២) នឹងជួយពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ក៏ប៉ុន្តែ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភាពខ្លាំងកម្រិតណាក្នុងការទប់ទល់នឹងវិបត្តិធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់ការប្រមូលចំណូល នៅមិនទាន់អាចសន្និដ្ឋានបាននៅឡើយ ដោយសារប្រព័ន្ធត្រួតពិនិត្យលើការធានាចំណាយនៅមិនទាន់មានលក្ខណៈពេញលេញ (PI-20 សមាសធាតុ ១)។

ចំណុចដែលត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន មានដូចជាសមិទ្ធកម្មមិនល្អនៃការត្រួតពិនិត្យតាមដាន, បញ្ហាតម្លាភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ, កង្វះអង្គភាពដោះស្រាយបណ្តឹងឯករាជ្យក្នុងកិច្ចលទ្ធកម្ម (PI-19) និងភាពយឺតយ៉ាវ ឬការពន្យារពេលនៃការទូទាត់ចំណាយលើទំនិញនិងសេវា (PI-4) ដែលអាចនឹងនាំឱ្យតម្លៃមួយចំនួនត្រូវបានដំឡើងបន្ថែម មានន័យថា ថវិកានឹងមិនត្រូវបានប្រើប្រាស់ដោយសន្សំសំចៃឡើយ។

ក្រៅពីការត្រួតពិនិត្យទាន់ពេលវេលានិងតាមលំដាប់លំដោយពីអង្គនីតិប្បញ្ញត្តិ (PI-28), កង្វះចន្លោះនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (PI-18 សមាសធាតុ ៤, PI-20 សមាសធាតុ ២ និង ៣, និង PI-21), ប្រសិទ្ធភាពនៅមានកម្រិតនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្រៅទាប (PI-26) និងតម្លាភាពសាធារណៈនៅមានកម្រិតទាប (PI-10) បញ្ជាក់បន្ថែមថានៅមានចំណុចជាច្រើនទៀតដែលទាមទារឱ្យកែលម្អ ដើម្បីធានាប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ធនធានសាធារណៈ។

## ៣.៤ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានថវិកា

ការវាយតម្លៃលើសូចនាករសមិទ្ធកម្មខាងលើ ពឹងផ្អែកលើភាពគ្រប់គ្រាន់នៃទិន្នន័យថវិកាដែលអាចប្រមូលបាន។ ក៏ប៉ុន្តែ ទិន្នន័យទាំងនេះនៅមិនទាន់អាចជឿទុកចិត្តបានទាំងស្រុងនៅឡើយ។ សូចនាករសមិទ្ធកម្មមួយចំនួន នឹងបង្ហាញឱ្យឃើញពីភាពត្រឹមត្រូវនៃទិន្នន័យថវិកា។

ក្នុងន័យនេះ ចំណុចខ្សោយមួយចំនួនត្រូវបានកត់សម្គាល់។ បន្ថែមលើ ព័ត៌មានថវិកាដែលគ្របដណ្តប់មិនបានពេញលេញលើប្រតិបត្តិការរបស់រាជរដ្ឋាភិបាល (PI-7) និងការគ្រប់គ្រងបំណុលកកស្ទះដែលនៅមិនទាន់បានគ្រប់ជ្រុងជ្រោយ (PI-4), នៅមានកង្វះចន្លោះមួយចំនួនទៀត ដូចជាការផ្ទៀងផ្ទាត់ឬកសរុបទិន្នន័យ និងការរៀបចំរបាយការណ៍ (PI-22 និង PI-25)។ លើសពីនេះ កង្វះខាតចម្បងៗ ក៏ត្រូវបានកំណត់ និងត្រូវបានតាមដានត្រួតពិនិត្យជាទៀងទាត់ ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយ និងសុក្រឹតភាពនៃការកត់ត្រាចំណូលនិងចំណាយ និងដើម្បីរៀបចំវិធានការទប់ស្កាត់ ឬកែលម្អកង្វះខាតនេះ រួមបញ្ចូលទាំងមុខងារសវនកម្មផ្ទៃក្នុង (PI-21) និងការឆ្លើយតបទៅនឹងសវនកម្មផ្ទៃក្រៅ (PI-26)។

**តារាង ក÷ សេចក្តីសង្ខេបរួមអំពីពិន្ទុនៃការវាយតម្លៃសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥**

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | សមាសធាតុ | | | | ពិន្ទុសរុប |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | |
| A. *លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ ភាពជឿទុកចិត្តនៃថវិកា* | | | | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | | | | A |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | D | B | | | D+ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | | | | A |
| PI-4 | សន្និធិបំណុលកកស្ទះ និងការតាមដានបំណុលកកស្ទះ | M1 | D | C | | | D+ |
| B. *ការងារត្រួតស៊ីគ្នាសំខាន់ៗ÷ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា* | | | | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | M1 | C | | | | C |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | M1 | C | | | | C |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | M1 | C | C | | | C |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល | M2 | A | A | D | | B |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀតក្រៅពីក្រសួង-ស្ថាប័ន | M1 | C | A | | | C+ |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | M1 | D | | | | D |
| C. *វដ្តថវិកា* | | | | | | | |
| C(i) *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* | | | | | | | |
| PI-11 | កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | M2 | A | A | A | | A |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា, គោលនយោបាយចំណាយ និងការរៀបចំថវិកា | M2 | C | A | C | C | C+ |

| សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | វិធីសាស្ត្រដាក់ពិន្ទុ | សមាសធាតុ | | | | ពិន្ទុសរុប |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | |
| C(ii) *ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា* | | | | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធនិងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | M2 | C | B | C | | C+ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | M2 | D | C | C | | D+ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | M1 | D | B | C | | D+ |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | M1 | B | B | C | | C+ |
| PI-17 | ការកត់ត្រានិងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | M2 | C | B | C | | C+ |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | M1 | B | C | B | D | D+ |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | M2 | B | D | D | D | D+ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | M1 | C | C | C | | C |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | M1 | C | C | C | | C |
| C(iii) *គណនេយ្យ, ការកត់ត្រា និងរបាយការណ៍* | | | | | | | |
| PI-22 | ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | M2 | B | D | | | C |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | M1 | D | | | | D |
| PI-24 | គុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | M1 | C | A | C | | C+ |
| PI-25 | គុណភាពនិងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | D | B | C | | D+ |
| C(iv) *ការត្រួតពិនិត្យនិងសវនកម្មផ្ទៃក្រៅ* | | | | | | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មផ្ទៃក្រៅ | M1 | NR | A | C | | NR |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំ ដោយអង្គនីតិប្បញ្ញត្តិ | M1 | C | B | C | B | C+ |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្រៅដោយអង្គនីតិប្បញ្ញត្តិ | M1 | B | B | B | | B |
| D. *ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍* | | | | | | | |
| D-1 | ការប៉ាន់ប្រមាណការគាំទ្រថវិកាដោយផ្ទាល់ | M1 | D | D | | | D |
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកានិងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី | M1 | C | D | | | D+ |
| D-3 | ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ | M1 | D | | | | D |

## ៤. បម្រែបម្រួលការអនុវត្តធៀបនឹងការវាយតម្លៃ ឆ្នាំ២០១០

តារាង ខ ប្រៀបធៀបពិន្ទុសូចនាករសមិទ្ធកម្មនៃការវាយតម្លៃលើកនេះ ជាមួយនឹងពិន្ទុនៃការវាយតម្លៃឆ្នាំ២០១០។ នៅក្នុងតារាង ខ នេះ មានកូឡោនមួយបង្ហាញពី "ភាពអាចប្រៀបធៀបគ្នា" បាននៃពិន្ទុវាយតម្លៃទាំងពីរលើក។ ការប្រៀបធៀបមិនអាចធ្វើទៅរួចលើសូចនាករចំនួន ១២ ក្នុងចំណោមសូចនាករទាំង ៣១ ដោយហេតុថា (ក) លក្ខខណ្ឌវិនិច្ឆ័យរបស់រចនាសម្ព័ន្ធ និង/ឬ ពិន្ទុសូចនាករនៃក្របខ័ណ្ឌវាយតម្លៃ ត្រូវបានផ្លាស់ប្តូរខុសពីការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងឆ្នាំ២០១០ (PI-2, PI-3, និង PI-19); ឬ (ខ) ការវាយតម្លៃឆ្នាំ២០១០ មិនមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់ ឬមានភាពខុសគ្នារវាងការបកស្រាយព័ត៌មានចាំបាច់ ឬកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការផ្តល់ពិន្ទុ។ ចំណែកសូចនាករចំនួន ២ ផ្សេងទៀត (PI-27 និង PI-28) មិនអាចប្រៀបធៀបបាន ព្រោះមិនមានក្នុងការវាយតម្លៃកាលពីឆ្នាំ២០១០។ ទោះជាមិនអាចប្រៀបធៀបរវាងពិន្ទុនឹងពិន្ទុសម្រាប់សូចនាករចំនួន ១០ ក្នុងចំណោមសូចនាករទាំង១៤ ខាងលើ តែគេនៅតែអាចធ្វើការប្រៀបធៀបបានទៅតាមទិសដៅនៃបម្រែបម្រួល។ គួរកត់សម្គាល់ផងដែរថា ការផ្លាស់ប្តូរសមិទ្ធកម្មនៃសមាសធាតុនីមួយៗរបស់សូចនាករប្រហែលជាអាចមាននៅក្នុងការវាយតម្លៃកាលពីឆ្នាំ២០១០ ប៉ុន្តែមិនមានបម្លាស់ប្តូរក្នុងពិន្ទុសរុបឡើយ។ ផ្អែកលើមូលដ្ឋាននេះ ទិសដៅនៃការផ្លាស់ប្តូរត្រូវបានបង្ហាញនៅក្នុងកូឡោនខាងស្តាំក្នុងតារាងនេះ ហើយមួយចំនួនអាចបញ្ជាក់បានថាភាពទន់ខ្សោយជាមូលដ្ឋាននៅតែមាននៅក្នុងសូចនាករនោះ ទោះជាមានភាពល្អប្រសើរនៅក្នុងទិដ្ឋភាពផ្សេងទៀតក៏ដោយ។

ភាពល្អប្រសើរឡើងក្នុងសមិទ្ធកម្ម ត្រូវបានបង្ហាញក្នុងសូចនាករចំនួន ៧ សម្រាប់ការអនុវត្តរបស់រាជរដ្ឋាភិបាល ចំណែកឯការធ្លាក់ចុះពិន្ទុនៃសមិទ្ធកម្មត្រូវបានរកឃើញក្នុងសូចនាករចំនួន ៣ ផ្សេងទៀត។ ការវាស់វែងសមិទ្ធកម្មមិនអាចធ្វើទៅបានទេសម្រាប់សូចនាករចំនួន ៤ ផ្សេងទៀត។ ដោយឡែក សមិទ្ធកម្មនៃសូចនាករចំនួន ១៤ មិនបានបង្ហាញអំពីការផ្លាស់ប្តូរសំខាន់ណាមួយគួរឱ្យកត់សម្គាល់ក្នុងទិសដៅទាំងពីរ។

ភាពប្រសើរឡើងនៃសមិទ្ធកម្មត្រូវបានគេរកឃើញថា ភាគច្រើនជាសូចនាករដែលជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វិន័យថវិកា (PI-1, PI-3, និង PI-16) និងសូចនាករដែលពាក់ព័ន្ធនឹងការតាមដាន និងរបាយការណ៍ប្រតិបត្តិការថវិកា (PI-21, PI-24, PI-25, និង PI-26)។

ការធ្លាក់ចុះរបស់សមិទ្ធកម្មត្រូវបានរកឃើញជាចម្បង ក្នុងសូចនាករដែលជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់យុទ្ធសាស្ត្រវិភាជន៍ធនធាន និងតម្លាភាព (PI-2, PI-6, PI-10)។ ការធ្លាក់ចុះមួយចំនួននៅក្នុងចំណាត់ថ្នាក់សមិទ្ធកម្ម កើតឡើងដោយសារការធ្លាក់ចុះបន្តិចបន្តួចនៃប្រសិទ្ធភាពនៃការអនុវត្ត ដែលពិន្ទុទាំងនេះអាចកើនឡើងវិញប្រសិនបើមានការកែលម្អការអនុវត្ត, ឧទាហរណ៍ ភាពទាន់ពេលវេលានៃការផ្សព្វផ្សាយរបាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ (PI-10)។

ចំពោះការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ភាពអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាផ្ទាល់ត្រូវបានពង្រឹងពីកម្រិតចន្លោះ ១២-១៥% ទៅកម្រិត ២៥% នៃហិរញ្ញប្បទានខាងក្រៅ ដោយសារការកែលម្អក្នុងការធ្វើរបាយការណ៍លើការគាំទ្រគម្រោងតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC database) និងការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ។

## ៥. ទិសដៅបន្តនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សមិទ្ធកម្មជារួមនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹងនិងកែលម្អបន្តិចបន្តួច គិតចាប់ពីឆ្នាំ២០១០ ដោយការប្រែប្រួលមួយចំនួនមានទិសដៅផ្ទុយគ្នា, ប៉ុន្តែការងារកែទម្រង់សំខាន់ៗត្រូវបានរៀបចំក្នុងអំឡុងពេលនោះ និងស្ថានភាពអនុវត្តនាពេលបច្ចុប្បន្នបង្ហាញថាកិច្ចខិតខំប្រឹងប្រែងកែលម្អទាំងនេះ នឹងនាំឱ្យទទួលបានលទ្ធផលល្អក្នុងពេលឆាប់ៗខាងមុខនេះ។ ការវាយតម្លៃនេះ គិតបញ្ចូលតែវឌ្ឍនភាពនានានៅមុនដំណាច់ឆ្នាំ២០១៤ ប៉ុណ្ណោះ។ ការងារកែទម្រង់ជាច្រើនដែលត្រូវបានបន្តនិងចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១៥ នឹងត្រូវបានរៀបរាប់នៅក្នុងប្រអប់ “ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត” ទៅតាមសូចនាករនីមួយៗ ក្នុង **ផ្នែក គ** នៃរបាយការណ៍នេះ។

លើសពីនេះ ការដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ថ្មីដំបូង ក្នុងឆ្នាំ២០១៥ និងពេញលេញនៅឆ្នាំបន្តបន្ទាប់ ក៏ដូចជាការណែនាំក្នុងការប្រើប្រាស់ប្លង់គណនីរួម អាចនាំឱ្យមានការពង្រឹងបន្ថែមលើសមត្ថភាពវិភាជន៍ធនធាន។ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងជួយឱ្យការរៀបចំរបាយការណ៍អនុវត្តថវិកាស្ថិតក្នុងទម្រង់តែមួយស្របជាមួយច្បាប់ថវិកាដែលបានអនុម័ត (PI-24) ព្រមទាំងការបូកសរុបទិន្នន័យជារួមរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលគ្រប់ថ្នាក់ (PI-8 សមាសធាតុ ៣)។

ជាផ្នែកមួយគាំទ្រដល់យុទ្ធសាស្ត្រវិភាជន៍ថវិកា គឺការកាត់បន្ថយថវិកាមិនបានគ្រោងទុក ដោយវិភាជន៍ថវិកាឱ្យចំគោលដៅដល់គ្រប់ក្រសួង-ស្ថាប័ន ចាប់ពីឆ្នាំ២០១៦ តទៅ ព្រមទាំងការបន្តពង្រីកការអនុវត្តថវិកាកម្មវិធី, ប្លង់គណនីថ្មី និងការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងអាចបំពេញកង្វះខាតនានាក្នុងការពង្រឹងវិន័យថវិកា និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ដោយពង្រឹងការវិភាជថវិកាដល់គ្រប់ក្រសួង-ស្ថាប័ន (P-16 សមាសធាតុ ២), ពង្រឹងការត្រួតពិនិត្យលើការធានាចំណាយ (P-20 សមាសធាតុ ២), ពង្រឹងរបាយការណ៍នៃការធានាចំណាយ និងសមតុល្យធានាចំណាយ (P-24 សមាសធាតុ ១) និងការតាមដានការទូទាត់បំណុលកកស្ទះគិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានវិក្កយបត្រ (P-4 សមាសធាតុ ២)។

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែលចាប់ផ្តើមអនុវត្តដោយអង្គភាពប្រមូលចំណូលនឹងពង្រឹងសមិទ្ធកម្មនៃសូចនាករ PI-13, PI-14 និង PI-15 តាមរយៈការបង្កើនចំនួននៃអ្នកបង់ពន្ធស្ម័គ្រចិត្ត។

ចាប់តាំងពីឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលចែកចេញជា ៤ដំណាក់កាល។ ក្រោយពីបានសម្រេចជោគជ័យលើភាពជឿទុកចិត្តនៃថវិកា នៅក្នុងដំណាក់កាលទី១ កម្មវិធីកែទម្រង់បានឈានទៅដំណាក់កាលទី២ គឺគណនេយ្យភាពហិរញ្ញវត្ថុ។ ដំណាក់កាលបន្ទាប់ គឺការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP3) ដែលនឹងផ្តោតលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

របាយការណ៍នេះនឹងក្លាយជាឧបករណ៍ជួយដល់ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ ដោយប្រមូលផ្តុំនូវ (ក) សកម្មភាពដែលបានសម្រេចក្នុងដំណាក់កាលទី១, (ខ) សកម្មភាពដែលបានសម្រេចក្នុងដំណាក់កាលទី២ និង (គ) សកម្មភាពដែលត្រូវរៀបចំដើម្បីសម្រេចឱ្យបានក្នុងដំណាក់កាលទី៣។

## តារាង ១÷ បម្រែបម្រួលលើលទ្ធផល/ សមិទ្ធកម្ម ធៀបនឹងការវាយតម្លៃឆ្នាំ២០១០

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១០ | ២០១៥ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| A. *លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ភាពជឿទុកចិត្តនៃថវិកា* | | | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | B | A | មិនបាន | ⬆ |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | D | D+ | មិនបាន | ⬇ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | A | មិនបាន | ⬆ |
| PI-4 | សន្និធិបំណុលកកស្ទះ និងការតាមដានបំណុលកកស្ទះ | M1 | C+ | D+ | មិនបាន | ? |
| B. *ការងារត្រួតស៊ីគ្នាសំខាន់ៗ÷ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា* | | | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | M1 | C | C | បាន | គ្មាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | M1 | B | C | បាន | ⬇ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | M1 | C | C | បាន | គ្មាន |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល | M2 | C+ | B | មិនបាន | គ្មាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | M1 | C+ | C+ | បាន | គ្មាន |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | M1 | C | D | មិនបាន | ⬇ |
| C. *វដ្តថវិកា* | | | | | | |
| C(i) *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* | | | | | | |
| PI-11 | កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | M2 | A | A | បាន | គ្មាន |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា, គោលនយោបាយចំណាយ និងការរៀបចំថវិកា | M2 | B | C+ | បាន | គ្មាន |
| C(ii) *ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា* | | | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធនិងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | M2 | B | C+ | មិនបាន | គ្មាន |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | M2 | C | D+ | មិនបាន | គ្មាន |

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១០ | ២០១៥ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | M1 | D+ | D+ | បាន | គ្មាន |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | M1 | C+ | C+ | បាន | ⬆ |
| PI-17 | ការកត់ត្រានិងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | M2 | C+ | C+ | បាន | គ្មាន |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | M1 | D+ | D+ | បាន | គ្មាន |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | M2 | C | D+ | មិនបាន | ? |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | M1 | C | C | មិនបាន | គ្មាន |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | M1 | D+ | C | បាន | ⬆ |
| C(iii) *គណនេយ្យ, ការកត់ត្រា និងរបាយការណ៍* | | | | | | |
| PI-22 | ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | M2 | C | C | បាន | គ្មាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្ដីពីធនធានដែលទទួលបានពីអង្គភាពផ្ដល់សេវា | M1 | C | D | មិនបាន | គ្មាន |
| PI-24 | គុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | M1 | C+ | C | បាន | ⬆ |
| PI-25 | គុណភាពនិងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | D+ | D+ | បាន | ⬆ |
| C(iv) *ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ* | | | | | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មផ្ទៃក្រៅ | M1 | D+ | NR | បាន (មួយផ្នែក) | ⬆ |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ | M1 | NU | C+ | NA | ? |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្រៅដោយអង្គនីតិបញ្ញត្តិ | M1 | NU | B | NA | ? |
| D. *ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍* | | | | | | |
| D-1 | ការប៉ាន់ប្រមាណនៃការគាំទ្រថវិកាដោយផ្ទាល់ | M1 | C | D | មិនបាន | ⬇ |

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១០ | ២០១៥ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកានិងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី | M1 | D | D+ | បាន | ⬆ |
| D-3 | ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ | M1 | D | D | បាន | ⬆ |

*ចំណាំ៖ ក្នុងកូឡោន "បម្រែបម្រួល" បង្ហាញពីទិសដៅនៃការប្រែប្រួលធៀបនឹងការវាយតម្លៃឆ្នាំ២០១០ និងឆ្នាំ២០១៥ ដោយវិភាគលម្អិតទៅលើសមាសធាតុនីមួយៗ។*

# ក. សេចក្តីផ្តើម

## ក.១ សាវតារ និងគោលបំណងនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ជាជំហានៗឆ្ពោះទៅរកស្តង់ដារអន្តរជាតិ នោះគឺ *ការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើលទ្ធផល ឫសមិទ្ធកម្ម និងវិមជ្ឈការ* តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលវែង គ្រប់ជ្រុងជ្រោយ និងអនុវត្តយុទ្ធសាស្ត្រ៤ជំហាន ឬ/និង ៤ដំណាក់កាលគឺ (១) ការបង្កើនភាពជឿទុកចិត្តនៃថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤) ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។ ជាក់ស្តែង ភាពជឿទុកចិត្តនៃថវិកាដែលជាគោលដៅចម្បងនៃដំណាក់កាលទី១ ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០០៤ និងត្រូវបានអនុវត្តយ៉ាងពេញលេញនៅឆ្នាំ២០០៥ ហើយត្រូវបានបញ្ចប់ដោយជោគជ័យជាមួយនឹងការប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” នៅចុងឆ្នាំ២០០៨ ដែលត្រូវបានអនុវត្តយ៉ាងពេញលេញនៅដើមឆ្នាំ២០០៩។

ទោះបីជាការអនុវត្តដំណាក់កាលទី១និងដំណាក់កាលទី២ សម្រេចបានជោគជ័យក្នុងការធានានូវភាពជឿទុកចិត្តនៃថវិកាគួរជាទីមោទនៈ ស្របពេលដែលគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានបង្កើនក៏ដោយ ក៏រាជរដ្ឋាភិបាលបានវាយតម្លៃថា ភាពជឿទុកចិត្តនៃថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុ ពិតជាចាំបាច់ត្រូវបន្តពង្រឹងបន្ថែមទៀតនៅក្នុងដំណាក់កាលបន្ទាប់ គឺដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”។ ទន្ទឹមនេះ ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយចាំបាច់ត្រូវតែសម្រេចឱ្យបាន មុននឹងអាចឈានទៅដំណាក់កាលទី៤ គឺ “ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម” ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងន័យនេះ ឧបករណ៍វាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ក្នុងគោលបំណងវាស់វែងពីលទ្ធផលជាក់ស្តែង និងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តដំណាក់កាលទាំង២ (ដំណាក់កាលទី១ និងទី២) ព្រមទាំងកំណត់ឱ្យបាននូវការងារអាទិភាពដែលត្រូវកែលម្អ និងបន្តអនុវត្តនៅក្នុងដំណាក់កាលបន្ទាប់។ ឧបករណ៍ PEFA ធ្លាប់ត្រូវបានប្រើប្រាស់កាលពីឆ្នាំ២០១០ ម្តងរួចមកហើយ ដោយពេលនោះ លទ្ធផលនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី២ (CAP2)។ ដូចគ្នានេះដែរ ការប្រើប្រាស់ឧបករណ៍ PEFA ក្នុងឆ្នាំ២០១៥ នេះ មានគោលដៅស្វែងរកឱ្យឃើញច្បាស់នូវកង្វះខាតនៃការអនុវត្តកម្មវិធីកែ

ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាមូលដ្ឋានមុតស្រួចសម្រាប់ការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP3) ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ ខាងមុខ។

## គ.២ កិច្ចដំណើរការនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីធានាបាននូវការអភិវឌ្ឍសមត្ថភាពផ្ទៃក្នុង ការវាយតម្លៃត្រូវបានអនុវត្តជាពីរដំណាក់កាល។ ដំណាក់កាលទី១ គឺការរៀបចំសេចក្តីព្រាងរបាយការណ៍បឋម (ការវាយតម្លៃផ្ទៃក្នុង) ដោយក្រុមការងាររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ដែលមានការចូលរួមពីក្រសួង-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធ ក្នុងកិច្ចសហការជាមួយទីប្រឹក្សាលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំតំបន់នៃស្ថាប័នរូបិយវត្ថុអន្តរជាតិ (IMF) ដែលមានការិយាល័យស្ថិតនៅរាជធានីភ្នំពេញ ក្រោមការតម្រង់ទិសផ្ទាល់ពីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ដែលមានភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត តាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។ ដំណាក់កាលទី២ គឺការពិនិត្យ ផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពលើរបាយការណ៍បឋម ដោយទីប្រឹក្សាបរទេសជាន់ខ្ពស់ ៣រូប ដែលមានបទពិសោធន៍យូរឆ្នាំ និងមានជំនាញច្បាស់លាស់ក្នុងការប្រើប្រាស់ឧបករណ៍វាយតម្លៃ PEFA ដោយសហការជាមួយក្រុមការងារ អ.គ.ហ. និងទីប្រឹក្សា IMF ប្រចាំតំបន់។ អ្នកដែលត្រូវបានប្រឹក្សាយោបល់មានបង្ហាញក្នុងបញ្ជីឧបសម្ព័ន្ធ ២។

ជាមួយនឹងការណែនាំបន្ថែមពីទីប្រឹក្សាការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ IMF ប្រចាំរាជធានីភ្នំពេញ ក្រុមការងារ អ.គ.ហ. បានចាប់ផ្តើមប្រមូលទិន្នន័យក្នុងអំឡុងឆ្នាំ២០១៤។ កិច្ចដំណើរការប្រមូលទិន្នន័យត្រូវបានបញ្ចប់ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៥ រីឯសេចក្តីព្រាងរបាយការណ៍បឋមត្រូវបានបញ្ចប់នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១៥។

ក្រុមការងារទីប្រឹក្សាបរទេស បានពិនិត្យរបាយការណ៍បឋម ដែលរៀបចំដោយក្រុមការងារ អ.គ.ហ. ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៥ ដើម្បីកំណត់ពីតម្រូវការទិន្នន័យបន្ថែម និងបញ្ហាផ្សេងៗ មុននឹងចុះមកបំពេញបេសកកម្មផ្ទាល់នៅកម្ពុជា។ បេសកកម្មនេះ មានរយៈពេល ២សប្តាហ៍ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥។ ក្រុមការងារទីប្រឹក្សាបរទេស ត្រូវបានអមដោយក្រុមការងារ អ.គ.ហ. ក្នុងអំឡុងពេលបំពេញបេសកកម្មចុះជួបជាមួយស្ថាប័នពាក់ព័ន្ធក្នុងរាជធានីភ្នំពេញ រួមមានក្រសួង-ស្ថាប័នថ្នាក់កណ្តាល, ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ, អង្គការសង្គមស៊ីវិល និងតំណាងវិស័យឯកជន។ ក្រុមការងារទីប្រឹក្សាបរទេស បានផ្ញើសេចក្តីព្រាងរបាយការណ៍ទី១ មក អ.គ.ហ. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥។ បន្ទាប់មក ក្រុមការងារ អ.គ.ហ. បានផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ខាងលើ និងបានរៀបចំសេចក្តីព្រាងរបាយការណ៍ទី២ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ដោយមានបញ្ចូលទិន្នន័យបន្ថែមដែលទទួលបានក្រោយការបំពេញបេសកកម្មរបស់ក្រុមការងារទីប្រឹក្សា។

**ប្រអប់ ក.១: ការគ្រប់គ្រងការវាយតម្លៃ និងការធានាគុណភាព**

**រចនាសម្ព័ន្ធការគ្រប់គ្រងវាយតម្លៃ PEFA**

- ក្រុមការងារស្នូល : សមាជិករួមមាន កសហវ/អ.គ.ហ.,ស្ថាប័នរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ដឹកនាំដោយប្រធាន ឯ.ឧ. បណ្ឌិត សុខ សារ៉ុវឌ្ឍ និង ឯ.ឧ. រស់ សីលវ៉ា (ឧបសម្ព័ន្ធ ២)
- អ្នកគ្រប់គ្រងការវាយតម្លៃ : ឯ.ឧ. បណ្ឌិត ហ៊ែល ចំរើន
- អ្នកដឹកនាំក្រុមវាយតម្លៃ និងសមាជិកក្រុម : បញ្ជីក្នុងឧបសម្ព័ន្ធ ២ ដឹកនាំដោយលោក យ៉េត វីណែល និង លោក ទៀង សុខភិរម្យ

**ការត្រួតពិនិត្យទស្សនាទាន និង/ឬលក្ខខណ្ឌយោង**

- កាលបរិច្ឆេទពិនិត្យសេចក្តីព្រាងទស្សនាទាន និង/ឬលក្ខខណ្ឌយោង: ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤, រួមមាន អ.គ.ហ., ស្ថាប័នរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី និង លេខាធិការដ្ឋាន PEFA
- អ្នកដែលបានផ្តល់យោបល់: ឯ.ឧ. រស់ សីលវ៉ា អគ្គលេខាធិការ អ.គ.ហ., លោក Suhas Joshi នៃស្ថាប័នរូបិយវត្ថុអន្តរជាតិ, Leah April នៃធនាគារពិភពលោក, Christian Provoost នៃសហភាពអឺរ៉ុប, លេខាធិការដ្ឋាន PEFA នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤
- កាលបរិច្ឆេទនៃទស្សនាទានចុងក្រោយ និង/ឬលក្ខខណ្ឌយោង: ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៤

**ការត្រួតពិនិត្យរបាយការណ៍វាយតម្លៃ**

- កាលបរិច្ឆេទពិនិត្យសេចក្តីព្រាងរបាយការណ៍ ÷ សេចក្តីព្រាងរបាយការណ៍ទី២ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ និង សេចក្តីព្រាងចុងក្រោយ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥
- អ្នកត្រូវបានសម្ភាស : គ្រប់អង្គភាពក្រោមឱវាទ កសហវ, ស្ថាប័នរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, UNICEF និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អ្នកដែលបានផ្តល់យោបល់
    - ស្ថាប័នរូបិយវត្ថុអន្តរជាតិ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
    - លេខាធិការដ្ឋាន PEFA (០៩ តុលា ២០១៥ និង ១៦ ធ្នូ ២០១៥)
    - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងធនាគារពិភពលោក (បានឆ្លើយតប តែមិនមានយោបល់)។

គុណភាពនៃការវាយតម្លៃ ត្រូវបានធានា ដោយក្រុមការងារវាយតម្លៃបានអញ្ជើញភាគីពាក់ព័ន្ធ រួមមាន ភាគីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងលេខាធិការដ្ឋាន PEFA ដែលមានការិយាល័យនៅក្នុងរដ្ឋធានី Washington DC ដើម្បីពិនិត្យសេចក្តីព្រាងទី២ (ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥) និងផ្តល់យោបល់បន្ថែម (យោងប្រអប់ ក.១)។ សិក្ខាសាលាពិគ្រោះយោបល់ទូលំទូលាយមួយ ត្រូវបានរៀបចំឡើងនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ សម្រាប់ឱ្យភាគីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិនិត្យពិភាក្សាលើលទ្ធផលនៃការវាយតម្លៃ ក្នុងសេចក្តីព្រាងរបាយការណ៍ទី២ និងដើម្បីប្រមូលធាតុចូលនិងទិន្នន័យបន្ថែមសម្រាប់ការរៀបចំបញ្ចប់របាយការណ៍ចុងក្រោយ។ សេចក្តីព្រាងរបាយការណ៍ចុងក្រោយ

ត្រូវបានរៀបចំនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ និងត្រូវបានផ្ញើចេញដើម្បីពិនិត្យជាលើកចុងក្រោយក្នុងក្រុមការងារវាយតម្លៃ និងសម្រេចបានស្ថាពរនៅខែធ្នូ ឆ្នាំ២០១៥។

## ក.៣ វិធីសាស្ត្រនៃការវាយតម្លៃ

ការវាយតម្លៃត្រូវបានរៀបចំដោយប្រើប្រាស់ក្របខ័ណ្ឌ PEFA ដែលត្រូវបានកែសម្រួលជាថ្មី នៅក្នុងខែមករា ឆ្នាំ២០១១។ វិធីសាស្ត្រនៃការវាយតម្លៃ និងការកែសម្រួលវិធីសាស្ត្រទាំងនេះ មានចែងក្នុងមគ្គុទេសក៍ណែនាំ PEFA (Fieldguide) ដែលត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងខែឧសភា ឆ្នាំ២០១៥ ដោយលេខាធិការដ្ឋាន PEFA។

ក្របខ័ណ្ឌ PEFA គឺជាឧបករណ៍ស្តួលសម្រាប់វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេស ដោយផ្តោតលើចំណាយសាធារណៈ កិច្ចលទ្ធកម្ម និងប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការងារកែទម្រង់ ដើម្បីធានាឱ្យបាននូវ ១).វិន័យថវិកា ២).ប្រសិទ្ធភាពវិភាជន៍ធនធាន និង ៣).ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ក្របខ័ណ្ឌ PEFA ត្រូវបានប្រកាសឱ្យប្រើនៅខែមិថុនា ឆ្នាំ២០០៥ និងត្រូវបានអនុវត្តប្រមាណជា ៣៦០ លើក ក្នុង ១៤០ ប្រទេសដែលមានស្ថានភាពរដ្ឋបាល និងរចនាសម្ព័ន្ធខុសៗគ្នា។ ក្របខ័ណ្ឌ PEFA ត្រូវបានកែសម្រួលតិចតួចប៉ុណ្ណោះក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ដោយក្នុងឆ្នាំ២០១១[1] ក្របខ័ណ្ឌ PEFA មាន ៣១សូចនាករសមិទ្ធកម្ម ក្នុងនោះ ចំនួន ២៨ គ្របដណ្តប់លើការអនុវត្តរបស់រដ្ឋាភិបាល និងចំនួន ៣ ផ្សេងទៀត សម្រាប់ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍។

**រូបភាព ក.១ រចនាសម្ព័ន្ធសូចនាករសមិទ្ធកម្មរបស់ PEFA**




[1] ក្របខ័ណ្ឌ PEFA ដែលបានធ្វើបច្ចុប្បន្នភាពគ្រប់ជ្រុងជ្រោយ បាននិងកំពុងប្រើប្រាស់តាមរយៈកម្មវិធីចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ។ ក្របខ័ណ្ឌដែលបានកែសម្រួលចុងក្រោយនេះ ត្រូវបានរំពឹងថានឹងដាក់ចេញឱ្យអនុវត្តដើមឆ្នាំ២០១៦ និងប្រសិទ្ធភាពនៃការវាយតម្លៃ PEFA នឹងត្រូវដាក់ឱ្យប្រើប្រាស់បន្ទាប់។ ក្របខ័ណ្ឌដែលបានកែសម្រួលចុងក្រោយនេះ មិនមានជាបច្ច័យអាក្រក់សម្រាប់ការវាយតម្លៃនាពេលបច្ចុប្បន្នទេ។

សូចនាករសមិទ្ធកម្មនីមួយៗ មានសមាសធាតុចំនួន ០១ ឬ ច្រើន ដើម្បីវាយតម្លៃធាតុគន្លឹះនៃកិច្ចដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ មានពីរ គឺ÷

- *វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុទី១ (M1)* គឺត្រូវពិនិត្យមើលលើសមាសធាតុនីមួយៗ និងសមាសធាតុទាំងអស់ រួចតម្រូវឱ្យធ្វើការផ្តល់ពិន្ទុសម្រាប់គ្រប់សមាសធាតុនីមួយៗដែលបានកំណត់នៅក្នុងសូចនាករសមិទ្ធកម្ម នឹងត្រូវជ្រើសយកសមាសធាតុណាដែលទទួលបានពិន្ទុទាបជាងគេ ជាមូលដ្ឋាននៃលទ្ធផលចុងក្រោយដោយផ្តល់សញ្ញាបូកបន្ថែម (+), មានន័យថា បើទោះជាសមាសធាតុណាមួយនៃសូចនាករសមិទ្ធកម្មនោះទទួលបានពិន្ទុទាបជាងគេ ក៏នឹងមិនជះឥទ្ធិពលជាអវិជ្ជមានទៅដល់រាល់សមាសធាតុដទៃដែលទទួលបានពិន្ទុខ្ពស់ជាងឡើយ។
- *វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុទី២ (M2)* គឺតម្រូវឱ្យបូកសរុបគ្រប់ពិន្ទុរបស់សមាសធាតុនីមួយៗ ដែលបានកំណត់នៅក្នុងសូចនាករ និងរកមធ្យមភាគរបស់វា, មានន័យថា បើសិនសមាសធាតុមួយណាក្នុងចំណោមសមាសធាតុទាំងអស់ដែលទទួលបានពិន្ទុទាបជាងគេ នឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សមាសធាតុដទៃដែលទទួលបានពិន្ទុខ្ពស់។

ការវាយតម្លៃនេះគឺផ្អែកលើឯកសារសាធារណៈ និងឯកសារផ្ទៃក្នុងរបស់ស្ថាប័នរដ្ឋ។ ព័ត៌មានត្រូវបានប្រមូលតាមរយៈកិច្ចសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលបំពេញបេសកកម្ម ដូចមានក្នុងឧបសម្ព័ន្ធ ៣។ បញ្ជីឈ្មោះឯកសារ ដែលត្រូវបានប្រើសម្រាប់ការផ្តល់ពិន្ទុនៃសូចនាករនីមួយៗ ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ៤។

គោលបំណងនៃការវាយតម្លៃ គឺការតាមដានវឌ្ឍនភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ២០១០។ ទោះបីជាការវាយតម្លៃលើកទី១ ត្រូវបានយកជាមូលដ្ឋានសម្រាប់វាស់វែងបម្រែបម្រួលនៃសមិទ្ធកម្ម ក៏ប៉ុន្តែការវាយតម្លៃ មិនមែនផ្តោតតែលើការស្វែងរកបម្រែបម្រួលក្នុងសូចនាករនីមួយៗឡើយ។ ម្យ៉ាងទៀត ក្របខ័ណ្ឌ PEFA ផ្តោតលើភាពប្រទាក់ក្រឡានៃគ្រប់ផ្នែកនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឥទ្ធិពលនៃការសម្រេចបាននៃផ្នែកនីមួយៗ ទៅលើការសម្រេចបានជារួម នូវគោលដៅចវិការបស់រាជរដ្ឋាភិបាល ដែលរួមមាន វិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍ថវិកា និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ដោយសារតែក្របខ័ណ្ឌវាយតម្លៃនេះ ផ្តល់សារៈសំខាន់ទៅលើភាពប្រទាក់ក្រឡានៃគ្រប់ផ្នែកនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទើបការវាយតម្លៃនេះត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល របស់រាជរដ្ឋាភិបាល។

វិធីសាស្ត្រនៃក្របខ័ណ្ឌវាយតម្លៃនេះ មានពន្យល់អំពីការប្រែប្រួលពិន្ទុ ឬលក្ខខណ្ឌ ដែលអាចនាំឱ្យសូចនាករសមិទ្ធកម្មណាមួយអាចទទួលបានពិន្ទុខ្ពស់ជាងមុន។ ប៉ុន្តែ ក្នុងករណីដែលមានការប្រែប្រួលពិន្ទុដោយពុំមានការប្រែប្រួលក្នុងវិធីសាស្ត្រ នោះនឹងមានការពន្យល់ជាយថាហេតុ។ ដោយសារមានការកែប្រែក្របខ័ណ្ឌវាយតម្លៃ PEFA ក្នុងឆ្នាំ២០១១ និងការកែសម្រួលជាបន្តបន្ទាប់ ការប្រៀបធៀបនិងការពន្យល់អំពីការប្រែប្រួលនៃលទ្ធផលសូចនាករសមិទ្ធកម្មចំនួន ៣ មិនអាចធ្វើទៅបានដោយពេញលេញឡើយ។ ដោយឡែក សូចនាករសមិទ្ធកម្មដទៃទៀត ពិន្ទុភាគច្រើន អាចប្រៀបធៀបបាន លើកលែងតែក្នុងករណីមួយចំនួន ដែលមានការពន្យល់ខុសប្លែកពីគ្នា រវាងការវាយតម្លៃឆ្នាំ២០១០ និងឆ្នាំ២០១៥ ឬក្នុងករណីពុំមានឯកសារគ្រប់គ្រងសម្រាប់វាយតម្លៃដាក់ពិន្ទុបាន។

## ក.៤ វិសាលភាពនៃការវាយតម្លៃ

ការវាយតម្លៃនេះ បង្ហាញអំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅពេលដែលក្រុមការងារ អ.គ.ហ. បានប្រមូលនិងទទួលទិន្នន័យភាគច្រើន ពោលគឺនៅក្នុងអំឡុងត្រីមាសទី១ នៃឆ្នាំ២០១៥។ ដូចនេះ សូចនាករសមិទ្ធកម្ម បង្ហាញពីស្ថានភាពនៃប្រព័ន្ធ គិតត្រឹមដំណាច់ឆ្នាំ២០១៤ ដោយសូចនាករភាគច្រើនផ្តោតលើសមិទ្ធកម្មក្នុងឆ្នាំសារពើពន្ធចុងក្រោយគឺ ឆ្នាំ២០១៤។ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួនដែលទិន្នន័យក្នុងឆ្នាំ២០១៤ ពុំមាន ឬពុំអាចប្រមូលបាន គិតត្រឹមកាលបរិច្ឆេទនៃបេសកកម្មចុះផ្ទៀងផ្ទាត់ទិន្នន័យដោយក្រុមទីប្រឹក្សាបរទេស ជាអាទិ៍ សូចនាករ PI-1, PI-2, PI-3, PI-7 សមាសធាតុ ១ និង PI-15 សមាសធាតុ ១, នោះការវាយតម្លៃ បានយកទិន្នន័យត្រឹមឆ្នាំសារពើពន្ធ ២០១៣ មកធ្វើជាមូលដ្ឋាន។ សេចក្តីបរិយាយអំពីសូចនាករសមិទ្ធកម្មនីមួយៗ នឹងបញ្ជាក់បន្ថែមពីមូលដ្ឋានឆ្នាំនៃទិន្នន័យ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃ។ គួរកត់សម្គាល់ផងដែរថា ការប្រែប្រួល និងវឌ្ឍនភាពនានានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលកើតមាននៅក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ប៉ុន្តែដែលមិនមានឥទ្ធិពលនាំឱ្យប្រែប្រួលលទ្ធផលនៃការវាយតម្លៃនោះ ត្រូវបានចាត់ទុកជា “ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត” ដែលត្រូវបានសង្ខេបខ្លី និងដាក់នៅក្នុងប្រអប់នៅខាងក្រោមការវាយតម្លៃសូចនាករសមិទ្ធកម្មនីមួយៗ។

អនុលោមតាមក្របខ័ណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ, ការវាយតម្លៃនេះមានវិសាលភាពគ្របដណ្តប់លើកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៅគ្រប់រដ្ឋបាលថ្នាក់ជាតិ ដែលរួមមាន ក្រសួង-ស្ថាប័ន, អង្គភាព និងមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រដ្ឋបាលរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈទាំង២៦ ទៅតាមវិសាលភាពនៃសូចនាករសមិទ្ធកម្មនីមួយៗ (ក្នុងឧបសម្ព័ន្ធ ៥.១)។ ការវាយតម្លៃនេះ មិនគ្របដណ្តប់ដល់រដ្ឋបាលឃុំ-សង្កាត់ (ដូចមានក្នុងការបកស្រាយក្នុងផ្នែក ខ.៣.៨) និងសហគ្រាសសាធារណៈទាំង១៥ (ក្នុងឧបសម្ព័ន្ធ ៥.២) ក្រៅពីមុខងារត្រួតពិនិត្យសមិទ្ធកម្មរបស់រដ្ឋបាលថ្នាក់កណ្តាល ដូចមានក្នុងសូចនាករសមិទ្ធកម្ម PI-7, PI-8 និង PI-9 ឡើយ។

## ក.៥ រចនាសម្ព័ន្ធរបាយការណ៍

របាយការណ៍វាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្អែកលើក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ឆ្នាំ២០១៥ ត្រូវបានបែងចែកជា ៦ ផ្នែកសំខាន់ៗ ទៅតាមលំហូរស្ថានភាពជាក់ស្តែងនៃការវាយតម្លៃដូចខាងក្រោម÷

- **សេចក្តីសង្ខេប** ÷ បរិយាយអំពីចំណុចខ្លាំងនិងចំណុចខ្សោយ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា និងការវាយតម្លៃដែលមានភាពគ្រប់ជ្រុងជ្រោយនិងដែលពាក់ព័ន្ធទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ដែលរួមមាន ការធានាឱ្យបាននូវវិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍ថវិកា និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ផ្នែកនេះ រំលេចនូវវឌ្ឍនភាព ឬការប្រែប្រួលដែលកើតមាន ធៀបនឹងលទ្ធផលនៃការវាយតម្លៃនាឆ្នាំ២០១០ និងបង្ហាញជាសង្ខេបនូវការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត និងដែលត្រូវគិតគូររៀបចំដាក់ឱ្យអនុវត្ត។

- **ក. សេចក្តីផ្តើម÷** បរិយាយអំពីគោលបំណងរួមនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបង្ហាញពីវិធីសាស្ត្រ និងវិសាលភាពនៃការវាយតម្លៃ ព្រមទាំងកិច្ចដំណើរការនៃការរៀបចំរបាយការណ៍។
- **ខ. ស្ថានភាពប្រទេសកម្ពុជា÷** បរិយាយអំពីទិដ្ឋភាពរួមនៃរដ្ឋបាលសាធារណៈកម្ពុជា, បរិបទនៃការកែទម្រង់នានារបស់រាជរដ្ឋាភិបាល ស្ថានភាព និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាការបង្ហាញពីលទ្ធផលនៃការអនុវត្តថវិកា ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ។ ទន្ទឹមនេះ ក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏មានយកមកបង្ហាញផងដែរ។
- **គ. ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នីតិវិធី និងស្ថាប័ន÷** បង្ហាញអំពីការវាយតម្លៃប្រព័ន្ធនីតិវិធី និងស្ថាប័នទៅតាមសូចនាករសមិទ្ធកម្ម ដែលរួមមាន លទ្ធផលនៃសូចនាករ និងសមាសធាតុក្នុងសូចនាករនីមួយៗ រួមនឹងការបង្ហាញពីទឡ្ហីករណ៍នៃការផ្តល់ពិន្ទុផងដែរ។ លទ្ធផលនៃការវាយតម្លៃត្រូវបានបែងចែកទៅតាមក្រុមទាំង ៧ នៃសូចនាករសមិទ្ធកម្ម ដូចមានក្នុងជ្យាក្រាមលទ្ធផលវាយតម្លៃខាងលើ ដែលរួមមាន÷ គ.១).ភាពជឿទុកចិត្តនៃថវិកា គ.២).ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពថវិកា គ.៣).ថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ គ.៤). ភាពអាចប៉ាន់ប្រមាណបាននិងការត្រួតពិនិត្យការអនុវត្តថវិកា គ.៥).គណនេយ្យ ការកត់ត្រា និងរបាយការណ៍ គ.៦). ការត្រួតពិនិត្យនិងសវនកម្មខាងក្រៅ និង គ.៧). ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍។
- **ឃ. បម្រែបម្រួលសមិទ្ធកម្មធៀបនឹងការវាយតម្លៃឆ្នាំ២០១០÷** បរិយាយដោយសង្ខេបនូវលទ្ធផលនៃការវាយតម្លៃក្នុងឆ្នាំ២០១០ ធៀបនឹងលទ្ធផលនៃការវាយតម្លៃក្នុងឆ្នាំ២០១៥ និងកត់សម្គាល់អំពីការប្រែប្រួលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- **ង. ការវិវត្តនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷** បរិយាយអំពីវឌ្ឍនភាពដែលសម្រេចបាន និងជំហានបន្ទាប់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបង្ហាញពីសារៈសំខាន់នៃឆន្ទៈនយោបាយនិងស្ថាប័ន រួមទាំងយុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំ និងយន្តការត្រួតពិនិត្យតាមដានលើការអនុវត្ត។

# ២. ស្ថានភាពប្រទេសកម្ពុជា

## ២.១ ការពិពណ៌នាអំពីស្ថានភាពសេដ្ឋកិច្ច

### ២.១.១ ទិដ្ឋភាពទូទៅរបស់ប្រទេស

ប្រទេសកម្ពុជា ប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ចំនួនប្រជាជនមានប្រមាណ ១៥លាននាក់ ក្នុងនោះប្រមាណជា ៧៨% រស់នៅក្នុងតំបន់ជនបទ ហើយកំណើនប្រជាជនជាមធ្យមគឺ ១,៥% ក្នុង១ឆ្នាំ គិតតាំងពីការចាប់ផ្តើមអនុវត្តរបបនយោបាយបច្ចុប្បន្ន ក្នុងអំឡុងឆ្នាំ១៩៩០។ ទន្ទឹមនេះ ការងារកែទម្រង់ទាំងឡាយត្រូវបានដាក់ឱ្យអនុវត្ត ក្នុងគោលដៅពង្រឹងស្ថាប័នសម្រាប់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងពង្រឹងគោលនយោបាយសេដ្ឋកិច្ច។

ក្របខ័ណ្ឌអភិបាលកិច្ច (រួមទាំង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) និងគោលនយោបាយពាក់ព័ន្ធផ្សេងៗ ត្រូវបានពង្រឹង ដែលការណ៍នេះបានចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច, អត្រាអតិផរណាទាប និងការកាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចជាមធ្យមមានប្រមាណ ៧% ក្នុងមួយឆ្នាំក្នុងរយៈពេល ៤ឆ្នាំចុងក្រោយនេះ តាមរយៈការរីកចម្រើននៃវិស័យឧស្សាហកម្ម វិស័យរ៉ែ និងសំណង់។ ទោះជាយ៉ាងណា វិស័យកសិកម្ម នៅតែមានភាពចាំបាច់សម្រាប់សេដ្ឋកិច្ចកម្ពុជា។ អត្រាអតិផរណានៅតែរក្សាបានក្នុងរង្វង់ ៣% ក្នុងមួយឆ្នាំ គឺក្រោមគោលដៅ ៥%។ ប្រតិបត្តិការសេដ្ឋកិច្ច ពឹងផ្អែកខ្លាំងលើរូបិយប័ណ្ណដុល្លារអាមេរិក ដែលកត្តានេះបានរួមចំណែករក្សាបាននូវស្ថិរភាពនៃអត្រាប្តូរប្រាក់ ហើយទុនបម្រុងរបស់រាជរដ្ឋាភិបាលជារូបិយប័ណ្ណអន្តរជាតិរក្សាបានក្នុងបរិមាណលើសពីចំនួន ៤ ខែនៃការនាំចូលសរុប ជាមួយនឹងចំណូលសម្រាប់ប្រជាជនម្នាក់ប្រមាណ ១ ០៤២ ដុល្លារអាមេរិក នាំឱ្យកម្ពុជាឈានទៅក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧% ជាមធ្យមនៅចន្លោះឆ្នាំ ១៩៩០-១៩៩៥ នៅត្រឹម ៣០% ក្នុងឆ្នាំ ២០០៧ និង ១៨% ក្នុងឆ្នាំ២០១៣ ស្របពេលដែលអត្រាភាពក្រីក្រក្នុងទីប្រជុំជន មានកម្រិតទាប គឺ ១៤-១៥% ប៉ុណ្ណោះ។ សូចនាករសង្គមត្រូវបានកែលម្អ ដោយរួមមាន ការចុះឈ្មោះចូលរៀនក្នុងកម្រិតបឋមសិក្សាកើនឡើងពី ៩០% ទៅ ៩៧% ក្នុងអំឡុង ០៦ឆ្នាំចុងក្រោយ។ ទន្ទឹមនេះ លទ្ធភាពទទួលបានការប្រើប្រាស់ទឹកស្អាតនៅជនបទបានកើនឡើងពី ៤១% ទៅ ៤៤% ហើយអត្រាអាយុសង្ឃឹមរស់ជាមធ្យមក៏មានភាពល្អប្រសើរ គឺ ៦៧ឆ្នាំ សម្រាប់បុរស និង ៧១ឆ្នាំសម្រាប់ស្ត្រី។

## ២.១.២ កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល

អភិបាលកិច្ចល្អ នៅតែជាស្នូលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ជាក់ស្តែងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពារបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីកែទម្រង់ធំៗ ៤ ត្រូវបានដាក់ឱ្យអនុវត្ត ក្នុងគោលដៅលើកកម្ពស់អភិបាលកិច្ចល្អ ដែលកម្មវិធីកែទម្រង់ទាំងនេះនៅតែជាការងារអាទិភាពសម្រាប់រាជរដ្ឋាភិបាល ក្នុងការឆ្ពោះទៅកាន់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ស្ថិរភាព និងសមភាពនៃការទទួលបានឱកាស សមភាពចំពោះមុខច្បាប់ និងយុត្តិធម៌សង្គម។ កំណែទម្រង់សំខាន់ៗទាំងនេះរួមមាន (១) ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (២) កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈ (រួមទាំង វិមជ្ឈការនិងវិសហមជ្ឈការ) និង (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ ទន្ទឹមនេះ គោលដៅចម្បងនៃកម្មវិធីកំណែទម្រង់ទាំងអស់ ដោយរាប់បញ្ចូលការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កំណែទម្រង់រដ្ឋបាលដីធ្លី, កំណែទម្រង់រដ្ឋបាលព្រៃឈើនិងជលផល គឺពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ ដើម្បីបង្កើនភាពជឿទុកចិត្តពីសាធារណជនទៅលើការអនុវត្តការងាររបស់រាជរដ្ឋាភិបាល និងដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន និងសហគមន៍ធុរកិច្ច។

ដោយឡែក បញ្ហាប្រឈមមួយចំនួនដែលនឹងជួបប្រទះក្នុងការអភិវឌ្ឍនាពេលអនាគត ត្រូវបានគូសបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដូចខាងក្រោម÷

- ជាមួយនឹងការបោះជំហានសេដ្ឋកិច្ចទៅកាន់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ប្រទេសកម្ពុជានឹងត្រូវទទួលបានហិរញ្ញប្បទានជាជំនួយឥតសំណងកាន់តែតិច ហើយនឹងត្រូវពឹងផ្អែកច្រើនលើកម្ចីដើម្បីគាំទ្រដល់ការវិនិយោគលើវិស័យសាធារណៈ
- កម្ពុជារំពឹងថានឹងធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅដំណាច់ឆ្នាំ២០១៥។ ឧបសគ្គជាច្រើនរវាងប្រទេសនិងប្រទេសនឹងកើតឡើង។ រាជរដ្ឋាភិបាលចាំបាច់ត្រូវត្រៀមខ្លួនសម្រាប់ចលនាការនៃមូលធន និងពលករជំនាញ សមភាវូបនីយកម្មនៃអត្រាពន្ធ និងការកាត់បន្ថយអត្រាពន្ធចំពោះពាណិជ្ជកម្មអន្តរជាតិ។ ទាំងនេះ នឹងបង្កើតជាបញ្ហានៅក្នុងទីផ្សារពលកម្ម គោលនយោបាយឧស្សាហកម្ម ការប្រើប្រាស់ដី និងការប្រមូលចំណូលរបស់រដ្ឋ។
- ជំហានបន្ទាប់នៃអភិបាលកិច្ចល្អ នឹងទាមទារនូវការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យសាធារណៈ (E-Governance) ដើម្បីពង្រឹងប្រសិទ្ធភាពអភិបាលកិច្ច។ ដើម្បីអាចអនុវត្តកិច្ចការនេះបាន រាជរដ្ឋាភិបាលចាំបាច់ត្រូវបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅទូទាំងប្រទេស កសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យលើអ៊ីនធើណែត (Online Database) នៅគ្រប់កម្រិតនៃរដ្ឋបាលសាធារណៈ និងផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (E-Services)។ ការវិនិយោគលើសមត្ថភាពធនធានមនុស្សនៅក្នុងរដ្ឋបាលសាធារណៈ និងការវិនិយោគលើរចនាសម្ព័ន្ធរូបវន្ត មានសារៈសំខាន់ក្នុងការធ្វើទំនើបកម្មអភិបាលកិច្ច។
- សម្រាប់កម្ពុជា ក្នុងការគ្រប់គ្រងវិសាលភាពនៃសេដ្ឋកិច្ច ជាពិសេស គោលនយោបាយរូបិយវត្ថុ ប្រាក់រៀលគួរតែត្រូវបានប្រើប្រាស់សម្រាប់គ្រប់ប្រតិបត្តិការទាំងក្នុងស្រុក និងក្នុងតំបន់ ក្នុងគោលដៅកាត់បន្ថយដុល្លារភាវូបនីយកម្ម។

- បញ្ហាបរិស្ថានក៏ត្រូវតែជាចំណុចសំខាន់នៃកិច្ចដំណើរការអភិវឌ្ឍ តែបច្ចុប្បន្នមិនទាន់ត្រូវបានគិតគូរល្អិតល្អន់នៅឡើយ។ ទោះជាយ៉ាងណា កិច្ចខិតខំប្រឹងប្រែងដែលគួរកត់សម្គាល់ មាននៅក្នុងការអភិរក្សធនធានទឹក ដូចជាបឹងទន្លេសាបជាដើម, ការអភិរក្សព្រៃឈើដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព, ការគិតគូរពីចីរភាព នៃជីវភាពរបស់ប្រជាជននៅជនបទ និងក្នុងការធ្វើកសិកម្មប្រកបដោយចីរភាព។

### ខ.១.៣ សមានគតិភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការពិពណ៌នានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងបរិយាយនៅក្នុង**ផ្នែក ង** នៃរបាយការណ៍។

## ខ.២ ការពិពណ៌នាអំពីការអនុវត្តថវិកា

### ខ.២.១ ការអនុវត្តថវិកា

តារាង ខ.១ និង ខ.២ ខាងក្រោម បង្ហាញពីការអនុវត្តថវិការបស់រាជរដ្ឋាភិបាលពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ (ព្យាករណ៍)។ តារាងទាំងនេះ ត្រូវបានដកស្រង់ចេញពី របាយការណ៍ពិគ្រោះយោបល់ របស់ស្ថាប័នរូបិយវត្ថុអន្តរជាតិ "Article 4 Consultation" ស្តីពីការពិគ្រោះយោបល់ និងការវិភាគបុគ្គលិក ដែលគ្របដណ្តប់លើរដ្ឋបាលសាធារណៈទាំងមូល។ កិច្ចការទាំងនេះ មានវិសាលភាពធំជាងវិសាលភាពនៃរបាយការណ៍ចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ព្រោះវារាប់បញ្ចូលទាំងរដ្ឋបាលឃុំ-សង្កាត់។ ទោះជាយ៉ាងណាក៏ដោយ ការបញ្ចូលទិដ្ឋភាពទាំងនេះនឹងមិនធ្វើឱ្យមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះទេ ដោយហេតុថា រដ្ឋបាលឃុំ-សង្កាត់ប្រមូលចំណូលបានតិច និងពឹងផ្អែកលើការផ្ទេរថវិកាពីរដ្ឋបាលថ្នាក់ជាតិស្ទើរតែទាំងស្រុង។ មាតិកាថវិកា មានសង្គតិភាពនឹងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលឆ្នាំ១៩៨៦ (GFS 1986) ដែលការរៀបចំរបាយការណ៍បច្ចុប្បន្ន ភាគច្រើនមានសង្គតិភាពជាមួយនឹងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលឆ្នាំ២០០១ (GFS 2001)[2]។ ហេតុដូចនេះ ទិន្នន័យក្នុងតារាងទាំងនេះ អាចមិនដូចគ្នានឹងទិន្នន័យក្នុងឧបសម្ព័ន្ធ ៥ ដែលគណនាពិន្ទុសម្រាប់សូចនាករសមិទ្ធកម្មទី១ (PI-1), ទី២ (PI-2) និងទី៣ (PI-3) ដែលក្នុងចំណុចនីមួយៗនឹងមានអំណះអំណាងផ្សេងៗដូចជា ការមិនរាប់បញ្ចូលចំណាយសម្រាប់គម្រោងគាំទ្រដោយហិរញ្ញប្បទានខាងក្រៅ នៃសូចនាករសមិទ្ធកម្មទី១ និងទី២ ជាដើម។

តារាងនេះ បង្ហាញពីយន្តការកៀរគរចំណូលដែលត្រូវបានកែលម្អក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ គឺកំណើនចំណូលពី ១៣,១% ទៅ ១៥,១% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ ដោយឡែក កំណើននៃចំណាយ បានជួបប្រទះបញ្ហាប្រឈម ដោយហេតុថាប្រាក់បៀវត្សកើនឡើងខ្ពស់ធៀបនឹង ផ.ស.ស ដែលនាំឱ្យថវិកាដែលត្រូវបានរក្សាទុកសម្រាប់ចំណាយលើមូលធន ត្រូវធ្លាក់ចុះពី ៦,៥ ទៅ ៥,៩% នៃ ផ.ស.ស។ ទន្ទឹមនេះ ឱនភាពថវិកា ត្រូវបានកែលម្អពី ៧,៥% ទៅ ៥,៥% នៃ ផ.ស.ស ដែលនាំឱ្យលទ្ធភាពថវិកាកាន់តែមានវិសាលភាពធំជាងមុន ស្របពេលដែលអតិរេកថវិកាចរន្ត កាន់តែមានភាពល្អប្រសើរ គឺកើនឡើងពី ០,៩% ទៅ ២,២% នៃ ផ.ស.ស។

---

[2] មាត្រាទី៤ នៃរបាយការណ៍ផ្តល់នូវការបង្ហាញទាំងទម្រង់ឆ្នាំ១៩៨៦ និង២០០១។

### ២.២.២ ការវិភាជថវិកា

មុននឹងការដាក់ឱ្យអនុវត្តប្លង់គណនីថ្មីក្នុងឆ្នាំ២០១៥ មិនមានការប្រើប្រាស់មាតិកាមុខងាររបស់រដ្ឋាភិបាល (COFOG) ឬមាតិកាមុខងារផ្សេងឡើយ ក្រៅពីការប្រើប្រាស់មាតិកាតាមវិស័យ ដែលរួមមាន វិស័យរដ្ឋបាលទូទៅ, ការពារជាតិនិងសន្តិសុខសាធារណៈ, សង្គមកិច្ច និងវិស័យសេដ្ឋកិច្ច។ ដូចនេះ គឺគ្មានមាតិកាមុខងារសម្រាប់ការអនុវត្តថវិកា ត្រូវបានបង្ហាញសម្រាប់រយៈពេលនៃការវាយតម្លៃ និងរៀបចំរបាយការណ៍នេះទេ។

### ២.២.៣ គោលដៅនៃគោលនយោបាយសារពើពន្ធ ២០១៤-២០១៨

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅនៃការប្រមូលចំណូលសម្រាប់ថវិកាជាតិ គឺត្រូវធ្វើយ៉ាងណាបង្កើនការប្រមូលចំណូលឱ្យមានកំណើនជាមធ្យម ០,៥% នៃ ផ.ស.ស ក្នុងមួយឆ្នាំ។ ទន្ទឹមនេះ ចំណូលថវិកាជាតិ នឹងរំពឹងថាកើនទាបបំផុតត្រឹម ១៦,៩% នៃ ផ.ស.ស នៅក្នុងឆ្នាំ២០១៨ ថ្វីបើជាក់ស្តែង តួលេខដែលបានគូសបញ្ជាក់នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ ១៨%។

ដោយឡែក សម្រាប់ចំណាយ រាជរដ្ឋាភិបាល នឹងបន្តផ្តោតជាអាទិភាពលើវិស័យសង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការកែលម្អសមត្ថភាព និងការទ្រទ្រង់ជីវភាពមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ។ បន្ថែមពីនេះ ចាប់ពីឆ្នាំ២០១៨ ការវិភាជថវិកាទៅវិស័យអប់រំ នឹងត្រូវបានកំណត់មិនឱ្យទាបជាង ៣% នៃ ផ.ស.ស និងវិស័យសុខាភិបាលមិនទាបជាង ២% នៃ ផ.ស.ស។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏បានកំណត់កម្រិតនៃបំណុលសាធារណៈ មិនឱ្យលើសពី ៣១% នៃ ផ.ស.ស នៅក្នុងឆ្នាំ២០១៣។ លើសពីនេះ យន្តការចាំបាច់នឹងត្រូវបង្កើតឡើង ដើម្បីបង្កើនអតិរេកថវិកាចរន្ត ក្នុងគោលដៅធានាមិនឱ្យមានការរាំងស្ទះដល់វិនិយោគសាធារណៈ និងការសងបំណុល ទន្ទឹមនឹងការរក្សាទុនបម្រុងរបស់រាជរដ្ឋាភិបាលឱ្យបានយ៉ាងតិចស្មើនឹង ៤ខែ នៃការនាំចូលសរុប។ ជាក់ស្តែង រាជរដ្ឋាភិបាលបានកំណត់នូវផែនការកាត់បន្ថយឱនភាពថវិកាឱ្យនៅត្រឹម ៣% នៃ ផ.ស.ស នាឆ្នាំ២០១៨។

**តារាង ខ.១ ÷ ការអនុវត្តថវិកាទូទៅរបស់រដ្ឋាភិបាល ២០១១-២០១៤ (ពាន់លានរៀល)**

| | ២០១១ (ទិន្នន័យបឋម) | ២០១២ (ទិន្នន័យបឋម) | ២០១៣ (ព្យាករណ៍) | ២០១៤ (ព្យាករណ៍) |
|---|---|---|---|---|
| **ចំណូលសរុប** | **6 822** | **8 596** | **9 070** | **10 427** |
| ចំណូលសារពើពន្ធ | 5 476 | 6 674 | 7 526 | 8 616 |
| ពន្ធផ្ទាល់ | 960 | 1 276 | 1 550 | 1 780 |
| ពន្ធប្រយោល | 4 132 | 4 932 | 5 478 | 6 236 |
| ពន្ធថ្នាក់រាជធានី-ខេត្ត | 385 | 465 | 498 | 601 |
| ចំណូលមិនមែនសារពើពន្ធ | 959 | 1 344 | 1 192 | 1 451 |
| ចំណូលមូលធន | 386 | 579 | 352 | 359 |
| | | | | |
| **ចំណាយ និងការផ្តល់កម្ចីសរុប** | **10 744** | **12 176** | **12 549** | **14 202** |
| ចំណាយចរន្ត | 5 997 | 6 946 | 7 344 | 8 570 |
| បៀវត្ស | 2 233 | 2 598 | 3 086 | 3 782 |
| មិនមែនបៀវត្ស | 3 521 | 4 039 | 3 970 | 4 400 |
| ចំណាយរដ្ឋបាលរាជធានី-ខេត្ត | 243 | 308 | 287 | 388 |
| ចំណាយមូលធន | 4 548 | 5 122 | 5 484 | 5 632 |
| ដោយហិរញ្ញប្បទានក្នុងស្រុក | 1 145 | 1 100 | 1 335 | 1 536 |
| ដោយហិរញ្ញប្បទានក្រៅស្រុក | 3 403 | 4 023 | 4 149 | 4 096 |
| កម្ចីសរុប | 198 | 107 | 122 | 0 |
| | | | | |
| **សមតុល្យ** | **-3 922** | **-3 579** | **-3 879** | **-3775** |
| | | | | |
| **ហិរញ្ញប្បទាន** | **3 922** | **3 579** | **3 879** | **3 775** |
| ហិរញ្ញប្បទានបរទេស | 3 457 | 3 923 | 4 091 | 4 025 |
| ហិរញ្ញប្បទានជាជំនួយឥតសំណង | 1 678 | 1 572 | 1 982 | 2 002 |
| កម្ចី | 1 943 | 2 541 | 2 389 | 2 355 |
| រំលស់បំណុល | -164 | -190 | -280 | -331 |
| ហិរញ្ញប្បទានក្នុងស្រុក | 465 | -344 | -212 | -250 |

ប្រភព÷ ព្រឹត្តិប័ត្រលេខ ៤ របាយការណ៍មូលនិធិរូបិយវត្ថុអន្តរជាតិ

## តារាង ១.២÷ ការអនុវត្តថវិកាទូទៅរបស់រដ្ឋាភិបាល ២០១១-២០១៤ (% នៃចំណូលក្នុងស្រុកសរុប)

| | ២០១១ (ទិន្នន័យបឋម) | ២០១២ (ទិន្នន័យបឋម) | ២០១៣ (ព្យាករ) | ២០១៤ (ព្យាករ) |
|---|---|---|---|---|
| **ចំណូលសរុប** | 13,1 | 15,2 | 14,5 | 15,1 |
| ចំណូលសារពើពន្ធ | 12,3 | 14,3 | 1,7 | 14,2 |
| ពន្ធផ្ទាល់ | 10,5 | 11,8 | 12,0 | 12,5 |
| ពន្ធប្រយោល | 1,8 | 2,3 | 2,5 | 2,6 |
| ពន្ធថ្នាក់រាជធានី-ខេត្ត | 7,9 | 8,7 | 8,8 | 9,0 |
| ចំណូលមិនមែនសារពើពន្ធ | 1,8 | 2,4 | 1,9 | 2,1 |
| ចំណូលមូលធន | 0,7 | 1,0 | 0,6 | 0,5 |
| | | | | |
| **ចំណាយ និងការផ្តល់កម្ចីសរុប** | 20,6 | 21,5 | 20,7 | 20,5 |
| ចំណាយចរន្ត | 11,5 | 12,2 | 11,7 | 12,4 |
| បៀវត្ស | 4,3 | 4,6 | 4,9 | 5,5 |
| មិនមែនបៀវត្ស | 6,8 | 7,1 | 6,3 | 6,4 |
| ចំណាយរដ្ឋបាលរាជធានី-ខេត្ត | 0,5 | 0,5 | 0,5 | 0,6 |
| ចំណាយមូលធន | 8,7 | 9,0 | 8,8 | 8,1 |
| ដោយហិរញ្ញប្បទានក្នុងស្រុក | 2,2 | 1,9 | 2,1 | 2,2 |
| ដោយហិរញ្ញប្បទានក្រៅស្រុក | 6,5 | 7,1 | 6,6 | 5,9 |
| កម្ចីសរុប | 0,4 | 0,2 | 0,2 | 0,0 |
| | | | | |
| **សមតុល្យ** | -7,5 | -6,3 | -6,2 | -5,5 |
| | | | | |
| **ហិរញ្ញប្បទាន** | 7,5 | 6,3 | 6,2 | 5,5 |
| ហិរញ្ញប្បទានបរទេស | 6,6 | 6,9 | 6,5 | 5,8 |
| ហិរញ្ញប្បទានជាជំនួយឥតសំណង | 3,2 | 2,8 | 3,2 | 2,9 |
| កម្ចី | 3,7 | 4,5 | 3,8 | 3,4 |
| រំលស់បំណុល | -0,3 | -0,3 | -0,4 | -0,5 |
| ហិរញ្ញប្បទានក្នុងស្រុក | 0,9 | -0,6 | -0,3 | -0,4 |

ប្រភព÷ របាយការណ៍មូលនិធិរូបិយវត្ថុអន្តរជាតិ “Article 4 Consultation”

## ២.៣ ក្របខ័ណ្ឌគតិយុត្ត និងក្របខណ្ឌស្ថាប័នសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ២.៣.១ ក្របខ័ណ្ឌអភិបាលកិច្ច

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ រាល់ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ត្រូវធានានូវធម្មនុញ្ញភាពឱ្យបានជាដាច់ខាត។ មាត្រា៥១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ១៩៩៩ បានចែងថា ប្រជាជនកម្ពុជាទាំងអស់មានសិទ្ធិក្នុងការស្នើ ឬបញ្ចេញយោបល់តាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល (គណៈរដ្ឋមន្ត្រី) និងតាមរយៈស្ថាប័នតុលាការ ដោយស្ថាប័នទាំងនេះមានមុខងារដាច់ដោយឡែកពីគ្នា។ រដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ពីបូរណភាពទឹកដី របបនយោបាយ, ស្ថាប័នព្រះមហាក្សត្រ, ស្ថាប័ននីតិប្បញ្ញត្តិ, ស្ថាប័ននីតិប្រតិបត្តិ, ស្ថាប័នតុលាការ, ក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងមូលដ្ឋាននៃសិទ្ធិ និងករណីយកិច្ចនៃប្រជាពលរដ្ឋ, សេដ្ឋកិច្ច,និងការអប់រំ វប្បធម៌ និងកិច្ចការសង្គម។

ច្បាប់ដែលត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ នឹងត្រូវប្រកាសដាក់ឱ្យអនុវត្តដោយព្រះរាជក្រមរបស់ព្រះមហាក្សត្រ។ ទន្ទឹមនេះ វិធាននៃការអនុវត្តច្បាប់ទាំងនេះ នឹងត្រូវកំណត់ក្នុងលិខិតបទដ្ឋានរបស់អង្គនីតិប្រតិបត្តិតាមឋានានុក្រម ដែលរួមមាន អនុក្រឹត្យ ដែលចេញដោយប្រមុខរាជរដ្ឋាភិបាល (តាមរយៈ ឬមិនតាមរយៈការអនុម័តដោយគណៈរដ្ឋមន្ត្រី) និងប្រកាស ដែលចេញដោយរដ្ឋមន្ត្រីក្រសួង។

អំណាចនីតិប្បញ្ញត្តិ ត្រូវអនុវត្តដោយរដ្ឋសភា និងព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមបង្កើតច្បាប់ ដោយរៀបចំជាសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់។ កិច្ចដំណើរការនៃការអនុម័តច្បាប់ដោយអង្គនីតិប្បញ្ញត្តិ ជាធម្មតាត្រូវការរយៈពេលប្រមាណពី ៣ ទៅ ៤ខែ។ ទោះជាយ៉ាងណា ក្នុងករណីចាំបាច់បន្ទាន់ ច្បាប់មួយចំនួនត្រូវបានរៀបចំ និងអនុម័តក្នុងក្នុងរយៈពេលតែ ២ ឬ ៣ថ្ងៃ។ សេចក្តីព្រាងច្បាប់អាចនឹងត្រូវបានអនុម័តដោយសម្លេងភាគច្រើនដាច់ខាត ឬសម្លេង ២ ភាគ ៣ នៃចំនួនតំណាងរាស្ត្រសរុប ទៅតាមប្រភេទនៃច្បាប់ និងត្រូវចូលជាធរមានទៅតាមបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងច្បាប់នោះ។

ប្រព័ន្ធតុលាការកម្ពុជា មានបីថ្នាក់ គឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ យោងតាមមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ តុលាការត្រូវធានានូវឯករាជ្យភាព លើកកម្ពស់ និងការពារសិទ្ធិនិងសេរីភាពប្រជាពលរដ្ឋ។ រដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ដែរថា អំណាចតុលាការ ជាអំណាចឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចណាមួយផ្សេងទៀតឡើយ ហើយត្រូវគ្របដណ្តប់លើគ្រប់រឿងក្តីទាំងអស់ រួមទាំងវិវាទរដ្ឋបាល។

អំណាចនីតិប្រតិបត្តិ ត្រូវអនុវត្តដោយរាជរដ្ឋាភិបាល ដែលមាននាយករដ្ឋមន្ត្រីជាប្រមុខ។

### ២.៣.២ រចនាសម្ព័ន្ធនៃវិស័យសាធារណៈ

រដ្ឋបាលថ្នាក់ជាតិមាន ៣៨ ក្រសួង-ស្ថាប័ន (គិតត្រឹមឆ្នាំ២០១៣)។ ក្រសួង-ស្ថាប័ននីមួយៗ មានអគ្គនាយកដ្ឋាន នាយកដ្ឋាន នៅថ្នាក់កណ្តាល និងមន្ទីរជំនាញនៅតាមបណ្តារាជធានី-ខេត្ត។ ក្រសួងដែលមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ។ រចនាសម្ព័ន្ធរបស់

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបង្ហាញក្នុងឧបសម្ព័ន្ធ ៦។ ដោយឡែក ស្ថាប័នដែលមានសមត្ថកិច្ចធ្វើសវនកម្មលើកិច្ចប្រតិបត្តិការរបស់រាជរដ្ឋាភិបាល គឺអាជ្ញាធរសវនកម្មជាតិ។

រដ្ឋបាលថ្នាក់ជាតិ មានរាប់បញ្ចូលផងដែរនូវគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាអង្គភាពស្វយ័ត ចំនួន ២៦ (ឆ្នាំ ២០១៣) ហើយអង្គភាពនីមួយៗត្រូវរាយការណ៍ជូនក្រសួង-ស្ថាប័នដែលជាអាណាព្យាបាលបច្ចេកទេស (យោងឧបសម្ព័ន្ធ ៥.១)។ ប្រាក់ចំណូលដែលបានមកពីការប្រមូលផ្ទាល់របស់គ្រឹះស្ថានសាធារណៈចំនួន ១៦ មានប្រមាណ ៣៣០ ពាន់លានរៀល ប្រហែលនឹង ៦០% នៃហិរញ្ញប្បទានដែលបានផ្ទេរពីថវិកាជាតិទៅអង្គភាពទាំងនេះ។ ចំណាយរបស់គ្រឹះស្ថានសាធារណៈមានចំណែកប្រហែលជា ៥% នៃចំណាយសរុបរបស់រដ្ឋ។

រដ្ឋបាលកណ្តាល ក៏មានភារកិច្ចគ្រប់គ្រងសហគ្រាសសាធារណៈ ចំនួន ១៥ ដែលរដ្ឋមានភាគកម្មទាំងស្រុង ឬភាគច្រើននៃភាគកម្មសរុប។ ប្រាក់ចំណូលសរុបនៃសហគ្រាសសាធារណៈចំនួន ១៥ ក្នុងឆ្នាំ២០១៤ មានប្រមាណ ៣ ២២៦ ពាន់លានរៀល ក្នុងនោះ ៨០% ជាប្រាក់ចំណូលដែលបានមកពីអគ្គិសនីកម្ពុជា។

ក្រៅពីរដ្ឋបាលថ្នាក់ជាតិ ការវាយតម្លៃនេះក៏មានវិសាលភាពគ្របដណ្តប់ទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រឹមកម្រិតរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ (យោង ផ្នែក ២.៣.៨)។ ដោយឡែក ឃុំ-សង្កាត់ មិនត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃនេះឡើយ។ គួរបញ្ជាក់ផងដែរថា ចំណាយសរុបរបស់រដ្ឋបាលឃុំ-សង្កាត់ មានប្រមាណជា ២,៥% នៃចំណាយសរុបរបស់រដ្ឋ។

### ២.៣.៣ ក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូល-ចំណាយ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុម័តនៅក្នុងខែឧសភា ឆ្នាំ២០០៨ អមដោយលិខិតបទដ្ឋានផ្សេងៗដែលត្រូវបានរៀបចំដើម្បីអនុវត្តក្របខ័ណ្ឌនៃច្បាប់នេះ[3]។ ជាក់ស្តែង មាត្រា ២ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក, ការបញ្ជាចំណាយត្រូវទាមទារឱ្យមានការត្រួតពិនិត្យ និងបោះត្រាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន។ នៅក្នុងមាត្រា៨ ប្រធានស្ថាប័នដែលជាអាណាប័កត្រូវបោះផ្សាយអាណត្តិទូទាត់ អមដោយឯកសារគាំទ្រពាក់ព័ន្ធសម្រាប់គណនេយ្យករសាធារណៈ ដែលត្រូវទទួលបន្ទុកទូទាត់ចំណាយ។ មានតែគណនេយ្យករសាធារណៈប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តថវិការដ្ឋ (មាត្រា៧២)។ ដូចនេះ អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី-ខេត្ត ជាអង្គភាពតែមួយគត់ដែលទទួលបន្ទុកទូទាត់បៀវត្ស និងទូទាត់ជូនអ្នកផ្គត់ផ្គង់។

មាត្រា៤៧-៥០ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក គ្របដណ្តប់លើការធានាចំណាយ រីឯមាត្រា៥៣-៥៦ គ្របដណ្តប់លើការបញ្ជាចំណាយ (អាណត្តិជាមួយនឹងទិដ្ឋាការបោះត្រា), មាត្រា៥៧-៦៣ គ្របដណ្តប់លើការអនុវត្ត

[3] ច្បាប់នេះមិនទាន់បានដាក់ឱ្យអនុវត្តពេញលេញនៅឡើយពាក់ព័ន្ធនឹងការអនុវត្តថវិកា (មាត្រា ៧៦) ដោយហេតុថាការកែសម្រួលអនុក្រឹត្យ (បានដាក់ឆ្លងគណៈរដ្ឋមន្ត្រី) មិនទាន់បានបញ្ចប់នៅឡើយ។

ចំណាយ និងមាត្រា៦៤-៦៧ គ្របដណ្តប់លើរដ្ឋទេយ្យបុរេប្រទាន។ មាត្រា៩៤-១១៦ គ្របដណ្តប់លើការរៀបចំនិងប្រព្រឹត្តទៅរបស់គណនេយ្យ ដោយរាប់បញ្ចូលការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (មាត្រា១១៣)។

មាត្រា ១១៣ ចែងថា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំគួរត្រូវបញ្ចូលនូវ (១) តារាងសមតុល្យសាកល្បងនៃគណនី ដែលជាការប្រមូលផ្តុំនូវលទ្ធផលរបស់គណនីរួមដោយគណនេយ្យករសាធារណៈ (២) ស្ថានភាពចំណូលថវិកា (៣) ស្ថានភាពនៃការរៀបចំចំណាយថវិកាដោយអគ្គនាយកដ្ឋាន/នាយកដ្ឋានរបស់ក្រសួង-ស្ថាប័ននីមួយៗ រួមទាំងទំហំចំណាយសរុបក្នុងជំពូកនីមួយៗដែលបានបញ្ជាក់ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ (៤) ស្ថានភាពនៃប្រតិបត្តិការក្នុងគណនីពិសេសរតនាគារ និង (៥) របាយការណ៍ចំណូល។

សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំដោយផ្អែកលើវិធានគតិយុត្តដែលចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈខាងលើ រីឯច្បាប់ទូទាត់ថវិកា (និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ) ត្រូវក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ និងផ្ញើទៅអាជ្ញាធរសវនកម្មជាតិ។

ការកែប្រែថវិកាក្នុងឆ្នាំ ត្រូវបានអនុញ្ញាតដោយមាត្រា៥៥-៦២ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ តាមរយៈការរៀបចំច្បាប់ថវិកាកែតម្រូវ ឬអនុក្រឹត្យ ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាមី។ ការផ្ទេរឥណទានថវិកាពីអង្គភាពសាធារណៈមួយ ទៅអង្គភាពសាធារណៈមួយទៀត ត្រូវធ្វើឡើងដោយច្បាប់ថវិកាកែតម្រូវ ឬអនុក្រឹត្យ។ ការកែសម្រួលឥណទានថវិកាក្នុងករណីគ្រោះធម្មជាតិ និងករណីបន្ទាន់ ឬអាសន្ន ក៏ត្រូវធ្វើឡើងក្នុងលក្ខខណ្ឌដូចគ្នា ហើយការកែសម្រួលនេះ ត្រូវរំលេចចេញនៅក្នុងច្បាប់ថវិកាឆ្នាំបន្ទាប់។

ការផ្ទេរឥណទានពីជំពូកមួយទៅជំពូកមួយទៀត (ឧទាហរណ៍÷ ការទិញទំនិញ ក្នុងជំពូក៦០ នៃប្លង់គណនីផ្ទេរទៅជាសេវា ក្នុងជំពូក៦១) ក្នុងស្ថាប័នតែមួយ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។ ប៉ុន្តែ ការផ្ទេរឥណទានពីចំណាយមូលធន (ជំពូក២១) ទៅឥណទានចំណាយចរន្ត (ជំពូក៦០-៦៥) គឺមិនត្រូវបានអនុញ្ញាតឡើយ។ ការផ្ទេរឥណទាន ពីជំពូក ០៩ ចំណាយមិនបានគ្រោងទុក ទៅជំពូកណាមួយផ្សេងទៀត ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

ការផ្ទេរឥណទានឆ្លងគណនី នៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រីឯការផ្ទេរឥណទានឆ្លងអនុគណនី នៅក្នុងគណនីតែមួយ អាចធ្វើឡើងដោយប្រកាសរបស់ក្រសួង-ស្ថាប័នសាមី ដោយត្រូវចម្លងជូនអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការប្រមូល និងគ្រប់គ្រងចំណូល ដោយអង្គភាពចំណូលធំៗ ដូចជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវគ្រប់គ្រងដោយច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីគយ ដែលព័ត៌មានលម្អិតនៃច្បាប់នេះ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធនឹងត្រូវបានបង្ហាញក្នុងសូចនាករសមិទ្ធកម្មទី១៣ សមាសធាតុ ១។ ដោយឡែកការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវគ្រប់គ្រងដោយក្រសួង-ស្ថាប័នសាមី ហើយមានចែងក្នុងសារាចររបស់រាជរដ្ឋាភិបាល នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ និងប្រកាសផ្សេងៗទៀតក៏បានផ្តល់មូលដ្ឋានបច្ចេកទេស និងរដ្ឋបាលសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ។

### ២.៣.៤ ការរៀបចំផែនការ និងថវិកា

ប្រព័ន្ធនៃការរៀបចំថវិកាត្រូវបានអនុវត្តតាមយន្តការពីរដាច់ដោយឡែកពីគ្នាសម្រាប់ថវិកាចរន្ត និងថវិកាមូលធន។ នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុករៀបចំថវិកាចរន្ត និងក្របខ័ណ្ឌនៃការអនុវត្តថវិកាក្នុងឆ្នាំ។ កិច្ចដំណើរការ ត្រូវបានបរិយាយក្នុង PI-11 និង PI-16 នៃ**ផ្នែក គ**។ ដោយឡែកក្រសួងផែនការទទួលបន្ទុករៀបចំកម្មវិធីវិនិយោគសាធារណៈ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ក្នុងន័យនេះ រាល់សំណើគម្រោងវិនិយោគពីក្រសួង-ស្ថាប័ន ត្រូវបានត្រួតពិនិត្យដោយក្រសួងផែនការ ដើម្បីពិចារណាថាកម្មវិធី ឬគម្រោងណាគួរត្រូវដាក់បញ្ចូលនៅក្នុងកម្មវិធីវិនិយោគសាធារណៈ។ ជាទូទៅថវិកាវិនិយោគត្រូវបានគាំទ្រដោយហិរញ្ញប្បទាដៃគូអភិវឌ្ឍន៍ ហើយក្រសួង-ស្ថាប័នចាំបាច់ត្រូវអនុវត្តកិច្ចសម្របសម្រួលផ្ទាល់ជាមួយដៃគូអភិវឌ្ឍន៍ ឬតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នមានមុខងារកៀរគរហិរញ្ញប្បទានខាងក្រៅសម្រាប់គម្រោង ក៏ដូចជាគ្រប់គ្រងលើប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ។ ទន្ទឹមនេះ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា គឺការងារអាទិភាពក្នុងឆ្នាំ២០១៤ (PI-12) ដែលបានជំរុញឱ្យធ្វើសមាហរណកម្មថវិកាចរន្តជាមួយនឹងថវិកាវិនិយោគ។

នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ទទួលបន្ទុកក្នុងការរៀបចំបូកសរុបរួមនូវថវិកាវិនិយោគ។ សម្រាប់ថវិកាមូលធនដែលគាំទ្រដោយហិរញ្ញប្បទានខាងក្រៅ (ជាក់ស្តែង ថវិកាដៃគូអភិវឌ្ឍន៍ គឺដាក់បញ្ចូលសមាសធាតុចំណាយ) ដែលទាញយកពីសំណើរបស់ក្រសួង-ស្ថាប័ន និងកម្មវិធីវិនិយោគសាធារណៈ ដោយបន្សុីពីលើចុះក្រោមជាមួយនឹងទំហំនៃការផ្តល់ថវិកាក្នុងឆ្នាំជាក់ស្តែង (ជាគម្រោងដែលគ្មានការកែប្រែឱ្យយឺតជាងការគ្រោងផែនការ)។ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ជាគោលការណ៍ ចាំបាច់ត្រូវត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគដែលគាំទ្រដោយហិរញ្ញប្បទានខាងក្រៅ ដែលត្រូវតម្កល់ក្នុងគណនីនៅក្នុងធនាគារជាតិនៃកម្ពុជា (រួមទាំងកិច្ចលទ្ធកម្ម) រួមមាន កម្ចីហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី និងគម្រោងរបស់ធនាគារពិភពលោក។ ក្នុងនោះ អង្គភាពអនុវត្តគម្រោង ត្រូវបានបង្កើតឡើងនៅក្នុងនាយកដ្ឋានវិនិយោគ ដែលជាអង្គភាពមានមុខងារគ្រប់គ្រងគម្រោង។ ទន្ទឹមនេះ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក៏ចាំបាច់ត្រូវតាមដានការផ្តល់ថវិកា និងចំណាយរបស់គម្រោងផ្ទាល់ (ជាពិសេសការគាំទ្រថវិកាផ្ទាល់) ដែលគ្រប់គ្រងដោយក្រសួង-ស្ថាប័ន តាមរយៈអង្គភាពគ្រប់គ្រងគម្រោងផ្ទៃក្នុងដែលបានបង្កើតឡើង។ ទោះជាយ៉ាងនេះក៏ដោយ លំហូរនៃព័ត៌មាននៅមិនទាន់មានភាពរលូនសម្រាប់គម្រោងដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៅឡើយ។

នាយកដ្ឋានវិនិយោគ គ្រប់គ្រងថវិកាវិនិយោគដែលគាំទ្រដោយហិរញ្ញប្បទានក្នុងស្រុកដែលស្មើនឹងមួយភាគបួននៃចំណាយថវិកាសរុប។

### ២.៣.៥ ការទិញលទ្ធកម្ម

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២។ មុនមានច្បាប់នេះ កិច្ចលទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយក្របខ័ណ្ឌគតិយុត្ត

ដែលមានភាពបែកខ្ញែកគ្នាមិនប្រមូលផ្តុំ។ ច្បាប់លទ្ធកម្មសាធារណៈថ្មី មានភាពគ្រប់ជ្រុងជ្រោយ និងមានវិសាលភាពអនុវត្តនៅគ្រប់កិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ ក៏ប៉ុន្តែមិនមានបញ្ចូលនូវទិដ្ឋភាពគតិយុត្តមួយចំនួន នៃលទ្ធកម្មសាធារណៈទំនើបនេះទេ ដូចជាផែនការលទ្ធកម្ម, ការអនុវត្តប្រព័ន្ធតាមដាន, វិធីសាស្ត្រលទ្ធកម្ម, និងយន្តការឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម[4]។ ទន្ទឹមនេះ ច្បាប់នេះ ក៏មិនមានចែងច្បាស់លាស់ពីនិរាករណ៍ ឬការបន្តអនុវត្តនូវលិខិតបទដ្ឋានជាច្រើនដែលពាក់ព័ន្ធនឹងវិស័យលទ្ធកម្មសាធារណៈ ដូចជា អនុក្រឹត្យ និងប្រកាសលេខ ៣១៩ ឆ្នាំ ១៩៩៥ និងការដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិគ្រប់គ្រងលទ្ធកម្មសាធារណៈ ដែលចេញក្នុងឆ្នាំ២០១០។ ក្រុមការងារវាយតម្លៃក៏ត្រូវបានប្រាប់ផងដែរថា ចាប់តាំងពីការដាក់ឱ្យអនុវត្តច្បាប់ថ្មីមក អនុក្រឹត្យ និងប្រកាសចំនួន៥ កំពុងត្រូវបានពិភាក្សា។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកលើការអនុវត្តកិច្ចលទ្ធកម្មដោយថវិកាជាតិ ដែលការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវបានធ្វើវិមជ្ឈការទៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពអនុវត្តកិច្ចលទ្ធកម្ម។ ដោយឡែក កិច្ចលទ្ធកម្មសម្រាប់កម្មវិធី/គម្រោងហិរញ្ញប្បទានខាងក្រៅ ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិរបស់បណ្តាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ គោលការណ៍ណែនាំស្តីពីលទ្ធកម្មសម្រាប់គម្រោងរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានបោះផ្សាយក្នុងខែកញ្ញា ឆ្នាំ២០០៥។ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកត្រួតពិនិត្យ និងតាមដានកិច្ចលទ្ធកម្មទាំងនេះ។

## ២.៣.៦ ការអនុវត្តថវិកា ការគ្រប់គ្រងបំណុលនិងសាច់ប្រាក់ គណនេយ្យ និងការរៀបចំរបាយការណ៍

ការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន តម្រូវឱ្យមានការពិនិត្យ និងអនុម័តដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមានការអនុម័តពីនាយកដ្ឋានហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (និងនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ សម្រាប់ចំណាយវិនិយោគហិរញ្ញប្បទានក្នុងស្រុក) សម្រាប់ការស្នើធានាចំណាយ។ ជាក់ស្តែង នៅពេលដែលគម្រោងត្រូវបានអនុម័ត (ផ្អែកលើភាពត្រឹមត្រូវសមស្របជាមួយនឹងថវិកាដែលបានអនុម័ត) ក្រសួង-ស្ថាប័ន អាចពិនិត្យ និងតាមដានការធានាចំណាយ និងកិច្ចដំណើរការលទ្ធកម្ម (លើការកំណត់ពិដាន ដូចក្នុង PI-19 ដោយកិច្ចលទ្ធកម្មត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)។ ក្នុងន័យនេះ នៅពេលដែលទំនិញ និងសេវា ត្រូវបានទទួល និងត្រួតពិនិត្យ ក្រសួង-ស្ថាប័នត្រូវរៀបចំសំណើបញ្ជាការទូទាត់ ផ្ញើទៅនាយកដ្ឋានហិរញ្ញកិច្ច/នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ដោយភ្ជាប់ជាមួយនឹងឯកសារពាក់ព័ន្ធ។ បន្ទាប់ពីពិនិត្យ និងផ្ទៀងផ្ទាត់លើសំណើទូទាត់រួចមក នាយកដ្ឋានហិរញ្ញកិច្ច/នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ត្រូវបោះត្រាលើអាណត្តិទូទាត់ រួចផ្ញើបន្តទៅអគ្គ-នាយកដ្ឋានរតនាគារជាតិសម្រាប់ការទូទាត់ចំណាយជាក់ស្តែងទៅអ្នកផ្គត់ផ្គង់។

---

[4] ច្បាប់នេះមិនមានបោះផ្សាយជាភាសាអង់គ្លេសទេ។ មានការប្រែសម្រួលក្រៅផ្លូវការដោយការិយាល័យធនាគារពិភពលោកប្រចាំប្រទេស។

នៅថ្នាក់រាជធានី-ខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវដើរតួនាទីជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ហើយអភិបាលនៃគណៈអភិបាលខេត្ត ត្រូវចុះហត្ថលេខាលើអាណត្តិទូទាត់ដែលត្រូវផ្ញើទៅរតនាគារខេត្ត (គឺប្រព្រឹត្តិទៅដូចនឹងមុខងាររបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅថ្នាក់ជាតិដែរ) សម្រាប់ការទូទាត់។

ដោយឡែក ការបើកប្រាក់បៀវត្ស គឺត្រូវបានផ្ទេរត្រង់ចូលក្នុងគណនីផ្ទាល់របស់មន្ត្រីរាជការ។ រីឯចំណូលក៏ត្រូវបង់ចូលទៅក្នុងគណនីទោលរតនាគារ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៣។

គោលការណ៍ដោយឡែក និងនីតិវិធីនិងប្រព័ន្ធពាក់កណ្តាលស្វ័យប្រវត្តិ នៅតែត្រូវបានប្រើប្រាស់ក្នុងការអនុវត្តថវិកា ការរៀបចំរបាយការណ៍ និងដំណើរការគណនេយ្យ។ សូម្បីតែនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន/នាយកដ្ឋាននីមួយៗ នៅតែប្រើប្រាស់ប្រព័ន្ធផ្ទាល់ខ្លួនដោយគ្មានការគាំទ្រពីប្រព័ន្ធបច្ចេកវិទ្យា។ ទោះជាយ៉ាងនេះ អគ្គនាយកដ្ឋានរតនាគារជាតិ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ (ប្រព័ន្ធព័ត៌មានវិទ្យាខ្មែរ KIT) ប៉ុន្តែវានៅតែមានបញ្ហាពាក់ព័ន្ធនឹងដំណើរការ (មានពន្យល់ក្នុង PI-4 សមាសធាតុ ២ ក្នុង**ផ្នែក គ**)។ លើសពីនេះ អគ្គនាយកដ្ឋានរតនាគារជាតិ មិនមានភ្ជាប់ប្រព័ន្ធកុំព្យូទ័រជាមួយអគ្គនាយកដ្ឋាន/នាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ និងអង្គភាពគ្រប់គ្រងសាច់ប្រាក់) ឬជាមួយក្រសួង-ស្ថាប័នឡើយ។ ទោះយ៉ាងណា នាពេលបច្ចុប្បន្ន ការធ្វើសមាហរណកម្មប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានរៀបចំសម្រាប់ដាក់ឱ្យអនុវត្តក្នុងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកំពុងត្រៀមបន្តទៅក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ដែលនឹងភ្ជាប់ជាមួយប្រព័ន្ធផ្សេងទៀត។

## ២.៣.៧ សវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ

មុខងារសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតដោយច្បាប់ស្តីពីសវនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ និងអនុក្រឹត្យលេខ ៤០ អនក្រ.បក ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់សវនកម្មផ្ទៃក្នុងសម្រាប់ក្រសួង-ស្ថាប័ន និងសហគ្រាសរដ្ឋ ហើយកម្មវត្ថុនៃច្បាប់នេះ គឺដើម្បីអនុញ្ញាតឱ្យបង្កើតសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន និងសហគ្រាសរដ្ឋនីមួយៗ។

ដោយផ្អែកលើមូលដ្ឋានអនុក្រឹត្យលេខ ៤០ អនក្រ.បក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរសវនកម្មជាតិ បានចេញប្រកាសលេខ ៤០៥ សហវ.ប្រក (ខែឧសភា ឆ្នាំ២០០៥) ស្តីពី "បទដ្ឋានសវនកម្មផ្ទៃក្នុងសម្រាប់ការអនុវត្តវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង" និង "ក្រមសីលធម៌សវនករ" (នៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និងប្រកាសលេខ ១១០៩ សហវ.ប្រក (ខែវិច្ឆិកា ឆ្នាំ២០០៦) ស្តីពី "របាយការណ៍គោលនយោបាយគ្រប់គ្រងផ្ទៃក្នុង"។

អាជ្ញាធរសវនកម្មជាតិ ត្រូវបានបង្កើតឡើងនៅក្នុងច្បាប់សវនកម្ម ឆ្នាំ២០០០ ដែលត្រូវបានធ្វើវិសោធនកម្មនៅខែវិច្ឆិកា ឆ្នាំ២០០០ (ព្រះរាជក្រមលេខ នស/រកម/១១០០/១១) និងខែសីហា ឆ្នាំ២០០៦ (ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤)។ ទន្ទឹមនេះ អាជ្ញាធរសវនកម្មជាតិ ក៏មានថវិកាដាច់ដោយឡែករបស់ខ្លួន ដែលត្រូវបានផ្តល់ដោយថវិកាជាតិ ប៉ុន្តែក៏ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (មាត្រា ១៧) និងតម្រូវ

ឱ្យចូលឆ្លើយបំភ្លឺនៅចំពោះមុខរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលផងដែរ (មាត្រា ១៤)។ របាយការណ៍សវនកម្មត្រូវបានចាត់ទុកថាជាឯកសារសាធារណៈ (មាត្រា ២៩) លើកលែងតែខ្លឹមសារមួយចំនួនដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ។ អគ្គសវនករមានឋានៈ និងបុព្វសិទ្ធិស្មើទេសរដ្ឋមន្ត្រី ហើយអគ្គសវនកររងមានឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋមន្ត្រី។ អគ្គសវនករ និងអគ្គសវនកររងត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងត្រូវបានអនុម័តដោយសម្លេងពីរភាគបី (មាត្រា ១៨) នៃសមាជិកសភា។ អគ្គសវនករ មានសិទ្ធិក្នុងការកំណត់ប្រាក់បៀវត្សរបស់មន្ត្រីរាជការនៅក្នុងអាជ្ញាធរសវនកម្មជាតិ។

មាត្រា ២ ចែងថា អាជ្ញាធរសវនកម្មជាតិ មានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មរាល់ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល រួមទាំងរដ្ឋអំណាចថ្នាក់មូលដ្ឋាន និងអង្គភាពផ្សេងៗទៀត រួមមានសហគ្រាសសាធារណៈដែលទទួលបានសម្បទាន ឬអត្ថប្រយោជន៍ពីរាជរដ្ឋាភិបាលផងដែរ។

## ខ.៣.៨ រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិ ចែកចេញជាបីកម្រិត គឺ កម្រិតរាជធានី-ខេត្ត កម្រិតក្រុង-ស្រុក-ខណ្ឌ និងកម្រិតឃុំ-សង្កាត់ (រូបភាព ខ.១)។ ក្នុងឆ្នាំ ២០១៤ រដ្ឋបាលថ្នាក់ក្រោមជាតិ មានរាជធានីចំនួន ១, ខេត្តចំនួន ២៤, ក្រុង-ស្រុក-ខណ្ឌចំនួន ១៨៥ និងឃុំ-សង្កាត់ចំនួន ១៦៣៣។ ឃុំ-សង្កាត់ មានភូមិចំនួន ១៤ ១៣៩ ប៉ុន្តែពុំមានក្នុងរចនាសម្ព័ន្ធរដ្ឋបាលឡើយ។ រដ្ឋបាលថ្នាក់ក្រោមជាតិ មានបង្ហាញក្នុងរូបភាព ខ.១ ខាងក្រោម។

រដ្ឋបាលរាជធានី-ខេត្ត និងរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ជាតិ តាមរយៈការចាត់តាំងគណៈអភិបាល អមនឹងក្រុមប្រឹក្សាដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតអសកល។ រដ្ឋបាលទាំងពីរកម្រិតនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ហើយកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ។ រដ្ឋបាលឃុំ-សង្កាត់ ត្រូវគ្រប់គ្រងផ្ទាល់ដោយក្រុមប្រឹក្សាដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាសកល នៅមូលដ្ឋាន (៥ឆ្នាំម្តង)។

**រូបភាព ខ.១÷ រចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**



ការរៀបចំថវិកាសម្រាប់រដ្ឋបាលរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ត្រូវរៀបចំជាមួយនឹងការរៀបចំថវិកានៃរដ្ឋបាលថ្នាក់ជាតិ ឯការអនុវត្តថវិកាក៏ត្រូវអនុវត្តតាមវិធាននិងនីតិវិធីដូចគ្នា។ ចាប់ពីឆ្នាំ២០០២ រដ្ឋបាលឃុំ-សង្កាត់ត្រូវរៀបចំថវិកាដាច់ដោយឡែក និងមិនទាមទារឱ្យមានការអនុម័តពីរាជរដ្ឋាភិបាលឡើយ ទោះបីជាចំណូលរបស់រដ្ឋបាលឃុំ-សង្កាត់ពឹងផ្អែកខ្លាំងទៅលើឧបត្ថម្ភធនពីថ្នាក់ជាតិក៏ដោយ។ ការអនុវត្តថវិកានៃរដ្ឋបាលឃុំ-សង្កាត់ ត្រូវឆ្លងកាត់រតនាគាររាជធានី-ខេត្ត។

ថវិកាដែលបានវិភាជទៅរដ្ឋបាលក្រុង-ស្រុក ក្នុងឆ្នាំ២០១៤ មានប្រមាណ ៦៨ ពាន់លានរៀល គឺប្រហែលនឹង ០,៨% នៃចំណូលថវិកាចរន្តសរុបរបស់រដ្ឋ។ ការផ្ទេរឥណទានទៅរដ្ឋបាលឃុំ-សង្កាត់ ក្នុងឆ្នាំ២០១៤ មានប្រមាណ ២៣៧ ពាន់លានរៀល គឺប្រហែល ២,៨% នៃចំណូលថវិកាចរន្តសរុបរបស់រដ្ឋ, ដែលក្នុងឥណទាននេះ ១០៥ ពាន់លានរៀល សម្រាប់កិច្ចដំណើរការរដ្ឋបាល និង ១៣២ពាន់លានរៀលទៀត សម្រាប់គម្រោងអភិវឌ្ឍន៍នៅមូលដ្ឋានដែលអនុញ្ញាតឱ្យឃុំ-សង្កាត់កំណត់នូវអាទិភាពនៃការអភិវឌ្ឍរបស់ខ្លួន។

ដើម្បីជំរុញការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័ត ក្នុងឆ្នាំ២០០៨។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលទាំងពីរកម្រិតនេះ ត្រូវបានរៀបចំឡើងដំបូងនៅក្នុងឆ្នាំ២០០៩ ទន្ទឹមនឹងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១០។ កម្មវិធីនេះ ចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១១។

ជោគជ័យសំខាន់ៗនៃការអនុវត្តច្បាប់ថ្មីនេះ រួមមានការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្មី និងការផ្ទេរសមាហរណកម្មមន្ត្រីរាជការប្រមាណ ១០ ០០០ នាក់ ទៅក្នុងរចនាសម្ព័ន្ធថ្មីនេះ។ យន្តការគតិយុត្តចំនួនពីរ កំពុងត្រូវបានរៀបចំដើម្បីអនុញ្ញាតឱ្យមានការផ្ទេរវិមជ្ឈការសិទ្ធិអំណាច និងការទទួលខុសត្រូវ ក្នុងការជ្រើសរើស តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចរបស់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ។ លើសពីនេះ មូលនិធិក្រុង-ស្រុក ត្រូវបានបង្កើតឡើង ដោយទទួលបានការផ្ទេរឥណទានប្រចាំឆ្នាំប្រមាណ ០,៨% នៃចំណូលថវិកាចរន្ត ចាប់ពីឆ្នាំ២០១៤។

# គ. ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចដំណើរការ និងស្ថាប័ន

## គ.១ ភាពជឿទុកចិត្តនៃថវិកា

### គ.១.១ ចំណាយសរុបធៀបនឹងច្បាប់ថវិកា (PI-1)

**(១) ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត**

វិសាលភាពដែលរដ្ឋាភិបាលអនុវត្តចំណាយថវិកាគ្រោងទុក គឺជាចំណុចគន្លឹះនៃការផ្តល់សេវាសាធារណៈ ក្នុងឆ្នាំ ដែលបានបង្ហាញក្នុងរបៀបវារៈគោលនយោបាយ (Policy Statements) ការសន្យាលើលទ្ធផលក្នុងឆ្នាំ (Output Commitments) និងផែនការការងារ (Work Plans)។ សូចនាករនេះ វាស់វែងចំណាយជាក់ស្តែងសរុប ធៀបនឹងចំណាយសរុបគោលដែលបានគ្រោង (ដូចបានកំណត់ក្នុងឯកសារថវិកា និងរបាយការណ៍ថវិការបស់រដ្ឋាភិ-បាល) ដោយមិនរួមបញ្ចូលនូវចំណាយ ០២ ផ្នែក ដែលរដ្ឋាភិបាល មានការត្រួតពិនិត្យតាមដានតិចតួច គឺការទូទាត់សេវាបំណុល (debt service payments) និងចំណាយវិនិយោគសាធារណៈដោយគម្រោងហិញ្ញប្បទានក្រៅប្រទេស។ ចំណាយសរុប រួមបញ្ចូលចំណាយចរន្ត និងចំណាយវិនិយោគនៃរដ្ឋបាលថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី-ខេត្ត) ព្រមទាំងសាលារាជធានី-ខេត្ត។

តារាង គ.១ បង្ហាញពីការអនុវត្តថវិកា ធៀបនឹងច្បាប់ថវិកាដែលបានអនុម័តដោយរដ្ឋសភា ក្នុងរវាងឆ្នាំ ២០១១ និង២០១៣។ នាពេលថ្មីៗនេះ ការវាយតម្លៃលើភាពជឿទុកចិត្តនៃថវិកា បង្ហាញថាស្ថិរភាពនៃការអនុវត្តនៅពុំទាន់អាចរក្សាបានល្អនៅឡើយ ហើយការងារមួយចំនួនត្រូវបន្តកែលម្អបន្ថែមទៀត ជាពិសេសការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម និងការត្រួតពិនិត្យនិងការគ្រប់គ្រងចំណាយ[5]។ នៅក្នុងការវាយតម្លៃ PEFA ឆ្នាំ២០១០ ករណីខាងលើត្រូវបានកត់សម្គាល់ថាមានការកែលម្អ ជាក់ស្តែងក្នុងឆ្នាំ ២០០៨ ការចំណាយជាក់ស្តែងមានគម្លាតថវិកាត្រឹមតែ ១២,២% ប៉ុណ្ណោះពីថវិកាគ្រោងទុក។ ទោះបីជាមានការបង្កើនប្រាក់បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលយ៉ាងណាក៏ដោយ អ្វីដែលគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០១៣ នោះ គឺចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានរក្សានៅក្នុងកម្រិតដែលបានកំណត់ក្នុងកញ្ចប់ថវិកាដែលបានអនុម័ត។ យ៉ាងណាក៏ដោយ ការបន្តកើនឡើងនៃ

[5] អ.គ.ហ./គសហវ (២០១៤) *របាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

បៀវត្សនៅក្នុងឆ្នាំ ២០១៤ ក្នុងរង្វង់ 0,៥% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ដែលបៀវត្សសរុបកើនឡើងដល់ ៥,៥% នៃ ផ.ស.ស.[6] គឺជាចំណុចគួរឱ្យបារម្ភមួយនៃចំណាយសាធារណៈ។

### តារាង គ.១÷ លទ្ធផលចំណាយសរុបធៀបថវិកាដែលបានអនុម័ត[7]

| គិតជាលានរៀល | ២០១១ | | ២០១២ | | ២០១៣ | |
|---|---|---|---|---|---|---|
| | ច្បាប់ថវិកា | ការអនុវត្ត | ច្បាប់ថវិកា | ការអនុវត្ត | ច្បាប់ថវិកា | ការអនុវត្ត |
| ចំណាយចរន្ត | ៥ ៨០១ ៨០៨ | ៦ ១៤៨ ៣៧៤ | ៦ ៦៧៣ ៤៦៩ | ៧ ១២៧ ៥៦៥ | ៧ ៦១៥ ៣៨៧ | ៧ ៤៣៨ ៤៤០ |
| ចំណាយមូលធន | ១ ៨០៥ ៤២៧ | ១ ៦១៦ ៣០២ | ១ ៦៦២ ៣៤៣ | ១ ៥២៥ ១៨៩ | ១ ៨៥៣ ៩០៧ | ១ ៦៣៣ ៧៧០ |
| ចំណាយសរុប | ៧ ៦០៧ ២៣៥ | ៧ ៧៦៤ ៦៧៦ | ៨ ៣៣៥ ៨១២ | ៨ ៦៥២ ៧៥៤ | ៩ ៤៦៩ ២៩៤ | ៩ ០៧២ ២១០ |
| ដក ការទូទាត់អត្រាការប្រាក់ | ១៤០ ០០០ | ១៣៩ ៦៥០ | ១៧១ ០០០ | ៣០៥ ១១៧ | ២៥៦ ០០០ | ៤៣៩ ២៩៨ |
| ដក ការទូទាត់ប្រាក់ដើម | ១៨០ ០០០ | ១៦៣ ៦៩៨ | ២៥០ ០០០ | ១៩០ ២៣៨ | ២៨០ ០០០ | ២៤២ ២៥៦ |
| ចំណាយគោលសរុប | ៧ ២៨៧ ២៣៥ | ៧ ៤៦១ ៣២៨ | ៧ ៩១៤ ៨១២ | ៨ ១៥៧ ៣៩៩ | ៨ ៩៣៣ ២៩៤ | ៨ ៣៩០ ៦៥៦ |
| គម្លាត | ២,៤% | | ៣,១% | | -៦.១% | |

ប្រភព÷ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ

ផ្អែកលើទិន្នន័យខាងលើ ពិន្ទុសូចនាករសមិទ្ធកម្មទី១ ត្រូវបានផ្តល់ពិន្ទុដូចមានក្នុងតារាងខាងក្រោម[8]។ សូចនាករនេះ ទទួលបានពិន្ទុ A ពីព្រោះគម្លាតដែលមានខ្ពស់ជាង៥% មានតែមួយឆ្នាំប៉ុណ្ណោះក្នុងរយៈពេល៣ឆ្នាំចុងក្រោយ។

### តារាង គ.២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១

| សូចនាករ | សមាសធាតុ/ វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុ ឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត (M1) | B | A | គម្លាតនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកា ដែលជាតម្លៃដាច់ខាត គឺ ឆ្នាំ២០១១ (២,៤%), ឆ្នាំ២០១២ (៣,១%), និងឆ្នាំ២០១៣ (៦,១%) |

[6] មូលនិធិរូបិយវត្ថុអន្តរជាតិ (២០១៤) *កម្ពុជា÷ ការពិគ្រោះយោបល់អត្ថបទ IV ឆ្នាំ២០១៣* របាយការណ៍តាមប្រទេស របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

[7] ចំនួនសរុបដែលបង្ហាញក្នុងតារាងគឺមិនបានបញ្ចូលចំណាយវិនិយោគសាធារណៈដោយគម្រោងហិរញ្ញប្បទានក្រៅប្រទេសទេ។ ចំណាយជាក់ស្តែងដោយចំណាយវិនិយោគសាធារណៈដោយគម្រោងហិរញ្ញប្បទានក្រៅប្រទេស មានចំនួន ៣.៤០២.៧០៤លានរៀល សម្រាប់ឆ្នាំ២០១១, ៤.០២៧.៤៨៧លានរៀល សម្រាប់ឆ្នាំ២០១២ និង ៤.៣០៦.០៨៤លានរៀល សម្រាប់ឆ្នាំ២០១៣។

[8] ទិន្នន័យបឋមសម្រាប់ឆ្នាំ២០១៤ បង្ហាញថាគម្លាតសរុបរវាងចំណាយជាក់ស្តែង និងចំណាយដែលបានរៀបចំផែនការគឺ ៦,៨%។

## គ.១.២ សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកា (PI-2)

សូចនាករនេះប្រៀបធៀបចំណាយគោលសរុប (ផែនការចំណាយនិងការអនុវត្ត) ទៅតាមក្រសួង-ស្ថាប័ន។ សមាសធាតុទី១ វាស់វែងអំពីកម្រិតនៃការវិភាជឡើងវិញនូវថវិការបស់ក្រសួង-ស្ថាប័ន ក្នុងអំឡុងពេលអនុវត្តថវិកា ដែលរួមចំណែកធ្វើឱ្យមានគម្លាតនៅក្នុងសមាសភាគចំណាយ ដោយមិនគិតចំណាយមិនបានគ្រោងទុករបស់ក្រសួង ស្ថាប័ន។ ការប្រើប្រាស់ចំណាយមិនបានគ្រោងទុករបស់ក្រសួង-ស្ថាប័ន នឹងត្រូវបានវាយតម្លៃនៅក្នុងសមាសធាតុទី២។ ការវាយតម្លៃធ្វើឡើងសម្រាប់រដ្ឋបាលថ្នាក់កណ្ដាលនិងផ្អែកលើទិន្នន័យដែលមានក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ។

### (១) កម្រិតនៃការប្រែប្រួលក្នុងសមាសភាគចំណាយនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក

ក្នុងករណីដែលសមាសភាគចំណាយ មានភាពខុសគ្នាពីច្បាប់ថវិកាដែលបានអនុម័ត នោះថវិកានឹងមិនអាចដើរតួនាទីជាឧបករណ៍នៃគោលនយោបាយបានពិតប្រាកដឡើយ។ ការវាស់វែងនៃសូចនាករនេះតម្រូវឱ្យមានការវាយតម្លៃការអនុវត្តចំណាយផ្អែកលើបទពិសោធន៍និងកម្រិតចំណាយសរុបធៀបនឹងច្បាប់ថវិកា។ សូចនាករសមិទ្ធកម្មទី២ ធ្វើការប្រៀបធៀបការអនុវត្ត ទៅនឹងថវិកាដែលបានគ្រោងសម្រាប់ក្រសួង-ស្ថាប័ន។ សមាសភាគចំណាយដែលបានគ្រោង និងចំណាយដែលបានរាយការណ៍ដោយអង្គភាពរដ្ឋបាល គឺត្រូវបានរៀបចំក្នុងតារាង គ.៣។

តារាង គ.៣ បង្ហាញថាថវិកាដែលបានគ្រោង មិនទាន់ត្រូវបានប៉ាន់ប្រមាណបានល្អនៅឡើយ។ គម្លាតសរុបក្នុងសមាសភាគចំណាយរវាងចំណាយជាក់ស្តែងនិងច្បាប់ថវិកា មានចាប់ពី២៥% ដល់ ៣៨% ក្នុងអំឡុងឆ្នាំ ២០១១-២០១៣[9]។ សម្រាប់រយៈពេល៣ឆ្នាំចុងក្រោយ ថវិការបស់ក្រសួង-ស្ថាប័ន ដូចជាក្រសួងអភិវឌ្ឍន៍ជនបទ មានគម្លាតជាមធ្យម ១៩៥%, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានគម្លាតជាមធ្យម ៥៧% និងចំណាយក្នុងជំពូកមិនបានគ្រោងទុកដែលមានមុខសញ្ញា មានគម្លាតជាមធ្យម ៥៦%។ ក្នុងអំឡុងឆ្នាំនីមួយៗ ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលមូលនិធិបន្ថែមពីទុនបម្រុងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ចំណាយថែទាំនិងជួសជុល និងចំណាយវិនិយោគដោយត្រូវទូទាត់គ្រង់ (នេះបង្ហាញពីគម្លាតខ្ពស់នៃឆ្នាំនីមួយៗ)។ អគ្គនាយកដ្ឋានថវិកា បានបញ្ជាក់ផងដែរថា ក្រសួង-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកបញ្ជាចំណាយក្នុងជំពូកចំណាយមានមុខសញ្ញាដែលពុំទាន់បែងចែក ក្នុងនាមក្រសួង-ស្ថាប័នផ្សេងទៀត។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា បានចំណាយឥណទានចំណាយដែលមានមុខសញ្ញាសម្រាប់ក្រសួង-ស្ថាប័នតិចជាងឆ្នាំ២០១១, ឆ្នាំ២០១២ និងឆ្នាំ២០១៣ ដោយសារកញ្ចប់ថវិកាសម្រាប់ប្រើប្រាស់ដោយឃុំ-សង្កាត់ និងកិច្ចការបន្ទាន់ មិនត្រូវបានចំណាយ។

---

[9] ទិន្នន័យបឋមសម្រាប់ឆ្នាំ២០១៤ បង្ហាញថាគម្លាតសមាសធាតុគឺ ១៧,៦%

### តារាង គ.៣÷ គម្លាតជាភាគរយនៃថវិកាដែលបានគ្រោង ធៀបនឹងការអនុវត្តតាមក្រសួង-ស្ថាប័ន

| ក្រសួង-ស្ថាប័ន | គម្លាត | | |
|---|---|---|---|
| | ២០១១ | ២០១២ | ២០១៣ |
| ក្រសួងអប់រំ យុវជន និងកីឡា | ១២,១% | ៩,៦% | ៧,៣% |
| ក្រសួងការពារជាតិ | ១,៤% | ៣,៧% | ៣,៣% |
| ក្រសួងសុខាភិបាល | ២,៧% | ១,៦% | ១,០% |
| ក្រសួងមហាផ្ទៃ (សន្តិសុខសាធារណ:) | ០,៣% | ៥,០% | ៣,៣% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៨,៧% | ២,២% | ៤,៨% |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ១១២,២% | ១១,៥% | ១១,៤% |
| រដ្ឋសភា | ១,១% | ០,១% | ២,៩% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១,៥៥ | ៩,៨% | ២៩,៣% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៣៤,៩% | ២៤,៨% | ១២,៦% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ២០៦,៥% | ១៥៤,០% | ២២៤,៣% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០,៩% | ៦,៦% | ១០,៧% |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៦,៦% | ២,៨% | ៣,០% |
| ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | ៥,៤% | ២៤,៩% | ៣០,៩៥ |
| ក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) | ៣៩,២% | - | - |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | - | ២,៩៤% | ១៥,៤% |
| ចំណាយគ្រោងទុកមានមុខសញ្ញា | ៥៤,៧% | ៣៩,៦% | ៧២,២% |
| រាជធានី-ខេត្ត | ៣១,៥% | ៣៤,០% | ១៦,២% |
| ក្រសួង ២៣ផ្សេងទៀត | ១១០,១% | ៨៧,២% | ៦៦,២% |
| ចំណាយសរុបដែលបានវិភាជ (គម្លាត PI-2) | ៣៧,៩% | ២៥,៤% | ៣០,៤% |

ប្រភព÷ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ

ដើម្បីគណនាដាក់ពិន្ទុលើសមាសធាតុ (១) ត្រូវយកការអនុវត្តជាក់ស្តែងនូវចំណាយមានមុខសញ្ញាដែលពុំទាន់បែងចែក [10] ធៀបនឹងចំណាយមានមុខសញ្ញាដែលបានគ្រោង។ រីឯចំណាយគ្រោងទុកដែលមិនមានមុខសញ្ញា គឺ

[10] សមាសមាត្រនៃចំណាយគឺត្រូវបានបង្ហាញជា ចំណាយ "មានមុខសញ្ញា" គឺក្រសួង ស្ថាប័នបានដឹងតាំងពីដើមឆ្នាំ។ រាល់មុខសញ្ញាគ្រោងទុករួមបញ្ចូលមូលនិធិថែទាំផ្លូវថ្នល់ (កសហវ ផ្ទេរមូលនិធិទៅក្រសួងសាធារណការ និងដឹកជញ្ជូន), ពន្ធ និងអាករ, ចំណាយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ចំណាយកាត់វិសាយកងទ័ព និងឧបត្ថម្ភធនផ្អែកលើថ្លៃប្រេងសម្រាប់អគ្គិសនីកម្ពុជា។

ជាចំណាយសម្រាប់ករណីបន្ទាន់ ឬប្រធានស័ក្តិ។ ចំណាយប្រភេទនេះ មិនបានបញ្ចូលក្នុងការគណនាខាងលើឡើយ។ ភាគរយនៃចំណាយមិនមានមុខសញ្ញា គឺត្រូវបានវាយតម្លៃក្នុងសមាសធាតុបន្ទាប់ ជាចំណាយមិនបានគ្រោងទុក។ ព័ត៌មានលម្អិតនៃការគណនា ត្រូវបានបង្ហាញក្នុងឆ្នាំនីមួយៗ ក្នុងឧបសម្ព័ន្ធ ៥.៣។

សមាសធាតុនេះ ត្រូវផ្តល់ពិន្ទុ D ដោយសារគម្លាតសមាសធាតុចំណាយលើសពី ១៥% ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ។

**(២) ចំនួនជាមធ្យមនៃចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុកនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ**

តារាង គ.៤ បង្ហាញនូវភាគរយនៃចំណាយអនុវត្តជាក់ស្តែង ក្នុងរយៈពេល ៣ ឆ្នាំ គឺពីឆ្នាំ ២០១១ ដល់ ២០១៣ ដែលជាចំណាយមិនមានមុខសញ្ញា (ឬ ចំណាយមិនបានគ្រោងទុកសម្រាប់ក្រសួង-ស្ថាប័ន)។ ចំណាយមិនបានគ្រោងទុកជាក់ស្តែងជាមធ្យមសម្រាប់ឆ្នាំ២០១១ ឆ្នាំ២០១២ និង២០១៣ មានស្មើនឹង ៥,៣ % នៃច្បាប់ថវិកា។

**តារាង គ.៤÷ ភាគរយនៃចំណាយជាក់ស្តែងដែលជាចំណាយមិនមានមុខសញ្ញា**

| ចំណាយ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|
| ចំណាយគ្រោងទុកមិនមានមុខសញ្ញា | ៥,០% | ៥,៨% | ៥,១% |
| ជាមធ្យមរយៈពេល៣ ឆ្នាំ | ៥,៣% | | |

ប្រភព÷ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ B ពីព្រោះជាមធ្យម ភាគរយនៃចំណាយជាក់ស្តែងដែលជាចំណាយមិនបានគ្រោងទុក មានខ្ពស់ជាង ៣% ប៉ុន្តែទាបជាង ៦% ក្នុងរយៈពេល ៣ ឆ្នាំសារពើពន្ធចុងក្រោយ។

**តារាង គ.៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-2 | **សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | D | D+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | កម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយ នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក | D | D | គម្លាតនៃសមាសធាតុក្នុងការអនុវត្តចំណាយមានលើសពី១៥% ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ គឺឆ្នាំ២០១១ (៣៧,៩%) ឆ្នាំ២០១២ (២៥,៤%) និងឆ្នាំ២០១៣ (៣០,៤%)។ |

| | | | | |
|---|---|---|---|---|
| (២) | ចំនួនជាមធ្យមនៃការចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុកនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ | - | B | ចំណាយមិនបានគ្រោងទុកជាក់ស្តែងជាមធ្យមសម្រាប់ឆ្នាំ២០១១ ឆ្នាំ២០១២ និង២០១៣ មានស្មើនឹង ៥,៣% នៃច្បាប់ថវិកា។ |

**ប្រអប់ គ.១ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ដើម្បីជំរុញឱ្យមានតម្លាភាព រាជរដ្ឋាភិបាលកំពុងឈានទៅកាត់បន្ថយថវិកាដែលវិភាជទុកសម្រាប់ចំណាយមិនបានគ្រោងទុក ទាំងមានមុខសញ្ញា និងមិនមានមុខសញ្ញា។ សម្រាប់ការគ្រោងថវិកាឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជានឹងផ្ទេរបញ្ចាំងថវិកាពេញលេញរបស់ក្រសួងអាទិភាពចំនួន៥ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងសុខាភិបាល ឬនិយាយម្យ៉ាងទៀតថា នឹងគ្មានទៀតឡើយ ការវិភាជចំណាយមិនបានគ្រោងទុក សម្រាប់ក្រសួងទាំង៥នេះ។

## គ.១.៣ ចំណូលសរុបធៀបនឹងច្បាប់ថវិកា (PI-3)

សូចនាករសមិទ្ធកម្មនេះ ប្រៀបធៀបចំណូលក្នុងស្រុកជាក់ស្តែងសរុប ជាមួយចំណូលក្នុងស្រុកដែលបានអនុម័តសម្រាប់រយៈពេល ០៣ ឆ្នាំសារពើពន្ធចុងក្រោយ [11]។

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការព្យាករណ៍ចំណូល ដោយធ្វើការពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២។ នាយកដ្ឋាននេះ ព្យាករណ៍ចំណូលដែលរំពឹងប្រមូលបានដោយអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមទាំងនិន្នាការសេដ្ឋកិច្ចនិងនិន្នាការវិស័យផ្សេងទៀត។ នាយកដ្ឋាននេះប្រើម៉ូដែលដើម្បីបង្កើត សេណារីយ៉ូមូលដ្ឋាន (Baseline Scenarios) ដោយផ្អែកលើប្រវត្តិទិន្នន័យ និងសេណារីយ៉ូតាមករណីផ្សេងៗ (ករណីទាប និងខ្ពស់) ដោយផ្អែកលើនិន្នាការឬកត្តាខាងក្រៅផ្សេងៗទៀត។ សេណារីយ៉ូមូលដ្ឋាន និងសេណារីយ៉ូតាមករណីផ្សេងៗ ផ្តោតលើប្រភេទពន្ធសំខាន់ៗទាំង ១៦។ ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចស្នើឱ្យនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ កែតម្រូវការកំណត់សេណារីយ៉ូទាំងនេះ។

តារាង គ.៦ បង្ហាញនូវលទ្ធផលចំណូលសរុបធៀបនឹងច្បាប់ថវិកាសម្រាប់ឆ្នាំ២០១១, ឆ្នាំ២០១២, និងឆ្នាំ២០១៣។ ជាមធ្យមសម្រាប់៣ឆ្នាំនេះ ចំណូលសារពើពន្ធមាន ៨៣% នៃចំណូលក្នុងស្រុកសរុប។ ពន្ធលើការនាំចេញ-នាំចូល

---

[11] វិធីសាស្ត្រ PEFA ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ២០១១ បញ្ជាក់ថាការប្រមូលចំណូលបានតិចជាងការគ្រោង ជះឥទ្ធិពលអវិជ្ជមានខ្លាំងជាងការប្រមូលចំណូល លើស។

រួមចំណែកខ្ពស់ជាងគេនៃចំណូលសរុប ដែលជាមធ្យមស្មើនឹង ៤៣,៥% នៃចំណូលក្នុងស្រុកសរុបសម្រាប់រយៈពេល ៣ឆ្នាំនេះ។ គម្លាតសរុបនៃការអនុវត្ត មានកម្រិតទាប ០,៦% ក្នុងឆ្នាំ២០១១ និងកម្រិតខ្ពស់ ១២% ក្នុងឆ្នាំ២០១២[12] ក្នុងពេលដែលកំណើន ផសស មាន ៧,៣% ដែលខ្ពស់ជាងការរំពឹងទុកដែលមាន ៦,៥%[13]។ លើសពីនេះ ក្នុងឆ្នាំ២០១២ លទ្ធផលល្អប្រសើរជាងមុននៃការប្រមូលចំណូល ក៏ដោយសារការបង្កើនប្រសិទ្ធភាពនៃសវនកម្មពន្ធដារផងដែរ បន្ទាប់ពីមានការជ្រើសរើសមន្ត្រីសវនករពន្ធដារបន្ថែម ២០០នាក់[14]។

លើកលែងតែក្នុងឆ្នាំ២០១១ មួយដែលកម្រិតចំណូលមានភាពថេរ តែចាប់ពីឆ្នាំ២០០៩ មក ចំណូលក្នុងស្រុកមានកំណើនជាលំដាប់។ ជាពិសេស ចំណូលក្នុងស្រុកកើនពី ១១,៥% នៃ ផសស ក្នុងឆ្នាំ២០០៩ ទៅប្រមាណ ១៤% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៣។ ទោះជាយ៉ាងណា សក្តានុពលក្នុងការបង្កើនចំណូលក្នុងស្រុក នៅមានច្រើនទៀត ដើម្បីឱ្យស្របនឹងកម្រិតសេដ្ឋកិច្ច។ ចុងឆ្នាំនេះ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ដោយឡែក សម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់និងទំនើបកម្មគយ និងរដ្ឋាករ ២០១៤-២០១៨។ ការកែទម្រង់នឹងរួមចំណែកបង្កើនចំណូលចរន្ត ០,៥ពិន្ទុភាគរយ នៃ ផ.ស.ស ប្រចាំឆ្នាំ ក្នុងរយៈពេលមធ្យម។

## តារាង គ.៦÷ ការអនុវត្តចំណូល ២០១១-២០១៣

| គិតជាពាន់លានរៀល | ឆ្នាំ២០១១ | | | ឆ្នាំ២០១២ | | | ឆ្នាំ២០១៣ | | |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ថវិកា | ការអនុវត្ត | គម្លាត | ច្បាប់ថវិកា | ការអនុវត្ត | គម្លាត | ច្បាប់ថវិកា | ការអនុវត្ត | គម្លាត |
| ចំណូលសារពើពន្ធពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | ២.៨៩២ | ៣.១៣២ | ៨,៣% | ៣.៤៤១ | ៣.៦៦២ | ៦,៤% | ៤.០៦៥ | ៣.៩៥៦ | -២,៧% |
| ពន្ធលើការនាំចូល | ១.១០៧ | ១.០០៨ | -៨,៩% | ១.១៥៧ | ១.១៥៣ | -០,៣% | ១.៣៣៤ | ១.២៦២ | -៥,៤% |
| ពន្ធលើការនាំចេញ | ១២ | ៧៤ | ៥២៣,៦% | ៦៧ | ៥៤ | -១៩,៩ | ៧៣ | ៩១ | ២៤,៧% |
| អាករពិសេសលើទំនិញមួយចំនួន | ៧៧១ | ៧៩០ | ២,៥% | ៨៧៥ | ៩៥៨ | ៩,៤% | ១.០៦៦ | ៩៨៣ | -៧,៨% |
| អាករលើតម្លៃបន្ថែម (របបនាំចូល) | ៩៨៥ | ១.២៥០ | ២៦,៨% | ១.៣២៥ | ១.៤៨៧ | ១២,៣% | ១.៥៧២ | ១.៦០៦ | ២,២% |
| ផ្សេងៗទៀត | ១៧ | ១០ | -៤០,៨% | ១៨ | ១១ | -៣៨,៣% | ២០ | ១៣ | -៣៤,៥% |

[12] ទិន្នន័យបឋមនៃចំណូលប្រមូលបានសម្រាប់ឆ្នាំ២០១៤ គឺ ១១ ៦៥៨ ពាន់លានរៀល ដែលស្មើនឹង ១១០,៩% នៃចំណូលក្នុងស្រុកសរុប ដែលបានអនុម័ត។ ការប្រើប្រាស់ទិន្នន័យពីឆ្នាំ២០១២-២០១៤ ជាមូលដ្ឋាន នឹងផ្លាស់ប្តូរពិន្ទុទៅB ដោយសារតែលទ្ធផលរយៈពេល២ឆ្នាំ ក្នុង៣ឆ្នាំចុងក្រោយលើសពី១០៦%។

[13] ភាគរយនៃផ.ស.ស. ពីរបាយការណ៍បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០១៣ និងឆ្នាំ២០១៤។

[14] មូលនិធិរូបិយវត្ថុអន្តរជាតិ *កម្ពុជា÷ ការពិគ្រោះយោបល់អត្ថបទ IV* របាយការណ៍ប្រទេសនៃមូលនិធិរូបិយវត្ថុលេខ ១៣/២។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ ពីអគ្គនាយកដ្ឋានពន្ធដារ** | ២.៤១៤ | ១.៩៧៣ | -១៨,៣% | ២.៦៣២ | ២.៥៦៩ | -២,៤% | ៣.០៥៣ | ៣.១០២ | ១,៦% |
| ពន្ធលើប្រាក់ចំណេញ | ៧៤០ | ៧១៦ | -៣,៣% | ៩៥៨ | ៩៦៧ | ០,៩% | ១.១៩៣ | ១.១៦៧ | -២.១% |
| ពន្ធលើប្រាក់បៀវត្ស | ២៣៦ | ១៨៥ | -២១,៧% | ២៤១ | ២៣៤ | -៣% | ២៨២ | ៣០១ | ៦,៧% |
| ពន្ធលើផលទុននៃដីធ្លីផ្ទះសម្បែង | ៦៨ | ៥៩ | -១២,៨% | ៧៩ | ៧៥ | -៥,១% | ៨៨ | ៩៤ | ៦,៤% |
| អាករលើផលរបរ | ៤៤ | ២៣ | -៤៨,៤% | ៣០ | ២៤ | -១៨,៧% | ៣២ | ២៦ | -១៩,០% |
| ពន្ធអាករពិសេសលើទំនិញក្នុងស្រុកមួយចំនួន | ៣១៨ | ៣០៤ | -៤,៦% | ៣៤៥ | ៣៦០ | ៤,៣% | ៤២១ | ៤១៧ | -១% |
| ពន្ធលើតម្លៃបន្ថែម (របបផ្ទៃក្នុង) | ៩៩៣ | ៦៧១ | -៣២,៤% | ៩៦២ | ៨៨៩ | -៧,៥% | ១.០១៨ | ១.០៧៣ | ៥,៤% |
| ផ្សេងៗទៀត | ១៥ | ១៦ | ៦,៨% | ១៧ | ១៩ | ១១,៩% | ១៩ | ២៤ | ២៨,៩% |
| **ចំណូលសារពើពន្ធផ្សេងៗ** | ១៧១ | ២០០ | ១៧,១% | ២០៧ | ២១២ | ២,៤% | ២០៤ | ២៣២ | ១៣,៨% |
| **ចំណូលពីរដ្ឋបាលខេត្ត** | ២៦២ | ៤១១ | ៥៦,៧% | ៣៣២ | ៤៩៣ | ៤៨,៣% | ៤៣២ | ៥២៥ | ២១,៦% |
| **ចំណូលមិនមែនសារពើពន្ធ (រួមបញ្ចូលចំណូលមូលធន)** | ១.០៨០ | ១.១៤២ | ៥,៧% | ១.១០០ | ១.៧០០ | ៥៤,៥% | ១.២៣៥ | ១.៤៨៥ | ២០៣% |
| **សរុប** | ៦.៨១៩ | ៦.៨៥៧ | ០.៦% | ៧.៧១៣ | ៨.៦៣៦ | ១២% | ៨.៩៨៨ | ៩.២៩៩ | ៣,៥% |
| **អនុវត្ត/ច្បាប់** | **១០០.៥៧%** | | | **១១១.៩៧%** | | | **១០៣.៥%** | | |

ប្រភព÷ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ និងអគ្គនាយកដ្ឋានរតនាគារជាតិ

ពិន្ទុសូចនាករសមិទ្ធកម្មទី៣ មានបង្ហាញក្នុងតារាងខាងក្រោម។ សូចនាករនេះ ត្រូវបានផ្តល់ពិន្ទុ A ដោយសារលទ្ធផលអនុវត្តមានក្នុងចន្លោះ ៩៧% ដល់ ១០៦% សម្រាប់២ឆ្នាំ ក្នុងរយៈពេល៣ឆ្នាំសារពើពន្ធចុងក្រោយ។

**តារាង គ.៧÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៣**

| សូចនាករ | សមាសធាតុ / វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-3 | លទ្ធផលចំណូលសរុបធៀបនឹងច្បាប់ថវិកា (M1) | A | A | ចំណូលក្នុងស្រុកសរុបធៀបនឹងច្បាប់ថវិកាក្នុងឆ្នាំ ២០១១ (១០០.៦%) និង ២០១៣ (១០៣.៥%) ដោយឡែកការ អនុវត្តគឺស្ថិតចន្លោះ៩៧%- ១០៦% សម្រាប់២ឆ្នាំ នៃរយៈពេល៣ ឆ្នាំចុងក្រោយនេះ។ |

**ប្រអប់ គ.២÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

យុទ្ធសាស្ត្ររយៈពេលមធ្យមរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (២០១៤-២០១៨) មានគោលបំណងជាយុទ្ធ-សាស្ត្រ ចំនួន៦ ដែលផ្តោតលើលទ្ធផលគន្លឹះ ដូចជា ការកៀរគរចំណូល, អនុលោមភាពនិងការពង្រឹងការអនុវត្ត, កិច្ចសម្រួលពាណិជ្ជកម្ម, ទំនើបកម្ម/ស្វ័យប្រវត្តិកម្មនីតិវិធីគយ, អភិបាលកិច្ចនិងការគ្រប់គ្រងធនធានមនុស្ស និងកម្មវិធីកំណែទម្រង់ និងទំនើបកម្មគយ។

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែលកំពុងត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារផ្តោតលើការពង្រឹងរដ្ឋបាលចំណូល, ជំរុញការអនុវត្តច្បាប់, ពង្រីកមូលដ្ឋានពន្ធ, កែលម្អសេវាអ្នកបង់ពន្ធ, លើកកម្ពស់បរិយាកាសធុរកិច្ច និងជំរុញឱ្យមានសមធម៌និងភាពស្មោះត្រង់។

## គ.១.៤ សន្និធិ និងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ (PI-4)

បំណុលកកស្ទះ គឺជាចំណាយដែលត្រូវបានខកខានអនុវត្តឱ្យបានទាន់ពេលវេលាកំណត់នៅក្នុងបទប្បញ្ញត្តិច្បាប់ ឬ នៅក្នុងកិច្ចសន្យា ដូចជាចំណាយលើបន្ទុកបុគ្គលិក, អ្នកផ្គត់ផ្គង់ ភាគីកិច្ចសន្យា ឬម្ចាស់បំណុល របស់រាជ-រដ្ឋាភិបាល។ សូចនាករសមិទ្ធកម្មនេះ វាស់វែងវិសាលភាពនៃសន្និធិបំណុលកកស្ទះ និងវិសាលភាពនៃការត្រួតពិនិត្យ និងដោះស្រាយបញ្ហាបំណុលកកស្ទះ។ ការវាយតម្លៃសមាសធាតុ (១) ប្រើប្រាស់ឆ្នាំសារពើពន្ធចុងក្រោយដែលមានទិន្នន័យ គឺឆ្នាំ២០១៣។ ការវាយតម្លៃសមាសធាតុ (២) ផ្អែកលើ ២ឆ្នាំសារពើពន្ធចុងក្រោយដែលមានទិន្នន័យគឺឆ្នាំ ២០១២ និងឆ្នាំ២០១៣។

### (១) សន្និធិនៃបំណុលកកស្ទះ

ចំណាយសាធារណៈ ត្រូវបានគ្រប់គ្រង ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ (មាត្រា ២៤, មាត្រា៥០ និងមាត្រា៦៤) និងតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ។ តាមរយៈអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងនិងប្រធានស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល គឺជាអាណាប័កដើមខ្សែនៃថវិការបស់ក្រសួង-ស្ថាប័ន និងត្រូវទទួលបន្ទុកបញ្ជាចំណាយ។

បន្ទាប់ពីឥណទានថវិកាត្រូវបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ការវិភាជលម្អិតត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយអង្គភាពនីមួយៗក្រោមឱវាទក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈត្រូវរៀបចំសំណើថវិកា ដោយអនុលោមតាមសៀវភៅថវិកា។ ការអនុវត្តថវិកាត្រូវបានចែកចេញជា ៤ ដំណាក់កាល គឺដំណាក់កាលស្នើសុំធានាចំណាយ, ដំណាក់កាលអនុវត្តកិច្ចលទ្ធកម្ម, ដំណាក់កាលជម្រះបញ្ជី (ការរៀបចំលិខិតយុត្តិការ និងការបោះផ្សាយអាណត្តិទូទាត់) និងដំណាក់កាលអាណត្តិកិច្ចនិងទូទាត់ ។

ជាទូទៅ សំណើសុំធានាចំណាយ ត្រូវរៀបចំដោយអង្គភាពចំណាយក្រោមឱវាទក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ (សូមមើល PI-20 សមាសធាតុ ១)។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចត្រួតពិនិត្យលើការចំណាយថវិកា ដើម្បីធានាអនុលោមភាពតាមការកំណត់នៃច្បាប់ (ចាប់តាំងពីការធានាចំណាយរហូតដល់ការបញ្ជាការទូទាត់) មានន័យថាឥណទានចំណាយត្រូវស្ថិតក្នុងកម្រិតឥណទានអនុម័តក្នុងច្បាប់ និងអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននិងលក្ខខណ្ឌបច្ចេកទេសមួយចំនួននៃមុខសញ្ញាចំណាយ។ ក្នុងន័យនេះ ធនធានត្រូវតែប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព រីឯការធានាចំណាយនិងការទូទាត់ចំណាយ ត្រូវតែបានត្រួតពិនិត្យឱ្យបានហ្មត់ចត់ ដើម្បីចៀសវាងការខាតបង់ថវិកា ការខូចខាត ការខ្ជះខ្ជាយ និង/ឬកំហុសក្នុងការកត់ត្រា។

ដើម្បីអនុវត្តចំណាយ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន និងអង្គភាពថវិកា ត្រូវបញ្ជូនអាណត្តិទូទាត់សម្រាប់ចំណាយចរន្តទៅមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលស្ថិតនៅតាមក្រសួង-ស្ថាប័ន។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទាំងនេះ ជាមន្ត្រីនៃនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិមជ្ឈការដល់ក្រសួង-ស្ថាប័ន)។ ដោយឡែក អាណត្តិបើកប្រាក់សម្រាប់ចំណាយមូលធន ត្រូវត្រួតពិនិត្យដោយនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការអនុម័តចុងក្រោយ។ នាយកដ្ឋានទាំង២ នេះ បញ្ជូនអាណត្តិទូទាត់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ដែលទទួលខុសត្រូវលើប្រតិបត្តិការទូទាត់។ អគ្គនាយកដ្ឋានរតនាគារជាតិទូទាត់លើអាណត្តិទូទាត់ ប្រសិនបើមានការយល់ព្រមពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមានលិខិតយុត្តិការគ្រប់គ្រាន់។ នៅពេលទទួលអាណត្តិស្នើសុំទូទាត់ និងនៅពេលទូទាត់រួច, អគ្គនាយកដ្ឋានរតនាគារជាតិ នឹងបោះត្រាសម្គាល់កាលបរិច្ឆេទចូល និងកាលបរិច្ឆេទទូទាត់។

បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាមានបំណុលកកស្ទះ បើសិនអាណត្តិទូទាត់មិនត្រូវបានទូទាត់ក្នុងរយៈពេល៩០ថ្ងៃ <u>ក្រោយពីរតនាគារជាតិទទួលបានអាណត្តិទូទាត់</u> ក៏ប៉ុន្តែ រយៈពេលនេះត្រូវបានកាត់បន្ថយមកត្រឹម ៦០ថ្ងៃ ក្រោយពីរតនាគារជាតិទទួលបានអាណត្តិទូទាត់វិញ កាលពីពេលថ្មីៗនេះ ។ ៩០ថ្ងៃ ឬ ៦០ថ្ងៃ នៅតែមិនដូចការកំណត់ក្នុងនិយមន័យនៃបំណុលកកស្ទះ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលបានកំណត់យក *ការមិនបានទូទាត់លើសពី៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានវិក្កយបត្រដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ*។ និយមន័យនេះ ក៏ខុសពីលក្ខខណ្ឌស្តង់ដារសម្រាប់ការទូទាត់នៅកម្ពុជា ដល់អគ្គាហាកៈ ឬអ្នកផ្គត់ផ្គង់ ដែលជាទូទៅមានចំនួន ៣០ថ្ងៃ ឬ ៤៥ថ្ងៃ ក្រោយពីទទួលបានវិក្កយបត្រ។ ប្រការនេះបង្ហាញពីភាពយឺតយ៉ាវ និងភាពស្មុគស្មាញនៃដំណើរការក្នុងក្រសួង-ស្ថាប័ន មុនពេលអាណត្តិទូទាត់ត្រូវបានអនុម័ត និងបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ។ ជាទូទៅ

អ្នកផ្គត់ផ្គង់ និងភាគីកិច្ចសន្យា ត្រូវរង់ចាំរហូតដល់ ៦ខែ ចាប់ពីការបញ្ជូនវិក្កយបត្ររហូតដល់ការទូទាត់ជាក់ស្តែងចូលក្នុងគណនីរបស់ពួកគេ បើទោះបីជាលិខិតយុត្តិការមានគ្រប់គ្រាន់ហើយក៏ដោយ។ បញ្ហាយឺតយ៉ាវនេះបណ្តាលមកពីភាពស្មុគស្មាញនៃដំណើរការទូទាត់ ជាជាងការខ្វះខាតសាច់ប្រាក់។

តារាង គ.៨ បង្ហាញតួលេខប៉ាន់ស្មានអំពីបំណុលកកស្ទះ សម្រាប់ប្រភេទចំណាយនីមួយៗ ដែលរួមមាន ៣ ប្រភេទធំៗ គឺ (ក) ទំនិញនិងសេវា (ខ) បៀវត្ស និង (គ) សេវាបំណុល។ ការទូទាត់បំណុលកកស្ទះសម្រាប់ទំនិញនិងសេវា មានចំនួនប្រហាក់ប្រហែលនឹងតម្លៃនៃអាណត្តិបើកប្រាក់មិនទាន់ត្រូវបានទូទាត់នៅចុងឆ្នាំ។ ការវាយតម្លៃលើសន្និធិបំណុលកកស្ទះនេះ គឺផ្អែកលើបំណុលមិនទាន់សង ដែលមានរយៈពេលច្រើនជាង ៦០ថ្ងៃ ស្របនឹងគោលដៅដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដាក់ចេញនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥។

បៀវត្ស ត្រូវបើកនៅដំណាច់ខែ[15] តែប្រសិនបើមិនទាន់ទូទាត់ ចំនួនទឹកប្រាក់ទាំងនោះនឹងក្លាយជាបំណុលកកស្ទះភ្លាម។ ទិន្នន័យនៃបំណុលកកស្ទះលើបៀវត្សកើនឡើង បណ្តាលមកពីការពន្យារពេលបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិលថ្មី និងការបង្កើនបៀវត្ស ដែលនាំឱ្យប្រាក់បៀវត្សដែលមិនទាន់ត្រូវបានផ្តល់ជូន មានចំនួន ២៧២,៤ពាន់លានរៀល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ១៥៧ពាន់លានរៀល គិតត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៤។

ការប្រាក់ និងការពិន័យលើបំណុលជំពាក់សហព័ន្ធរុស្ស៊ី និងសហរដ្ឋអាមេរិកដែលនៅសល់ពីសម័យសង្គ្រាម មានចំនួន ២៨០លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ១ ១៤៣ ពាន់លានរៀល។ បំណុលនេះនៅតែកត់ត្រាជាបំណុលកកស្ទះដរាបណាមិនទាន់ត្រូវបានជម្រះចោល ហើយបំណុលនេះកំពុងស្ថិតក្នុងការចរចារ ដោយរំពឹងថានឹងត្រូវលុបចោលទាំងប្រាក់ដើមនិងការប្រាក់ ប៉ុន្តែសព្វថ្ងៃ ការប្រាក់និងពិន័យគឺជាបំណុលកកស្ទះ។

តារាង គ.៨ បង្ហាញតួលេខប៉ាន់ស្មានអំពីបំណុលកកស្ទះ សម្រាប់រយៈពេល ៣ ឆ្នាំចុងក្រោយ គឺឆ្នាំ ២០១១, ២០១២ និង២០១៣ ដែលមានប្រមាណពី២១% ទៅ ២៣% នៃចំណាយសរុប ដែលទិន្នន័យនេះត្រូវបានសង្កេតថាមានការប្រែប្រួលតិចតួចប៉ុណ្ណោះពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងរយៈពេល៣ឆ្នាំនេះ បំណុលកកស្ទះលើសេវាបំណុល មានទំហំធំៗជាងបំណុលកកស្ទះពីរប្រភេទទៀត។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ D ពីព្រោះសន្និធិបំណុលកកស្ទះ មានលើសពី ១០% នៃចំណាយសរុប។

---

[15] ទិន្នន័យពី អ.គ.ហ. ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥

### តារាង ៣.៨ ការវិភាគលើបំណុលកកស្ទះ

| | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|
| ចំណាយសរុប (គិតជាពាន់លានរៀល) | ៧ ៤៦១ | ៨ ១៥៧ | ៨ ៣៩០ |
| សន្និធិនៃអាណត្តិទូទាត់ លើសពី៦០ថ្ងៃ នៅចុងឆ្នាំ<br>បៀវត្សមិនទាន់ទូទាត់ នៅចុងឆ្នាំ<br>បំណុលកកស្ទះលើសេវាបំណុល | ៣២១<br>២៤៩<br>១ ១៤៣ | ៤៩៤<br>២៧២<br>១ ១៤៣ | ៤៧១<br>១៥៧<br>១ ១៤៣ |
| បំណុលកកស្ទះសរុប (ពាន់លានរៀល) | ១ ៧១៣ | ១ ៩០៩ | ១ ៧៧១ |
| ភាគរយនៃចំណាយសរុប | ២៣,០% | ២៣,៤% | ២១,១% |
| ភាគរយប្រែប្រួល | | +១១% | -៧% |

ប្រភព៖ អគ្គនាយកដ្ឋានរតនាគារជាតិ មិនគិតបញ្ចូលគម្រោងហិរញ្ញប្បទានគម្រោងវិនិយោគក្រៅប្រទេស

**(២) ទិន្នន័យដែលអាចស្វែងរកបានសម្រាប់ការត្រួតពិនិត្យតាមដានលើបំណុលកកស្ទះ**

ត្រឹមឆ្នាំ២០១១ អគ្គនាយកដ្ឋានរតនាគារជាតិ បានប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាខ្មែរ (KIT) ដែលអនុញ្ញាតឱ្យអគ្គនាយកដ្ឋានដឹងអំពីបរិមាណនិងតម្លៃនៃអាណត្តិទូទាត់ដែលមិនទាន់បានទូទាត់ និងចំនួនថ្ងៃប្រើប្រាស់សម្រាប់ការទូទាត់។ ប្រព័ន្ធ KIT កត់ត្រានិងរក្សាកាលបរិច្ឆេទ ដែលអគ្គនាយកដ្ឋានរតនាគារជាតិបានទទួលនិងបានទូទាត់អាណត្តិបើកប្រាក់។ ប្រព័ន្ធ KIT មិនត្រូវបានប្រើប្រាស់សម្រាប់បង្កើតរបាយការណ៍ជាប្រចាំទេ។ ប្រព័ន្ធសម្រាប់តាមដានការពន្យារពេល រាប់ចាប់ពីការបញ្ជូនវិក្កយបត្ររបស់អ្នកផ្គត់ផ្គង់/ភាគីកិច្ចសន្យា រហូតដល់កាលបរិច្ឆេទនៃការបោះផ្សាយអាណត្តិទូទាត់និងការបញ្ជូនអាណត្តិទៅរតនាគារជាតិ នៅមិនទាន់មាននៅឡើយ។ ទិន្នន័យនៃបំណុលកកស្ទះនៃបៀវត្ស ត្រូវបានប្រមូលជាប្រចាំខែ។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ C ដោយសារមានប្រព័ន្ធដើម្បីប៉ាន់ស្មានបំណុលកកស្ទះសម្រាប់ប្រភេទចំណាយសំខាន់ៗនីមួយៗ ប៉ុន្តែប្រព័ន្ធនេះមិនមានភាពពេញលេញ និងមិនរៀបចំរបាយ-ការណ៍ជាប្រចាំសម្រាប់ការត្រួតពិនិត្យតាមដានជាបន្តនោះទេ។

### តារាង ៣.៩៖ ពិន្ទុសូចនាករសមិទ្ធកម្មទី៤

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-4 | **សន្និធិបំណុលកកស្ទះនិងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ** | C+ | D+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | កម្រិតស្តុកនៃចំណាយដែលនៅជំពាក់ (គិតជាភាគរយនៃចំណាយសរុបជាក់ស្តែងសម្រាប់ឆ្នាំថវិកាដែលពាក់ព័ន្ធ) | A | D | ចំនួនប៉ាន់ស្មាននៃបំណុលដែលមិនទាន់សងដែលលើសពី៦០ថ្ងៃ សម្រាប់ទំនិញនិងសេវា ព្រមទាំងបំណុលកកស្ទះនៃបៀវត្ស និងបំណុល |

| | | | | |
|---|---|---|---|---|
| | និងការប្រែប្រួលថ្មីៗនៅក្នុងស្តុកចំណាយដែលនៅជំពាក់នេះ | | | កកស្ទះនៃអត្រាការប្រាក់បំណុល រួមទាំងការពិន័យ បញ្ជាក់ថា សន្និធិសរុបនៃបំណុលកកស្ទះមានទំហំធំជាង ១០%នៃចំណាយសរុប។ ការប៉ាន់ស្មាននេះប្រហែលច្រើនជាងនេះទៀត ប្រសិនបើទិន្នន័យអាចរកបានក្នុងវិក្កយបត្រសម្រាប់អាណត្តិទូទាត់ដែលមិនទាន់ត្រូវបានបោះផ្សាយ។ |
| (២) | ទិន្នន័យដែលអាចស្វែងរកបានសម្រាប់ការត្រួតពិនិត្យតាមដាននៃចំណាយដែលនៅជំពាក់ | C | C | ទោះបីជាទិន្នន័យដែលរក្សាទុកក្នុងប្រព័ន្ធកត់ត្រាអាចទាញយកដាក់ក្នុងប្រព័ន្ធ Excel ដើម្បីរៀបចំជារបាយការណ៍ និងត្រូវបានប្រើប្រាស់ដើម្បីផ្តល់ទិន្នន័យសម្រាប់ PEFA ២០១៥នេះ, ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ មិនមែនជាមុខងារប្រចាំថ្ងៃឡើយ រីឯប្រព័ន្ធក៏មិនទាន់មានមុខងារពេញលេញនៅឡើយ។ |

**ប្រអប់ គ.៣÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ប្រព័ន្ធ KIT គឺសម្រាប់ការប្រើប្រាស់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ប្រព័ន្ធនេះនឹងត្រូវជំនួសដោយប្រព័ន្ធ FMIS ដែលនឹងតាមដានការអនុវត្តរបស់ក្រសួង-ស្ថាប័ន ចាប់ពីការធានាចំណាយ រហូតដល់ពេលទូទាត់។ ប្រព័ន្ធ FMIS គួររក្សាកំណត់ត្រាលម្អិតនៃការធានាចំណាយនីមួយៗ, ការបញ្ជាទិញ, អាណត្តិទូទាត់ និងការទូទាត់ ដោយបញ្ចូលផងដែរនូវកាលបរិច្ឆេទប្រតិបត្តិការ, លេខយោង និងចំនួនទឹកប្រាក់។ ម៉ូឌុលតារាងបៀវត្សនិងការគ្រប់គ្រងបំណុលនៃប្រព័ន្ធ FMIS បង្ហាញនូវចំណាយដែលមិនបានទូទាត់ ទៅក្នុងគណនីឥណទាយក ដែលចំណុចនេះបង្កើតភាពងាយស្រួលសម្រាប់ការតាមដាន។ ប្រព័ន្ធ FMIS ក៏គួរតែអាចបង្កើតរបាយការណ៍អំពីបំណុលមិនទាន់សង និងបំណុលកកស្ទះ ជាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

## គ.២ ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា

### គ.២.១ ចំណាត់ថ្នាក់ថវិកា (PI-5)

គោលបំណងនៃសូចនាករសមិទ្ធកម្មនេះ គឺធ្វើការវាយតម្លៃអំពីការសម្របគ្នាដោយត្រង់រវាងមាតិកាថវិកានិងប្លង់គណនី ដែលនាំឱ្យគណនីរួមរបស់រដ្ឋាភិបាល របាយការណ៍អនុវត្តថវិកា និងទិន្នន័យផ្សេងទៀតនៃការអនុវត្តថវិកាអាចរៀបចំដោយលម្អិត ដែលឆ្លើយឆ្លងបានទៅនឹងឯកសារសម្រាប់ការរៀបចំសំណើថវិកានិងការអនុម័តថវិកា។ ការវាយតម្លៃនេះ គឺផ្អែកទាំងស្រុងលើឆ្នាំសារពើពន្ធពេញលេញចុងក្រោយ ពោលគឺឆ្នាំ២០១៤។

ការរៀបចំនិងការអនុវត្តថវិកា គឺផ្អែកលើចំណាត់ថ្នាក់រដ្ឋបាល សេដ្ឋកិច្ច និងមុខងារ។ ចំណាត់ថ្នាក់រដ្ឋបាល ត្រូវបានប្រើប្រាស់ដោយក្រសួង-ស្ថាប័ន អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំនិងការអនុវត្តចំណូល-ចំណាយ និងត្រូវបានចែកចេញជា ៥កម្រិត គឺក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី។ ក្នុងឆ្នាំ២០១៣ ប្លង់គណនីឆ្នាំ២០០៧ ត្រូវបានធ្វើបច្ចុប្បន្នភាពនិងកែសម្រួលឱ្យស្របតាមស្តង់ដារអន្តរជាតិ។ ប្លង់គណនីនេះអាចផលិតជាទិន្នន័យស្ថិតិដែលមានសង្គតិភាពជាមួយនឹងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលឆ្នាំ២០០១ (GFS 2001) ដូចមានរបាយការណ៍ទិន្នន័យប្រចាំខែ ក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលតាំងពីឆ្នាំ២០១១ ជាសំអាង។ ក្នុងគោលបំណងនេះ តារាងចម្លងទិន្នន័យរវាង ប្លង់គណនី តារាងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ឆ្នាំ២០០១ (CoA-TOFE-GFS 2001 Bridge Table) កំពុងត្រូវបានប្រើប្រាស់។ សម្រាប់មុខសញ្ញាចំណូលមួយចំនួន ប្លង់គណនីមិនមានបង្ហាញលម្អិតឡើយ ប៉ុន្តែទិន្នន័យទាំងនេះត្រូវបានដាក់បញ្ចូលក្នុងកូដស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល សម្រាប់មុខសញ្ញាចំណូលពាក់ព័ន្ធភាគច្រើន។ ទន្ទឹមនេះ លេខកូដចំណាយមួយចំនួន នៅក្នុងកម្រិតមុខសញ្ញា មានភាពខុសគ្នាដោយឡែកៗសម្រាប់រាជធានី-ខេត្ត ស្រុក និងឃុំ (កម្រិតនីមួយៗ មានការប្រើប្រាស់ប្លង់គណនីផ្សេងៗគ្នា) ដែលតម្រូវឱ្យមានការផ្ទៀងផ្ទាត់សម្រាប់ការបូកសរុបរបាយការណ៍រួមទៅលើមុខសញ្ញាលម្អិត។

ដោយឡែក ចំណាត់ថ្នាក់មុខងារ ត្រូវបានប្រើប្រាស់សម្រាប់បង្ហាញគោលបំណងនៃចំណាយ តាមវិស័យ ឬអនុវិស័យ និងមាន ២កម្រិត គឺមុខងារ និងអនុមុខងារ។ ចំណាត់ថ្នាក់មុខងារ ត្រូវបានអនុវត្តចំពោះ ០៤ វិស័យធំៗ រួមមាន សេវាសាធារណៈទូទៅ, ការពារជាតិ, សន្តិសុខសាធារណៈ និងវិស័យសេដ្ឋកិច្ច; ចំណាត់ថ្នាក់នេះមិនមានរំលេចក្នុងប្លង់គណនីឡើយ។ ដូចនេះ ការអនុវត្តចំណាត់ថ្នាក់មុខងារ នៅមិនទាន់គ្រប់ជ្រុងជ្រោយ និងអនុលោមតាមស្តង់ដារអន្តរជាតិ នៅឡើយ ដូចជាការអនុវត្តនូវមុខងារទាំង១០ នៃ COFOG។

ថវិកាកម្មវិធី ត្រូវបានដាក់ឱ្យអនុវត្តសាកល្បង សម្រាប់ក្រសួងចំនួន ៨ ក្នុងឆ្នាំ២០១៤។ ចំណាត់ថ្នាក់តាមកម្មវិធី ត្រូវបានប្រើប្រាស់សម្រាប់ការធ្វើចំណាត់ថ្នាក់ថវិកាតែប៉ុណ្ណោះ តែមិនមែនជាចំណែកនៃប្លង់គណនីឡើយ។ លើសពីនេះ ថវិកាកម្មវិធី គ្របដណ្តប់តែលើចំណាយក្រៅពីបៀវត្សប៉ុណ្ណោះ តែមិនបានគ្របដណ្តប់សកម្មភាពនិងចំណាយរបស់ក្រសួងអនុវត្តសាកល្បងទាំង ០៨ ទេ។ ទិដ្ឋភាពរួមនៃប្រព័ន្ធមាតិកាថវិកាដែលត្រូវបានប្រើប្រាស់ មាននៅក្នុងតារាង គ.១០។

**តារាង គ.១០÷ ទិដ្ឋភាពរួមនៃមាតិកាថវិកាឆ្នាំ២០១៤**

| ប្រភេទ | ឆ្នាំសារពើពន្ធ ២០១៤ | | កំណត់ចំណាំ |
|---|---|---|---|
| | ការរៀបចំថវិកា | របាយការណ៍ថវិកា | |
| រដ្ឋបាល | មាន | មាន | មាន ៣៧ សម្រាប់អង្គភាពថវិកាថ្នាក់កណ្តាល<br>មាន ២៤ សម្រាប់រដ្ឋបាលរាជធានី-ខេត្ត |
| សេដ្ឋកិច្ច | មាន | មាន | រចនាសម្ព័ន្ធលេខកូដ មានសង្គតិភាពច្រើនជាមួយនឹងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល និងអាចផលិតជាស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលដោយព័ត៌មាន បន្ស៊ីជាមួយនឹងតម្រូវការរបស់តារាងចម្លងទិន្នន័យ (Bridget table) |
| មុខងារ | (មាន) | មិនមាន | ប្រើប្រាស់តែ៨វិស័យ/មុខងារ ពោលមិនមានសង្គតិភាពជាមួយ COFOG |
| កម្មវិធី | (មាន) | មិនមាន | ចំណាត់ថ្នាក់តាមកម្មវិធី ត្រូវបានប្រើប្រាស់ត្រឹមមួយចំណែកសម្រាប់ក្រសួងអនុវត្តសាកល្បងទាំង៨ |

សូចនាករនេះទទួលបានពិន្ទុ C ពីព្រោះទាំងការរៀបចំថវិកានិងគណនេយ្យ បានផ្អែកលើចំណាត់ថ្នាក់រដ្ឋបាល និងសេដ្ឋកិច្ច រីឯចំណាត់ថ្នាក់សេដ្ឋកិច្ចមានសង្គតិភាពទៅនឹងស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ លុះត្រាតែចំណាត់ថ្នាក់មុខងារមានសង្គតិភាពទៅនឹង COFOG។

**តារាង គ.១១÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៥**

| សូចនាករ | សមាសធាតុ/ មធ្យោបាយវាយតម្លៃ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-5 | ចំណាត់ថ្នាក់ថវិកា (M1) | C | C | មាតិកាដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកា និងគណនេយ្យ ក្នុងឆ្នាំសារពើពន្ធ២០១៤ មានតែចំណាត់ថ្នាក់រដ្ឋបាលនិងចំណាត់ថ្នាក់សេដ្ឋកិច្ចប៉ុណ្ណោះ។ |

**ប្រអប់ គ.៤÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

បុលង់គណនីថ្មីនិងឯកភាពមួយ ត្រូវបានរៀបចំ និងដាក់បង្ហាញនៅក្នុងឆ្នាំ២០១៥ ដើម្បីអាចដំណើរការសម្រាប់ការរៀបចំថវិកា និងការកត់ត្រាគណនេយ្យ ចាប់ពីឆ្នាំ២០១៦ តទៅ។ ប្លង់គណនីនេះ មាន ៧ ផ្នែក÷ ភូមិសាស្ត្រ, មុខងារ, រដ្ឋបាល/អង្គភាពប្រតិបត្តិ, សេដ្ឋកិច្ច, ប្រភពធនធាន, កម្មវិធី និងគម្រោង) ដែលមានសរុប ៤២ ខ្ទង់។ ប្លង់គណនីថ្មីនេះនឹងត្រូវអនុវត្តនៅគ្រប់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលរាជធានី-ខេត្ត ស្រុក ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលនឹងធ្វើឱ្យការប្រមូលសរុបទិន្នន័យ/ព័ត៌មាន នៅគ្រប់កម្រិត អាចធ្វើទៅរួច រួមទាំងការរៀបចំរបាយការណ៍តាមមាតិកាមុខងារ ទៅក្នុងប្រព័ន្ធ GFS។

## គ.២.២ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា (PI-6)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើសំណុំឯកសារពាក់ព័ន្ធនឹងការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិសម្រាប់ពិនិត្យ និងអនុម័ត ដែលបង្ហាញនូវការព្យាករណ៍ថវិការបស់រដ្ឋាភិបាល សំណើថវិកា និងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំចាស់។ ការវាយតម្លៃនេះ គឺផ្អែកលើថវិកាដែលបានបង្ហាញជូនអង្គនីតិប្បញ្ញត្តិចុងក្រោយបង្អស់ ពោលគឺឆ្នាំសារពើពន្ធ២០១៥។ តារាង គ.១២ ជាការសង្ខេបនូវធាតុសំខាន់ៗនៃថវិកា និងព័ត៌មានផ្សេងៗអំពីថវិកា។

ច្បាប់ថវិកា មាន៥ ផ្នែក ដែលមានជំពូកផ្សេងៗគ្នា (១) ច្បាប់ និងបទប្បញ្ញត្តិ (២) ថវិកាជាតិ, ក្រសួង-ស្ថាប័ន (៣) មន្ទីរជំនាញរាជធានី-ខេត្ត (៤) រាជធានី-ខេត្ត (៥) ក្រុង ស្រុក និងខណ្ឌ និង (៦) មូលនិធិឃុំ-សង្កាត់។

**តារាង គ.១២ ÷ ព័ត៌មានគន្លឹះក្នុងឯកសារថវិកាឆ្នាំ២០១៥**

| ល.រ. | ឈ្មោះឯកសារ | បញ្ជាក់ | ការពន្យល់ |
|---|---|---|---|
| ១ | សមត្ថកម្មម៉ាក្រូសេដ្ឋកិច្ច ដែលយ៉ាងហោចណាស់រួមបញ្ចូលនូវការព្យាករណ៍អំពីកំណើនសរុប, អត្រាអតិផរណា និងអត្រាប្តូរប្រាក់ | មាន | ការព្យាករណ៍អំពីកំណើនសរុប, អត្រាអតិផរណា និងអត្រាប្តូរប្រាក់ គឺត្រូវបានដាក់បញ្ចូលក្នុងឯកសារថវិកាដែលបានផ្ញើជូនអង្គនីតិប្បញ្ញត្តិ។ |
| ២ | ឱនភាពថវិកា ដែលត្រូវបានកំណត់ស្របទៅតាម GFS ឬនិយាមដទៃទៀតដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ | មិនមាន | ឱនភាពថវិកាត្រូវបានបង្ហាញ ប៉ុន្តែជាទម្រង់មិនមានសង្គតិភាពជាមួយនឹងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលទេ។ |
| ៣ | ហិរញ្ញប្បទានឱនភាព (deficit financing) | មាន | ព័ត៌មាននៃឱនភាពថវិកាត្រូវបានផ្តល់ ដែលញែកជាថវិកាក្នុងស្រុក (ប្រភេទឧបករណ៍មិនបានបញ្ជាក់ច្បាស់ទេ) និងហិរញ្ញប្បទានពីក្រៅស្រុក (បែងចែកជាហិរញ្ញវត្ថុថវិកាទូទៅ ហិរញ្ញប្បទានគម្រោងវិនិយោគ និងការរំលស់បំណុល)។ |
| ៤ | ស្តុកនៃបំណុល | មិនមាន | មិនមានព័ត៌មានលម្អិត។ |
| ៥ | ទ្រព្យហិរញ្ញវត្ថុ ដែលយ៉ាងហោចណាស់រួមបញ្ចូលនូវ សេចក្តីលំអិតសម្រាប់ដើមឆ្នាំបច្ចុប្បន្ន | មិនមាន | មិនមានព័ត៌មានលម្អិត។ |
| ៦ | លទ្ធផលថវិកាឆ្នាំកន្លងទៅ ដែលត្រូវបានបង្ហាញក្នុងទម្រង់ដូចគ្នាទៅនឹងសំណើថវិកា | មិនមាន | ការអនុវត្តថវិកាឆ្នាំមុនបានបង្ហាញក្នុងទម្រង់ដូចគ្នានឹងសំណើថវិកាសម្រាប់តែចំណូល (មានលម្អិតមុខសញ្ញា) ផ្ទុយទៅវិញការប្រៀបធៀបចំណាយបានបង្ហាញតែតារាងសង្ខេបទេ។ |
| ៧ | ថវិកាឆ្នាំបច្ចុប្បន្ន (ថវិកាដែលត្រូវបានកែតម្រូវ ឬលទ្ធផលដែលបានព្យាករណ៍) | មិនមាន | ថវិកាឆ្នាំបច្ចុប្បន្ន បានបង្ហាញក្នុងទម្រង់ដូចគ្នានឹងសំណើថវិកាសម្រាប់តែចំណូល (មានលម្អិតមុខសញ្ញា) ផ្ទុយទៅវិញ |

| ល.រ. | ឈ្មោះឯកសារ | បញ្ជាក់ | ការពន្យល់ |
|---|---|---|---|
| | ត្រូវបានបង្ហាញក្នុងទម្រង់ដូចគ្នាទៅនឹងសំណើថវិកា | | ការប្រៀបធៀបចំណាយបានបង្ហាញតែតារាងសង្ខេបទេ។ |
| ៨ | ទិន្នន័យថវិកាសង្ខេបសម្រាប់ចំណូលនិងចំណាយ ស្របទៅតាមចំណងជើងសំខាន់ៗនៃចំណាត់ថ្នាក់ដែលត្រូវបានប្រើ, រួមបញ្ចូលទាំងទិន្នន័យសម្រាប់ឆ្នាំបច្ចុប្បន្ននិងឆ្នាំចាស់ | មាន | ទិន្នន័យថវិកាសង្ខេបសម្រាប់ចំណូលនិងចំណាយ ត្រូវបានរៀបចំ ដោយអនុលោមតាមចំណាត់ថ្នាក់រដ្ឋបាល សេដ្ឋកិច្ច និងមុខងារ។ |
| ៩ | ការពន្យល់អំពីបម្រែបម្រួលថវិកាតាមគោលនយោបាយថ្មី ដោយមានការព្យាករណ៍អំពីការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគោលនយោបាយចំណូល និង/ឬការផ្លាស់ប្តូរសំខាន់ៗមួយចំនួននៃកម្មវិធីចំណាយ | មិនមាន | ការប្រែប្រួលគោលនយោបាយចំណូល-ចំណាយត្រូវបានពន្យល់។ ម្រែបម្រួលថវិកាតាមការផ្លាស់ប្តូរគោលនយោបាយថ្មីមានបញ្ចូលក្នុងការព្យាករណ៍ថវិកា ប៉ុន្តែមិនបានពន្យល់សម្រាប់ការផ្លាស់ប្តូរគោលនយោបាយនីមួយៗ ដាច់ដោយឡែកពីគ្នាទេ។ |

សូចនាករនេះ ទទួលបានពិន្ទុ C ពីព្រោះមានតែ ៣ ឯកសារប៉ុណ្ណោះ ដែលអាចស្វែងរកបាន។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ លុះត្រាតែមានឯកសារយ៉ាងហោចណាស់ ចំនួន៥ ក្នុងចំណោមឯកសារដូចបានរៀបរាប់ខាងលើ។

**តារាង គ.១៣÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៦**

| សូចនាករ | សមាសធាតុ | ពិន្ទុឆ្នាំ២០១០ | ពិន្ទុឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-6 | **ភាពគ្រប់ជ្រុងជ្រោយនៃពត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា** | **B** | **C** | ឯកសារថវិកាចំនួន ៣ ក្នុងចំណោមឯកសារថវិកាសរុបចំនួន ៩ (១,៣,៨) មានក្នុងឯកសារសំណើថវិកា ដែលត្រូវបានបញ្ជូនទៅអង្គនីតិប្បញ្ញត្តិ ក្នុងឆ្នាំ២០១៥។ |

**ប្រអប់ គ.៥ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ពុំមានរាយការណ៍។

## គ.២.៣ ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ (PI-7)

សូចនាករសមិទ្ធកម្មនេះ មានគោលបំណងធ្វើការវាយតម្លៃទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ តាមរយៈការពិនិត្យលើសមាសធាតុសំខាន់ពីរ គឺ÷ (១) ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយ-ការណ៍ និង (២) ព័ត៌មានស្ដីអំពីចំណូល-ចំណាយ លើគម្រោងហិរញ្ញប្បទានខាងក្រៅដែលបញ្ចូលក្នុងរបាយការណ៍ថវិកាគន្លឹះរបស់រាជរដ្ឋាភិបាល។ សូចនាករនេះ វាយតម្លៃលើកម្រិតនៃប្រតិបត្តិការដែលមិនបានរាយការណ៍នៅរដ្ឋបាលថ្នាក់ជាតិ ដូចមានបញ្ជាក់ក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល របស់ស្ថាប័នរូបិយវត្ថុអន្តរជាតិ[16]។ ចំណូលមិនមែនសារពើពន្ធស្ថិតនៅក្នុងវិសាលភាពនៃការវាយតម្លៃនៃសូចនាករនេះ ដោយរាប់បញ្ចូលទាំងចំណូលពីការបង់ថ្លៃសេវាសាធារណៈ ការពិន័យ និងការជួលទ្រព្យសម្បត្តិរដ្ឋជាដើម។ សម្រាប់ការវាយតម្លៃសូចនាករនេះ ចំណាយគួរត្រូវបានកត់ត្រាទាំងមុនពេលអនុវត្ត (ការព្យាករណ៍ថវិកា) និងក្រោយការអនុវត្ត (ចំណាយជាក់ស្ដែង) នៅក្នុងរបាយការណ៍ថវិកាគន្លឹះ ដូចជា ឥណទានថវិកាប្រចាំឆ្នាំ, របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយបូកសរុបជាមួយនឹងចំណាយរបស់រដ្ឋបាលថ្នាក់កណ្ដាលផ្សេងទៀត ឬបង្ហាញនៅក្នុងឯកសារដាច់ដោយឡែកណាផ្សេងទៀត ដែលត្រូវដាក់ជូនអង្គនីតិប្បញ្ញត្តិ ដើម្បីត្រូវបានចាត់ទុកថា "ត្រូវបានរាយការណ៍" ។ ការវាយតម្លៃ គ្របដណ្ដប់លើថវិកានៃឆ្នាំសារពើពន្ធចុងក្រោយ។

### (១) ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍

ជាទូទៅ ក្រសួង-ស្ថាប័នមួយចំនួន ប្រមូលចំណូលមិនមែនសារពើពន្ធដែលត្រូវបានបង្កើតដោយប្រកាសផ្សេងៗគ្នា។ ចំណូលមិនមែនសារពើពន្ធទាំងនេះ បានមកពីសេវាកម្មអាកាសចរណ៍ ទេសចរណ៍ ទូរគមនាគមន៍ អាជ្ញាប័ណ្ណទូរទស្សន៍និងវិទ្យុ ថ្លៃឈ្នួលទិដ្ឋាការ សម្បទាន និងការផាកពិន័យ ក៏ដូចជា ភាគលាភ។ លើសពីនេះ គ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រមូលចំណូលមិនមែនសារពើពន្ធ តាមរយៈថ្លៃឈ្នួលសាលា ថ្លៃឈ្នួលបង់សេវាពេទ្យ និងថ្នាំ។ ភាគលាភពីសហគ្រាសសាធារណៈ ត្រូវបានកំណត់ផ្អែកលើប្រាក់ចំណេញដែលបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈនីមួយៗ និងត្រូវបានបង់ចូលថវិកាជាតិក្នុងអំឡុងពេល ៩ខែ ក្រោយពីឆ្នាំថវិកាបានបញ្ចប់ ហើយភាគលាភត្រូវកត់ត្រាជាចំណូលរបស់ក្រសួង-ស្ថាប័នអាណាព្យាបាល នៃសហគ្រាសសាធារណៈនោះ។ ទោះជាយ៉ាងនេះក្ដី ការរាយការណ៍ពីការប្រមូលចំណូលមិនមែនសារពើពន្ធក្នុងឆ្នាំ២០១៣ គឺមានប្រមាណជា ១ ៤១៦ ពាន់លានរៀល ប្រហាក់ប្រហែលនឹង ១២% នៃចំណាយសរុបរបស់រាជរដ្ឋាភិបាល។

ជាទូទៅ ចំណូលទាំងនេះត្រូវបង់ផ្ទាល់ចូលទៅអគ្គនាយកដ្ឋានរតនាគារជាតិ និងរាប់បញ្ចូលក្នុងរបាយការណ៍ថវិកា ប៉ុន្តែមានករណីលើកលែងមួយចំនួន។ អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទទួលបន្ទុកក្នុងការពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធនេះ។ អគ្គនាយកដ្ឋានទ្រព្យ-

---

[16] ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល រួមបញ្ចូលនូវប្រតិបត្តិការហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ជាតិ ដែលរាប់បញ្ចូលមិនត្រឹមតែក្រសួង-ស្ថាប័នប៉ុណ្ណោះទេ តែក៏មានអង្គភាពសាធារណៈដទៃទៀត (គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ) ដែលទទួលបានហិរញ្ញប្បទានគាំទ្រពីថវិការដ្ឋ ប៉ុន្តែពុំមានរាប់បញ្ចូលនូវរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

សម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនមានសិទ្ធិអំណាចទៅប្រមូលចំណូល និងមិនទទួលខុសត្រូវក្នុងការត្រួតពិនិត្យចំណូលទាំងនេះ នៅក្នុងគណនីទោលរតនាគារទេ ប៉ុន្តែអាចទទួលព័ត៌មានពីចំណូលដែលបង់ចូលដោយផ្អែកលើរបាយការណ៍ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

តាមរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា សាលារដ្ឋប្រមូលចំណូលភាគច្រើនដោយមិនមានគោលការណ៍ គឺអនុវត្តតាមការសម្រេចរបស់គណៈគ្រប់គ្រងសាលា (រួមមាន អាហារដ្ឋាន ការជួលដីសាលា...) ហើយចំណូលប្រភេទនេះគឺមិនដែលបានរាយការណ៍មកក្រសួងទេ។ ទំហំចំណូលមានទំហំធំជាងការផ្ទេរសាច់ប្រាក់ទៅឱ្យសាលាពីថវិកាជាតិ គឺប្រហែលច្រើនជាង ១១ពាន់លានរៀល ឬ ប្រមាណជា ១% នៃចំណាយសរុបរបស់រដ្ឋ។ ដោយឡែក ក្រសួងសុខាភិបាល ធ្វើការតាមដានចំណូលពីថ្លៃសេវាដែលប្រមូលដោយមន្ទីរពេទ្យរដ្ឋ (មិនរាប់បញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល) គ្លីនិកសុខភាព និងពេទ្យបង្អែក ដែលត្រូវបានរាយការណ៍មកក្រសួង និងដាក់បញ្ចូលក្នុងការព្យាករណ៍ថវិកា។ បទប្បញ្ញត្តិតម្រូវឱ្យមានការកំណត់ថ្លៃសេវា សម្រាប់ប្រភេទសេវានីមួយៗ ដោយពិគ្រោះយោបល់ជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ជាក់ស្តែង ប្រកាសអន្តរក្រសួងសម្រាប់សេវានីមួយៗ កំណត់ឱ្យចាត់ចែងចំណូលពីសេវាដូចតទៅ÷ ៦០% សម្រាប់ការលើកទឹកចិត្តបុគ្គលិក, ៣៩% សម្រាប់ចំណាយប្រតិបត្តិការក្រៅបន្ទុកបុគ្គលិក និង ១% ផ្ទេរចូលគណនីទោលរតនាគារ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល រក្សាទុកមួយភាគធំ នៃចំណូលថវិកាបន្ថែម និងប្រើប្រាស់ថវិកាទាំងនេះសម្រាប់ចំណាយចរន្ត និងវិនិយោគ។ ទោះជាយ៉ាងនេះក្តី ចំណូល-ចំណាយ ត្រូវបានរាយការណ៍ទៅរដ្ឋបាលកណ្តាលសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលភាគច្រើន (សូចនាករសមិទ្ធកម្មទី៩ សមាសធាតុ ១) ថ្វីបើគ្មានស្តង់ដារច្បាស់លាស់សម្រាប់ការកត់ត្រាប្រតិបត្តិការទាំងនោះក្តី។ ចំណូលផ្ទាល់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មិនត្រូវបានបញ្ចូលក្នុងការព្យាករណ៍ថវិកា ឬក្នុងរបាយការណ៍អនុវត្តថវិកាឡើយ។ ទំហំចំណូលក្នុងឆ្នាំ២០១៣ មានប្រមាណ ១៨៤ ពាន់លានរៀល (ឧបសម្ព័ន្ធ ៥.១) ស្មើនឹង ១,២% នៃចំណាយសរុបរបស់រដ្ឋ ប៉ុន្តែទំហំនេះរាប់បញ្ចូលតែ ១៦ គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងចំណោម ២៦ ប៉ុណ្ណោះ ហើយក្នុងនោះ គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ១ មិនមានរាយការណ៍នៅក្នុងបញ្ជីរាយឈ្មោះគ្រឹះស្ថានរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធឡើយ។ លើសពីនេះ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បានទទួលឧបត្ថម្ភធនពីថវិការដ្ឋក្នុងឆ្នាំ ២០១៣ ប្រមាណជា ១៨៦ពាន់លានរៀល (១,៥% នៃចំណាយសរុបរបស់រដ្ឋ) ដែលក្នុងនោះ ចំណាយជាក់ស្តែងមិនមានរាយការណ៍ក្នុងរបាយការណ៍អនុវត្តថវិកាទេ។ ប្រសិនបើតាមការប៉ាន់ប្រមាណ ចំណូល-ចំណាយផ្ទាល់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានរាយការណ៍ គឺមានប្រមាណជា ៤% នៃចំណាយថវិកាសរុបរបស់រដ្ឋ។

ទោះយ៉ាងណាក៏ដោយ តាមការគូសបញ្ជាក់ ចំណាយថវិកាបន្ថែមដែលមិនបានរាយការណ៍ គឺមានប្រមាណ ៥% នៃចំណាយថវិកាសរុបរបស់រដ្ឋ ដែលការសន្និដ្ឋានលើចំនួននេះ មិនបានផ្អែកលើព័ត៌មានពីក្រសួង-ស្ថាប័នជាច្រើនផ្សេងទៀត ដែលប្រមូលចំណូលមិនមែនសារពើពន្ធដោយផ្ទាល់ ឬតាមរយៈអង្គភាពក្រោមឱវាទក្រសួង-ស្ថាប័នទាំងនោះឡើយ។ បើគេសន្មតថា ក្រសួង-ស្ថាប័នដទៃទៀតក្រៅពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល (ឥណទានថវិកាចំណាយចរន្តរបស់ក្រសួងទាំងពីរនេះ មានប្រមាណជិត ១/៤ នៃចំណាយសរុប

របស់រដ្ឋ) បានប្រមូលចំណូលមិនមែនសារពើពន្ធក្នុងទំហំប្រហាក់ប្រហែលនឹងក្រសួងទាំងពីរនេះ ហើយមិនបានរាយការណ៍នោះ ទំហំនៃចំណូលសរុបដែលមិនបានរាយការណ៍ នឹងមានប្រមាណជា ៤-៥% នៃចំណាយសរុបរបស់រដ្ឋ។ នៅពេលដែលចំណាយមិនបានរាយការណ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានបូកបញ្ចូល ចំណាយសរុបដែលមិនបានរាយការណ៍ នឹងមានប្រមាណជា ៨-៩% នៃចំណាយសរុបរបស់រដ្ឋ។ ទោះបីជាការប៉ាន់ប្រមាណខាងលើអាចមិនមានភាពជាក់លាក់ ក៏ចំណាយមិនបានរាយការណ៍ហាក់ដូចជាច្បាស់ថា មានទំហំធំជាង ៥% នៃចំណាយសរុបរបស់រដ្ឋ ប៉ុន្តែមិនលើសពី ១០% ឡើយ។

សមាសធាតុនេះទទួលបានពិន្ទុ C ពីព្រោះទំហំថវិកាដែលបានព្យាករសម្រាប់ចំណាយថវិកាបន្ថែមមិនបានរាយការណ៍ គឺក្នុងចន្លោះរវាង ៥% និង ១០% នៃចំណាយថវិកាសរុបរបស់រដ្ឋ តែមិនរាប់បញ្ចូលគម្រោងហិរញ្ញប្បទានខាងក្រៅ។

**(២) ព័ត៌មានស្តីពីចំណូល-ចំណាយ សម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍**

ឯកសារពេញលេញនៃថវិកាប្រចាំឆ្នាំ មានបង្ហាញពីការព្យាករណ៍ចំណាយរបស់ក្រសួង-ស្ថាប័ន ដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ ដោយផ្អែកលើកម្មវិធីវិនិយោគសាធារណៈ។ ការព្យាករណ៍ថវិកាភាគច្រើនមានភាពពេញលេញ បើទោះជាកម្មវិធីវិនិយោគសាធារណៈនៅមិនទាន់មានទិន្នន័យពេញលេញសម្រាប់គម្រោងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការក៏ដោយ (ផ្នែក គ.៧ ខាងក្រោម)។ ទិន្នន័យស្តីពីការអនុវត្តចំណាយជាក់ស្តែង (ពោលគឺរបាយការណ៍ចុងក្រោយ) មិនមានភាពពេញលេញឡើយ។ ចំណាយជាក់ស្តែង ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ តែក្នុងតួលេខសរុបប៉ុណ្ណោះ។ ទោះបីជាការផ្តល់កម្ចី និងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ដែលឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកត់ត្រាក៏ដោយ ប៉ុន្តែមិនមានទិន្នន័យច្បាស់លាស់សម្រាប់ចំណាយនៃគម្រោងដែលប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ថាតើត្រូវបានអនុវត្តតាមរយៈការផ្តល់ឱ្យដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ ឬតាមរយៈការប្រើប្រាស់គណនីរបស់ដៃគូអភិវឌ្ឍន៍ដែលមានក្នុងធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជឡើយ។ ព័ត៌មាន និងទិន្នន័យរវាងអគ្គនាយកដ្ឋានថវិកា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មិនមានសង្គតិភាពនឹងគ្នាទេ ប៉ុន្តែបានបង្ហាញថាការផ្តល់ហិរញ្ញប្បទានជាក់ស្តែងសម្រាប់គម្រោង មានប្រមាណតិចជាង ៥០% នៃចំនួនគម្រោងទាំងអស់ប៉ុណ្ណោះ។

សមាសធាតុនេះទទួលបានពិន្ទុ C ពីព្រោះរាល់ចំណាយដោយគម្រោងហិរញ្ញប្បទានខាងក្រៅតាមរយៈកម្ចី ត្រូវបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍អនុវត្តថវិកា ទាំងការព្យាករណ៍ និងការអនុវត្ត។ សមាសធាតុនេះមិនអាចទទួលបានពិន្ទុខ្ពស់ ដោយហេតុថា ការផ្តល់ហិរញ្ញប្បទានជាក់ស្តែងសម្រាប់ចំណាយគម្រោង មានប្រមាណក្រោម ៥០% នៃគម្រោងទាំងអស់ប៉ុណ្ណោះ។

## តារាង គ.១៤÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៧

| សូចនាករ | សមាសធាតុ/ មធ្យោបាយវាយតម្លៃ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-7 | **ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍** | C | C | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M1 |
| (១) | ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍ | C | C | ផ្អែកលើគំរូរបស់នាយកដ្ឋាន ការព្យាករណ៍ចំណូលមិនមែនសារពើពន្ធ បញ្ជាក់ថា កម្រិតនៃចំណាយបន្ថែមដែលមិនត្រូវបានរាយការណ៍មានច្រើនជាង ៥% ប៉ុន្តែទាបជាង ១០% នៃចំណាយថវិកាសរុបរបស់រដ្ឋ។ |
| (២) | ព័ត៌មានស្តីពីចំណូល-ចំណាយសម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ | C | C | គ្រប់ថវិកាគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ខាងក្រៅ (ការព្យាករណ៍) មានបង្ហាញនៅក្នុងឯកសារថវិកា ផ្អែកលើកម្មវិធីវិនិយោគសាធារណៈ។ ការអនុវត្តចំណាយជាក់ស្តែង មានបង្ហាញក្នុងរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ ប៉ុន្តែមានភាពពេញលេញ ចំពោះតែគម្រោងដែលប្រើប្រាស់កម្ចី។ ការព្យាករណ៍ឱ្យបានសុក្រឹតពីទំហំគម្រោងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានកត់ត្រានៅក្នុងរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំមិនអាចធ្វើទៅរួចឡើយ ប៉ុន្តែតាមការប៉ាន់ស្មានមានទំហំតិចជាង ៥០%។ |

### ប្រអប់ គ.៦ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ បានកំណត់នូវសកម្មភាពសំដៅពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ រួមទាំងការកែលម្អការត្រួតពិនិត្យតាមដាន ការកត់ត្រា និងការកៀរគរចំណូលមិនមែនសារពើពន្ធ។

## គ.២.៤ តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) (PI-8)

សូចនាករសមិទ្ធកម្មនេះ មានគោលបំណងវាយតម្លៃអំពីតម្លាភាពនៃការផ្ទេរថវិកាពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណនេយ្យភាពនៃការប្រើប្រាស់ធនធានទាំងនេះ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។ ដោយអនុលោមតាមរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានបង្ហាញក្នុង**ផ្នែក ខ.៣.៨** មូលដ្ឋាននៃការដាក់ពិន្ទុលើសូចនាករនេះ គឺផ្តោតលើរដ្ឋបាលឃុំ-សង្កាត់ ដែលរៀបចំ និងអនុវត្តថវិកាផ្ទាល់ខ្លួន ជាមួយនឹងស្វ័យភាពខ្ពស់ និងត្រូវមានគណនេយ្យភាពចំពោះប្រជាជននៅមូលដ្ឋាន តាមរយៈក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត។

### (១) តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ

ការវិភាជតាមខ្សែបណ្តោយ (Vertical) ទៅកម្រិតទាំង៣ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានកំណត់ជាភាគរយថេរនៃចំណូលថវិកាចរន្តក្នុងឆ្នាំចាស់ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ជាតិ, ជាក់ស្តែង សម្រាប់ រដ្ឋបាលឃុំ-សង្កាត់ ក្នុងឆ្នាំ២០១៤ មានប្រមាណជា ២,៨%។

ការវិភាជតាមខ្សែទទឹង (Horizontal) គឺត្រូវកំណត់តាមរូបមន្ត ឬវិធីសាស្ត្រជាក់លាក់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានបែងចែកជាសមាសធាតុរដ្ឋបាល និងសមាសធាតុអភិវឌ្ឍន៍។ សម្រាប់ឃុំ-សង្កាត់ ការវិភាជមានដូចខាងក្រោម÷

- ១/៣ ត្រូវបានវិភាជទៅសមាសធាតុរដ្ឋបាលសម្រាប់ចំណាយចរន្ត (បុគ្គលិក ប្រតិបត្តិការ និងការថែទាំ) និង ២/៣ ត្រូវបានវិភាជទៅគម្រោងអភិវឌ្ឍន៍ផ្ទាល់នៅមូលដ្ឋាន
- តួលេខសម្រាប់សមាសធាតុរដ្ឋបាល ត្រូវបានកំណត់ដូចតទៅ÷ ៣០% ស្មើគ្នាជូនគ្រប់ឃុំ-សង្កាត់, ៦០% ដោយយោងលើចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និង ១០%ទៀតផ្អែកលើសន្ទស្សន៍នៃភាពក្រីក្រ
- សមាសធាតុអភិវឌ្ឍន៍ផ្ទាល់នៅមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ÷ ៣០% ស្មើគ្នាជូនគ្រប់ឃុំ-សង្កាត់, ៣០% ផ្អែកលើចំនួនប្រជាជនក្នុងឃុំ-សង្កាត់, ៣០% ផ្អែកលើសន្ទស្សន៍នៃភាពក្រីក្រ និង ១០%សម្រាប់ចំនួនភូមិនៅក្នុងឃុំ-សង្កាត់។

សន្ទស្សន៍នៃភាពក្រីក្រ ត្រូវបានរៀបចំដោយក្រសួងផែនការ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ឃុំ-សង្កាត់មានសិទ្ធិអំណាចប្រមូលចំណូល តែពីប្រភពមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍ ថ្លៃសេវារដ្ឋបាល ដូចជា លិខិតបញ្ជាក់សំបុត្រកំណើត និងលិខិតបញ្ជាក់អាពាហ៍ពិពាហ៍)។ ឃុំ-សង្កាត់ ពឹងផ្អែកទាំងស្រុងលើឧបត្ថម្ភធន ព្រោះចំណូលពីប្រភពដទៃទៀតមានទំហំតូចតាច ធៀបនឹងចំណាយសរុបរបស់ឃុំ-សង្កាត់។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថាការវិភាជតាមខ្សែទទឹង (Horizontal) នៃការផ្ទេរថវិកាទាំងអស់ទៅឃុំ-សង្កាត់ គឺផ្អែកលើប្រព័ន្ធដែលមានតម្លាភាព និងមានរូបមន្តច្បាស់លាស់។

### (២) ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបាន អំពីការវិភាជថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឃុំ-សង្កាត់ រៀបចំថវិកាដោយផ្ទាល់ខ្លួន ដោយមិនមានការចូលរួមពីរដ្ឋបាលថ្នាក់ជាតិទេ។ ឃុំ-សង្កាត់ផ្ញើគម្រោងថវិកាទៅក្រសួងមហាផ្ទៃ នៅក្នុងខែតុលា នៃឆ្នាំមុនឆ្នាំអនុវត្តថវិកា ដើម្បីជ្រាបជាព័ត៌មាន។ ដោយហេតុថារូបមន្តវិភាជន៍ ផ្អែកលើចំណូលចរន្តនៃថវិកាថ្នាក់ជាតិនៃឆ្នាំដែលគម្រោងថវិកាកំពុងត្រូវបានរៀបចំ ដូចនេះ គ្រប់ទិន្នន័យចាំបាច់សម្រាប់រៀបចំថវិកា ត្រូវបានដឹងជាមុនដោយរដ្ឋបាលឃុំ-សង្កាត់។ ក្នុងការអនុវត្ត ឃុំ-សង្កាត់នឹងត្រូវបានជូនដំណឹងក្នុងខែកក្កដា អំពីឧបត្ថម្ភធនដែលនឹងត្រូវទទួលបាននៅឆ្នាំថវិកាបន្ទាប់។

ឧបត្ថម្ភធននឹងត្រូវផ្ទេរជា ៤ត្រីមាស ក្នុងទំហំស្មើៗគ្នាក្នុង ១ត្រីមាស។ ការផ្ទេរលើកទី១ ប្រព្រឹត្តទៅនៅក្នុងសប្តាហ៍ទី១ នៃឆ្នាំអនុវត្តថវិកា។ ការផ្ទេរជាបន្តបន្ទាប់ប្រព្រឹត្តទៅ បន្ទាប់ពីការផ្តល់របាយការណ៍ចំណាយនៅក្នុងត្រីមាសមុន ដោយឃុំ-សង្កាត់ទៅក្រសួងមហាផ្ទៃ។ ក្នុងការអនុវត្ត ឃុំ-សង្កាត់មួយចំនួន មានបញ្ហាកង្វះសមត្ថភាពក្នុងការរៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ ដែលនាំឱ្យមានការពន្យារពេលនៃការផ្ទេរថវិកា ប៉ុន្តែការពន្យារពេលនេះ គឺមិនដែលលើសពី ១ខែទេ។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថា ឃុំ-សង្កាត់ត្រូវបានផ្តល់ឱ្យនូវព័ត៌មានច្បាស់លាស់អំពីឧបត្ថម្ភធនដែលរដ្ឋបាលឃុំ-សង្កាត់នីមួយៗនឹងទទួលបានសម្រាប់ឆ្នាំបន្ទាប់ ក្នុងអំឡុង ២ ឬ ៣ខែ មុននឹងបញ្ចប់ការរៀបចំថវិការបស់ខ្លួន។

### (៣) កម្រិតនៃបូកសរុបទិន្នន័យសារពើពន្ធរបស់រដ្ឋាភិបាល ដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ

ក្នុងឆ្នាំ២០១៣ ប្លង់គណនីសម្រាប់ឃុំ-សង្កាត់ មានភាពខុសគ្នាពីស្តង់ដារប្លង់គណនីរបស់រដ្ឋបាលថ្នាក់ជាតិ និងករណីខ្លះមិនបានបញ្ចូលនូវចំណាត់ថ្នាក់មុខងារទេ។ ការណ៍នេះនាំឱ្យការបូកសរុបព័ត៌មានពីរដ្ឋបាលគ្រប់កម្រិតមិនអាចធ្វើទៅបាន។ ដោយឡែក មានការកែលម្អច្រើនក្នុងការធ្វើឱ្យមានសង្គតិភាពជាមួយនឹងមាតិកាសេដ្ឋកិច្ចក្នុងឆ្នាំថវិកា២០១៤ តែចំណាត់ថ្នាក់មុខងារនៅពុំទាន់ត្រូវបានអនុវត្តនៅឡើយ។ ការបូកសរុបចំណាយទាំងអស់របស់រដ្ឋាភិបាលសម្រាប់ឆ្នាំថវិកា២០១៤ មិនទាន់ត្រូវបានរៀបចំតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ឬចំណាត់ថ្នាក់ផ្សេងទៀតទេ (លើកលែងតែចំណាត់ថ្នាក់រដ្ឋបាល)។

សមាសធាតុនេះទទួលបានពិន្ទុ D ដោយហេតុថាព័ត៌មានថវិកាពីឃុំ-សង្កាត់ មិនទាន់អាចបូកសរុបដាក់បញ្ចូលជាមួយនឹងចំណាយថ្នាក់ជាតិបានទេ បើយោងតាមចំណាត់ថ្នាក់មុខងារ និងវិស័យ។

**តារាង គ.១៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៨**

| សូចនាករ | សមាសធាតុ/ មធ្យោបាយវាយតម្លៃ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-8 | **តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិនិងក្រោមជាតិ)** | C+ | B | វិធីសាស្ត្រវាយតម្លៃផ្ដល់ពិន្ទុ M2 |
| (១) | តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ | C | A | ឃុំសង្កាត់ ជាទូទៅពឹងផ្អែកទាំងស្រុងលើឧបត្ថម្ភធនពីមូលនិធិឃុំ-សង្កាត់។ ការវិភាជតាមខ្សែបណ្ដោយ (Vertical) ទៅមូលនិធិ និងការវិភាជតាមខ្សែទទឹង (Horizontal) ទៅគ្រប់ឃុំ-សង្កាត់ ផ្អែកលើប្រព័ន្ធដែលមានតម្លាភាព និងមានរូបមន្តច្បាស់លាស់។ |
| (២) | ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបានស្ដីពីការវិភាជថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំ-សង្កាត់ត្រូវបានផ្ដល់ព័ត៌មាន អំពីឧបត្ថម្ភធនដែលនឹងត្រូវទទួលបាន ក្នុងរវាងប៉ុន្មានខែមុននឹងបញ្ចប់ការរៀបចំថវិការបស់ខ្លួន រីឯការផ្ដល់ថវិកាធ្វើឡើងតាមកាលវិភាគច្បាស់លាស់ ដោយមានការពន្យារពេលតែចំពោះ ឃុំ-សង្កាត់ណាដែលមិនបានផ្ដល់របាយការណ៍ត្រឹមាសទាន់ពេលវេលា |
| (៣) | កម្រិតនៃការប្រមូលសរុបទិន្នន័យសារពើពន្ធរបស់រដ្ឋាភិបាលដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ | D | D | ចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់វិស័យនៃចំណាយ មិនត្រូវបានបញ្ចូលទាំងក្នុងប្លង់គណនីរបស់រដ្ឋបាលថ្នាក់ជាតិ និងរបស់រដ្ឋបាលឃុំ-សង្កាត់។ |

**ប្រអប់ គ.៧ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ប្លង់គណនីថ្មី ដែលនឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៥ នឹងអនុញ្ញាតឱ្យធ្វើចំណាត់ថ្នាក់ និងការប្រមូលសរុបចំណាយរបស់រដ្ឋបាលគ្រប់កម្រិត ដែលនឹងអាចនាំឱ្យពិន្ទុនៃសមាសធាតុ ៣ នៃសូចនាករនេះ កើនល្អជាងមុន។

## គ.២.៥ ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ (PI-9)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃអំពីកម្រិតនៃការតាមដាន និងការគ្រប់គ្រងដោយរាជរដ្ឋាភិបាល លើហានិភ័យថវិកា ព្រមទាំងឥទ្ធិពលនៃការអនុវត្តសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពស្វយ័តរបស់រដ្ឋ និងសហគ្រាសសាធារណៈ។ ហានិភ័យថវិកា អាចជាការមិនសងបំណុល (ដែលមាន ឬគ្មានការធានារបស់រដ្ឋ), ការខាតបង់ក្នុង

ប្រតិបត្តិការ ដែលបណ្តាលមកពីការអនុវត្តថវិកា (quasi-fiscal operation) បំណុលកកស្ទះ និងការមិនបានបង់កាតព្វកិច្ចប្រាក់សោធន។ ការវាយតម្លៃនេះគឺផ្អែកលើឆ្នាំសារពើពន្ធចុងក្រោយ។

**(១) កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើអង្គភាពស្វយ័ត និងសហគ្រាសរដ្ឋ**

នាពេលបច្ចុប្បន្ន មានសហគ្រាសសាធារណៈចំនួន ១២ ដែលគ្រប់គ្រងទាំងស្រុងដោយរដ្ឋ និង ៣ ផ្សេងទៀតដែលរដ្ឋមានភាគកម្មភាគច្រើន (ឧបសម្ព័ន្ធ ៥.២)។ សហគ្រាសសាធារណៈធំជាងគេ គឺ អគ្គិសនីកម្ពុជា ដែលមានប្រាក់ចំណូលច្រើនជាង ៨០% នៃចំណូលសរុបនៃសហគ្រាសសាធារណៈទាំងអស់។ បន្ទាប់ពីនេះ គឺ ប្រៃសណីយ៍កម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ កំពង់ផែស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ បន្ថែមពីនេះ យោងតាមការកំណត់នៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាល គឺជាសហគ្រាសហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែស្ថិតនៅក្នុងលក្ខន្តិកៈ និងការត្រួតពិនិត្យដោយឡែក។

គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២៦ (ពោល គឺអង្គភាពស្វយ័តរដ្ឋ) ដែលក្នុងនោះ គ្រឹះស្ថានធំៗ ៥ មានដូចជាអាជ្ញាធរជាតិអប្សរា (គ្រប់គ្រងលើតំបន់អង្គរ) បេឡាជាតិសន្តិសុខសង្គម មន្ទីរពេទ្យកាល់ម៉ែត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (ឧបសម្ព័ន្ធ ៥.១)។

សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំទៅរដ្ឋបាលថ្នាក់ជាតិ។ សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈសហគ្រាសសាធារណៈ, ព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ រីឯគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យបង្កើតគ្រឹះស្ថាន និងសារាចរណែនាំលេខ ០០៥ សហវ.សរ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ជាតិតម្រូវឱ្យមានការតាមដានការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ព្រមទាំងតាមរយៈកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាល ។ ដោយឡែក សហគ្រាសសាធារណៈ ត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានធ្វើសវនកម្មរួច មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នអាណាព្យាបាលបច្ចេកទេស។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ប្រមូលរបាយការណ៍ផ្ទាល់ពីសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ លើកលែងតែធនាគារជាតិនៃកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំពីសហគ្រាសសាធារណៈ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនឯកជន ឬក្រុមការងារសវនកម្មអន្តរក្រសួង។ ដោយឡែករបាយការណ៍ពីគ្រឹះស្ថានសាធារណៈរដ្ឋបាល គឺត្រូវរៀបចំជាប្រចាំខែ និងប្រចាំឆ្នាំ។ របាយការណ៍ពីធនាគារជាតិនៃកម្ពុជា គឺត្រូវរៀបចំជាប្រចាំឆ្នាំ និងត្រូវធ្វើសវនកម្មដោយក្រុមហ៊ុនឯកជន (ថ្មីៗនេះ គឺក្រុមហ៊ុន PwC)។ របាយការណ៍ទាំងនេះត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល និងអាចផ្តល់ជូនតាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានមុខងារប្រមូលសរុបព័ត៌មានហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍ប្រចាំឆ្នាំ (របាយការណ៍របស់សហគ្រាសសាធារណៈ និងរបាយការណ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំដាច់ដោយឡែកពីគ្នា) ដើម្បីគោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយក្នុងនោះត្រូវបញ្ចូលចំណូលសរុប (មានប្រភពជាក់លាក់) និងចំណាយសរុប (តាមជំពូក) ព្រមទាំងទ្រព្យសកម្ម ទ្រព្យរដ្ឋអតិរេកប្រចាំឆ្នាំ ការទូទាត់ពន្ធ និងភាគលាភ សម្រាប់សហគ្រាសសាធារណៈនីមួយៗ។ របាយការណ៍ទាំងនេះ ក៏បង្ហាញពីបម្រែបម្រួលនៃទិន្នន័យខាងលើផងដែរ។ ទោះជាយ៉ាងណា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មិនទាន់បានរៀបចំយន្តការ នីតិវិធី ឬយុទ្ធសាស្ត្រដើម្បីត្រួតពិនិត្យតាមដាន និងគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុនៅឡើយ ជាពិសេសការរៀបចំ និងការព្យាករណ៍ចំណូល-ចំណាយសម្រាប់អង្គភាពសាធារណៈទាំងនេះ ដើម្បីចៀសផុតពីការជួបប្រទះបញ្ហាប្រឈមដែលប៉ះពាល់ជាអវិជ្ជមានដល់រដ្ឋបាលថ្នាក់ជាតិ។ របាយការណ៍បូកសរុប ហាក់មានភាពពេញលេញសម្រាប់សហគ្រាសសាធារណៈពាក់ព័ន្ធ (លើកលែងតែធនាគារជាតិនៃកម្ពុជា) ប៉ុន្តែចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាលវិញ មានតែចំនួន ១៦ ក្នុងចំណោម ២៦ ប៉ុណ្ណោះ ដែលមាននៅក្នុងរបាយការណ៍។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថា ភាគច្រើននៃសហគ្រាសសាធារណៈ និង គ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើរបាយការណ៍ប្រចាំឆ្នាំទៅរដ្ឋបាលថ្នាក់ជាតិ។ ដើម្បីបានពិន្ទុខ្ពស់ជាងនេះ ចាំបាច់ត្រូវមានព័ត៌មានពេញលេញនៃការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលធំៗ ទើបរដ្ឋបាលថ្នាក់ជាតិអាចបូកសរុបព័ត៌មានទាំងនោះជារបាយការណ៍ និងធ្វើការវិភាគហានិភ័យថវិកាបាន។

### (២) កម្រិតនៃការត្រួតពិនិត្យតាមដានរបស់រដ្ឋបាលថ្នាក់ជាតិ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ជាតិទទួលរបាយការណ៍ប្រចាំត្រីមាសពីឃុំ-សង្កាត់[17] ដែលបានផ្ញើជូនក្រសួងមហាផ្ទៃ។ របាយការណ៍នេះ មានដាក់បញ្ចូលព័ត៌មាននៃចំណាយដែលបានអនុវត្តក្នុងត្រីមាសមុន និងសមតុល្យនៃចំណូលពីឧបត្ថម្ភធន។ របាយការណ៍នេះ មិនបានគូសបញ្ជាក់ពីបញ្ហាដែលគួរត្រូវបានពិចារណាសម្រាប់ការវាយតម្លៃហានិភ័យថវិកាទេ (ដូចជា ទំហំនៃកិច្ចសន្យា ។ល។)។

ទោះយ៉ាងនេះក្តី ជាទូទៅ ឃុំ-សង្កាត់ មិនអាចមានលទ្ធភាពបង្កើតជាហានិភ័យថវិកាសម្រាប់រដ្ឋបាលថ្នាក់ជាតិបានទេ ដោយហេតុថា ឃុំ-សង្កាត់ ត្រូវរៀបចំ និងអនុវត្តថវិកាដោយខ្លួនឯង ហើយមានប្រភពចំណូលពឹងផ្អែកលើការផ្ទេរពីរដ្ឋបាលថ្នាក់ជាតិស្ទើរតែទាំងស្រុង ហើយរាល់ការទូទាត់ត្រូវឆ្លងកាត់រតនាគារ។ ឃុំ-សង្កាត់ មិនត្រូវបានអនុញ្ញាតឱ្យខ្ចី ឬចំណាយលើសពីថវិកាដែលបានគ្រោង ដោយមិនមានការអនុញ្ញាតជាមុនពីរដ្ឋបាលថ្នាក់ជាតិទេ ដែលយន្តការនេះគឺអាចបញ្ចៀសការជំពាក់បំណុល។ ឃុំ-សង្កាត់ ត្រូវបានអនុញ្ញាតឱ្យសន្សំ និងរក្សាទុករជ្ជទេយ្យបុរេប្រទានរហូតដល់កម្រិត ១/៣ នៃថវិកាដែលបានអនុម័តផ្តល់ឱ្យ។ ជារួម ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ ឃុំ-សង្កាត់

[17] សម្រាប់សូចនាករ ១៨ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានចាត់ទុកជាអង្គភាពចំណុះឱ្យរដ្ឋបាលថ្នាក់កណ្តាល និងជាក់ស្តែងមិនបានគ្របដណ្តប់ដោយវិសាលភាពក្នុងសូចនាករ ១៩ ទេ។

មិនបានបង្កើតជាបំណុលកកស្ទះ ឬចំណាយលើសពីសមតុល្យគណនីធនាគារ ឬកាតព្វកិច្ចផ្សេងដែលអាចនាំឱ្យក្លាយជាបំណុលដល់រដ្ឋបាលថ្នាក់ជាតិទេ។ ប្រសិនបើមានហានិភ័យបែបនេះកើតឡើងមែននោះ វាក៏ស្ថិតក្នុងកម្រិតមួយតូចដែរ ម្យ៉ាងទៀត របាយការណ៍ក៏បានបង្ហាញពីភាពវិជ្ជមាននៃការអនុវត្តថវិការបស់ ឃុំ-សង្កាត់ ផងដែរ។

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ[18] បូកសរុបរបាយការណ៍ឃុំ-សង្កាត់ ទៅជារបាយការណ៍ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ-សង្កាត់ ហើយការរៀបចំរបាយការណ៍បូកសរុបនេះ កម្រនឹងមានការពន្យារពេលណាស់ ដោយហេតុថា ការពន្យារពេល ក្នុងការទទួលបានរបាយការណ៍ពីឃុំ-សង្កាត់ និងការផ្ទៀងផ្ទាត់ទិន្នន័យជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ កម្រលើសពីរយៈពេល ១ខែផងដែរ។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថាឃុំ-សង្កាត់ ជាទូទៅមិនអាចបង្កើតហានិភ័យហិរញ្ញវត្ថុ ទៅដល់រដ្ឋបាលថ្នាក់ជាតិទេ។

---

[18] យោងតាមព័ត៌មានពីអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិតែមួយ។ បេសកកម្មពិនិត្យ និងធ្វើបច្ចុប្បន្នភាព មិនបានជួបផ្ទាល់ជាមួយក្រសួងមហាផ្ទៃទេ។

**តារាង គ.១៦÷ ពិន្ទុសូចនាករសមិទ្ធកម្មទី៩**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-9 | **ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ (PI-9)** | C+ | C+ | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M1 |
| (១) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់កណ្តាលទៅលើអង្គភាពស្វ័យតនិងសហគ្រាសរដ្ឋ | C | C | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ទទួលបានរបាយការណ៍ប្រចាំឆ្នាំពីគ្រប់សហគ្រាសសាធារណៈ និងភាគច្រើននៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ការបូកសរុបរួម នៃរបាយការណ៍ថវិកាត្រូវបានរៀបចំ (មិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា) ប៉ុន្តែមិនបានកំណត់ និងវិភាគពីហានិភ័យហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ជាតិឡើយ ហើយគ្របដណ្តប់តែ ៦០%នៃ គ្រឹះស្ថានសាធារណៈរដ្ឋបាលប៉ុណ្ណោះ។ |
| (២) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ស្ថានភាពហិរញ្ញវត្ថុនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានតាមដានជាត្រីមាស និងរៀបចំជារបាយការណ៍ដាច់ដោយឡែកពីគ្នា សម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង របាយការណ៍នេះមិនបានកំណត់ ឬ វិភាគពីបញ្ហាហានិភ័យហិរញ្ញវត្ថុទេ តាមការអនុវត្ត ឃុំ-សង្កាត់មិនអាចបង្កើតជាហានិភ័យទៅលើរដ្ឋបាលថ្នាក់ជាតិបានទេ។ |

**ប្រអប់ គ.៨÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ពុំមានរាយការណ៍។

## គ.២.៦ លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ (PI-10)

សូចនាករនេះ មានគោលបំណងវាយតម្លៃអំពីលទ្ធភាព និងភាពងាយស្រួលរបស់សាធារណជន ឬយ៉ាងហោចណាស់ អ្នកពាក់ព័ន្ធ ក្នុងការទទួលបានព័ត៌មានស្តីពីថវិកា។ គោលការណ៍តម្លាភាព តម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំ និងផ្សព្វផ្សាយព័ត៌មានថវិកា ដែលងាយស្រួលទទួលបាន មានលក្ខណៈគ្រប់ជ្រុងជ្រោយ ងាយយល់ និងទាន់ពេលវេលា។ ការវាយតម្លៃនេះ ផ្អែកលើឆ្នាំសារពើពន្ធចុងក្រោយ ពោលគឺឆ្នាំថវិកា២០១៤ (តារាង គ.១៧)។

**តារាង គ.១៧÷ សមាសធាតុនៃព័ត៌មានដែលចាំបាច់សម្រាប់សាធារណជន**

| សមាសធាតុនៃព័ត៌មាន | ការបំពេញតាមលក្ខខណ្ឌ | កំណត់ចំណាំ |
|---|---|---|
| **១) ឯកសារថវិកាប្រចាំឆ្នាំ÷** សំណុំឯកសារពេញលេញអាចរកបានដោយសាធារណជនតាមរយៈមធ្យោបាយ សមស្រប នៅមុនពេលដែលឯកសារនេះត្រូវបានបញ្ជូនទៅកាន់អង្គនីតិប្បញ្ញត្តិ | មិនបាន | ឯកសារថវិកាត្រូវបានបោះផ្សាយ ប៉ុន្តែបន្ទាប់ពីច្បាប់ថវិកាត្រូវបានអនុម័ត។ ក្នុងសម័យប្រជុំរបស់រដ្ឋសភាក្នុងខែវិច្ឆិកា/ធ្នូ ឆ្នាំ២០១៤ សេចក្តីព្រាងច្បាប់ថវិកាដែលត្រូវបានការពារដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះមុខនឹងអង្គនីតិ-ប្បញ្ញត្តិ ត្រូវបានបើកទូលាយសម្រាប់អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសារព័ត៌មាន |
| **២) របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ÷** របាយការណ៍ទាំងនេះ ត្រូវបានផ្សព្វផ្សាយជាប្រចាំតាមរយៈមធ្យោបាយសមស្រប សម្រាប់ សាធារណជននៅក្នុងរយៈពេលមួយខែ បន្ទាប់ពីបានរៀបចំបញ្ចប់ | មិនបាន | របាយការណ៍អនុវត្តថវិកាប្រចាំខែ គឺផ្អែកលើទម្រង់ TOFE និងបានបោះផ្សាយក្រោយរយៈពេល២ខែបន្ទាប់ពីរបាយការណ៍ត្រូវបានរៀបចំបញ្ចប់[19]។ ការរៀបចំរបាយការណ៍នេះ ត្រូវចំណាយពេលពី ២ ទៅ ៤សប្តាហ៍ (យោងសូចនាករសមិទ្ធកម្មទី២៤) ដើម្បីធ្វើការបោះផ្សាយ តែបានពន្យារពេលរហូតច្រើនជាង ១ខែបន្ទាប់ពីរបាយការណ៍ត្រូវបានរៀបចំបញ្ចប់ |
| **៣) របាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ÷** របាយការណ៍ទាំងនោះ បានផ្សព្វផ្សាយជាប្រចាំតាមរយៈមធ្យោបាយសមស្រប សម្រាប់ សាធារណជនបន្ទាប់ពីត្រូវបានធ្វើសវនកម្មចប់សព្វគ្រប់ | មិនបាន | របាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ ត្រូវបានបោះផ្សាយ (យោង ច្បាប់ទូទាត់ថវិកា) ប៉ុន្តែក៏មានការពន្យារពេលផងដែរ។ របាយ-ការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំថវិកា២០១៣ មានភាពគ្រប់ជ្រុងជ្រោយ និងត្រូវបានធ្វើសវនកម្មនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ប៉ុន្តែមិនទាន់ត្រូវបានបោះផ្សាយនៅឡើយ បើគិតត្រឹមថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ |
| **៤) របាយការណ៍សវនកម្មពីខាងក្រៅ÷** គ្រប់របាយការណ៍សរុបស្តីពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ | មិនបាន | របាយការណ៍សវនកម្មចុងក្រោយ ត្រូវបានរៀបចំដោយបូកសរុបការអនុវត្តថវិកាសម្រាប់ឆ្នាំថវិកា២០១៣ និ |

[19] ជាឧទាហរណ៍ ក្នុងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ របាយការណ៍ចុងក្រោយបានបញ្ចូលទៅក្នុងគេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយក្នុងខែមេសា ឆ្នាំ២០១៥ និងរបាយការណ៍ថ្ងៃទី០៨ ខែកញ្ញា ចុងក្រោយទៀត បានបញ្ចូលក្នុងខែឧសភា ឆ្នាំ២០១៥។ ជាងនេះទៅទៀត សេចក្តីព្រាងអង្កេតតម្លាភាពថវិកាឆ្នាំ២០១៥ សម្រាប់កម្ពុជាមានបង្ហាញថា របាយការណ៍ក្នុងឆ្នាំបានបោះផ្សាយលើសពី៣ខែបន្ទាប់ពីបានបញ្ចប់របាយការណ៍ចុងឆ្នាំ យោង ព័ត៌មានដែលទទួលបានពីអង្គការវេទិកា NGO។

| សមាសធាតុនៃព័ត៌មាន | ការបំពេញតាមលក្ខខណ្ឌ | កំណត់ចំណាំ |
|---|---|---|
| រដ្ឋបាលថ្នាក់កណ្ដាលបានផ្សព្វផ្សាយជាប្រចាំតាមរយៈមធ្យោបាយសមស្រប សម្រាប់សាធារណជននៅក្នុងរង្វង់ប្រាំមួយខែ បន្ទាប់ពីត្រូវបានធ្វើសវនកម្មចប់សព្វគ្រប់ | | ងត្រូវបានបញ្ចប់ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ របាយការណ៍នេះនៅមិនទាន់បានបោះផ្សាយនៅឡើយ ពោលគឺលើសពី៦ខែ បន្ទាប់បញ្ចប់របាយការណ៍។ |
| **៥) ការផ្ដល់កិច្ចសន្យា÷** ការផ្ដល់កិច្ចសន្យាទាំងអស់ ដែលមានតម្លៃលើសពី ១០០ ០០០ ដុល្លារអាមេរិក ត្រូវបានផ្សព្វផ្សាយយ៉ាងហោចណាស់ប្រចាំត្រីមាស តាមរយៈមធ្យោបាយសមស្រប | មិនត្រូវបានបំពេញ | មិនមានបោះផ្សាយ |
| **៦) ធនធានដែលមានសម្រាប់ អង្គភាពផ្ដល់សេវាមូលដ្ឋាន (primary service units)÷** ព័ត៌មានសម្រាប់អង្គភាពផ្ដល់សេវាមូលដ្ឋាន ដែលគ្របដណ្ដប់ទូទាំងប្រទេស ក្នុងវិស័យពីរយ៉ាងតិច (ដូចជា សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ត្រូវបានផ្សព្វផ្សាយ តាមរយៈមធ្យោបាយសមស្របយ៉ាងហោចណាស់ប្រចាំឆ្នាំ ឬផ្ដល់ជូនតាមសំណើ | មិនត្រូវបានបំពេញ | ព័ត៌មានអំពីប្រភពធនធាន ត្រូវបានបង្ហាញលើផ្ទាំងព័ត៌មានរបស់សាលានីមួយៗ ប៉ុន្តែ តែងតែពុំមានភាពពេញលេញ។ ព័ត៌មានអំពីធនធានដែលមាន មិនត្រូវបានផ្ដល់ជូនសាធារណជន។ |

ដូចមានក្នុងតារាង ត.១៧ សមាសធាតុសំខាន់ ៤ នៃព័ត៌មានថវិកា កំពុងត្រូវបានផ្សព្វផ្សាយ ប៉ុន្តែមានការពន្យារពេលយូរលើសពីលក្ខខណ្ឌកំណត់សម្រាប់ការដាក់ពិន្ទុ។ ដូចនេះ សូចនាករនេះទទួលបានពិន្ទុ D។ ដើម្បីបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យមានភាពទាន់ពេលវេលា សម្រាប់យ៉ាងហោចណាច់មួយសមាសធាតុខាងលើ ដោយគួរផ្ដោតការយកចិត្តទុកដាក់ជាពិសេស លើរបាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ។

**តារាង ត.១៨÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១០**

| សូចនាករ | សមាសធាតុ/ មធ្យោបាយវាយតម្លៃ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-10 | **លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ (M1)** | C | D | ពុំមានលក្ខខណ្ឌណាមួយ ក្នុងចំណោម ៦ ខាងលើ ត្រូវបានបំពេញឡើយ។ ទោះបីជាមានឯកសារចំនួន ៤ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក៏មានការយឺតយ៉ាវក្នុងការផ្សព្វផ្សាយដែរ។ |

**ប្រអប់ គ.៩ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

រាជរដ្ឋាភិបាលបានចាប់ផ្តើមរៀបចំ "ថវិកាពលរដ្ឋ" ដែលជាសេចក្តីសង្ខេបនៃច្បាប់ថវិកាដែលបានអនុម័ត។ ថវិកាសង្ខេបសម្រាប់ឆ្នាំ២០១៥ ត្រូវបានបោះផ្សាយក្នុងគេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងខែមីនា ឆ្នាំ២០១៥។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានឆ្លើយនឹងសំណួររបស់អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសារព័ត៌មាន នៅក្នុងវេទិកាសាធារណៈ កាលពីខែឧសភា ឆ្នាំ២០១៥ និងបានបង្ហាញជាសង្ខេបពីកិច្ចដំណើរការរៀបចំថវិកាឆ្នាំ២០១៦។

# គ.៣ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

## គ.៣.១ កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ (PI-11)

សូចនាករនេះមានគោលបំណងវាយតម្លៃអំពីភាពរៀបរយ ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយ នៃកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ក៏ដូចជាការចូលរួមរបស់ក្រសួង-ស្ថាប័ន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព[20]។

### (១) អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានចែង និងកំណត់ពីកាលវិភាគនៃការរៀបចំថវិកា ដូចខាងក្រោម÷

*-ដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកា (មីនា-ឧសភា)*

នៅក្នុងសប្តាហ៍ទី១ នៃខែមីនា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ផ្តើមរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងគោលនយោបាយថវិកា ឱ្យមានសង្គតិភាពទៅនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល (គណៈរដ្ឋមន្ត្រី) ពិនិត្យ និងអនុម័ត។ ដោយឡែក នៅក្នុងសប្តាហ៍ទី១ នៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរទៅគ្រប់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ដែលណែនាំអំពីការរៀបចំផែនការយុទ្ធ-សាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងគោលនយោបាយថវិកា ដែលបានអនុម័តដោយរាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រថវិកាត្រូវបង្ហាញពីការផ្សារភ្ជាប់រវាងចំណាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងត្រូវបញ្ចូលចំណាយមូលធន (ព្រមទាំង ឆ្លុះបញ្ចាំងគម្រោងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍)។ ទន្ទឹមនេះ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គួរតែត្រូវបានសម្របសម្រួលដោយក្រុមការងារកែទម្រង់អន្តរនាយកដ្ឋាន ហើយកាលបរិច្ឆេទសម្រាប់ផ្តល់ផែនការយុទ្ធសាស្ត្រថវិកា គឺនៅពាក់កណ្តាលខែឧសភា មានន័យថាក្រសួង-ស្ថាប័នមានពេលប្រមាណ ៦ សប្តាហ៍ សម្រាប់ការរៀបចំ។

[20] នាយកដ្ឋាន និងអង្គភាពដែលទទួលបានធនធានតាមរយៈក្រសួង-ស្ថាប័នសាមី មិនត្រូវបានចាត់ចូលសម្រាប់ការវាយតម្លៃទេ លើកលែងតែអង្គភាពដែលមានការពាក់ព័ន្ធផ្ទាល់សម្រាប់ការអនុវត្តថវិកា ឬទទួលបានធនធានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

*- ដំណាក់កាលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ (មិថុនា-កញ្ញា)*

នៅក្នុងសប្តាហ៍ទី១ នៃខែមិថុនា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសេចក្តីព្រាងសារាចរណែនាំស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ ដោយរួមមានទាំងទម្រង់ស្តង់ដារ និងសេចក្តីពន្យល់។ សារាចរណែនាំ ត្រូវដាក់ជូនរាជរដ្ឋាភិបាលដើម្បីអនុម័ត និងផ្ញើទៅគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។ តាមគោលការណ៍ច្បាប់ គម្រោងថវិកាត្រូវតែផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅត្រឹមថ្ងៃទី១៥ ខែកក្កដា[21] នៃឆ្នាំនីមួយៗ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គម្រោងថវិកា នៃក្រសួង-ស្ថាប័នមួយចំនួន ត្រូវផ្ញើជូននៅដំណាច់ខែកក្កដា។ ក្នុងអំឡុងខែសីហា ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញជុំវិញរាជធានី-ខេត្ត ចាំបាច់ត្រូវពិភាក្សាកញ្ចប់ថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីមានការឯកភាព និងការស្រុះស្រួលគ្នា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ នៅក្នុងអំឡុងខែកញ្ញា។

*- ដំណាក់កាលអនុម័តថវិកា (តុលា-ធ្នូ)*

នៅក្នុងសប្តាហ៍ទី១ នៃខែតុលា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់ថវិកាទៅគណៈរដ្ឋមន្ត្រី ដើម្បីត្រួតពិនិត្យ និងអនុម័ត និងដើម្បីដាក់ជូនទៅរដ្ឋសភាក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ត្រួតពិនិត្យ និងអនុម័ត។ បន្ទាប់មក សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅព្រឹទ្ធសភា នៅក្នុងសប្តាហ៍ទី១ នៃខែធ្នូ សម្រាប់ត្រួតពិនិត្យ និងអនុម័ត ដែលនឹងត្រូវបានអនុម័តនៅមុនដំណាច់ឆ្នាំ។ កាលវិភាគ នៃការរៀបចំថវិកាឆ្នាំ២០១៥ ត្រូវបានបង្ហាញក្នុងតារាង គ.១៩។

**តារាង គ.១៩÷ កាលវិភាគថវិកា ផ្អែកតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
និងកាលបរិច្ឆេទជាក់ស្តែង នៃការរៀបចំថវិកា នៅក្នុងឆ្នាំ២០១៤**

| ដំណាក់កាលនៃការរៀបចំថវិកា | កាលវិភាគច្បាប់ហិរញ្ញវត្ថុ | កាលបរិច្ឆេទជាក់ស្តែង នៃការរៀបចំថវិកាឆ្នាំ២០១៥ |
|---|---|---|
| កសហវ. ផ្ញើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័ត | សប្តាហ៍ទី១ នៃខែមីនា | |
| កសហវ. ផ្ញើសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ទៅក្រសួង-ស្ថាប័ន | សប្តាហ៍ទី១ នៃខែមេសា | ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ |
| កាលកំណត់នៃការផ្ញើផែនការយុទ្ធសាស្ត្រថវិកាមក កសហវ. | ថ្ងៃទី១៥ ខែឧសភា | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ |
| កសហវ. រៀបចំសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីពិនិត្យ និងអនុម័ត និងផ្ញើជូនគ្រប់ក្រសួង-ស្ថាប័ន/អង្គភាពថវិកា | សប្តាហ៍ទី១ នៃខែមិថុនា | ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ |

[21] ក្រសួងសាធារណៈការនិងដឹកជញ្ជូន បានលើកឡើងពីបញ្ហាក្នុងការទទួលបានធាតុចូលទាន់ពេលវេលាពីមន្ទីរដែលនាំឱ្យមានការយឺតក្នុងការផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

| **ដំណាក់កាលនៃការរៀបចំថវិកា** | **កាលវិភាគច្បាប់ហិរញ្ញវត្ថុ** | **កាលបរិច្ឆេទជាក់ស្តែង នៃការរៀបចំថវិកាឆ្នាំ២០១៥** |
|---|---|---|
| ក្រសួង-ស្ថាប័នផ្ញើសំណើថវិកាមក កសហវ. | ផុតកំណត់ត្រឹមថ្ងៃទី១៥ ខែកក្កដា | ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ |
| កសហវ. រៀបចំកិច្ចប្រជុំពិភាក្សាលើសំណើកញ្ចប់ថវិកាជាមួយគ្រប់ក្រសួង-ស្ថាប័ន (កម្រិតបច្ចេកទេស) | ខែសីហា | |
| កសហវ. រៀបចំសេចក្តីព្រាងច្បាប់ថវិកា ដោយបញ្ចូលទាំងចំណូល និងចំណាយ (រួមទាំងកិច្ចពិភាក្សាកម្រិតនយោបាយ) | ខែកញ្ញា | |
| កសហវ. ផ្ញើសេចក្តីព្រាងច្បាប់ថវិកាទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងអនុម័ត | សប្តាហ៍ទី១ នៃខែតុលា | |
| កសហវ. ផ្ញើសេចក្តីព្រាងច្បាប់ថវិកាដែលទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី ទៅរដ្ឋសភា ដើម្បីពិនិត្យ និងអនុម័ត | សប្តាហ៍ទី១ នៃខែវិច្ឆិកា | ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ |
| រដ្ឋសភា ផ្ញើសេចក្តីព្រាងច្បាប់ដែលត្រូវបានអនុម័តទៅព្រឹទ្ធសភា | សប្តាហ៍ទី១ នៃខែធ្នូ | ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ |
| ច្បាប់ថវិកាត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា | ត្រឹមថ្ងៃទី២៥ ខែធ្នូ | ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ |
| ព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើច្បាប់ថវិកា | ត្រឹមថ្ងៃទី១ ខែមករា | ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ |

ប្រភព÷ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨, ច្បាប់ថវិកាឆ្នាំ២០១៥ សារាចរស្តីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៥

សូចនាករនេះទទួលបានពិន្ទុ A ដោយហេតុថាមានកាលវិភាគថវិកាច្បាស់លាស់ និងជាទូទៅ ត្រូវបានអនុវត្តតាម។ កាលវិភាគនេះផ្តល់ជូនក្រសួង-ស្ថាប័ន រយៈពេលច្រើនជាង ៦សប្តាហ៍ សម្រាប់ការរៀបចំសំណើថវិកា។

**(២) ភាពច្បាស់លាស់/ភាពគ្រប់ជ្រុងជ្រោយ និងការចូលរួមផ្នែកនយោបាយ ក្នុងការណែនាំអំពីការរៀបចំសំណើថវិកា**

ដូចមានពន្យល់ខាងលើ ក្រសួង-ស្ថាប័នត្រូវរៀបចំសំណើជា ២ ដំណាក់កាល គឺដំណាក់កាលទី១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងទី២ ការរៀបចំសំណើថវិកាលម្អិតប្រចាំឆ្នាំ។

ទម្រង់ស្តង់ដារសម្រាប់ណែនាំការរៀបចំផែនការយុទ្ធសាស្ត្រថវិកាមាន ៤ សមាសធាតុធំៗ÷ (១) តួនាទី និងការទទួលខុសត្រូវរបស់សាមីក្រសួង-ស្ថាប័ន (២) គោលបំណងគោលនយោបាយ (៣) កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ដែលមានសង្គតិភាពជាមួយគោលបំណងគោលនយោបាយ និងដែលបង្ហាញពីតម្រូវការធនធាន សម្រាប់រយៈពេល ០៣ឆ្នាំបន្ទាប់ ដោយចែកចេញជាចំណាយបៀវត្ស, មិនមែនបៀវត្ស, ចំណាយចរន្ត និងមូលធន និងដាក់បញ្ចូលគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ (១ជួរ សម្រាប់ ១ប្រភេទចំណាយ) និងការព្យាករណ៍ប្រភពចំណូល

ដោយខ្លួនឯង (ដាក់បញ្ចូលទាំងដៃគូអភិវឌ្ឍន៍) និងយុទ្ធសាស្ត្រពង្រឹងការប្រមូលចំណូល និង (៥) សូចនាករសមិទ្ធកម្ម និងគោលដៅសម្រាប់កម្មវិធីនិងយុទ្ធសាស្ត្រអាទិភាពនីមួយៗ។

ឯកសារណែនាំអមដោយទម្រង់មួយចំនួនដែលត្រូវបំពេញ ជាគោលការណ៍ណែនាំសម្រាប់ការរៀបចំថវិកាលម្អិតប្រចាំឆ្នាំ ត្រូវបានផ្ញើទៅក្រសួង-ស្ថាប័ន។ ពិដានសម្រាប់ចំណាយសរុប ត្រូវបានកំណត់ ដោយបញ្ជាក់ជាភាគរយនៃផលិតផលក្នុងស្រុកសរុប (ថវិកាចរន្ត និងថវិកាមូលធន ត្រូវបានកំណត់ដាច់ពីគ្នា)។ ពិដានថវិកា ត្រូវបានកំណត់ក្នុងវិស័យចំនួន ៤ (សង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាលទូទៅ និងការពារជាតិនិងសន្តិសុខសាធារណៈ) ប៉ុន្តែការកំណត់ពិដាននេះមានភាពទន់ភ្លន់ និងមានលក្ខណៈជាចង្អុលបង្ហាញ ជាងការកំណត់បែបតឹងរ៉ឹង ដោយហេតុថាមូលដ្ឋាននៃការវិភាគពិដាន មិនទាន់ត្រូវបានកំណត់ឱ្យបានពេញលេញនៅឡើយ។ វិស័យអាទិភាពត្រូវបានបង្ហាញច្បាស់លាស់ (ឧទាហរណ៍ វិស័យអប់រំ និងសុខាភិបាល)។

មូលដ្ឋានចម្បងនៃការរៀបចំថវិកាប្រចាំឆ្នាំ ត្រូវផ្អែកលើការអនុវត្តថវិកាក្នុងឆ្នាំ និងត្រូវកែសម្រួលផ្អែកលើកម្រិតនៃការកើនឡើងនៃប្រាក់បៀវត្ស, ការជ្រើសរើសមន្ត្រីបន្ថែមជំនួសឱ្យមន្ត្រីចូលនិវត្តន៍, ការកែសម្រួលថវិកាក្នុងឆ្នាំ និងការប្រែប្រួលថ្លៃមួយចំនួនដែលមិនបានព្យាករណ៍។ ចំណាយចរន្តថេរ និងមិនមែនបៀវត្ស (ឧទាហរណ៍ ទឹក និងអគ្គិសនី) មិនអាចត្រូវបង្កើនឡើយ។ និយាយម្យ៉ាងទៀត មូលដ្ឋានសម្រាប់ការរៀបចំ គឺការបន្តនិរន្តរភាពនៃការផ្តល់សេវានាពេលបច្ចុប្បន្ន។

លើសពីនេះ ក្រសួង-ស្ថាប័នអាចស្នើថវិកាបន្ថែម សម្រាប់គាំទ្រដល់ចំណាយចរន្តបន្ថែម ដែលបានគ្រោងសកម្មភាពនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា (ចំណាយតាមកិច្ចលទ្ធកម្ម) រហូតដល់កម្រិតកំណត់មួយ ជាពិសេសសម្រាប់ក្រសួង-ស្ថាប័នដែលអនុវត្តក្របខ័ណ្ឌថវិកាកម្មវិធី។ ក្រសួង-ស្ថាប័ន ត្រូវការពាររាល់សំណើបន្ថែមមុខសញ្ញាចំណាយ នៅក្នុងកិច្ចពិភាក្សាកញ្ចប់ថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងខែសីហា។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថា សារាចរពាក់ព័ន្ធនឹងការរៀបចំថវិកាប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងភាពច្បាស់លាស់ (សម្រាប់ផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ) ត្រូវបានផ្ញើទៅគ្រប់ក្រសួង-ស្ថាប័ន ដោយឆ្លុះបញ្ចាំងពីពិដានដែលបានអនុម័តជាមុនដោយរាជរដ្ឋាភិបាល។

**(៣) ការអនុម័តថវិកាទាន់ពេលវេលាដោយអង្គនីតិប្បញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល**

រដ្ឋសភា និងព្រឹទ្ធសភា បានអនុម័តសេចក្តីព្រាងច្បាប់ថវិកា នៅមុនថ្ងៃទី២៥ ខែធ្នូ សម្រាប់រយៈពេល ០៣ឆ្នាំចុងក្រោយ គឺឆ្នាំ២០១២, ២០១៣ និង២០១៤។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថា ច្បាប់ថវិកាត្រូវបានអនុម័តនៅមុនការចាប់ផ្តើមនៃឆ្នាំអនុវត្តថវិកា នៅក្នុងអំឡុង ០៣ឆ្នាំសារពើពន្ធចុងក្រោយ។

## តារាង គ.២០ ÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១១

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-11 | **កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ** | A | A | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M2 |
| (១) | អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា | A | A | ក្រសួង-ស្ថាប័នមានរយៈពេល ៤ ទៅ ៥សប្តាហ៍ ក្នុងមួយដំណាក់កាល ដើម្បីរៀបចំថវិកាទាំងពីរដំណាក់កាល ពោលគឺសរុបប្រហែល ៩សប្តាហ៍។ ដំណាក់កាលទាំង២មានពិដានថវិកា (ទន់ភ្លន់) ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះ មានការពន្យាររយៈពេលខ្លីដោយក្រសួង-ស្ថាប័នមួយចំនួន តែមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ និងមិនមានអ្វីប៉ះពាល់ដល់ការអនុវត្តតាមកាលវិភាគឡើយ។ |
| (២) | ភាពច្បាស់លាស់/ភាពគ្រប់ជ្រុងជ្រោយ និងការចូលរួមផ្នែកនយោបាយ ក្នុងការណែនាំអំពីការរៀបចំដាក់សំណើថវិកា | A | A | សារាចរផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដោយផ្អែកលើការអនុម័តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការសើរើ និងការធ្វើអាទិភាវូបនីយកម្មឡើងវិញនូវគោលនយោបាយ។ សារាចររៀបចំកញ្ចប់ថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល និងផ្ញើជូនគ្រប់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត។ ការកំណត់ពិដានពីលើចុះក្រោម គឺកំណត់សម្រាប់ចំណាយសរុប (ថវិកាចរន្ត និងថវិកាមូលធន ត្រូវកំណត់ដាច់ពីគ្នា) និងសម្រាប់វិស័យទាំង ៤ (សង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាលទូទៅ និងការពារជាតិនិងសន្តិសុខសាធារណៈ) ជាភាគរយ នៃ ផ.ស.ស (ជាការចង្អុលបង្ហាញ)។ ការរៀបចំគម្រោងថវិកាលម្អិត ដោយក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ត្រូវផ្អែកលើ កម្រិតកំណើនធៀបនឹងឆ្នាំចាស់ ដែលអនុញ្ញាត សម្រាប់ចំណាត់ថ្នាក់សេដ្ឋកិច្ចនីមួយៗ។ |
| (៣) | ការអនុម័តថវិកាទាន់ពេលវេលា ដោយអង្គនីតិបញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល | A | A | ច្បាប់ថវិកាត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់ ៣ឆ្នាំសារពើពន្ធចុងក្រោយនេះ |

**ប្រអប់ គ.១០ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

មានបញ្ជាក់ក្នុងសមាសធាតុ ២ ប្រអប់ គ.១១។ ពុំមានរបាយការណ៍អំពីការកែទម្រង់ផ្សេងទៀតទេ។

## គ.៣.២ ទស្សនវិស័យពហុឆ្នាំនៅក្នុងការធ្វើផែនការថវិកា គោលនយោបាយចំណាយ និងការរៀបចំថវិកា (PI-12)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនៅក្នុងរយៈពេលមធ្យម និងកម្រិតនៃការដាក់បញ្ចូលការគណនាចំណាយ សម្រាប់ការអនុវត្តគោលនយោបាយថ្មី ទៅក្នុងដំណើរការរៀបចំថវិកា។

### (១) ការរៀបចំព្យាករណ៍ថវិកាពហុឆ្នាំ និងការវិភាជថវិកាតាមមុខងារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតកិច្ចដំណើរការព្យាករណ៍ថវិកាជាពីរអភិក្រម ដែលផ្តល់ធាតុចូលសំខាន់ក្នុងការរៀបចំថវិកាថ្នាក់ជាតិប្រចាំឆ្នាំ។ អភិក្រមទី១ គឺការរៀបចំ "ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា" រយៈពេល ៣ឆ្នាំរំកិល ដែលអនុញ្ញាតឱ្យអនុវត្តពីក្រោមទៅលើ និងត្រូវរៀបចំដោយអគ្គនាយកដ្ឋានថវិកា។ ធាតុចូលដែលចាំបាច់សម្រាប់ការវិភាគក្នុងអភិក្រមនេះ គឺព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិភាក្សាជាមួយគ្រប់ក្រសួង-ស្ថាប័ន និងព័ត៌មានអំពីតម្រូវការចំណាយ ដែលក្រសួង-ស្ថាប័នផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់រយៈពេល ២ឆ្នាំបន្ទាប់។ អភិក្រមទី២ គឺជាការតាមដានការអនុវត្តចំណូល-ចំណាយ ក៏ដូចជាការព្យាករណ៍កម្រិតចំណូល-ចំណាយ ដែលហៅថា "ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម"។ ការព្យាករណ៍ថវិកា ត្រូវធ្វើឡើងផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ច ពីលើចុះក្រោម, គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងនិន្នាការនៃចំណូល-ចំណាយ។ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ទទួលបន្ទុកការងារនេះ។ អភិក្រមទាំងពីរ ត្រូវរៀបចំសម្រាប់រយៈពេល ៣ឆ្នាំ និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំឆ្នាំ។ ទោះជាយ៉ាងនេះក្តី អភិក្រមទាំងពីរនេះ មិនត្រូវបានតភ្ជាប់គ្នាដោយផ្ទាល់នោះទេ។ ជាក់ស្តែង មានតែថវិកាសរុប ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមប៉ុណ្ណោះ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបានផ្តល់ជូនទៅក្រសួង-ស្ថាប័ន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាជាថ្មី។ យ៉ាងណាមិញ តួលេខព្យាករណ៍នៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យម គ្រាន់តែជាតួលេខចង្អុលបង្ហាញ ដែលមិនត្រូវបានអនុម័តក្នុងកម្រិតនយោបាយ និងមិនបានកំណត់កម្រិត ឬពិដានថវិកាជាផ្លូវការនោះទេ។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថា ការព្យាករណ៍ថវិការយៈពេល ៣ឆ្នាំ ត្រូវបានរៀបចំជាប្រចាំឆ្នាំ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចសំខាន់ៗ។ ដើម្បីបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យការព្យាករណ៍ត្រូវបានធ្វើលម្អិតទៅតាមចំណាត់ថ្នាក់វិស័យ មុខងារ និងរដ្ឋបាល និងត្រូវផ្តល់សេចក្តីពន្យល់នៃបម្រែបម្រួលទិន្នន័យប្រចាំឆ្នាំ។

### (២) វិសាលភាព និងភាពញឹកញាប់នៃការវិភាគនិរន្តរភាពបំណុល

ការវិភាគចីរភាពបំណុល ទាំងបំណុលបរទេស និងក្នុងស្រុក ត្រូវបានគ្រប់គ្រង និងអនុវត្តជាប្រចាំឆ្នាំ ដោយការិយាល័យគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានថវិកា ចាប់ឆ្នាំ២០១១។ យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុល ការត្រួតពិនិត្យបំណុល ត្រូវបានកំណត់ឱ្យអនុវត្តរៀងរាល់ ២ឆ្នាំម្តង ឯការអនុវត្តជាក់ស្តែងគឺត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ។ ការវិភាគបំណុល ត្រូវបានអនុវត្តផ្អែកលើបច្ចេកទេសដែលទទួលបានពីការបណ្តុះបណ្តាលដោយ

ស្ថាប័នរូបិយវត្ថុអន្តរជាតិ (IMF)។ លទ្ធផលនៃការវិភាគ ត្រូវយកទៅប្រៀបធៀប ជាមួយនឹងការត្រួតពិនិត្យការវិភាគចីរភាពបំណុល ដោយស្ថាប័នរូបិយវត្ថុអន្តរជាតិ IMF/IDA ដែលមានកំណត់ក្នុង ឯកសារពិគ្រោះយោបល់ ប្រចាំឆ្នាំរបស់ស្ថាប័នរូបិយវត្ថុអន្តរជាតិ “Annual Article IV Consultations” ហើយត្រូវរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន។ យោងតាមរបាយការណ៍របស់ស្ថាប័នរូបិយវត្ថុអន្តរជាតិ ការវិភាគចីរភាពបំណុលសម្រាប់បំណុលបរទេស និងក្នុងស្រុក ប្រើប្រាស់សម្មតិកម្មស្រដៀងនឹងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និងឯកភាពថា បញ្ហាបំណុលរបស់ប្រទេសកម្ពុជានៅតែមិនមានស្ថានភាពធ្ងន់ធ្ងរ នៅក្នុងសេណារីយ៉ូមូលដ្ឋាន។ អ្វីដែលខុសគ្នា គឺស្ថាប័នរូបិយវត្ថុអន្តរជាតិ បានដាក់បញ្ចូលបំណុលជំពាក់របស់សហព័ន្ធរុស្ស៊ី និងសហរដ្ឋអាមេរិក តាំងពីអំឡុងសម័យសង្គ្រាម ដែលកំពុងត្រូវបានចរចាលុបចោល។ មកដល់ពេលនេះ នៅមិនទាន់មានកិច្ចព្រមព្រៀងអ្វីច្បាស់លាស់ទេ សម្រាប់មរតកបំណុលទាំងពីរខាងលើ ប៉ុន្តែស្ថាប័នរូបិយវត្ថុអន្តរជាតិ បានកត់បញ្ចូលការប្រាក់ និងប្រាក់ពិន័យរបស់បំណុល រីឯរាជរដ្ឋាភិបាលបានបញ្ឈប់ការកត់ត្រាការប្រាក់បង្គរ និងប្រាក់ពិន័យ ដោយកត់ត្រាតែប្រាក់ដើមដែលជំពាក់ប៉ុណ្ណោះ។ ហេតុដូចនេះ ទើបស្ថាប័នរូបិយវត្ថុអន្តរជាតិបានរកឃើញថា បំណុលសរុបមានប្រហែល ២៨០ លានដុល្លារអាមេរិក ច្រើនជាងតួលេខរបស់រាជរដ្ឋាភិបាល។

សមាសធាតុនេះទទួលបានពិន្ទុ A ដោយហេតុថា ការវិភាគចីរភាពបំណុលប្រចាំឆ្នាំ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺគ្របដណ្តប់ទាំងបំណុលបរទេស និងក្នុងស្រុក។

**(៣) យុទ្ធសាស្ត្រតាមវិស័យ ដែលមានការគណនាចំណាយចរន្ត និងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ៥ឆ្នាំ (២០១៤-២០១៨) ដែលបន្តពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣។ ការរៀបចំផែនការនេះ ត្រូវបានសម្របសម្រួលដោយក្រសួងផែនការ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមមានធាតុសំខាន់ចំនួន ៤ ដោយធាតុនីមួយៗ មានសមាសធាតុ ៤ ព្រមទាំងមានកំណត់នូវបរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូលចំនួន ៤ ក្នុងនោះក៏មាន បរិស្ថានម៉ាក្រូសេដ្ឋកិច្ចផងដែរ។ ទំហំនៃការគណនាចំណាយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ត្រូវបានរៀបចំដាច់ដោយឡែកពីគ្នា សម្រាប់ចំណាយចរន្ត និងចំណាយមូលធន។ ជារួម ការគ្រោងចំណាយ ស្របតាមការព្យាករណ៍ថវិកា។ ទោះយ៉ាងនេះក្តី ចំណាយសម្រាប់ថវិកាចរន្ត ត្រូវបានបែងចែកលម្អិតសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ ដោយឡែកចំណាយ មូលធន ត្រូវបានកំណត់ទៅតាមសមាសធាតុ។ ដោយសារការបែងចែកនេះមានលក្ខណៈខុសគ្នា ការដាក់បញ្ចូលគ្នារវាងថវិកាចរន្ត និងមូលធន ទៅតាមក្រសួង-ស្ថាប័ន, តាមវិស័យ ឬតាមប្រភេទមុខងារ ពុំអាចធ្វើទៅបានឡើយ។ លើសពីនេះ ក៏មិនមានសេចក្តីពន្យល់ពីភាពប្រទាក់ក្រឡា នៃចំណាយតាមកម្មវិធី ឬអនុមុខងារ និងមិនមានពន្យល់ពីការផ្សារភ្ជាប់គ្នារវាងថវិកាចរន្តនិងមូលធនឡើយ។

យុទ្ធសាស្ត្រតាមវិស័យរយៈពេល ៥ឆ្នាំ ឬវែងជាងនេះ ត្រូវបានរៀបចំសម្រាប់វិស័យអប់រំ និងវិស័យសុខាភិបាល ដោយរួមបញ្ចូលការគណនាចំណាយទៅតាមសមាសធាតុ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) បានរំលេចការព្យាករណ៍ចំណាយចរន្ត និងមូលធន សម្រាប់អនុវិស័យ ឬកម្មវិធី (ឧទាហរណ៍ ការអប់រំ

មូលដ្ឋាន) រីឯការព្យាករណ៍ចំណាយចរន្ត ធ្វើឡើងផ្អែកលើចំនួនសិស្សដែលបានចុះឈ្មោះ និងការប៉ាន់ស្មានតម្លៃឯកតាចំណាយ។ ការព្យាករណ៍ មានសង្គតិភាពជាមួយនឹងការព្យាករណ៍ថវិការដ្ឋ និងបានផ្សារភ្ជាប់ជាមួយចំណាយប៉ាន់ប្រមាណសរុប ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ចំណាយសរុបក្នុងវិស័យអប់រំ មានប្រមាណ ១២,៤% នៃចំណាយសរុប ក្នុងថវិកាឆ្នាំ២០១៣ (មិនរាប់បញ្ចូលគម្រោងហិរញ្ញប្បទានគាំទ្រពីខាងក្រៅ)។

ក្នុងផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល (២០០៨-២០១៥) ការព្យាករណ៍ចំណាយ មានសង្គតិភាពជាមួយនឹងការព្យាករណ៍ចំណាយសរុប។ មានតែចំណាយចរន្តទេដែលត្រូវបានព្យាករណ៍ រីឯចំណាយមូលធននឹងត្រូវព្យាករណ៍នាពេលក្រោយប្រសិនបើកាលៈទេសៈតម្រូវ ពីព្រោះគេសន្មតថាហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ននៅអាចប្រើប្រាស់បាន។ ចំណាយសម្រាប់វិស័យសុខាភិបាលក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល មានប្រមាណ ១០,៥% នៃចំណាយសរុប ក្នុងថវិកាឆ្នាំ២០១៣ (មិនរាប់បញ្ចូលគម្រោងហិរញ្ញប្បទានគាំទ្រពីខាងក្រៅ) ។

សម្រាប់វិស័យដទៃទៀត (ក្រសួង-ស្ថាប័ន) មានការរៀបចំផែនការយុទ្ធសាស្ត្រអាទិភាព ៣ឆ្នាំ ដែលជាផ្នែកមួយនៃកិច្ចដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ប៉ុន្តែមិនមានការបង្ហាញថាផែនការយុទ្ធសាស្ត្រថវិកាមានបញ្ចូលចំណាយលម្អិត (ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាក់ស្តែង មានលក្ខណៈជាការគ្រោងយុទ្ធសាស្ត្រ និងសកម្មភាព) ឬមានសង្គតិភាពជាមួយនឹងការព្យាករណ៍ថវិកាសរុបរបស់រដ្ឋនោះឡើយ (ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាក់ស្តែង មិនមានពិដានកំណត់ច្បាស់លាស់ ឬមិនមានបំពេញបន្ថែមចំណាយឱ្យស្របជាមួយថវិកាសរុប)។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថា វិស័យអប់រំ និងវិស័យសុខាភិបាល (ក្នុងទំហំធំ) បានកំណត់ចំណាយយ៉ាងពេញលេញក្នុងផែនការយុទ្ធសាស្ត្រវិស័យ ដោយបានតម្រឹមជាមួយនឹងថវិកាសរុប (វិស័យទាំងពីរនេះ ស្មើនឹងប្រមាណ ២៣% នៃចំណាយសរុបរបស់រដ្ឋ)។ ដោយឡែក សម្រាប់វិស័យផ្សេងទៀតក៏មានផែនការ-យុទ្ធសាស្ត្រដែរ ប៉ុន្តែមិនមានការព្យាករណ៍ចំណាយច្បាស់លាស់ និងមិនមានសង្គតិភាពនឹងថវិកាសរុបឡើយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ចាំបាច់ត្រូវមានការគ្រោងចំណាយពេញលេញ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាសម្រាប់វិស័យ ដែលត្រូវគ្របដណ្តប់ចំណាយយ៉ាងហោចណាស់ប្រមាណច្រើនជាង ២៥% នៃចំណាយសរុបរដ្ឋ ហើយគម្រោងចំណាយត្រូវមានសង្គតិភាពជាមួយនឹងការព្យាករណ៍ថវិកាសរុប។

### (៤) ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគ និងការព្យាករណ៍ចំណាយរំកិល

ថវិកាចរន្ត និងមូលធន ត្រូវបានរៀបចំដាច់ដោយឡែកពីគ្នា និងនៅក្នុងទម្រង់ផ្សេងគ្នា។ ថវិកាវិនិយោគប្រមាណ ២៥% មានប្រភពពីចំណូលទូទៅរបស់រដ្ឋ (រួមបញ្ចូលទាំងការគាំទ្រថវិកាផ្ទាល់ ដោយហិរញ្ញប្បទានសហប្រតិបត្តិការ និងដោយកម្ចី តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ) ដោយឡែក ៧៥% ទៀត មានប្រភពពីហិរញ្ញប្បទានខាងក្រៅ (ហិរញ្ញប្បទានសហប្រតិបត្តិការ និងកម្ចី) ដែលមានកំណត់មុខសញ្ញាចំណាយសម្រាប់គម្រោងច្បាស់លាស់។ ទោះបីជាមានគម្រោងវិនិយោគមួយចំនួនទាមទារឱ្យបញ្ចូលរួមគ្នានូវប្រភពធនធានពីក្នុងស្រុក និងក្រៅស្រុក ប៉ុន្តែការរៀបចំថវិកាសម្រាប់គម្រោងក្រោមប្រភពថវិការដ្ឋ និងគម្រោងក្រោមហិរញ្ញប្បទានពីខាងក្រៅ ត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នានៅឡើយ។ ការជ្រើសរើសគម្រោង ត្រូវមើលថា តើជាគម្រោងកំពុងដំណើរការ ឬជាគម្រោងដែលស្ថិតក្នុងដំណាក់កាលរៀបចំផែនការ ហើយបើគម្រោងកំពុងស្ថិតក្នុងដំណាក់កាលរៀបចំផែនការ ត្រូវមើលទៀតថា

តើហិរញ្ញប្បទានត្រូវបានអនុម័តរួចរាល់សម្រាប់គម្រោង (ពីអង្គភាពខាងក្រៅ) ឬមិនទាន់ត្រូវបានកំណត់នៅឡើយ (យោងកម្មវិធីវិនិយោគសាធារណៈ ២០១៥-២០១៧ កថាខណ្ឌ ៣៧)។

ចំណាយចរន្តសម្រាប់ប្រតិបត្តិការ និងការថែទាំ ត្រូវបានគ្រោងក្នុងថវិការដ្ឋជារៀងរាល់ឆ្នាំ នៅពេលដែលគម្រោងវិនិយោគត្រូវបានបញ្ចប់ និងដែលទ្រព្យសកម្មចាំបាច់ត្រូវមានហិរញ្ញប្បទានសម្រាប់ប្រតិបត្តិការ និងការថែទាំ។ បើតាមអគ្គនាយកដ្ឋានថវិកា ហិរញ្ញប្បទានសម្រាប់ចំណាយនេះ ជាធម្មតាតែងតែមិនមានគ្រប់គ្រាន់ឡើយ ដោយសារការគាំទ្រហិរញ្ញប្បទានខាងក្រៅដែលបានកំណត់មុខសញ្ញា មិនអាចប្រើប្រាស់បានសម្រាប់ការងារប្រតិបត្តិការ និងថែទាំនោះទេ។ ដោយឡែក មានតែវិស័យផ្លូវថ្នល់ និងធារាសាស្ត្រប៉ុណ្ណោះ ដែលទទួលបានការគាំទ្រដោយថវិកាចរន្ត (ថវិការដ្ឋ) ជាពិសេស សម្រាប់ប្រតិបត្តិការ និងការថែទាំផ្លូវថ្នល់ រហូតដល់ឆ្នាំ២០១៤ ដែលត្រូវបានបញ្ចូលក្នុងចំណាយមិនទាន់បែងចែក ប៉ុន្តែជាក់ស្តែងបានកំណត់មុខសញ្ញារួចស្រាច់ទៅហើយសម្រាប់វិស័យទាំងពីរនេះ។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថាការសម្រេចចិត្តជ្រើសយកកម្មវិធីវិនិយោគនៅមិនទាន់ធ្វើឡើងដោយផ្អែកលើមូលដ្ឋានវិភាគគ្រប់ជ្រុងជ្រោយនៅឡើយ ដើម្បីឈានទៅផ្សារភ្ជាប់យុទ្ធសាស្ត្រតាមវិស័យ និងដោយហេតុថា បច្ច័យជាចំណាយចរន្តដើម្បីគាំទ្រគម្រោងវិនិយោគ មិនទាន់ត្រូវបានព្យាករណ៍នៅឡើយ លើកលែងតែក្នុងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ។

## តារាង គ.២១÷ ពិន្ទុសម្រាប់សូចនាករសមិទ្ធកម្មទី១២

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-12 | **ទស្សនៈវិស័យច្រើនឆ្នាំនៅក្នុងការធ្វើផែនការថវិកាគោលនយោបាយចំណាយនិងការរៀបចំថវិកា** | B | C+ | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M2 |
| (១) | ការរៀបចំនូវការព្យាករណ៍ថវិកាពហុឆ្នាំ និងការវិភាជតាមមុខងារ | C | C | ការព្យាករណ៍ថវិកាសរុបរយៈពេល៣ឆ្នាំ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយផ្អែកលើសមាសធាតុធំៗនៃសេដ្ឋកិច្ច។ ប៉ុន្តែមិនមានការញែកចេញជាចំណាត់ថ្នាក់វិស័យ មុខងារ ឬរដ្ឋបាល ហើយបម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំទៀតក៏មិនត្រូវបានពន្យល់លម្អិតឡើយ។ |
| (២) | វិសាលភាពនិងភាពញឹកញាប់នៃ ការវិភាគនិរន្តរភាពបំណុល | A | A | ការវិភាគចីរភាពបំណុលដែលគ្របដណ្តប់បំណុលបរទេស និងក្នុងស្រុក ត្រូវបានគ្រប់គ្រងនិងពិនិត្យជាប្រចាំឆ្នាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |
| (៣) | យុទ្ធសាស្ត្រតាមវិស័យដែលមាន ការគណនាចំណាយចរន្ត និងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ | B | C | វិស័យអប់រំ និងវិស័យសុខាភិបាលបានធ្វើការកំណត់ចំណាយយ៉ាងពេញលេញក្នុងផែនការយុទ្ធសាស្ត្រដោយបានតម្រឹមជាមួយនឹងថវិកាសរុប។ វិស័យទាំងពីរនេះស្មើនឹងប្រមាណ ២៣%នៃចំណាយអាទិភាពសរុប។ ដោយឡែក សម្រាប់វិស័យផ្សេងទៀតក៏មានផែនការយុទ្ធសាស្ត្រដែរ ប៉ុន្តែមិនមានការព្យាករណ៍ចំណាយច្បាស់លាស់ និងនៅមិនទាន់មានសង្គតិភាព។ |
| (៤) | ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគនិងការព្យាករណ៍ចំណាយរំកិល | C | C | ការសម្រេចចិត្តវិនិយោគ គឺធ្វើឡើងដោយផ្អែកលើប្រភពធនធានខាងក្រៅច្បាស់លាស់ ជាជាងការយកយុទ្ធសាស្ត្រវិស័យជាមូលដ្ឋាន។ បច្ច័យជាចំណាយចរន្តសម្រាប់អាទិភាពគម្រោងមិនបានដាក់បញ្ចូលជាធាតុផ្សំសំខាន់សម្រាប់ការជ្រើសរើស និងមានតែនៅក្នុងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ អមដោយថវិកាចរន្តសម្រាប់ប្រតិបត្តិការ និងការថែទាំ |

### ប្រអប់ គ.១១ ÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត

ថវិកាកម្មវិធី កំពុងត្រូវបានដាក់ឱ្យអនុវត្តជាបណ្តើរៗ ដែលនាពេលនេះ មានក្រសួងអនុវត្តថវិកាកម្មវិធីសាកល្បងចំនួន១០។ ភាគរយនៃគម្រោងថវិកា ដែលត្រូវបានរៀបចំតាមកម្មវិធី មានតែប្រមាណ ៣%ប៉ុណ្ណោះ គិតត្រឹមឆ្នាំ២០១៤ ប៉ុន្តែការរៀបចំថវិកាតាមកម្មវិធី កំពុងត្រូវបានពង្រីកគួរឱ្យកត់សម្គាល់ ទៅលើមុខសញ្ញាចំណាយជាច្រើនថែមទៀត។ សមត្ថភាពរៀបចំផែនការយុទ្ធសាស្ត្រថវិកាក៏កំពុងត្រូវបានពង្រឹងផងដែរ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រោងនឹងពង្រីកវិសាលភាពនៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ឱ្យគ្របដណ្តប់គ្រប់វិស័យ ដើម្បីជាមូលដ្ឋានវិភាជថវិកា។

## គ.៤ ភាពអាចប៉ាន់ប្រមាណបាននិងការត្រួតពិនិត្យការអនុវត្តថវិកា

### គ.៤.១ តម្លាភាពនៃកាតព្វកិច្ច និងបំណុលពន្ធ របស់អ្នកជាប់ពន្ធ (PI-13)

សូចនាករសមិទ្ធកម្មនេះមានគោលបំណងវាយតម្លៃរដ្ឋបាលចំណូល តាមរយៈការពិនិត្យលើភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃគោលការណ៍ច្បាប់និងនីតិវិធីរដ្ឋបាលពាក់ព័ន្ធនឹងបំណុលពន្ធ លទ្ធភាពដែលអ្នកជាប់ពន្ធអាចទទួលបានព័ត៌មាន និងលទ្ធភាពអ្នកជាប់ពន្ធអាចតវ៉ាចំពោះការមិនពេញចិត្តនូវការកំណត់ពន្ធ ដោយពិនិត្យមើលលើសមាសធាតុបីសំខាន់គឺ÷ (១) ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃគោលការណ៍ច្បាប់និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ (២) លទ្ធភាពអ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល និង (៣) ដំណើរការនៃការតវ៉ាពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីប្រមូលចំណូលពន្ធចូលថវិកាជាតិ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានតួនាទីប្រមូលពន្ធលើទំនិញនាំចូល និងអាករលើតម្លៃបន្ថែម (VAT) លើទំនិញនាំចូល។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏មានភារកិច្ចសម្របសម្រួល និងធ្វើការជាមួយជើងសាគយ ដែលជាអ្នកតំណាងឱ្យអ្នកនាំចូលទំនិញ និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ។ ជើងសាគយ គឺជាក្រុមហ៊ុនដែលទទួលបានការបណ្តុះបណ្តាល និងទទួលស្គាល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីផ្តល់សេវាកម្មបំពេញបែបបទបញ្ចេញទំនិញពីគយដោយផ្ទាល់ជាមួយរដ្ឋបាលគយក្នុងនាមអ្នកនាំទំនិញចូល។ ដើម្បីជួយសម្រួលការងារបញ្ចេញទំនិញពីគយ (Clearance) ជើងសាគយត្រូវរៀបចំដាក់ប្រតិវេទន៍គយ (lodge declaration) ដោយប្រើប្រាស់ឯកសាររដ្ឋបាលតែមួយ (Single Administrative Document) ដែលទាញចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយអាស៊ីគូដា (ASYCUDA)។ ប្រព័ន្ធទិន្នន័យមេ (main server) នៃប្រព័ន្ធអាស៊ីគូដាត្រូវបានដំឡើងនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានតភ្ជាប់ទៅការិយាល័យគយទូទាំងប្រទេស។

ដោយឡែក អគ្គនាយកដ្ឋានពន្ធដារមានតួនាទីប្រមូលពន្ធក្នុងស្រុកសំខាន់ៗ មានដូចជា ពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម (VAT) ក្នុងស្រុក និងពន្ធលើប្រាក់បៀវត្ស។ នៅក្នុងឆ្នាំ២០១៤ ចំណូលបានមកពីពន្ធធំដែលមានចំនួនប្រហែល ២០០០ សហគ្រាស ចូលរួមចំណែកប្រមាណ ៧៤% នៃចំណូលពន្ធដារសរុប។ គួរកត់សម្គាល់ថា មូលដ្ឋានប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារនៅមានកម្រិតទាបនៅឡើយ គឺមានចំនួនប្រហែលជា ៣០០០០ សហគ្រាស (សហគ្រាសខ្នាតមធ្យមនិងខ្នាតធំ) បានចុះបញ្ជីតាមរបបស្វ័យប្រកាស និង រួមចំណែក ៩៤% នៃចំណូលពន្ធដារសរុបក្នុងឆ្នាំ២០១៤[22]។ សហគ្រាសចំនួន ៦៥០០០ ទៀតត្រូវបានកំណត់ឱ្យបង់ចំណូលពន្ធតាមរបបម៉ៅការ។ គិតត្រឹមឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ មានទីស្នាក់ការធំមួយ និងសាខាពន្ធដារនៅខណ្ឌចំនួន ១២ នៃរាជធានីភ្នំពេញ និងនៅតាមខេត្តចំនួន២៤។

---

[22] ប្រភព÷ ការិយាល័យស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធដារ

### (១) ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃគោលការណ៍ច្បាប់និងនីតិវិធីរដ្ឋបាលស្ដីពីបំណុលពន្ធ

ច្បាប់ពន្ធមានចំនួន ២ សំខាន់ៗគឺ ច្បាប់ស្ដីពីសារពើពន្ធ និងច្បាប់ស្ដីពីគយ។ ច្បាប់ស្ដីពីសារពើពន្ធ (LOT) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅឆ្នាំ១៩៩៧ និងត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៣ ដែលចែងអំពីការប្រមូលពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម ពន្ធកាត់ទុក និងពន្ធប្រថាប់ត្រា។ នៅក្នុងឆ្នាំ២០១៣ អគ្គនាយកដ្ឋានពន្ធដារ បានចាប់ផ្ដើមត្រួតពិនិត្យច្បាប់ស្ដីពីសារពើពន្ធឡើងវិញ ដើម្បីបញ្ចូលពន្ធជាក់លាក់សម្រាប់សហគ្រាសក្នុងវិស័យរ៉ែ ប្រេងកាត និងឧស្ម័ន និងកែសម្រួលការប្រើពាក្យបច្ចេកទេសមួយចំនួន (ឧទាហរណ៍ និយមន័យនៃពាក្យ "ការស្នាក់នៅ", "ប្រសិទ្ធភាពការគ្រប់គ្រង", "សេវាកម្មបច្ចេកទេស" និង "អំពើរំលងស្ទះ")។ ជាមួយគ្នានេះ ក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនគណនេយ្យអន្តរជាតិធំៗទាំងបួន បានបញ្ជាក់ថា ច្បាប់ស្ដីពីសារពើពន្ធចែងអំពីអំពើរំលងស្ទះមានលក្ខណៈទូលំទូលាយពេក[23]។ ជារួម ការកែសម្រួលច្បាប់ស្ដីពីសារពើពន្ធ មានបំណងលុបបំបាត់ភាពមិនច្បាស់លាស់នៃក្របខ័ណ្ឌច្បាប់ កាត់បន្ថយជម្លោះ និងលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យអនុវត្តតាមច្បាប់ឱ្យបានត្រឹមត្រូវ។

ដោយឡែក ច្បាប់ស្ដីពីគយ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ បានកែសម្រួលគោលនយោបាយ និងគោលការណ៍មួយចំនួនដើម្បីបង្កើនចំណូល។ នៅឆ្នាំ២០១១ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចាប់ផ្ដើមអនុវត្តការកំណត់តម្លៃគិតពន្ធគយ (Valuation Agreement) បន្ថែមទៅនឹងប្រកាសស្ដីពីនីតិវិធីតវ៉ាការកំណត់ពន្ធគយ នៅឆ្នាំ២០១០ ព្រមទាំងអនុវត្តគោលការណ៍កំណត់តម្លៃគិតពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ពេញលេញ នៅខែកក្កដា ឆ្នាំ២០១៤។ លើសពីនេះទៅទៀត អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏មានតួនាទីដោយឡែក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចន្លោះពីឆ្នាំ២០១០ និង២០១២។ តួនាទីនេះរួមមានការត្រួតពិនិត្យលើបញ្ជីអ្នកវិនិយោគ ការត្រួតពិនិត្យនិងអនុម័តលើចលនាទំនិញពីចំណុចត្រួតពិនិត្យតាមព្រំដែនទៅតំបន់សេដ្ឋកិច្ចពិសេស និងត្រួតពិនិត្យនិងអនុម័តទំនិញដែលនាំចូល និងនាំចេញពីតំបន់សេដ្ឋកិច្ចពិសេស។

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បច្ចុប្បន្ន នៅមិនទាន់គ្រប់គ្រាន់នៅឡើយ និងមានបញ្ហាកង្វះចន្លោះផ្នែកតម្លាភាព។ ឧទាហរណ៍ ច្បាប់ស្ដីពីសារពើពន្ធមិនបានចែងពីកិច្ចព្រមព្រៀងចៀសវាងការយកពន្ធត្រួតស៊ីគ្នា (double tax agreement) និងមិនមានគោលការណ៍ចែងអំពីការផ្ទេរថ្លៃ (transfer pricing)។ ក្នុងន័យនេះ អគ្គ-នាយកដ្ឋានពន្ធដារមានសិទ្ធិក្នុងការបែងចែកប្រាក់ចំណូលដុល ប្រាក់ផាត់ចេញ ឬអត្ថប្រយោជន៍ ក្នុងចំណោមម្ចាស់កម្មសិទ្ធិនៅក្នុងសហគ្រាស ដើម្បីទប់ស្កាត់ការចៀសវាង ឬគេចវេសពន្ធ[24]។ ជាមួយគ្នានេះដែរ តារាងពន្ធគយមួយចំនួនត្រូវការកែសម្រួល ជាពិសេស ពន្ធអាករពិសេសលើទំនិញ ដូចជា បារី, ប្រេងឥន្ធនៈ និងពន្ធគិតតាមតម្លៃ

[23] KPMG (២០១៣) ឯកសារសង្ខេបពន្ធកម្ពុជា. មជ្ឈមណ្ឌលពន្ធអាស៊ីប៉ាស៊ីហ្វិក KPMG.

[24] Deloitte (២០១៥) កម្ពុជា÷ ផ្ដោតសំខាន់លើឆ្នាំ ២០១៥, ពន្ធអន្តរជាតិ

(Valorem rates[25])។ ប្រការនេះនាំឱ្យមានការជាប់ពាក់ព័ន្ធរបស់មន្ត្រីរដ្ឋបាលចំណូល ក្នុងការប្រើសិទ្ធិអំណាចបកស្រាយច្បាប់ពន្ធមួយចំនួន ស្របពេលដែលប្រព័ន្ធគ្រប់គ្រង, ប្រព័ន្ធដំណើរការ និងប្រព័ន្ធត្រួតពិនិត្យនៅមានភាពទន់ខ្សោយទន្ទឹមនឹងកង្វះចន្លោះព័ត៌មានផ្សព្វផ្សាយដល់អ្នកជាប់ពន្ធ[26]។ ជាមួយគ្នានេះដែរ សភាពាណិជ្ជកម្មកម្ពុជាក៏បានបង្ហាញជំហរយល់ស្រប ដោយបានលើកជាឧទាហរណ៍បញ្ជាក់ថា បំណុលពន្ធដែលមិនទាន់បានទូទាត់ពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រាលើការផ្ទេរអចលនទ្រព្យ ត្រូវបានផ្ទេរបំណុលពន្ធទាំងស្រុងពីម្ចាស់ដើមអចលនទ្រព្យ (អាចមានចំនួនច្រើនលក់តគ្នា) ទៅអ្នកទិញចុងក្រោយដែលមានបំណងបង់ពន្ធត្រឹមត្រូវ។ ការអនុវត្តបែបនេះត្រូវបានបញ្ជាក់ថាមិនយុត្តិធម៌សម្រាប់អ្នកទិញចុងក្រោយឡើយ។

សូចនាករសមិទ្ធកម្មនេះ ត្រូវបានផ្ដល់ពិន្ទុ C ដោយហេតុថា ភាពគ្រប់ជ្រុងជ្រោយនិងភាពច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធនៅមានកម្រិត។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺតម្រូវឱ្យលិខិតបទដ្ឋានគតិ-យុត្តពាក់ព័ន្ធនឹងវិស័យពន្ធកាន់តែមានភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ហើយការប្រើប្រាស់សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលចំណូលក្នុងការសម្រេចចិត្ត ឬការបកស្រាយភាពមិនច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្តកាន់តែមានការថយចុះ ដើម្បីឱ្យក្របខ័ណ្ឌច្បាប់មានតម្លាភាព និងយុត្តិធម៌ (ឧទាហរណ៍ ពន្ធលើប្រាក់ចំណេញ, អាករលើតម្លៃបន្ថែម និងពន្ធគយ)។

**(២) លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបានទូវព័ត៌មានស្ដីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល**

អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានគេហទំព័រផ្ទាល់ខ្លួនសម្រាប់ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធបទប្បញ្ញត្តិពន្ធដែលមានដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ សេចក្ដីជូនដំណឹង និងនីតិវិធីរដ្ឋបាលជាភាសាខ្មែរ និង/ឬភាសាអង់គ្លេស[27]។ អគ្គនាយកដ្ឋានទាំងពីរក៏បានរៀបចំព័ត៌មានសង្ខេបអំពីពន្ធដែលបញ្ជាក់ពីអត្រាពន្ធដារ និងពន្ធគយ។

អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាច្រើនទូទាំងប្រទេស ហើយសិក្ខាសាលាដែលបានរៀបចំជាច្រើននាពេលថ្មីៗនេះ មានដូចជាការផ្សព្វផ្សាយពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់ចំណេញតាមវិស័យ។ អគ្គនាយកដ្ឋានពន្ធដារ ក៏បានបង្កើតឧបករណ៍ប្រើប្រាស់តាមរយៈទូរស័ព្ទឆ្លាតវៃ (smartphone) មានដូចជា ប្រតិទិនពន្ធនិងការណែនាំការបង់ពន្ធចំពោះពន្ធលើប្រាក់បៀវត្ស និងពន្ធលើមធ្យោបាយដឹកជញ្ជូន និងបានរៀបចំកូនសៀវភៅណែនាំស្ដីពីពន្ធប៉ាតង់ ពន្ធកាត់ទុក ពន្ធលើអចលនទ្រព្យ និងពន្ធលើប្រាក់ចំណេញ។ លើសពីនេះទៀត "ក្រុមការងារបច្ចេកទេសវិស័យឯកជន" ក៏ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលការជជែកពិភាក្សាជាមួយមន្ត្រី

---

[25] អគ្គនាយកដ្ឋានពន្ធដារ (២០១២) កម្ពុជា, បញ្ហាកែទម្រង់ចំណូលពន្ធ, ការកែទម្រង់បន្តទៀត. ធ្វើបទបង្ហាញដោយ លោក អ៊ុំ សីហា (Um Seyha) នៅក្នុងសន្និសិទ្ធពន្ធ របស់ IMF សម្រាប់បណ្ដាប្រទេសអាស៊ី និងប៉ាស៊ីហ្វិក

[26] អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (២០១៣) កម្ពុជា÷ ២០១២ របាយការណ៍ប្រឹក្សាយោបល់មាត្រា ៤. របាយការណ៍តាមប្រទេសរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ លេខ ១៣/២

[27] សូមមើលគេហទំព័រ www.customs.gov.kh និង www.tax.gov.kh (ទាញយកទិន្នន័យនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៥)

ពន្ធ អំពីការងារបច្ចេកទេសពន្ធ។ នៅក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានបានបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានពន្ធនៅរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានមូលដ្ឋានអំពីពន្ធដល់អ្នកជាប់ពន្ធ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបង្កើតយន្តការភាពជាដៃគូគយនិងវិស័យឯកជន (Custom Private Sector Partnership Mechanism (CPPM)) តាមរយៈប្រកាសលេខ ៩០៦ សហវ.ប្រក ខែតុលា ឆ្នាំ ២០០៩ ដែលជាវេទិកាមួយត្រូវបានបង្កើតឡើងក្រោមវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ដែលមាននាយករដ្ឋមន្ត្រីជាប្រធាន។ យន្តការភាពជាដៃគូគយនិងវិស័យឯកជនបានកំណត់កិច្ចប្រជុំរៀងរាល់ឆ្នាំ ចាប់ផ្តើមពីខែមករា ឆ្នាំ២០១០មក ដែលមានអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងប្រធានប្រតិបត្តិរបស់សភាពាណិជ្ជកម្មកម្ពុជា ជាសហប្រធាន ដើម្បីជជែកពិភាក្សាអំពីនិតិវិធីគយ និងដោះស្រាយកង្វល់និងបញ្ហាប្រឈមដែលកំពុងកើតឡើងក្នុងការអនុវត្តនិតិវិធីគយ។ កិច្ចប្រជុំចុងក្រោយនៃយន្តការភាពជាដៃគូគយនិងវិស័យឯកជន ត្រូវបានធ្វើឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ចំណែកឯរបាយការណ៍នៃការពិភាក្សាក៏ត្រូវបានបោះពុម្ពផ្សព្វផ្សាយផងដែរ។ គួរកត់សម្គាល់ផងដែរថា ចាប់តាំងពីឆ្នាំ២០១៥ មក កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងជាញឹកញាប់។

ប៉ុន្តែសកម្មភាពដែលបានរៀបរាប់ខាងលើនេះ ភាគច្រើន ចាប់ផ្តើមនៅឆ្នាំ២០១៣ សម្រាប់អគ្គនាយក-ដ្ឋានពន្ធដារ ឧទាហរណ៍ សភាពាណិជ្ជកម្មកម្ពុជាបានលើកឡើងថា កិច្ចប្រជុំក្រុមការងារបច្ចេកទេសវិស័យឯកជនត្រូវបានរៀបចំឡើងតែម្តងគត់គឺនៅឆ្នាំ ២០១៤។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីកង្វះសមត្ថភាពមន្ត្រីរដ្ឋបាលចំណូល និងកង្វះថវិកា ដែលជាការរារាំងក្នុងការជួយពន្យល់ណែនាំអ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ចបង់ពន្ធ[28]។

សមាសធាតុនេះ ទទួលបានពិន្ទុ B ដោយហេតុថា មានព័ត៌មានជាច្រើនត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានវេទិកាជំរុញការជជែកពិភាក្សារវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺទាមទារឱ្យពង្រឹងសមត្ថភាពមន្ត្រីនិងរដ្ឋបាលចំណូល និងធានាថាមានធនធានថវិកាដើម្បីពង្រឹងសេវាពន្ធនិងដើម្បីអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយនិងទាន់ពេលវេលា (ឧទាហរណ៍ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយជាបន្តបន្ទាប់ជាដើម)។

### (៣) ដំណើរការនៃយន្តការតវ៉ាពន្ធ

ការតវ៉ាពន្ធគយកើតចេញពីការវាយតម្លៃពន្ធគយ, ការរឹបអូសទំនិញ និងការផាកពិន័យខ្ពស់លើសពីតម្លៃទំនិញដើមដែលនាំចូល ឬនាំចេញ។ ដំណើរការនៃយន្តការតវ៉ាពន្ធ ត្រូវបានកំណត់នៅក្នុងប្រកាសលេខ ៥៧០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០។ ក្នុងប្រកាសនោះបានចែងថា អ្នកនាំទំនិញចូល ឬជើងសាគយ ត្រូវរៀបចំបណ្តឹងតវ៉ាទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីការផាកពិន័យ ឬពីថ្ងៃទំនិញត្រូវបានឃាត់ទុក។ ក្នុងបណ្តឹងតវ៉ាត្រូវបញ្ជាក់ពីមូលហេតុ និងសេចក្តីសម្រេចរបស់អគ្គនាយក-

---

[28] អគ្គនាយកដ្ឋានពន្ធដារ (២០១២) កម្ពុជា, បញ្ហាកែទម្រង់ចំណូលពន្ធ, ការកែទម្រង់បន្តទៀត. ធ្វើបទបង្ហាញដោយ លោក អ៊ុំ សីហា (Um Seyha) នៅក្នុងសន្និសីទពន្ធ របស់ IMF សម្រាប់បណ្តាប្រទេសអាស៊ី និងប៉ាស៊ីហ្វិក

ដ្ឋានគយនិងរដ្ឋាករកម្ពុជា។ បន្ទាប់មក បណ្តឹងត្រូវបានពិនិត្យដោយការិយាល័យច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវធ្វើការឆ្លើយតបទៅនឹងបណ្តឹងក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្តឹង។ ក្នុងប្រកាសនោះ ក៏បានចែងផងដែរថា ប្រសិនបើមានការមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អ្នកនាំទំនិញចូល ឬជើងសាគយ មានសិទ្ធិតវ៉ាទៅអង្គភាពដទៃទៀត ឬទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីពាក្យបណ្តឹងខាងលើ។

ក្រុមការងារវាយតម្លៃ PEFA ពិបាកនឹងធ្វើការវាយតម្លៃពីកិច្ចដំណើរការយន្តការតវ៉ាពន្ធ របស់អគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាក់ស្តែង ក្រុមការងារវាយតម្លៃមិនបានទទួលទិន្នន័យអំពីចំនួនអ្នកតវ៉ាឡើយ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានគ្រោងជ្រើសរើសអ្នកច្បាប់ ដើម្បីសម្របសម្រួលផ្លូវច្បាប់ជាមួយអ្នកជាប់ពន្ធតាំងពីឆ្នាំ២០០៩ មកម្ល៉េះ ប៉ុន្តែរហូតមកដល់ពេលនេះ នៅមិនទាន់ជ្រើសរើសបាននៅឡើយ។ ការដោះស្រាយបណ្តឹងតវ៉ាពន្ធដោយមិនមានអ្នកជំនាញផ្នែកច្បាប់ អាចនឹងប៉ះពាល់ដល់សមត្ថភាពផ្នែកច្បាប់របស់អគ្គនាយកដ្ឋាន។

យន្តការដោះស្រាយបណ្តឹងតវ៉ារបស់អគ្គនាយកដ្ឋានពន្ធដារ គឺមិនមានការប្រែប្រួលពីការវាយតម្លៃ PEFA លើកមុនទេ។ ច្បាប់ស្តីពីសារពើពន្ធបានចែងថា អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធឡើងវិញ ឬសេចក្តីសម្រេចផ្សេងៗ អាចធ្វើការតវ៉ាទៅអគ្គនាយដ្ឋានពន្ធដារបាន។ ប្រសិនបើអ្នកជាប់ពន្ធនៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការសម្របសម្រួលសារពើពន្ធ។ ប្រសិនបើអ្នកជាប់ពន្ធនៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចថ្មីរបស់គណៈកម្មាធិការសម្របសម្រួលសារពើពន្ធ អ្នកជាប់ពន្ធមានសិទ្ធិប្តឹងជំទាស់នឹងសេចក្តីសម្រេចនេះទៅតុលាការដែលមានសមត្ថកិច្ច។ តាមការបញ្ជាក់របស់អគ្គនាយក-ដ្ឋានពន្ធដារ ក្នុងការអនុវត្តជាក់ស្តែង អ្នកជាប់ពន្ធមិនប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីដោះស្រាយទេ ដោយហេតុថាពួកគេត្រូវតែតម្កល់ប្រាក់ដែលត្រូវបង់ពន្ធគ្រប់ចំនួនជាមុន មុនធ្វើការដោះស្រាយ។

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានពន្ធដារ កំពុងតែកែលម្អយន្តការដោះស្រាយបណ្តឹងតវ៉ាឡើងវិញ ពោលគឺនឹងបង្កើតគណៈកម្មាធិការសម្របសម្រួលសារពើពន្ធដែលមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធ និងរៀបចំអនុក្រឹត្យដាក់ឱ្យដំណើរការគណៈកម្មាធិការនេះ ។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថាប្រព័ន្ធនិងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធមានចែងច្បាស់លាស់រួចហើយ ប៉ុន្តែដើម្បីទទួលបានពិន្ទុខ្ពស់ គឺប្រព័ន្ធនេះត្រូវដំណើរការពេញលេញតាមច្បាប់ជាធរមាន។

**តារាង គ.២២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៣**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-13 | **តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ** | B | C+ | វិធីសាស្ត្រវាយតម្លៃ M2 |
| (១) | ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយ នៃគោលការណ៍ច្បាប់ និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ | B | C | នៅមានកង្វះខាត÷ (១) លិខិតបទដ្ឋានគតិយុត្តពន្ធ ត្រូវរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ និង (២) ការប្រើប្រាស់សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាល |

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| | | | | ចំណូលក្នុងការសម្រេច ឬការបកស្រាយភាពមិនច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្តត្រូវមានការថយចុះ ដើម្បីឱ្យក្របខ័ណ្ឌច្បាប់មានតម្លាភាពនិងយុត្តិធម៌ (ឧទាហរណ៍ ពន្ធលើប្រាក់ចំណេញ, អាករលើតម្លៃបន្ថែម និងពន្ធគយ)។ |
| (២) | លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល | B | B | មានព័ត៌មានជាច្រើន ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានវេទិកាដែលជំរុញការជជែកពិភាក្សារវាងរដ្ឋាភិបាលនិងវិស័យឯកជន។ ប៉ុន្តែត្រូវពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលចំណូល និងធានាឱ្យមានធនធានថវិកាដើម្បីពង្រឹងសេវាពន្ធ និងអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយនិងងាយស្រួល, ទាន់ពេលវេលា (ឧទាហរណ៍ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយជាបន្តបន្ទាប់) |
| (៣) | ដំណើរការនៃយន្តការតវ៉ាពន្ធ | C | C | ប្រព័ន្ធនិងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធមានចែងច្បាស់លាស់រួចហើយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ប្រព័ន្ធនេះដំណើរការ មិនបានពេញលេញតាមច្បាប់ជាធរមាន។ |

### ប្រអប់ គ.១២ ÷ ការងារកែទម្រង់កំពុងអនុវត្ត

- ច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានកែតម្រូវ ត្រូវបានកំណត់ដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៥។ ប៉ុន្តែមានការកត់សម្គាល់ថាការដាក់ឱ្យអនុវត្តនឹងអាចត្រូវពន្យារពេល ដោយហេតុថាត្រូវការពេលវេលាពិភាក្សាបន្ថែមទៀត។ ទន្ទឹមនេះដែរ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាសស្តីពីពន្ធប្រថាប់ត្រា និងដំណើរការនៃយន្តការតវ៉ាពន្ធ ព្រមទាំងមានក្រុមការងារកែសម្រួលប្រកាសចំនួន ៦៤ កំពុងតែពិនិត្យលើផ្នែកពាក់ព័ន្ធនឹងការចុះបញ្ជីអ្នកជាប់ពន្ធ និងពន្ធប្រថាប់ត្រា។
- តាមរយៈយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នឹងដាក់ឱ្យអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្ម ចំពោះការប្រកាសពន្ធ និងការបញ្ជូនឯកសារអេឡិចត្រូនិចដែលកាត់បន្ថយការប្រើប្រាស់សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលចំណូល និងឱកាសឃុបឃិតគ្នា ព្រមទាំងពង្រឹងគុណភាពនៃសេវាសាធារណៈចំពោះអ្នកជាប់ពន្ធ និងការចែកចាយព័ត៌មានបានទូលំទូលាយ។
- នៅក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានពន្ធនៅរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានអំពីពន្ធដល់អ្នកជាប់ពន្ធ។
- ការរៀបចំម៉ូឌែល DTA ត្រូវបានបញ្ចប់ និងកំពុងតែចរចារជាមួយសមភាគី។
- ការកែទម្រង់ពន្ធរដ្ឋាករ (excise tax) នឹងត្រូវរៀបចំ ក្នុងពេលធ្វើវិសោធនកម្មច្បាប់សារពើពន្ធនាពេលខាងមុខ។ បច្ចុប្បន្ននេះ នាយកដ្ឋានពន្ធធំនៃអគ្គនាយកដ្ឋានពន្ធដារ បានបង្កើតការិយាល័យពន្ធរដ្ឋាករ ដើម្បីធ្វើការងារនេះ។

## គ.៤.២ ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ (PI-14)

សូចនាករសមិទ្ធកម្មនេះ មានគោលបំណងវាយតម្លៃលើប្រសិទ្ធភាពក្នុងការវាយតម្លៃពន្ធ ដោយធ្វើការពិនិត្យទៅលើប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃបំណុលពន្ធត្រឹមត្រូវដោយរដ្ឋបាលចំណូលទៅលើអ្នកជាប់ពន្ធ។ សូចនាករនេះ ពិនិត្យមើលលើសមាសធាតុបីសំខាន់គឺ (១) ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ (២) ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធនិងការប្រកាសពន្ធ និង (៣) ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ។ សមាសធាតុនីមួយៗត្រូវបានពិនិត្យ និងវាយតម្លៃដូចខាងក្រោម÷

### (១) ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម (២០០៥) និងច្បាប់ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម (១៩៩៥) បានចែងថាក្រុមហ៊ុនសហកម្មសិទ្ធិ, ការិយាល័យតំណាងឬសាខា និងក្រុមហ៊ុនឯកកម្មសិទ្ធិ ដែលមានទឹកប្រាក់ចាប់ពី ៤ ម៉ឺនលានរៀលឡើងទៅ និងមានទីតាំងនៅក្នុងប្រទេសកម្ពុជា ត្រូវចុះបញ្ជីពាណិជ្ជកម្ម និងបំពេញកាតព្វកិច្ចផ្លូវច្បាប់ជាធរមាន។

ពេលដែលក្រុមហ៊ុនស្នើសុំចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មនឹងបញ្ចូលព័ត៌មានក្រុមហ៊ុនទៅក្នុងប្រព័ន្ធទិន្នន័យ និងចេញលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មទៅឱ្យក្រុមហ៊ុនដែលបានស្នើសុំ។ បន្ទាប់មក ម្ចាស់ក្រុមហ៊ុនឬម្ចាស់អាជីវកម្ម ត្រូវបង្ហាញលិខិតនេះទៅសាខាពន្ធដារខណ្ឌដើម្បីបង់ប្រាក់លើការចុះបញ្ជីពន្ធ ចំនួន ១លានរៀល និងពន្ធប៉ាតង់ ចំនួន ១,១៤លានរៀល។ សាខាពន្ធដារខណ្ឌ បោះត្រាលើលិខិតចុះបញ្ជីពាណិជ្ជកម្ម ដើម្បីបញ្ជាក់ថាបានទទួលប្រាក់ចុះបញ្ជីពន្ធ និងចេញលិខិតបញ្ជាក់ពន្ធប៉ាតង់ទៅឱ្យក្រុមហ៊ុនឬម្ចាស់អាជីវកម្ម។ បន្ទាប់ពីបានបង់ប្រាក់ពន្ធនិងចុះបញ្ជីពន្ធបានត្រឹមត្រូវក្នុងរយៈពេល១៥ថ្ងៃ ក្រុមហ៊ុនឬអាជីវកម្មនោះ នឹងក្លាយទៅជាអ្នកជាប់ពន្ធតាមរបបពិត ហើយត្រូវតែស្នើសុំលេខអត្តសញ្ញាណកម្មអ្នកជាប់ពន្ធ (TIN)។ TIN មួយ ត្រូវបានប្រើប្រាស់សម្រាប់សម្គាល់សហគ្រាសដែលបានចុះបញ្ជីពន្ធតែមួយគត់។ TIN ក៏ត្រូវបានប្រើប្រាស់ ក្នុងឯកសាររដ្ឋបាលតែមួយ (SAD) របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ប្រើប្រាស់សម្រាប់ស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម (Tax Return) របស់អគ្គនាយកដ្ឋានពន្ធដារ និងតាមមាត្រា ១០២ នៃច្បាប់ស្តីពីសារពើពន្ធ គឺត្រូវប្រើប្រាស់សម្រាប់ “សម្គាល់សហគ្រាសក្នុងគ្រប់ឯកសារពាក់ព័ន្ធនឹងពន្ធ និងកិច្ចសន្យានានាជាមួយស្ថាប័នរដ្ឋ” ផងដែរ។

ប្រព័ន្ធចុះបញ្ជីពន្ធនៅមានកម្រិត ដោយហេតុថា ទី១-ប្រព័ន្ធចុះបញ្ជីបានផ្តោតសំខាន់តែលើអ្នកជាប់ពន្ធតាមរបបពិត។ ជាលទ្ធផល ព័ត៌មានអ្នកជាប់ពន្ធតាមរបបម៉ៅការទទួលបានមិនពេញលេញ ពីព្រោះរបបម៉ៅការត្រូវបានត្រួតពិនិត្យដោយសាខាពន្ធដារខេត្ត-ខណ្ឌ និងមិនតម្រូវឱ្យមាន TIN នោះទេ ដែលនេះអាចបង្កើតឱ្យមានឱកាសគេចវេសពន្ធ។ ទី២-តាមរយៈការធ្វើជំរឿនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១១ បានបង្ហាញថា មានសហគ្រាសចំនួន ៥០៥ ១៣៤ បានកំពុងប្រកបអាជីវកម្មនៅទូទាំងប្រទេស ប៉ុន្តែមានសហគ្រាសជាច្រើនកំពុងស្ថិតនៅក្រៅប្រព័ន្ធពន្ធដារ

ស្របពេលដែលសហគ្រាសចំនួនតែ ៩៥ ០០០ ត្រូវបានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ។ តាមការបញ្ជាក់របស់អគ្គនាយកដ្ឋានពន្ធដារ សហគ្រាសចំនួន ៥០៤ ១៣៤ ខាងលើ ត្រូវបានគេរាប់បញ្ចូលទាំងអ្នកលក់ដូរ នៅតាមចិញ្ចើមផ្លូវ និងវត្តអារាមផងដែរ ដូច្នេះហើយ ពិបាកក្នុងការរាប់បញ្ចូលថាតើមានចំនួនសហគ្រាសប៉ុន្មានដែលត្រូវចាត់បញ្ចូលទៅក្នុងរបបពិត។ ទី៣-អគ្គនាយកដ្ឋានពន្ធដារ មិនបានរៀបចំយុទ្ធនាការចុះបញ្ជីអ្នកជាប់ពន្ធ ឬក៏ធ្វើជំរឿនតាមផ្លូវដើម្បីកំណត់អ្នកជាប់ពន្ធមានសក្តានុពល។ ទី៤-ប្រព័ន្ធចុះបញ្ជីពន្ធអាចបង្កើតកំហុសឆ្គងពីការកត់ត្រាទិន្នន័យអ្នកជាប់ពន្ធ ហើយមានលំបាកក្នុងការត្រួតពិនិត្យពីភាពត្រឹមត្រូវ នៃព័ត៌មានដែលត្រូវបានបញ្ចូលដោយអគ្គនាយកដ្ឋានពន្ធដារ (ឧទាហរណ៍÷ ការពិនិត្យមើលតាមរយៈទូរស័ព្ទ និងការប្រើព័ត៌មានភាគីទីបីតាមរយៈវិក្កយបត្រ), និងពិបាកតាមដានអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសពន្ធ និង/ឬ លុបឈ្មោះក្រុមហ៊ុនដែលឈប់ដំណើរការចោល។ ទី៥-ការបែងចែកព័ត៌មានអ្នកជាប់ពន្ធរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយដ្ឋានពន្ធដារនៅមានកម្រិត ពោលគឺប្រព័ន្ធទិន្នន័យនេះមិនត្រូវបានតភ្ជាប់គ្នារវាងស្ថាប័នទាំងពីរ និងមិនទាន់មានយន្តការស្ថាប័ន ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មានជាមួយគ្នាជាប្រចាំ។

សមាសធាតុនេះទទួលបានពិន្ទុ D ដោយហេតុថា មានប្រព័ន្ធត្រួតពិនិត្យរួចហើយ ប៉ុន្តែប្រព័ន្ធនេះមានភាពខ្វះចន្លោះ និងតម្រូវឱ្យមានភាពសកម្ម បុរេសកម្ម និងអន្តរសកម្ម ជាងនេះ។ ដើម្បីទទួលបានពិន្ទុខ្ពស់ តម្រូវឱ្យមានប្រព័ន្ធចុះបញ្ជីពន្ធដែលតភ្ជាប់គ្នារវាងក្រសួងពាណិជ្ជកម្មនិងអគ្គនាយកដ្ឋានពន្ធដារ ឬក៏តម្រូវឱ្យមានការរៀបចំអង្កេត (survey) ទៅលើអ្នកជាប់ពន្ធដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាថា ការចុះបញ្ជីពន្ធនិងការអនុវត្តកាតព្វកិច្ចពន្ធ ត្រូវបានអនុវត្តត្រឹមត្រូវ និងពេញលេញ។

### (២) ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ

ទោសទណ្ឌផ្នែករដ្ឋបាល ឬបទល្មើសផ្នែកព្រហ្មទណ្ឌ ចំពោះការមិនអនុវត្តកាតព្វកិច្ចចុះបញ្ជី និងប្រកាសពន្ធមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។ សហគ្រាសដែលមិនបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានចាត់ទុកថាមិនអនុវត្តតាមច្បាប់ (មាត្រា ១២៨) និងត្រូវផាកពិន័យចំនួន ០,៥លានរៀល (ក្រោមរបបម៉ៅការ) ឬ ចំនួន ២លានរៀល (ក្រោមរបបពិត)។ ការផាកពិន័យត្រូវអនុវត្តដូចគ្នាដែរចំពោះសហគ្រាសដែលមិនបានកត់ត្រាកិច្ចបញ្ជិការគណនេយ្យ, ធ្វើឱ្យបាត់បង់ឯកសារគណនេយ្យ ឬខកខានមិនបានប្រកាសពន្ធ ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលកំណត់។ លើសពីនេះទៅទៀត តាមមាត្រា១៣១ នៃច្បាប់សារពើពន្ធ សហគ្រាសដែលត្រូវបានរកឃើញថាប្រកាសពន្ធមិនបានគ្រប់ចំនួន ត្រូវទទួលការផាកពិន័យពី ១០% ទៅ ៤០% នៃចំនួនទឹកប្រាក់ពន្ធដែលមិនបានបង់ទៅតាមទំហំនៃកំហុសឆ្គង បូកនឹងការប្រាក់ ២% ក្នុងមួយឆ្នាំ។

ច្បាប់ស្តីពន្ធគយបានចែងពីការផាកពិន័យមានបីប្រភេទ គឺ (១) ផាកពិន័យពី ១០០ ០០០ រៀល ទៅ ៥០០ ០០០ រៀល សម្រាប់ការមិនអនុវត្តតាមបញ្ញត្តិពន្ធគយតូចតាច (២) ផាកពិន័យពី ៣ ទៅ ៤ដង នៃប្រាក់ពន្ធត្រូវបង់ចំពោះការគេចវេសពន្ធតាមរយៈការរត់ពន្ធ ឬខកខានមិនបានរាយការណ៍ទំនិញដែលត្រូវបង់ពន្ធ ឬទំនិញដែលមិនត្រូវអនុញ្ញាតឱ្យនាំចូល (តាមមាត្រា ៧៤) និង (៣) អ្នកនាំចូល/ក្រុមហ៊ុនដែលមិនអនុវត្តតាមការណែនាំរបស់មន្ត្រីគយ ឬរារាំង ឬមិនផ្តល់របាយការណ៍តាមគោលការណ៍ណែនាំ ត្រូវបានផាកពិន័យពី ១ លានរៀល ទៅ ៥ លានរៀល (មាត្រា ៧៤)។

ការអនុវត្តដែលបានរៀបរាប់ខាងលើ នៅមិនទាន់មានប្រសិទ្ធភាព ដើម្បីជំរុញការអនុវត្តតាមនីតិវិធីច្បាប់ជាធរមាននៅឡើយ ដោយហេតុថា (១)ការផាកពិន័យចំពោះក្រុមហ៊ុនមិនចុះបញ្ជីពន្ធគឺនៅមានកម្រិតទាបនៅឡើយ (២) មានបញ្ហាប្រឈមច្រើនក្នុងការតាមដាន និងការបង្ខំឱ្យអនុវត្តតាមច្បាប់។ ក្នុងន័យនេះ ទាំងអគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធ មានគំនិតស្របគ្នាថា សហគ្រាសមួយចំនួនដែលប្រកបអាជីវកម្មយូរឆ្នាំនៅតែអនុវត្តតាមរបបម៉ៅការ បើទោះបីជាសហគ្រាសនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចបញ្ចូលទៅក្នុងរបបពិតបានក៏ដោយ។ នេះគឺឧទាហរណ៍មួយនៃការមិនអនុវត្តការផាកពិន័យបានតឹងរ៉ឹងនៅឡើយ÷ មានសហគ្រាសពីរដែលមានទំហំអាជីវកម្មប្រហាក់ប្រហែលគ្នា មួយជាហាងលក់ទំនិញ និងមួយទៀតជាភោជនីយដ្ឋាន ឬសណ្ឋាគារ ប៉ុន្តែសហគ្រាសមួយបង់ពន្ធតែ ២០ម៉ឺនរៀល តាមរបបម៉ៅការ រីឯសហគ្រាសមួយទៀតបង់ពន្ធរាប់លានរៀល តាមរបបពិត។

តាមការអនុវត្តប៉ុន្មានឆ្នាំនេះ ទំហំនៃការផាកពិន័យមានការថយចុះដោយមូលហេតុថា ការធ្វើសវនកម្មនៅមានកង្វះចន្លោះ ជាពិសេស ពេលមានការគេចវេសពន្ធ នៅមិនទាន់មានប្រព័ន្ធអាចឱ្យសវនករបញ្ជូនក្រុមហ៊ុនទាំងនោះ ទៅផ្នែកជំនាញស៊ើបអង្កេតការបន្លំពន្ធ ដើម្បីស៊ើបអង្កេតបន្តទៀតនៅឡើយ។ ក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតអង្គភាពស៊ើបអង្កេតបទល្មើសពន្ធ។ ចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ការអនុវត្តទប់ស្កាត់បទល្មើសនៅតាមព្រំដែននៅមានចន្លោះច្រើន ដែលបង្កការលំបាកដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក្នុងការបង្ក្រាបបទល្មើសគេចវេសពន្ធចំពោះទំនិញមួយចំនួនដូចជា បារី, សម្ភារៈអេឡិចត្រូនិច និងរថយន្ត។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថា មានការផាកពិន័យសម្រាប់សហគ្រាសដែលមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងមិនបានប្រកាសពន្ធប្រចាំខែជាប្រចាំ។ ដើម្បីទទួលបានពិន្ទុខ្ពស់គឺតម្រូវឱ្យនីតិវិធីច្បាប់ចំពោះកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ ត្រូវបានអនុវត្តចំពោះសហគ្រាសទាំងអស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព។

### (៣) ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ

ក្នុងឆ្នាំ២០០៨ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឱ្យអនុវត្តវិធីសាស្ត្រសវនកម្មក្រោយការបញ្ចេញទំនិញពីគយ (PCA) ស្របតាមអនុសញ្ញាក្យូតូ (Kyoto Convention)។ PCA មានគោលដៅស្វែងរកកំហុសឆ្គងនិងបទល្មើសពាក់ព័ន្ធសកម្មភាពនាំចេញនាំចូល បន្ទាប់ពីទំនិញត្រូវបានបញ្ចេញពីគយ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជ្រើសរើសទំនិញសម្រាប់ធ្វើសវនកម្មដោយផ្អែកលើកត្តាហានិភ័យ ដូចជាតម្លៃទំនិញមួយក្រុម (មួយកុងតឺន័រ-consignment), និងបទពិសោធន៍ដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាធ្លាប់ធ្វើការជាមួយអ្នកនាំចូល ឬអ្នកនាំចេញកន្លងមក។ ជាពិសេស អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានធ្វើការបែងចែកទំនិញជា៤ប្រភេទផ្សេងគ្នា (១) ពណ៌ក្រហម÷ មានហានិភ័យខ្ពស់ដែលត្រូវការត្រួតពិនិត្យទាំងឯកសារនិងទំនិញជាក់ស្តែង (២) ពណ៌លឿង÷ មានហានិភ័យមធ្យមដែលទាមទារឱ្យត្រួតពិនិត្យឯកសារតែប៉ុណ្ណោះ (៣) ពណ៌ខៀវ÷ សម្រាប់ក្រុមហ៊ុនណាដែលអនុវត្តការបង់ពន្ធគយបានត្រឹមត្រូវខ្ពស់ និង (៤) ពណ៌បៃតង÷ សម្រាប់ស្ថាប័នដែលត្រូវបានអនុញ្ញាតលើកលែងពន្ធ ប៉ុន្តែត្រូវគោរពតាមគោលការណ៍សវនកម្ម ក្រោយការបញ្ចេញទំនិញពីគយផងដែរ។ ក្នុងឆ្នាំ២០១២ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានបង្កើតសវនករចំនួនបីក្រុម ហើយក្នុងមួយក្រុម មានសវនករពី

៥ ទៅ ៧ នាក់ ដោយអនុវត្ត PCA ផ្តោតលើតំបន់កែច្នៃដើម្បីនាំចេញ (export processing zone) និងតំបន់សេដ្ឋកិច្ចពិសេស។ ក្រុមសវនករទាំងនោះត្រូវបានបណ្តុះបណ្តាលនៅក្នុងប្រទេសជប៉ុន។ ការអនុវត្ត PCA ត្រូវបានពង្រីកពី ៣ ក្រុម ទៅ ៦ក្រុម នៅឆ្នាំ ២០១៣។ ទន្ទឹមនេះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានបំណងពង្រីកមុខងាររបស់ PCA ធ្វើសវនកម្មលើក្រុមហ៊ុននាំចូល/ នាំចេញទាំងអស់។

អគ្គនាយកដ្ឋានពន្ធដារ ធ្វើសវនកម្មតែលើអ្នកជាប់ពន្ធក្នុងរបបពិតតែប៉ុណ្ណោះ។ មានអង្គភាពច្រើនដែលពាក់ព័ន្ធការងារសវនកម្មពន្ធ ដូចជានាយកដ្ឋានអ្នកជាប់ពន្ធធំ, នាយកដ្ឋានសវនកម្មសហគ្រាស និងការិយាល័យសវនកម្ម (នៅសាខាខណ្ឌ)។ អគ្គនាយកដ្ឋានពន្ធដារ អនុវត្តសវនកម្មពេញលេញ និងមានដែនកំណត់ ពោលគឺ ការធ្វើសវនកម្មដំបូងផ្តោតលើប្រភេទពន្ធផ្សេងៗជាច្រើន និងគ្របដណ្តប់ច្រើនឆ្នាំ បន្ទាប់មកនៅឆ្នាំបន្តបន្ទាប់ទៀត ការធ្វើសវនកម្មត្រូវបានផ្តោតលើតែការងារក្នុងការិយាល័យពន្ធដារ (Desk Work), និងការបង្វិលសងអាករលើតម្លៃបន្ថែមតែប៉ុណ្ណោះ។ ចំពោះការរៀបចំផែនការ អង្គភាពនីមួយៗមានផែនការសវនកម្ម និងមានវិធីសាស្ត្រជ្រើសរើសក្រុមហ៊ុនសម្រាប់ធ្វើសវនកម្មរៀងៗខ្លួន។ ក្រុមហ៊ុនចុះបញ្ជីតាមរបបពិតដែលត្រូវបានធ្វើសវនកម្មមាន ៧,៨% នៃក្រុមហ៊ុនទាំងអស់ នៅឆ្នាំ២០១១ និងមាន ៦,២% នៃក្រុមហ៊ុនទាំងអស់នៅឆ្នាំ ២០១២[29]។ ទោះជាយ៉ាងណាក៏ដោយ មានការកត់សម្គាល់ថា វិសាលភាពនៃការធ្វើសវនកម្មលើសហគ្រាសខ្នាតធំនៅមានកម្រិតទាបនៅឡើយ ដែលត្រូវបង្កើនបន្ថែមទៀត។

សមាសធាតុនេះទទួលបានពិន្ទុ C ដោយហេតុថា រដ្ឋបាលប្រមូលចំណូលបានរៀបចំ និងអនុវត្តផែនការសវនកម្មនិងស៊ើបអង្កេតការគេចបន្លំពន្ធ។ ដើម្បីទទួលបានពិន្ទុខ្ពស់ ទាមទារឱ្យការអនុវត្តសវនកម្មត្រូវធ្វើឡើងតាមផែនការសវនកម្ម និងត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យច្បាស់លាស់ និងពេញលេញ។

**តារាង ត.២៣ ÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៤**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-14 | **ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ** | C | D+ | វិធីសាស្ត្រវាយតម្លៃ M2 |
| (១) | ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ | C | D | ប្រព័ន្ធចុះបញ្ជីពន្ធនៅមាន កង្វះខាត ជាពិសេសព័ត៌មានអ្នកជាប់ពន្ធនៅមិនទាន់ សុក្រឹត ឬពេញលេញ ព្រមទាំងដំណើរការជ្រើសរើសអ្នកជាប់ពន្ធថ្មីមិនទាន់ស៊ីសង្វាក់គ្នា រវាងស្ថាប័ន និងស្ថាប័ន និងផ្ទៃក្នុងស្ថាប័ន។ |
| (២) | ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌ | C | C | និតិវិធីច្បាប់នៃការដាក់ទោសទណ្ឌ សម្រាប់ការមិន |

[29] រាជរដ្ឋាភិបាលកម្ពុជា (២០១៣) និន្នាការពង្រឹងការអនុវត្តច្បាប់ និងកិច្ចប្រឈមនៅកម្ពុជា ធ្វើបទបង្ហាញដោយ លោក អេង វតនា ក្នុងសន្និសីទពន្ធ IMF-ជប៉ុន សម្រាប់បណ្តាប្រទេសអាស៊ី

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| | សម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ | | | អនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ មិនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយហេតុថា (១) ការផាកពិន័យនៅមានកម្រិតទាប (២) មានបញ្ហាប្រឈមច្រើន ក្នុងការតាមដាន និងការបង្ខំឱ្យអនុវត្តតាមច្បាប់។ |
| (៣) | ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ | C | C | នៅពេលដែលការអនុវត្តសវនកម្ម ត្រូវបានកែលម្អ និងពង្រឹង លក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យសម្រាប់ជ្រើសរើសអ្នកជាប់ពន្ធ នៅមិនទាន់រៀបចំបានពេញលេញ និងតាមស្តង់ដារ។ លើសពីនេះ វិសាលភាពនៃការអនុវត្តសវនកម្មនៅមានកម្រិត ចំពោះទំនិញនាំចូលនិងនាំចេញ (ចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) និងមានទំហំតូចធៀបនឹងអ្នកជាប់ពន្ធតាមរបបពិត (ចំពោះអគ្គនាយកដ្ឋានពន្ធដារ)។ |

**ប្រអប់ គ.១៣ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

- ក្នុងខែតុលា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារ បានចេញប្រកាសលេខ ៣៣៨៨ សហវ.ប្រក ដើម្បីធ្វើបច្ចុប្បន្នភាពការចុះបញ្ជីពន្ធ និងព័ត៌មានអ្នកជាប់ពន្ធ ដែលរួមមានការចុះបញ្ជីឡើងវិញ ចំពោះអ្នកជាប់ពន្ធដែលមានស្រាប់តាមរបបពិតដោយផ្តល់ឱ្យវិញ្ញាបនប័ត្រ VAT និងលេខ TINs ច្បាស់លាស់។ ក្នុងន័យនេះ ទាមទារឱ្យក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងម្ចាស់ក្រុមហ៊ុន ត្រូវផ្តល់រូបថត និងព្រីនម្រាមដៃ ព្រមទាំងបំពេញទម្រង់ការចុះបញ្ជីពន្ធ។ ចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការ ក៏ត្រូវបានអនុវត្តដូចគ្នាផងដែរ។
- អគ្គនាយកដ្ឋានពន្ធដារ បានបង្ហាញថា មិនមានផែនការផ្លាស់ប្តូរប្រព័ន្ធដាក់ទោសទណ្ឌចំពោះអ្នកជាប់ពន្ធទេ នាពេលបច្ចុប្បន្ននេះ ប៉ុន្តែមានផែនការលុបបំបាត់របបម៉ៅការ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ មានផែនការដាក់ឱ្យអនុវត្តរបបបំព្រួញ (simplified regime) ទៅក្នុងច្បាប់សារពើពន្ធ។ អ្នកជាប់ពន្ធក្នុងរបបនេះ ទាមទារឱ្យមានការកត់ត្រាបញ្ជីគណនេយ្យសាមញ្ញមួយ ហើយប្រព័ន្ធកត់ត្រាគណនេយ្យនេះ អគ្គនាយកដ្ឋានកំពង់តែសិក្សា។
- ជាមួយនឹង PCAs អគ្គនាយកដ្ឋានគយនិងរដ្ឋករ មានផែនការបង្កើនចំនួនសវនករឱ្យបាន៩ក្រុម ដែលក្រុមខ្លះអាចនឹងដាក់ពង្រាយឱ្យធ្វើការពេញម៉ោង ដើម្បីពង្រីកវិសាលភាពនៃការងារ PCAs គ្របដណ្តប់ដល់ក្រុមហ៊ុននាំចេញនិងនាំចូល។ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម អគ្គនាយកដ្ឋានគយនិងរដ្ឋាករនឹងជំរុញឱ្យមានការចែកចាយព័ត៌មាន តាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- អគ្គនាយកដ្ឋានពន្ធដារមានផែនការពង្រឹងវិធីសាស្ត្រវាយតម្លៃហានិភ័យ ដើម្បីជ្រើសរើសសហគ្រាសសម្រាប់ធ្វើសវនកម្ម ព្រមទាំងជ្រើសរើសសវនករបន្ថែមទៀត ដើម្បីសម្រួលការងារដែលមានច្រើន រៀបចំរបាយការណ៍សវនកម្មឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងជំរុញឱ្យមានការចែកចាញព័ត៌មាននៅក្នុងស្ថាប័នតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។ នៅក្នុងឆ្នាំ ២០១៤ អគ្គនាយកដ្ឋានពន្ធដារ បានអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់សវនករ។ ប្រព័ន្ធនេះបានអនុញ្ញាតឱ្យសវនករទទួលបានប្រាក់លើកទឹកចិត្តចំនួន ១០ភាគរយនៃប្រាក់ផាកពិន័យសរុបដែលក្រុមសវនករទាំងនោះរកឃើញថាមិនអនុវត្តតាមនីតិវិធីច្បាប់។
- នៅក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតអង្គភាពស៊ើបអង្កេតបទល្មើសពន្ធដើម្បីជំរុញដំណើរការស៊ើបអង្កេតការបន្លំ និងគេចវេសពន្ធ។

## គ.៤.៣ ប្រសិទ្ធភាពនៃការប្រមូលពន្ធ (PI-15)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើសមត្ថភាពរបស់អាជ្ញាធរគ្រប់គ្រងចំណូល ក្នុងការប្រមូលពន្ធ។ ការវាយតម្លៃគ្របដណ្តប់លើចំណូលពន្ធធំៗដែលប្រមូលបាននៅថ្នាក់កណ្តាលដោយសមាសធាតុ (១) ផ្តោតសំខាន់លើឆ្នាំសារពើពន្ធពីរឆ្នាំចុងក្រោយ និងសមាសធាតុ (២) និង (៣) ត្រូវបានវាយតម្លៃលើឆ្នាំដែលការវាយតម្លៃត្រូវបានធ្វើឡើង។

### (១) អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធសរុប

បំណុលពន្ធមានច្រើនជាង ៩០% ក្នុងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។[30] ចំពោះអគ្គនាយកដ្ឋានពន្ធដារ បំណុលពន្ធកើនឡើងភាគច្រើននៅក្រោយការវាយតម្លៃនៃសវនកម្ម ហើយអ្នកជាប់ពន្ធមានរយៈពេល ៣០ថ្ងៃ គិតចាប់ពីពេលចេញផ្សាយលិខិតជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទូទាត់បំណុលពន្ធ។ ក្នុងករណីមិនបានទូទាត់ សវនករអគ្គនាយកដ្ឋានពន្ធដារ នឹងបញ្ជូនព័ត៌មានលម្អិតនៃបំណុលមិនទាន់ទូទាត់ ទៅកាន់មន្ត្រីទទួលបន្ទុកបំណុលពន្ធដើម្បីតាមដានបន្ត។ ការិយាល័យបំណុលពន្ធ បញ្ជូនលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធឱ្យទូទាត់ក្នុងរយៈពេល ៣០ ថ្ងៃបន្តទៀត។ ប្រសិនបើបំណុលនៅតែមិនទាន់បានទូទាត់, ការិយាល័យបំណុលពន្ធនឹងបញ្ជូនសេចក្តីជូនដំណឹងចុងក្រោយ ដើម្បីឱ្យអ្នកជាប់ពន្ធមកទូទាត់បំណុលក្នុងរយៈពេល ១៥ ថ្ងៃ។ ហួសកំណត់រយៈពេល ១៥ ថ្ងៃចុងក្រោយនេះ ហើយបំណុលពន្ធនៅតែមិនទាន់ត្រូវបានទូទាត់, អគ្គនាយកដ្ឋានពន្ធដារអាចចេញផ្សាយនូវព័ត៌មានលម្អិតនៃអ្នកជាប់ពន្ធដែលល្មើសទៅក្នុងប្រព័ន្ធផ្សព្វផ្សាយ, និងបន្តតាមដានការទូទាត់បំណុលតាមរយៈការចេញផ្សាយនូវលិខិតបន្តបន្ទាប់ ឬតាមរយៈប្រព័ន្ធទូរសព្ទ។

មាត្រា ១០៩ និង មាត្រា ១១១ នៃ ច្បាប់ស្តីពីសារពើពន្ធ បានផ្តល់អំណាចឱ្យអគ្គនាយកដ្ឋានពន្ធដារ នូវសិទ្ធិក្នុងការកាន់កាប់ ឬរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលល្មើស។ ប៉ុន្តែជាក់ស្តែង មាត្រានេះមិនត្រូវបានអនុវត្តឡើយ។ ជាលទ្ធផល, ដូចបង្ហាញក្នុងតារាង គ.២៤, អ្នកជាប់ពន្ធភាគច្រើន មិនបានទូទាត់បំណុលពន្ធរបស់ពួកគេដែលនាំឱ្យការប្រាក់ និងប្រាក់ពិន័យកើនឡើង។ ក្នុងរវាងឆ្នាំ២០១១ និងឆ្នាំ២០១៣, បំណុលពន្ធបានកើនឡើងជាមធ្យម ១៣% ក្នុងមួយឆ្នាំ។ ការប្រមូលពន្ធ ក្នុងឆ្នាំ២០១១ គឺខ្ពស់ជាងនៅឆ្នាំបន្តបន្ទាប់ពោលគឺ ឆ្នាំ២០១២ និងឆ្នាំ២០១៣។

**តារាង គ.២៤÷ ការប្រមូលបំណុលពន្ធដោយអគ្គនាយកដ្ឋានពន្ធដារ**

| *គិតជាលានរៀល* | **២០១១** | **២០១២** | **២០១៣** |
|---|---|---|---|
| ចំនួនបំណុលពន្ធនៅដើមឆ្នាំ | ១ ៩៦០ | ២ ១៨៥ | ២ ៥១៧ |
| ចំណូលពន្ធដែលប្រមូលបានសរុប | ២ ៣៦០ | ៣ ០៣៦ | ៣ ៦០៥ |
| ចំនួនបំណុលពន្ធជាភាគរយធៀបទៅនឹងការប្រមូលបាននៅឆ្នាំមុន | ៩៣,៨ % | ៩២,៦ % | ៨២,៩ % |
| បំណុលពន្ធដែលប្រមូលបានសរុប | ៦២៦ | ៣៩០ | ៤៤៨ |
| បំណុលពន្ធសរុបដែលប្រមូលបានជាភាគរយធៀបនឹងចំនួនបំណុលពន្ធនៅដើមឆ្នាំ | ៣១,៩ % | ១៧,៨ % | ១៧,៨ % |

ប្រភព÷ អគ្គនាយកដ្ឋានពន្ធដារ

[30] បំណុលពន្ធក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ បានកើនឡើងព្រោះអ្នកនាំចូលប្រេងឥន្ធនៈមិនបានបង់ពន្ធគយ ដោយធ្វើការកាត់កងប្រាក់ពន្ធជាមួយនឹងប្រាក់ដែលរាជរដ្ឋាភិបាលជំពាក់ជំនួសវិញ

សមាសធាតុនេះ ទទួលបានពិន្ទុ D ពីព្រោះកម្រិតនៃបំណុលពន្ធខ្ពស់ ហើយអនុបាតនៃការប្រមូលបំណុលនៅក្នុងឆ្នាំទាំងបី ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ គឺស្ថិតក្រោម ៦០%។

**(២) ប្រសិទ្ធភាពនៃការផ្ទេរពន្ធដែលប្រមូលបានទៅរតនាគារដោយរដ្ឋបាលចំណូល**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ[31] ទទួលប្រាក់បង់ពន្ធភាគច្រើន តាមរយៈគណនីចំណូលនៅធនាគារជាតិនៃកម្ពុជា និង/ឬធនាគារពាណិជ្ជ។ តាមការណែនាំពីអគ្គនាយកដ្ឋានរតនាគារជាតិ ធនាគារពាណិជ្ជត្រូវផ្ទេរប្រាក់បង់ពន្ធ ទៅកាន់គណនីទោលរតនាគារជាតិ និងគណនីទោលរតនាគាររាជធានី-ខេត្ត ជាប្រចាំថ្ងៃ។ ជាមួយគ្នានេះដែរ ចំពោះចំណូលដែលទទួលបានពីការិយាល័យគយ និងសាខាពន្ធដារខេត្ត នៅតាមជនបទដែលការប្រើប្រាស់ប្រព័ន្ធធនាគារនៅមានកំណត់ និង/ឬ ដោយអ្នកជាប់ពន្ធស្ថិតក្រោមរបបម៉ៅការ ភាគច្រើនត្រូវបានបង់ពន្ធជាសាច់ប្រាក់សុទ្ធ និងត្រូវការពេលមួយចំនួនដើម្បីផ្ទេរសាច់ប្រាក់ទៅកាន់គណនីទោលរតនាគារ។

សមាសធាតុនេះ ទទួលបានពិន្ទុ B ព្រោះ ប្រាក់បង់ពន្ធត្រូវបានផ្ទេរទៅកាន់គណនីទោលរតនាគារយ៉ាងហោចណាស់មួយសប្តាហ៍ម្តង។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យចំណូលពន្ធទាំងអស់ត្រូវបានផ្ទេរទៅគណនីទោលរតនាគារជាតិជារៀងរាល់ថ្ងៃ។

**(៣) ពេលវេលា នៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគារជាតិ រវាងការវាយតម្លៃពន្ធ, ពន្ធដែលប្រមូលបាន, កំណត់ត្រាបំណុលពន្ធ និងវិក្កយបត្រ**

អគ្គនាយកដ្ឋានរតនាគារជាតិ គ្រប់គ្រងផែនការប្រមូលចំណូលតាមរយៈការត្រួតពិនិត្យចំណូលជារៀង-រាល់ខែ។ អគ្គនាយកដ្ឋានរតនាគារជាតិ ក៏ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការប្រមូលពន្ធជារៀងរាល់ថ្ងៃផងដែរ។ នៅពេលដែលអគ្គនាយកដ្ឋានរតនាគារជាតិ មិនអាចកំណត់បានពីមុខសញ្ញាចំណូលពន្ធ, អគ្គនាយកដ្ឋាន នឹងបង្កើតគណនីបណ្តោះអាសន្ន និងធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាបន្តបន្ទាប់។ ជាទូទៅការផ្ទៀងផ្ទាត់នេះ ត្រូវការពេលមួយសប្តាហ៍ ដើម្បីកំណត់មុខសញ្ញាពន្ធដែលត្រឹមត្រូវ ដើម្បីផ្ទេរទៅគណនីចំណូលសមស្រប តាមប្លង់គណនីរបស់រាជរដ្ឋាភិបាល។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ រៀបចំរបាយការណ៍វាយតម្លៃពន្ធ, ការប្រមូលចំណូលពន្ធ និងបំណុលពន្ធយ៉ាងហោចណាស់មួយឆ្នាំម្តង។ ដំណើរការនេះ គឺមានភាពងាយស្រួលជាងសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ដោយសារព័ត៌មាននេះអាចទាញចេញពីប្រព័ន្ធ ASYCUDA។ ផ្ទុយទៅវិញ, ចំពោះអគ្គនាយកដ្ឋានពន្ធដារ ប្រព័ន្ធទិន្នន័យត្រូវបានគ្រប់គ្រងដោយនាយកដ្ឋាន និងសាខាពន្ធដារផ្សេងៗគ្នា ដែលនេះទាមទារឱ្យមានការផ្ទៀងផ្ទាត់ឡើងវិញ។ ក្រុមការងារវាយតម្លៃ PEFA បានឃើញឯកសារពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់ប្រចាំឆ្នាំនៃសមតុល្យបំណុលពន្ធ និងការវាយតម្លៃសវនកម្ម[32]។

---

[31] អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារប៉ាន់ស្មានថា ៩៣% និង៩៧% នៃចំណូលប្រមូលបានត្រូវបានបង់ទៅកាន់ធនាគារដោយផ្ទាល់ ។

[32] ការធ្វើបទបង្ហាញដោយ លោក អេង រតនា ក្នុងសន្និសិទពន្ធជាន់ខ្ពស់ IMF ជប៉ុន សម្រាប់បណ្តាប្រទេសអាស៊ីស្តីពីនិន្នាការការពង្រឹងការអនុវត្ត និងកិច្ចប្រឈមការអនុវត្តច្បាប់នៅកម្ពុជា.

សមាសធាតុនេះ ទទួលបានពិន្ទុ C ព្រោះ ចំណូលពន្ធត្រូវបានផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិប្រចាំថ្ងៃ ដោយពិនិត្យមើលលើសមតុល្យចំណូលពន្ធ ស្របពេលដែលការផ្ទៀងផ្ទាត់ការវាយតម្លៃពន្ធ និងបំណុលពន្ធ ត្រូវបានផ្ទៀងផ្ទាត់ប្រចាំឆ្នាំ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យមានការផ្ទៀងផ្ទាត់ប្រចាំត្រីមាស។

**តារាង គ.២៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៥**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| **PI-15** | **ប្រសិទ្ធភាពក្នុងការប្រមូលពន្ធ** | D+ | D+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |
| (១) | អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធដុល ដែលជាភាគរយនៃបំណុលពន្ធនៅដើមឆ្នាំសារពើពន្ធ និងដែលត្រូវបានប្រមូលក្នុងឆ្នាំសារពើពន្ធនោះ | D | D | បំណុលពន្ធសរុបមានទំហំធំ ហើយអនុបាតប្រមូលពន្ធក្នុងឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ស្ថិតក្រោម ៦០% (១៧,៨% ក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣) |
| (២) | ប្រសិទ្ធភាពនៃការផ្ទេរប្រាក់ពន្ធដែលប្រមូលបានទៅរតនាគារដោយរដ្ឋបាលចំណូល | B | B | ចំណូលភាគច្រើនត្រូវបានផ្ទេរទៅកាន់ រតនាគារជាតិជារៀងរាល់ថ្ងៃ។ ចំណូលពន្ធមួយចំនួនត្រូវបានប្រមូលដោយការិយាល័យគយនិងរដ្ឋាករកម្ពុជា និងសាខាពន្ធដារខេត្ត-ខណ្ឌ និងត្រូវបានរក្សាទុកនៅធនាគារ។ ប្រាក់ទាំងនេះមិនត្រូវបានផ្ទេរជារៀងរាល់ថ្ងៃទេ ប៉ុន្តែយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍។ |
| (៣) | ពេលវេលា នៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគារ រវាងការវាយតម្លៃពន្ធ, ការប្រមូលពន្ធ, កំណត់ត្រាបំណុលពន្ធ និងវិក្កយបត្រ | C | C | ពន្ធដែលប្រមូលបានត្រូវបានផ្ទៀងផ្ទាត់ជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារទទួលបានភស្តុតាងដែលបញ្ជាក់ថាអ្វីផ្សេងៗទៀតត្រូវបានកត់ត្រាជារៀងរាល់ឆ្នាំ |

**ប្រអប់ គ.១៤÷ ការងារកែទម្រង់កំពុងអនុវត្ត**

ក្នុងយុទ្ធសាស្ត្រគ្រប់គ្រងចំណូល, អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថាមានគម្រោងរៀបចំគោលដៅប្រមូលបំណុលពន្ធនៅតាមសាខាពន្ធដារខេត្ត ខណ្ឌនីមួយៗ ដែលនឹងមានការរឹបអូសនិងលក់ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដើម្បីសងបំណុលពន្ធ និងប្តឹងអ្នកជាប់ពន្ធដែលល្មើសទៅតាមច្បាប់សារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារ នឹងចងក្រងសៀវភៅណែនាំស្តីពីការគ្រប់គ្រងបំណុលពន្ធ។ លើសពីនេះ អគ្គនាយកដ្ឋានពន្ធដារមានបំណងធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធដំណើរការរបស់ខ្លួន ដូចជាការដំឡើងកម្មវិធីគម្រោងគ្រប់គ្រងបំណុលដែលអនុញ្ញាតឱ្យស្វែងរកទិន្នន័យអ្នកជាប់ពន្ធបានទូទាំងប្រទេស។

## គ.៤.៤ ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពនៃថវិកាសម្រាប់ធានាចំណាយ (PI-16)

សូចនាករនេះ វាយតម្លៃឱ្យឃើញពីកម្រិតជឿជាក់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចផ្តល់ព័ត៌មានលើភាពទំនេរនៃថវិកាទៅកាន់ក្រសួង-ស្ថាប័ន ដែលជាអ្នកមានតម្រូវការចំណាយ។ ការវាយតម្លៃនេះ ផ្តោតទៅលើឆ្នាំសារពើពន្ធចុងក្រោយ។

### (១) ការព្យាករណ៍ និងត្រួតពិនិត្យតាមដានលំហូរសាច់ប្រាក់

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពង្រឹងការគ្រប់គ្រងធនធានសាច់ប្រាក់របស់ខ្លួន។ ដើម្បីបង្កើតគោលនយោបាយ, នីតិវិធី និងប្រព័ន្ធ សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ ក្នុងគោលបំណងធានាឱ្យបាននូវការព្យាករណ៍លំហូរសាច់ប្រាក់ និងតុល្យភាពចុងគ្រាឱ្យបានត្រឹមត្រូវនិងទៀងពេលវេលា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៨៨០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ ដើម្បីដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់។ គោលការណ៍ណែនាំស្តីពីការធ្វើផែនការសាច់ប្រាក់ ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៣ ក្រោមប្រកាសលេខ ៦១៧ សហវ.ប្រក។ អគ្គនាយកដ្ឋានរតនាគារជាតិ រៀបចំផែនការលំហូរសាច់ប្រាក់ ក្នុងគោលបំណងគ្រប់គ្រងធនធានសាច់ប្រាក់របស់ខ្លួនឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព និងដើម្បីធ្វើឱ្យប្រសើរឡើងនូវលំហូរសាច់ប្រាក់ចេញ និងចូលនៅក្នុងឆ្នាំ។

ការធ្វើផែនការលំហូរសាច់ប្រាក់ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ (Cash Management Technical Committee - CMTC) ក្រោមការដឹកនាំផ្ទាល់របស់អង្គភាពគ្រប់គ្រងសាច់ប្រាក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ CMTC គឺជាអង្គភាពបច្ចេកទេសបំពេញតួនាទីក្នុងនាមគណៈកម្មាធិការគ្រប់គ្រងថវិកា (Budget Management Committee - MBC), ដែលមានតំណាងមកពីអគ្គនាយកដ្ឋានពន្ធដារ, ធនាគារជាតិនៃកម្ពុជា, អគ្គនាយកដ្ឋានថវិកា, និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ គណៈកម្មាធិការនេះត្រួតពិនិត្យសមតុល្យសាច់ប្រាក់រតនាគារប្រចាំថ្ងៃ។ សមតុល្យធនាគារត្រូវបានផ្ទៀងផ្ទាត់ជាមួយនឹងសមតុល្យសៀវភៅធំប្រចាំខែយ៉ាងលម្អិត (សូមមើលសូចនាករសមិទ្ធកម្មទី២២ សមាសធាតុ ១)។

ក្រសួង-ស្ថាប័ន ជូនដំណឹងមក CMTC ពីតម្រូវការសាច់ប្រាក់ប្រចាំឆ្នាំរបស់ខ្លួន មុនថ្ងៃទី១៥ ខែវិច្ឆិកា ដោយចែកទៅតាមខែ និងលម្អិតតាមជំពូក គណនី និងអនុគណនី។ CMTC រៀបចំផែនការសាច់ប្រាក់ប្រចាំឆ្នាំ គោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងច្បាប់ចម្លងមួយច្បាប់ទៀត ជូនគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ដែលនេះនឹងធ្វើឱ្យពិដានសាច់ប្រាក់ប្រចាំខែសម្រាប់ក្រសួង-ស្ថាប័ននីមួយៗអាចត្រូវបានកំណត់នៅក្នុងឆ្នាំ និងត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិកា មុនពេលដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី១០ ខែធ្នូ ដើម្បីអនុម័ត។ នៅក្នុងឆ្នាំ ការព្យាករណ៍លំហូរសាច់ប្រាក់ ត្រូវបានធ្វើបច្ចុប្បន្នកម្មរៀងរាល់ត្រីមាស ដើម្បីឆ្លើយតបទៅនឹងសំណើសុំទូទាត់ និងការទូទាត់ជាក់ស្តែងសម្រាប់ខែមុនៗ និងដើម្បីព្យាករណ៍ចំណាយនិងការទូទាត់ឡើងវិញសម្រាប់ខែដែលនៅសល់នៅក្នុងឆ្នាំ។ មន្ត្រីក្រសួងសុខាភិបាលបាននិយាយថា ការព្យាករណ៍របស់ពួកគេត្រូវបានធ្វើឡើងតែនៅក្នុងត្រីមាសទីបី តែប៉ុណ្ណោះ។

អគ្គនាយកដ្ឋានរតនាគារជាតិ ទទួលបានរបាយការណ៍ប្រចាំខែពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធនឹងវិក្កយបត្រ និងការទូទាត់, និងការស្នើសុំតួលេខពិដានសាច់ប្រាក់ប្រចាំខែ។ ទាំងនេះត្រូវបានបូកសរុបនិងត្រូវបានប្រៀបធៀបជាមួយនឹងការគ្រោងធនធានដែលមាន, ហើយ CMTC ផ្សព្វផ្សាយនូវពិដានថវិកាថ្មីៗប្រចាំត្រីមាស។

បើទោះបីជាគោលការណ៍ណែនាំស្តីពីការធ្វើផែនការសាច់ប្រាក់ ទាមទារឱ្យការព្យាករណ៍នូវចំណាយក្រៅពីប្រាក់បៀវត្ស, ទឹកភ្លើង និងការជួល ត្រូវពឹងផ្អែកលើផែនការលទ្ធកម្មរបស់ក្រសួង-ស្ថាប័នក៏ដោយ, ការធ្វើផែនការលទ្ធកម្មនេះមិនត្រូវបានអនុវត្តពេញលេញនៅឡើយ ដែលនាំឱ្យការព្យាករណ៍ត្រូវពឹងផ្អែកលើទិន្នន័យលំហូរសាច់ប្រាក់កន្លងមក និងកាត់បន្ថយការប្រើទិន្នន័យព្យាករណ៍របស់ក្រសួង-ស្ថាប័នលើកម្មវិធីចំណូលនិងចំណាយ។ របាយការណ៍ព្យាករណ៍សាច់ប្រាក់ បង្ហាញតែកំណត់ត្រាស្តីពីលំហូរចូល និងលំហូរចេញរបស់សាច់ប្រាក់ប៉ុណ្ណោះ។ ចំណែកឯផែនការសាច់ប្រាក់គ្រប់ជ្រុងជ្រោយដែលវិភាគស្ថានភាពសាច់ប្រាក់ (ការប្រើប្រាស់សាច់ប្រាក់ដែលលើស ឬយន្តការបំពេញសាច់ប្រាក់ដែលខ្វះ) មិនត្រូវបានរៀបចំឡើយ។ ចំណែកការត្រួតពិនិត្យយន្តការ និងរបាយការណ៍ដែលវិភាគពីលំហូរសាច់ប្រាក់ចូលជាក់ស្តែងធៀបនឹងលំហូរចូលព្យាករណ៍នៅមានកម្រិតនៅឡើយ គិតត្រឹមឆ្នាំ២០១៤។

សមាសធាតុនេះទទួលបានពិន្ទុ B ព្រោះការព្យាករណ៍លំហូរសាច់ប្រាក់ប្រចាំឆ្នាំត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នកម្មប្រចាំត្រីមាស ផ្អែកលើមូលដ្ឋានលំហូរសាច់ប្រាក់ជាក់ស្តែងខែមុន និងព្យាករណ៍ឡើងវិញសម្រាប់ខែដែលនៅសល់ក្នុងឆ្នាំ។ ពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យការព្យាករណ៍សាច់ប្រាក់ត្រូវធ្វើបច្ចុប្បន្នកម្មយ៉ាងហោចណាស់ប្រចាំខែ។

### (២) សុក្រឹតភាព និងការផ្តល់ថវិកាគ្រប់គ្រាន់ទាន់ពេលវេលាសម្រាប់ការគ្រោងចំណាយដោយក្រសួង-ស្ថាប័ន

ក្រសួង-ស្ថាប័ន និងរដ្ឋបាលចំណូល រៀបចំកម្មវិធីចំណូល និងចំណាយប្រចាំត្រីមាស។ បន្ទាប់ពី កម្មវិធីចំណូល និងចំណាយប្រចាំត្រីមាសត្រូវបានឯកភាព, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការជូនដំណឹងទៅក្រសួង-ស្ថាប័ននីមួយៗ អំពីកម្មវិធីចំណូលនិងចំណាយប្រចាំត្រីមាសដោយបញ្ជាក់ពីពិដានសាច់ប្រាក់សម្រាប់ជំពូកនីមួយៗ និងកម្មវិធីនីមួយៗ (អនុវត្តចាប់ពីឆ្នាំ២០១៥), និងជូនដំណឹងទៅកាន់អង្គភាពគ្រប់គ្រងសាច់ប្រាក់ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន, មន្ទីររាជធានី-ខេត្ត និងអភិបាលរាជធានី-ខេត្ត។ សូមបញ្ជាក់ថា នេះគឺជាផែនការសាច់ប្រាក់, មិនមែនជាការធានាចំណាយទេ, និងជាពិដានសាច់ប្រាក់សម្រាប់ឱ្យក្រសួង-ស្ថាប័នអនុវត្តចំណាយ (សូមមើលសូចនាករសមិទ្ធកម្មទី ២០ សមាសធាតុ ១ លើការត្រួតពិនិត្យធានាចំណាយ)។

ជាទូទៅ កង្វះសាច់ប្រាក់មិនមែនជាបញ្ហាប្រឈមទេ ប៉ុន្តែគឺបញ្ហារដ្ឋបាល និងសមត្ថភាពមន្ត្រីដែលបណ្តាលឱ្យការធានាចំណាយ និងការទូទាត់ចំណាយមានការរាំងស្ទះ។ ក្នុងន័យនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល បានយល់ស្របថា ពួកគេមិនធ្លាប់មានបទពិសោធន៍ពាក់ព័ន្ធនឹងកង្វះខាតថវិកាសម្រាប់អនុវត្តចំណាយតាមផែនការចំណាយទេ ប៉ុន្តែក្នុងករណីខ្លះ ការដកប្រាក់មានភាពយឺតយ៉ាវដោយសារបែបបទរដ្ឋបាល ។

សមាសធាតុនេះទទួលបានពិន្ទុ B ព្រោះក្រសួង-ស្ថាប័ន បានរៀបចំកម្មវិធីចំណូលចំណាយប្រចាំត្រីមាស។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យក្រសួង-ស្ថាប័នផ្តល់កម្មវិធីចំណូលចំណាយដែលអាចជឿជាក់បាន ដើម្បីជាមូលដ្ឋានរៀបចំផែនការសាច់ប្រាក់ យ៉ាងហោចណាស់ ៦ ខែមុន។

**(៣) អត្រានៃការកើតឡើង (frequency) និងតម្លាភាពនៃការផ្ទេរថវិកា ដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន**

ថវិកាដែលបានអនុម័តរួចត្រូវបានត្រួតពិនិត្យនៅថ្នាក់កណ្ដាលយ៉ាងម៉ត់ចត់នៅពេលធ្វើចលនាឥណទាន។ ក្រសួង-ស្ថាប័ន ត្រូវបានអនុញ្ញាតឱ្យផ្ទេរថវិកាពីសកម្មភាពមួយទៅសកម្មភាពមួយទៀតនៅក្នុងអនុកម្មវិធីដូចគ្នា និងនៅក្នុងជំពូកដូចគ្នាតែប៉ុណ្ណោះ ដោយមិនចាំបាច់ស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះការវិភាជឡើងវិញនូវថវិកាដទៃទៀត ទាមទារឱ្យមានការអនុម័តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន។ ប៉ុន្តែបើសំណើសុំថវិកាចំណាយក្នុងឆ្នាំលើសពីថវិកាដែលបានអនុម័តរួច ចាំបាច់ត្រូវស្នើសុំការអនុម័តពីរដ្ឋសភា[33]។ ជាទូទៅ ការស្នើសុំវិភាជថវិកាឡើងវិញដោយក្រសួង-ស្ថាប័ននឹងមានការកើនឡើង ប្រសិនបើការត្រួតពិនិត្យចលនាឥណទានមានភាពធូរលុង។ ក្រុមការងារវាយតម្លៃ PEFA មិនបានទទួលទិន្នន័យអំពីចំនួននៃការស្នើសុំវិភាជថវិកាឡើងវិញដែលមិនត្រូវបានអនុញ្ញាតទេ ប៉ុន្តែការស្នើសុំវិភាជថវិកាឡើងវិញដែលត្រូវបានអនុញ្ញាតនោះ ត្រូវបានកំណត់ពេលវេលាជារៀងរាល់ឆ្នាំដោយអគ្គនាយកដ្ឋានថវិកា។ ក្នុងឆ្នាំ២០១២, សំណើសុំចំនួន ១៧៣ មកកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាត ដែលមានទឹកប្រាក់ចំនួន ៦៧១ ពាន់លានរៀល។ ក្រុមការងារវាយតម្លៃ PEFA រកឃើញថា ក្នុងឆ្នាំ២០១៤ មានការកែតម្រូវ ១៥ ឬ ១៦ ដង ក្នុងក្រសួងអប់រំ យុវជន និងកីឡា និងប្រហែល ២៣ ដង ក្នុងក្រសួងសុខាភិបាល។ ចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ចំនួនសំណើសុំជាមធ្យមមកកាន់អគ្គនាយកដ្ឋានថវិកា ដែលត្រូវបានអនុញ្ញាតមាន ៩២ ដែលមានទឹកប្រាក់ចំនួន ៦៨៩ ពាន់លានរៀល (ចន្លោះ ៧% ទៅ ៨% នៃចំណាយសរុប)។ យោងតាមការវាយតម្លៃផ្ទៃក្នុង, ជារៀងរាល់ឆ្នាំ មានការសម្របសម្រួលជាច្រើនបានកើតឡើងដើម្បីវិភាជថវិកាឡើងវិញ ជាពិសេស ពីជំពូកដែលមិនទាន់វិភាជន៍ (ជំពូក ៩) ដែលត្រូវបានអនុញ្ញាតដោយអនុក្រឹត្យ។ បើទោះបីជាជំពូក ៩ មានគោលដៅចម្បងចំពោះថវិកាជំនួយសង្គ្រោះសម្រាប់គ្រោះមហន្តរាយ និងជំនួយសង្គ្រោះបន្ទាន់ផ្សេងទៀត, ប៉ុន្តែជំពូកនេះត្រូវបានប្រើប្រាស់យ៉ាងទូលាយចំពោះចំណាយមិនតាមគម្រោងថវិកា ដែលចាំបាច់។

សមាសធាតុនេះទទួលបានពិន្ទុ C ព្រោះការផ្ទេរថវិកាក្នុងឆ្នាំមានចំនួនច្រើននិងតែងតែកើតឡើងច្រើនដង ប៉ុន្តែមានតម្លាភាព។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យការសម្របសម្រួលផ្ទេរថវិកាក្នុងឆ្នាំ ដែលធ្វើឡើងក្រៅពីដែនសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន កើតឡើងតែមួយដង ឬពីរដងក្នុងមួយឆ្នាំតែប៉ុណ្ណោះ។

**តារាង គ.២៦÷ ពិន្ទុសូចនាករសមិទ្ធកម្មទី ១៦**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-16 | **ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |

[33] ក្នុងឆ្នាំ២០១០, ការវិភាជន៍បន្ថែមត្រូវបានបន្ថែមចូលទៅក្នុងថវិកាក្នុងឆ្នាំ។ ជាការពិតណាស់ ច្បាប់ថវិកា ២០១០ ដែលត្រូវបានពិនិត្យឡើងវិញ និងអនុម័តថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ បានអនុញ្ញាតឱ្យមានកម្ចីបន្ថែមចំនួន ៣០ លាន SDR សម្រាប់ឆ្នាំ២០០៩ និង ១៧០ លាន SDR សម្រាប់ឆ្នាំ២០១០

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| (១) | វិសាលភាពដែលលំហូរសាច់ប្រាក់អាចព្យាករណ៍បាន និងត្រូវបានត្រួតពិនិត្យ | C | B | ការព្យាករណ៍សាច់ប្រាក់ត្រូវបានធ្វើបច្ចុប្បន្នកម្មប្រចាំត្រីមាស ដោយផ្អែកលើលំហូរសាច់ប្រាក់ជាក់ស្តែងត្រីមាសមុន និងព្យាករណ៍ឡើងវិញចំពោះពេលវេលាដែលនៅសល់ក្នុងឆ្នាំ។ |
| (២) | សុក្រឹតភាព និងការផ្តល់ថវិកាគ្រប់គ្រាន់ ទាន់ពេលវេលាសម្រាប់ការគ្រោងចំណាយដោយក្រសួង ស្ថាប័ន | B | B | ក្រសួង ស្ថាប័ន អាចរៀបចំកម្មវិធីចំណូល និងចំណាយរបស់ខ្លួន ជារៀងរាល់ត្រីមាស |
| (៣) | អត្រានៃការកើតឡើង (frequency) និងតម្លាភាពនៃការផ្ទេរថវិកាដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន | C | C | ការផ្ទេរថវិកាក្នុងឆ្នាំ មានចំនួនច្រើននិងកើតឡើងច្រើនដង ប៉ុន្តែ មានតម្លាភាព ។ |

**ប្រអប់ គ.១៥÷ ការងារកែទម្រង់កំពុងអនុវត្ត**

សមាសធាតុ (២)÷ នៅពេលប្រព័ន្ធ FMIS ដំណាក់កាលទី ១ ត្រូវបានផ្សព្វផ្សាយក្នុងខែកក្កដា ឆ្នាំ២០១៥, ជាពិសេសក្នុងបរិបទការអនុវត្ត និងការត្រួតពិនិត្យថវិកា, ព័ត៌មានចំពោះក្រសួង-ស្ថាប័ន លើពិដានសម្រាប់ការធានាចំណាយ នឹងកាន់តែមានភាពជឿជាក់។ ការពង្រីក ការអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០១៥ ត្រូវបានរំពឹងទុកថានឹងអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន កាន់តែច្រើនកាត់បន្ថយសំណើវិភាជន៍ឡើងវិញនៅពេលអនាគត។

## គ.៤.៥ ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់ បំណុល និងការធានា (PI-17)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃកំណត់ត្រាបំណុល, ការគ្រប់គ្រងបំណុល និងការប្រមូលសរុប និងត្រួតពិនិត្យសមតុល្យសាច់ប្រាក់រដ្ឋាភិបាលជារួម។ ការវាយតម្លៃសមាសធាតុ (១) និងសមាសធាតុ (២) ត្រូវបានធ្វើឡើងនៅឆ្នាំវាយតម្លៃ ចំណែកឯសមាសធាតុ (៣) ការវាយតម្លៃត្រូវផ្អែកលើការវាស់វែងសមិទ្ធកម្មក្នុងឆ្នាំសារពើពន្ធដែលបានបញ្ចប់ចុងក្រោយ។

### (១) គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៣ បំណុលសាធារណៈ នៅកម្ពុជា មាន ២៧% នៃ ផ.ស.ស (រួមទាំងបំណុលមរតកសល់ពីសម័យសង្គ្រាមដែលកំពុងត្រូវបានដោះស្រាយ)។ នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល (DCDM) នៃអគ្គនាយកដ្ឋានថវិកា មានទំនួលខុសត្រូវក្នុងការកត់ត្រាទិន្នន័យបំណុលក្នុងស្រុក និងបរទេស។ ប្រព័ន្ធទិន្នន័យសម្រាប់ការកត់ត្រាបំណុលសាធារណៈ មានឈ្មោះថា ប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ

UNCTAD (DMFAS)។ ប្រព័ន្ធនេះត្រូវបានដំឡើងនៅនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលដើម្បីគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ និងត្រូវបានភ្ជាប់ទៅនឹងអគ្គនាយកដ្ឋានរតនាគារជាតិ, នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទាញយករបាយការណ៍។ ប្រព័ន្ធ DMFAS មានសមត្ថភាពកត់ត្រាបំណុល, ការដកសាច់ប្រាក់ និងសេវាបំណុល។ ប៉ុន្តែប្រព័ន្ធនេះមិនមានបណ្តាញភ្ជាប់ជាមួយ KIT នៅអគ្គនាយកដ្ឋានរតនាគារជាតិទេ។ ដោយឡែក ការបញ្ចូលទិន្នន័យទាំងអស់ត្រូវបានធ្វើឡើងដោយនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល។

បើទោះបីជាមានបណ្តាញអេឡិចត្រូនិចសម្រាប់តភ្ជាប់រវាងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល និងអគ្គនាយកដ្ឋានរតនាគារជាតិ ដែលអនុញ្ញាតឱ្យអគ្គនាយកដ្ឋានរតនាគារជាតិអាចទាញយករបាយការណ៍ដោយផ្ទាល់ក៏ដោយ, ឯកសាររដ្ឋបាលជាក្រដាសស្នាម នៅតែត្រូវបានស្នើសុំ និងបញ្ជូនទៅកាន់រតនាគារជាតិដដែល ដើម្បីកត់ត្រាក្នុងប្រព័ន្ធគណនេយ្យ។

ការផ្ទៀងផ្ទាត់រវាងការកត់ត្រានៅក្នុងប្រព័ន្ធ DMFAS និងការកត់ត្រារបស់ឥណទាយី (Creditor) ត្រូវបានរៀបចំប្រចាំឆ្នាំ នៅពេលដែលនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទទួលបានសំណើសុំទូទាត់ ពីឥណទាយី។ នេះជាយន្តការត្រង់ ព្រោះមានតែគណនីរបស់ដៃគូអភិវឌ្ឍន៍ ចំនួន ១៤ និងឥណទាយីក្នុងស្រុកតែមួយប៉ុណ្ណោះ (បំណុលដែលមិនអាចជួញដូរបានលើការធ្វើមូលធនីយកម្មឡើងវិញរបស់ក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ)។

របាយការណ៍ស្ថានភាពបំណុល (រាប់បញ្ចូលបំណុលដុល, សេវាបំណុល និងការគ្រប់គ្រងបំណុល) ត្រូវបានរៀបចំនិងបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ និងធនាគារជាតិនៃកម្ពុជា ជារៀងរាល់ខែ, ទៅកាន់ធនាគារពិភពលោកជារៀងរាល់ត្រីមាស និងគោរពជូននាយករដ្ឋមន្ត្រី, រដ្ឋសភា និងព្រឹទ្ធសភា ជារៀងរាល់ឆមាស ព្រមទាំងស្ថាប័នដទៃទៀតតាមការស្នើសុំ។

បើទោះបីជាការកត់ត្រាបំណុលត្រូវបានពិនិត្យឃើញថាពេញលេញ និងមានរបាយការណ៍ជារៀងរាល់ខែ ប៉ុន្តែការផ្ទៀងផ្ទាត់ជាមួយឥណទាយី គឺធ្វើឡើងជារៀងរាល់ឆ្នាំ។

សមាសធាតុនេះ ទទួលបានពិន្ទុ C ព្រោះការកត់ត្រាបំណុលក្នុងស្រុក និងបរទេស មានភាពពេញលេញ និងត្រូវបានធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់របាយការណ៍កត់ត្រាបំណុលជាមួយឥណទាយីជារៀងរាល់ឆ្នាំ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យការផ្ទៀងផ្ទាត់នេះត្រូវធ្វើឡើងជារៀងរាល់ត្រីមាស។

### (២) វិសាលភាពនៃការប្រមូលសរុបសមតុល្យសាច់ប្រាក់របស់រដ្ឋាភិបាល

ក្នុងពេលនៃការផ្តល់សុពលភាពលើការវាយតម្លៃផ្ទៃក្នុង ពីទីប្រឹក្សាខាងក្រៅ (៩ កក្កដា ២០១៥), រាជរដ្ឋាភិបាលកម្ពុជាមានគណនីដែលកំពុងដំណើរការចំនួន ១ ០៣៧ នៅធនាគារជាតិកម្ពុជា ដែល ៤៤៧ គណនីជាប្រាក់រៀល ហើយ ៥៩០ គណនីទៀត ជាប្រាក់ដុល្លារ[34]។ ភាគច្រើននៃគណនីនេះគឺជាគណនីគម្រោងដែលត្រូវបាន

[34] នៅចុងឆ្នាំ២០១៤, ធនាគារជាតិកម្ពុជា មាន១៣០០ គណនី ជាមួយទីភ្នាក់ងាររាជរដ្ឋាភិបាល ដែលមានប្រាក់ចំនួន ១៦.២៣៦ ពាន់លានរៀល, កំណើនសុទ្ធ ២៦៦ ក្នុងឆ្នាំ។ តាមការពិត គណនីថ្មី ៣៩៩ ត្រូវបានបើកនៅឆ្នាំ២០១៤ សម្រាប់ទីភ្នាក់ងារក្រសួង និងអង្គភាពក្រោមឱវាទ ដែលទទួលបានរជ្ជទេយ្យបុរេប្រទាន

បើកតាមការស្នើសុំរបស់ដៃគូអភិវឌ្ឍន៍។ បើទោះបីជាមានការត្រួតពិនិត្យម៉ត់ចត់លើការបើកគណនីថ្មី ដែលការបើកគណនីថ្មីនេះអាចធ្វើទៅបាន តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់, ប៉ុន្តែមានការកត់សម្គាល់ឃើញថា ចំនួនគណនីមិនមានការថយចុះទេចាប់តាំងពីឆ្នាំ២០១០មក គឺមានតែកើនឡើងប៉ុណ្ណោះ។ យោងតាមការវាយតម្លៃផ្ទៃក្នុង មិនមានគណនីធនាគាររបស់រាជរដ្ឋាភិបាលដំណើរការក្រៅគណនីទោលរតនាគារជាតិឡើយ លើកលែងតែគណនីធនាគារសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដែលត្រូវបានគ្រប់គ្រងដោយអង្គភាពអនុវត្តគម្រោងនៅតាមក្រសួង-ស្ថាប័ន និងត្រូវបានត្រួតពិនិត្យដោយនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល។

សមតុល្យសាច់ប្រាក់គណនីទោលរតនាគារជាតិទាំងពីរ និងសមតុល្យសាច់ប្រាក់គណនីផ្សេងទៀតរបស់រាជរដ្ឋាភិបាល ត្រូវបានរាយការណ៍ជាប្រចាំថ្ងៃដោយធនាគារជាតិនៃកម្ពុជា ទៅកាន់អគ្គនាយកដ្ឋានរតនាគារជាតិ។ សាច់ប្រាក់សរុបប្រចាំថ្ងៃ ត្រូវបានរាយការណ៍ និងជាធាតុចូលមួយនៃការគ្រប់គ្រងសាច់ប្រាក់។ លើសពីនេះទៅទៀត វិសាលភាពគណនីទោលរតនាគារ ត្រូវបានពង្រីកទៅកាន់រាជធានី-ខេត្ត តាមរយៈការប្រើប្រាស់ធនាគារពាណិជ្ជមានដូចជា ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និងធនាគារឯកទេសវីង (Wing)។

ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់របស់គម្រោងក្រោមហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធធនាគារដែលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល។

មានការយឺតយ៉ាវខ្លះ ក្នុងការផ្ទេរសាច់ប្រាក់ពីចំណូលពន្ធដារ ចំណូលពន្ធគយ និងចំណូលមិនមែនសារពើពន្ធដែលប្រមូលបានដោយក្រសួង-ស្ថាប័ន ដែលប្រការនេះនាំឱ្យសាច់ប្រាក់មួយចំនួនស្ថិតនៅក្រៅគណនីទោលរតនាគារ និងការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរតនាគារជាតិ (សូមមើលសូចនាករសមិទ្ធកម្មទី ១៥ សមាសធាតុ ៣)។

សមាសធាតុនេះ ទទួលបានពិន្ទុ B ដោយហេតុថា សមតុល្យសាច់ប្រាក់ពីគ្រប់គណនីចំណូលរបស់រដ្ឋាភិបាលទាំងអស់ត្រូវបានគណនា និងបូកសរុបយ៉ាងហោចណាស់ប្រចាំសប្តាហ៍។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យចំណូលសាច់ប្រាក់ទាំងអស់ត្រូវបញ្ចូលទៅក្នុងគណនីចំណូលរបស់រដ្ឋាភិបាល និងមានរបាយការណ៍បូកសរុបសមតុល្យសាច់ប្រាក់ទាំងអស់ប្រចាំថ្ងៃ។

### (៣) ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការធានា

មាត្រា ៦៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានបញ្ជាក់ថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាស្ថាប័នរាជរដ្ឋាភិបាលតែមួយគត់ដែលត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាខ្ចី និងចេញផ្សាយការធានារបស់រាជរដ្ឋាភិបាល។ ច្បាប់នេះក៏បញ្ជាក់ដែរថាកម្ចីនិងពិដានការធានារបស់រដ្ឋត្រូវកំណត់ឱ្យច្បាស់ក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ។

---

និងចំណាយផ្សេងទៀតដោយផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ តាមលិខិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២១៦ សហវ/អរត ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៤ (របាយការណ៍ប្រចាំឆ្នាំធនាគារជាតិកម្ពុជា ឆ្នាំ២០១៤, ទំព័រ ២៦)។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបោះផ្សាយយុទ្ធសាស្ត្រគ្រប់គ្រងបំណុល (២០១១ - ២០១៨) ក្នុងឆ្នាំ ២០១១ ដែលកំពុងត្រូវបានធ្វើបច្ចុប្បន្នកម្មសម្រាប់ឆ្នាំ២០១៥ - ២០១៨។ ជាមួយនឹងការត្រៀមដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន (គម្រោងចំនួន ១៣ ក្នុងវិស័យថាមពល ដែលកំពុងស្ថិតក្នុងដំណាក់កាលរៀបចំ), គោលនយោបាយ និងគោលការណ៍ណែនាំលើការគ្រប់គ្រងហានិភ័យ ត្រូវបានរៀបចំ និងអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ។ ការងារនេះពាក់ព័ន្ធនឹងការកំណត់ពិដានសម្រាប់បំណុល និងការធានារបស់រដ្ឋ។

នាពេលបច្ចុប្បន្ន, ពិដានកម្ចី ត្រូវបានកំណត់នៅក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ។ លើសពីនេះ, កម្ចីត្រូវពឹងផ្អែកទៅលើលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងបំណុល។ ប៉ុន្តែមិនទាន់មាននីតិវិធីជាក់លាក់ និងការកំណត់ពិដានសម្រាប់ការធានារបស់រដ្ឋឡើយ។ យោងរបាយការណ៍ពិគ្រោះយោបល់មាត្រា៤ របស់ IMF ឆ្នាំ២០១៤ (2014 Article 4 IMF Consultation Report), "កាតព្វកិច្ចបំណុលជាយថាហេតុ (contigent liability) ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍគម្រោងបង្កើតថាមពល ក្រោមភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (PPPs) បង្កឱ្យមានហានិភ័យហិរញ្ញវត្ថុ គួរឱ្យកត់សម្គាល់។ ទំហំគម្រោង (ប្រហែលជា ៥០% នៃ ផ.ផ.ស ឆ្នាំ២០១១) និងភាពលំបាកក្នុងការកំណត់បរិមាណបំណុលពីពេលមុនៗ ទាមទារឱ្យមានការត្រួតពិនិត្យបន្តបន្ទាប់ និងត្រូវប្រុងប្រយ័ត្នខ្ពស់។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានរៀបចំអនុក្រឹត្យ ដើម្បីអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈដែលទើបបោះផ្សាយថ្មីៗ ដើម្បីពង្រឹងការវាយតម្លៃ, ការចុះកិច្ចសន្យា និងការត្រួតពិនិត្យកាតព្វកិច្ចបំណុលជាយថាហេតុ រួមទាំងការរៀបចំការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់សម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន និងការអភិវឌ្ឍគោលនយោបាយការធានាថ្មីមួយ។ ទោះជាយ៉ាងណាក៏ដោយ គម្លាតព័ត៌មាននៅតែមាន រវាងភ្នាក់ងាររាជរដ្ឋាភិបាលលើទំហំនិងស្ថានភាពកិច្ចសន្យា និងការធានារបស់រដ្ឋ"។

ការចុះកិច្ចសន្យាកម្ចី និងការធានារបស់រដ្ឋ ត្រូវបានអនុញ្ញាតដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់ ប៉ុន្តែការរៀបចំគោលការណ៍ណែនាំនិងលក្ខខណ្ឌវិនិច្ឆ័យលើការធានារបស់រដ្ឋ មិនទាន់ត្រូវបានបញ្ចប់ទាំងស្រុងនៅឡើយទេ។

សមាសធាតុនេះ ទទួលបានពិន្ទុ C ព្រោះការចុះកិច្ចសន្យាកម្ចី និងការធានារបស់រដ្ឋ ត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថិតក្នុងដែនកំណត់នៃបំណុលសរុប។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យមានការកំណត់ពិដាននៃការធានារបស់រដ្ឋ ហើយគោលការណ៍ណែនាំនិងលក្ខខណ្ឌវិនិច្ឆ័យត្រូវបានរៀបចំ និងអនុវត្តតាម។

**តារាង គ.២៧÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៧**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-17 | **ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M2 |

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| (១) | គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល | C | C | ការកត់ត្រាបំណុលក្នុងស្រុក និងបរទេស មានភាពពេញលេញ ធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍ឥណទាយីជារៀងរាល់ឆ្នាំ |
| (២) | វិសាលភាពនៃការប្រមូលសរុបសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល | B | B | សមតុល្យសាច់ប្រាក់ភាគច្រើនត្រូវបានគណនា និងបូកសរុបយ៉ាងហោចណាស់មួយសប្តាហ៍ម្តង។ |
| (៣) | ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការចេញផ្សាយការធានា | C | C | ការចុះកិច្ចសន្យាខ្ចីនិងការធានារបស់រដ្ឋ ត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងដែនកំណត់សម្រាប់បំណុលសរុប ប៉ុន្តែមិនទាន់មាននីតិវិធីច្បាស់លាស់សម្រាប់ការធានារបស់រដ្ឋ។ |

**ប្រអប់ គ.១៦÷ ការងារកែទម្រង់កំពុងអនុវត្ត**

សមាសធាតុ (៣)÷ តាមរយៈផែនការសកម្មភាពដំណាក់កាលទី២ ថ្មី , នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល បានរៀបចំផែនការសកម្មភាព លើការរៀបចំប្រកាសស្តីពីការធានាររបស់រដ្ឋ ដើម្បីកំណត់នីតិវិធី និងគោលការណ៍ណែនាំឱ្យច្បាស់លាស់ រួមទាំងការកំណត់ពិដានការធានារបស់រដ្ឋធៀបទៅនឹង ផ.ស.ស។

## គ.៤.៦ ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស (PI-18)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើប្រសិទ្ធភាពនៃប្រព័ន្ធបើកប្រាក់បៀវត្ស។ វិសាលភាពនៃសូចនាករនេះ គឺគ្របដណ្តប់លើគ្រប់បញ្ជីប្រាក់បៀវត្សទាំងអស់នៅរដ្ឋបាលថ្នាក់ជាតិ ដោយរួមទាំងគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពស្វយ័តនានា។ សូចនាករនេះ ផ្តោតលើការធ្វើសមាហរណកម្មនិងការផ្ទៀងផ្ទាត់រវាង ប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស, ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិកនិងបញ្ជីប្រាក់បៀវត្ស, ការត្រួតពិនិត្យផ្ទៃក្នុង, និងការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច។

សូចនាករនេះមាន ៤ សមាសធាតុ គឺ (១) ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស (២) ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិកនិងបញ្ជីប្រាក់បៀវត្ស (៣) ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស និង (៤) ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច។ ការវាយតម្លៃទៅលើសមាសធាតុខាងលើ ត្រូវបានធ្វើឡើងសម្រាប់ការអនុវត្តក្នុងឆ្នាំ២០១១, ២០១២ និង២០១៣ លើកលែងតែសមាសធាតុទី៤ ដែលត្រូវបានវាយតម្លៃ សម្រាប់ការអនុវត្តក្នុងឆ្នាំ២០១២,២០១៣ និង២០១៤។

ផ្អែកលើច្បាប់ទូទាត់ថវិកាឆ្នាំ២០១៣, ចំណាយសម្រាប់ប្រាក់បៀវត្សមានចំនួន ៤២,៣% នៃថវិកាជាតិសរុប។ ក្នុងឆ្នាំ២០១៤ ចំណាយលើប្រាក់បៀវត្សមានចំនួន ១៣ ២៦៥ ពាន់លានរៀល។ ជាធម្មតា ចំណាយលើប្រាក់បៀវត្ស

គឺជាបន្ទុកចំណាយដ៏ធំសម្រាប់រដ្ឋាភិបាល ប៉ុន្តែយន្តការសម្រាប់ត្រួតពិនិត្យលើចំណាយនេះ នៅតែមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដែលពេលខ្លះមានលេចឡើងនូវភាពមិនប្រក្រតីមួយចំនួនលើមុខចំណាយនេះ។

ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានដំឡើងលេខាធិការដ្ឋានមុខងារសាធារណៈ ទៅជាក្រសួងមុខងារសាធារណៈ ដែលជាក្រសួងទទួលខុសត្រូវក្នុងការគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបញ្ជីប្រាក់បៀវត្ស។ បច្ចុប្បន្ន មន្ត្រីរាជការមានប្រមាណ ២០០ ០០០ នាក់ ដែលក្នុងនោះ ១៨០ ០០០ នាក់ គឺជាមន្ត្រីរាជការក្របខ័ណ្ឌដែលអាចទទួលបានប្រាក់សោធននិវត្តន៍។ ក្រសួងបានប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស (Human Resource Management Information System-HRMIS) ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ SQL Database។ ប្រព័ន្ធនេះ បានរក្សាទុកទិន្នន័យមន្ត្រីរាជការនៅតាមក្រសួង-ស្ថាប័ន (ប្រមាណ ១៩%) និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រមាណ ៨១%)។

ក្រៅពីបញ្ជីប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល, មានបញ្ជីប្រាក់បៀវត្សផ្សេងៗទៀត ដែលមានដូចជា ១-បញ្ជីប្រាក់បៀវត្សសម្រាប់កងកម្លាំងប្រដាប់អាវុធការពារជាតិ គ្រប់គ្រងដោយក្រសួងការពារជាតិ ២-បញ្ជីប្រាក់បៀវត្សសម្រាប់នគរបាល គ្រប់គ្រងដោយក្រសួងមហាផ្ទៃ និង ៣-បញ្ជីប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការស្ថិតក្នុងលក្ខន្តិកៈដោយឡែក ដូចជាមន្ត្រីរាជការនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ព្រះបរមរាជវាំង អាជ្ញាធរសវនកម្មជាតិ ស្ថានតំណាងកម្ពុជានៅបរទេស និងមន្ត្រីរាជការ ប្រមាណ ៣៨% ដែលត្រូវបានតែងតាំងក្នុងកម្រិតនយោបាយ (អនុរដ្ឋលេខាធិការឡើងទៅ) ហើយដែលបញ្ជីប្រាក់បៀវត្សសម្រាប់មន្ត្រីទាំងនេះ មិនត្រូវបានធ្វើការវាយតម្លៃឡើយ។

បញ្ជីប្រាក់បៀវត្ស ត្រូវបានរៀបចំឡើងនៅតាមក្រសួង-ស្ថាប័ននីមួយៗ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មន្ទីរនៅតាមរាជធានី-ខេត្ត។ ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡា មានមន្ត្រីរាជការទាំងនៅថ្នាក់ក្រសួង និងមន្ទីរតាមរាជធានី-ខេត្ត សរុបប្រមាណ ១១៥ ០០០នាក់។ ចំណែកក្រសួងសុខាភិបាល មានមន្ត្រីរាជការប្រមាណ ២០ ០០០ នាក់ ដែលក្នុងនោះ មាន ២៨% នៅថ្នាក់កណ្តាល និង ៧២% នៅតាមរដ្ឋបាលរាជធានី-ខេត្ត។

ការតែងតាំងមន្ត្រីត្រូវធ្វើឡើងត្រឹមក្របខ័ណ្ឌក្រសួង-ស្ថាប័នសាមី ដោយមានការឯកភាពពីក្រសួងមុខងារសាធារណៈ សម្រាប់មុខដំណែងអនុប្រធាននាយកដ្ឋានចុះក្រោម ចំណែកឯការតែងតាំងដំណែងចាប់ពីប្រធាននាយកដ្ឋានឡើងទៅ ត្រូវចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិ តាមរយៈប្រព័ន្ធ HRMIS ដោយផ្អែកលើថ្ងៃ ខែ ឆ្នាំកំណើត ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធនេះ។ ក្រសួង-ស្ថាប័ននីមួយៗ មិនទាន់បានភ្ជាប់បណ្តាញទៅនឹងប្រព័ន្ធ HRMIS ទេ។ ក្រសួង-ស្ថាប័នភាគច្រើន រក្សាទុកស្ថានភាពមន្ត្រីរាជការរបស់ខ្លួនដោយប្រើប្រាស់តារាងក្នុង Microsoft Excel និងធ្វើការទាក់ទងជាមួយក្រសួងមុខងារសាធារណៈ តាមរយៈការបញ្ជូនឯកសារទៅវិញទៅមក។ ក្រសួង-ស្ថាប័ននីមួយៗ រៀបចំតារាងបញ្ជីប្រាក់បៀវត្ស និងបញ្ជូនជារៀងរាល់ខែ ទៅក្រសួងមុខងារសាធារណៈ។ នាយកដ្ឋានព័ត៌មានវិទ្យា និងគណនេយ្យ នៃក្រសួងក្រសួងមុខងារសាធារណៈ ផ្ទៀងផ្ទាត់បញ្ជីប្រាក់បៀវត្សដែលទទួលបាន ជាមួយនឹងប្រព័ន្ធទិន្នន័យ HRMIS។ បន្ទាប់ពីពិនិត្យឃើញថាត្រឹមត្រូវហើយ ទើបក្រសួងមុខងារសាធារណៈរៀបចំបញ្ជីប្រាក់បៀវត្សសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ។ ការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីប្រាក់បៀវត្សនេះ ត្រូវឆ្លងកាត់នីតិវិធីវែងអន្លាយដែលរួមមាន ការត្រួតពិនិត្យរបស់

ក្រសួងមុខងារសាធារណៈ ការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំក្រសួង-ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរតនាគារជាតិ ជាអ្នកបញ្ចេញថវិកាចំណាយសម្រាប់ប្រាក់បៀវត្សទាំងអស់ ដោយផ្ទេរថវិកាទាំងនោះទៅគណនីប្រាក់បៀវត្សសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ។ បន្ទាប់មក ក្រសួង-ស្ថាប័នសាមី បង្វែរប្រាក់បៀវត្សទៅកាន់គណនីផ្ទាល់ខ្លួនរបស់មន្ត្រីរាជការម្នាក់ៗ នៅក្នុងក្រសួង។ ក្រសួង-ស្ថាប័នមួយចំនួន បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន (WING) ឱ្យជួយសម្រួលការបើកប្រាក់បៀវត្សនេះ ដោយចេញជាមូលប្បទានបត្រ (cheques) សម្រាប់មន្ត្រីរាជការនីមួយៗ។

### (១) ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស

ក្រសួង-ស្ថាប័ននីមួយៗ មិនទាន់មានប្រព័ន្ធភ្ជាប់ជាស្វ័យប្រវត្តិទៅនឹង HRMIS ដើម្បីធានាសង្គតិភាពនៃទិន្នន័យទេ។ ការរៀបចំបញ្ជីប្រាក់បៀវត្សនៅក្នុងតារាង Microsoft Excel មិនមានសុវត្ថិភាពខ្ពស់ឡើយ ហើយក៏គ្មានការធ្វើសវនកម្មទៅលើតារាងនៅក្នុង Microsoft Excel ដែរ។ ទិន្នន័យនៃការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការ នៅតាមក្រសួង-ស្ថាប័ន ត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ ជាក្រដាសស្នាម ដែលពេលខ្លះឯកសារទាំងនេះមានការកែសម្រួលជាញឹកញាប់ និងបញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត។ ការអនុវត្តបែបនេះ ពិតជាពិបាកធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងបញ្ជីប្រាក់បៀវត្ស និងមន្ត្រីរាជការណាស់ និងថែមទាំងនាំឱ្យខាតពេលវេលាក្នុងការកែសម្រួលបញ្ជីប្រាក់បៀវត្ស និងស្ថានភាពមន្ត្រីរាជការទៀតផង។

ក្រសួងមុខងារសាធារណៈ ធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស និងស្ថានភាពមន្ត្រីរាជការ ជាប្រចាំខែ ដោយផ្អែកលើរបាយការណ៍ដែលក្រសួង-ស្ថាប័ន បានផ្ញើមក។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ B ដោយសារបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ មានភ្ជាប់មកជាមួយឯកសារយោងគ្រប់គ្រាន់ ហើយ ក្រសួង-ស្ថាប័នបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ លើបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ។ ពិន្ទុអាចនឹងទទួលបានខ្ពស់ជាងនេះ ប្រសិនបើមានការភ្ជាប់គ្នាជាប្រព័ន្ធរវាងទិន្នន័យមន្ត្រីរាជការទៅនឹងបញ្ជីប្រាក់បៀវត្ស។

### (២) ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិកនិងបញ្ជីប្រាក់បៀវត្ស

ក្រសួងមុខងារសាធារណៈ ធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស និងស្ថានភាពមន្ត្រីរាជការប្រចាំខែ ដោយផ្អែកលើរបាយការណ៍ដែលក្រសួង-ស្ថាប័ន បានផ្ញើមក។

កិច្ចសម្ភាសន៍ជាមួយក្រសួង-ស្ថាប័នមួយចំនួន លើការធ្វើបច្ចុប្បន្នភាពនៃការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការ និងបញ្ជីប្រាក់បៀវត្ស បានបង្ហាញថាការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការមិនត្រូវបានធ្វើបច្ចុប្បន្នភាពទាន់ពេលវេលាទេ ដោយសារតែក្រសួង-ស្ថាប័នមួយចំនួន មិនបានរាយការណ៍ពីការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការនៅក្រសួង-ស្ថាប័នរបស់ខ្លួនទៅក្រសួងមុខងារសារធារណៈ បានទាន់ពេលវេលា ទោះបីជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំតាមរយៈសារាចរ កុំឱ្យមានភាពយឺតយ៉ាវក្នុងការរៀបចំការបើកប្រាក់បៀវត្សក៏ដោយ។ ភាពយឺតយ៉ាវនៃការបញ្ជូន

របាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពមន្ត្រីពីក្រសួង-ស្ថាប័ន ទៅក្រសួងមុខងារសាធារណៈ អាចមានចាប់ពី ១ខែ ទៅ ៣ខែ (ហើយមានករណីមួយចំនួនទៀត គឺយូរជាងនេះ)។ ហេតុនេះហើយ មន្ត្រីរាជការមួយចំនួន ដែលបានកែសម្រួលឋានៈ និងតួនាទីរបស់ខ្លួនរួចហើយនោះ ត្រូវរង់ចាំរហូតដល់បីខែ ទើបទទួលបានប្រាក់បៀវត្សសមស្របទៅនឹងឋានៈ និងតួនាទីថ្មីរបស់ខ្លួន។

លើសពីនេះ នាយកដ្ឋានបុគ្គលិកនៅតាមក្រសួង-ស្ថាប័ន បានបង្កភាពសាំញ៉ាំមួយចំនួន ដូចជា ការណ៍ដែលតម្រូវឱ្យបុគ្គលិកទាំងអស់ បង្ហាញខ្លួន បំពេញទម្រង់ និងរាយការណ៍ពីការផ្លាស់ប្តូរស្ថានភាពរបស់ខ្លួន ក្នុងខណៈដែលនាយកដ្ឋានបុគ្គលិក មានព័ត៌មានស្តីពីការផ្លាស់ប្តូរស្ថានភាពទាំងនោះរួចហើយ។ ជាលទ្ធផល មានមន្ត្រីរាជការមួយចំនួន មានការយឺតយ៉ាវក្នុងការរាយការណ៍ពីការផ្លាស់ប្តូរស្ថានភាពរបស់ខ្លួនទៅនាយកដ្ឋានបុគ្គលិក ដែលជាហេតុនាំឱ្យមានការកែសម្រួលការចំណាយទៅលើបុគ្គលិក ហើយបានកាត់បន្ថយភាពជឿទុកចិត្តនៃថវិកា និងប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រីរាជការ និងបញ្ជីប្រាក់បៀវត្ស។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ C ដោយសារតែមានការយឺតយ៉ាវរហូតដល់ទៅ៣ខែ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស ព្រមទាំងមានការកែសម្រួលលើបញ្ជីទាំងនោះ (ប្រហែល ៣០%)។ ពិន្ទុអាចនឹងទទួលបានខ្ពស់ជាងនេះ ប្រសិនបើមានការកាត់បន្ថយការកែសម្រួលលើបញ្ជីប្រាក់បៀវត្ស។

### (៣) ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស

ដូចបានរៀបរាប់ខាងលើ ក្រសួងមុខងារសាធារណៈ ផ្ទៀងផ្ទាត់ព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្សប្រចាំខែ ដោយផ្អែកលើរបាយការណ៍ដែលក្រសួង-ស្ថាប័ន បានផ្ញើមក។ នីតិវិធីនៃការផ្ទៀងផ្ទាត់ តម្រូវឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិនិត្យមើលឱ្យបានហ្មត់ចត់នូវតារាងមន្ត្រីរាជការ និងបញ្ជីប្រាក់បៀវត្សរបស់ខ្លួន មុននឹងផ្ញើមកក្រសួងមុខងារសាធារណៈ ដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធចាំបាច់មួយចំនួន។ ជារួម តារាងស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្សមានភាពច្បាស់លាស់ ទោះបីជាគ្មានការធ្វើសវនកម្មទៅលើតារាងទាំងនោះក៏ដោយ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ B ដោយសារតារាងស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្សមានភាពច្បាស់លាស់ ទោះបីជាគ្មានការធ្វើសវនកម្មទៅលើតារាងទាំងនោះក៏ដោយ។ ពិន្ទុអាចទទួលបានខ្ពស់ជាងនេះ ប្រសិនបើមានការធ្វើសវនកម្មទៅលើតារាងស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្ស។

### (៤) ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មជាប្រចាំឆ្នាំ លើក្រសួង-ស្ថាប័ន ប៉ុន្តែមិនបានធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សទេ រីឯរបាយការណ៍សវនកម្ម ក៏មិនបានរំលេចរបកគំហើញលើការគ្រប់គ្រងបញ្ជីប្រាក់បៀវត្សដែរ។ ក្រុមការងារវាយតម្លៃមិនបានទទួលរបាយការណ៍សវនកម្មស្តីពីភាពមិនប្រក្រតី ចំពោះចំណាយលើប្រាក់បៀវត្ស ឬចំនួនមន្ត្រីខ្មោចនៅតាមក្រសួង-ស្ថាប័នទេ។ ទន្ទឹមនេះ សវនកម្មផ្ទៃក្នុង ក៏ត្រូវបានធ្វើនៅតាមក្រសួង-ស្ថាប័នដែរ។ ប៉ុន្តែការធ្វើសវនកម្ម ផ្តោតជាសំខាន់លើបញ្ជីវត្តមានមន្ត្រី តែមិនបានផ្តោតការយកចិត្តទុកដាក់លើចំណាយប្រាក់បៀវត្សឡើយ។ នៅក្នុងក្រសួងសាធារណៈការនិងដឹកជញ្ជូន សវនកម្មផ្ទៃក្នុង ផ្តោតលើផ្នែកដែលមានហានិភ័យ ដូចជាមន្ត្រី

ដែលមានឈ្មោះជាន់គ្នា និងមន្ត្រីរាជការដែលត្រូវដាក់ឱ្យចូលនិវត្តន៍។ ដូចគ្នាដែរ នៅក្នុងក្រសួងអប់រំ យុវជន និងកីឡា សវនកម្មផ្ទៃក្នុង មិនបានផ្តោតទៅលើចំណាយប្រាក់បៀវត្សទេ ដោយសារថាវាមិនមែនជាថវិកាកម្មវិធី។ សវនកម្មផ្ទៃក្នុង ផ្តោតការស៊ើបអង្កេតទៅលើការអនុវត្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ អធិការកិច្ចផ្តោតការស៊ើបអង្កេតទៅលើ ការតវ៉ារបស់គ្រូបង្រៀន ចំពោះប្រាក់បៀវត្ស ប៉ុន្តែមិនត្រួតគ្នាជាមួយការធ្វើសវនកម្មផ្ទៃក្នុងឡើយ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ D ដោយសារគ្មានការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ។

**តារាង គ.២៨÷ ពិន្ទុសូចនាករសមិទ្ធកម្មទី ១៨**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-18 | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស** | D+ | D+ | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | គ្មានការភ្ជាប់គ្នាដោយផ្ទាល់រវាងបញ្ជីបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស។ ប៉ុន្តែបញ្ជីប្រាក់បៀវត្ស ប្រចាំខែនីមួយៗ មានភ្ជាប់មកជាមួយឯកសារយោងគ្រប់គ្រាន់ហើយក្រសួង-ស្ថាប័ន បានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ទៅលើបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ។ |
| (២) | ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិកនិងបញ្ជីប្រាក់បៀវត្ស | C | C | មានការយឺតយ៉ាវ រហូតដល់ទៅ៣ខែ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស ព្រមទាំងមានការកែសម្រួលលើបញ្ជីទាំងនោះ (ប្រហែល ៣០%) |
| (៣) | ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | តារាងស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្ស មានភាពច្បាស់លាស់ ទោះបីជាគ្មានការធ្វើសវនកម្មទៅលើតារាងទាំងនោះក៏ដោយ។ |
| (៤) | ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច | D | D | គ្មានការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សឱ្យបានគ្រប់ជ្រុងជ្រោយក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ |

**ប្រអប់ គ.១៧ ៖ ការងារកែទម្រង់កំពុងអនុវត្ត**

ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ ២០១៥។ ប្រព័ន្ធ FMIS នេះអាចជួយភ្ជាប់ព័ត៌មានស្ដីពីមន្ត្រីរាជការ ទៅនឹងប្រព័ន្ធទិន្នន័យដែលគ្រប់គ្រងដោយក្រសួង-មុខងារសាធារណៈ។ ដូច្នេះនៅពេលដែលប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យដំណើរការបានពេញលេញ ព្រមទាំងការគ្រប់គ្រងមន្ត្រីរាជការ និងបញ្ជីប្រាក់បៀវត្សតាមប្រព័ន្ធកុំព្យូទ័រត្រូវបានកែលម្អ ពេលនោះការគ្រប់គ្រប់គ្រងមន្ត្រីរាជការ និងបញ្ជីប្រាក់បៀវត្សកាន់តែមានប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាពថែមទៀត។

## គ.៤.៧ តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម (PI-19)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើប្រសិទ្ធភាពនៃប្រព័ន្ធលទ្ធកម្ម។ សមាសធាតុ (១) ផ្ដោតលើក្របខ័ណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម។ ចំណែកឯសមាសធាតុដទៃទៀតផ្ដោតលើកិច្ចប្រតិបត្តិការនៃប្រព័ន្ធលទ្ធកម្ម។ ការវាយតម្លៃគ្របដណ្ដប់ គ្រប់កិច្ចលទ្ធកម្មនៅថ្នាក់កណ្ដាលទាំងអស់ដែលប្រើប្រាស់នីតិវិធីរបស់រដ្ឋាភិបាល ដែលរួមមានក្រសួង ស្ថាប័ន និងអង្គភាពស្វយ័តទាំងអស់ និងលើចំនួនឆ្នាំទាំងអស់ដែលត្រូវវាយតម្លៃលើគ្រប់សមាសធាតុ លើកលែងតែសមាសធាតុ (១) ដែលត្រូវវាយតម្លៃសម្រាប់ឆ្នាំថវិកាបញ្ចប់ចុងក្រោយ។

ចំណាយសាធារណៈមួយភាគធំ (ប្រហែល ៨% នៃ ផ.ស.ស) ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធលទ្ធកម្ម ក្នុងនោះមានប្រមាណ ៩,៥% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៣, ៧,៩% ក្នុងឆ្នាំ២០១៤ និងប្រមាណ ៧,៧% ក្នុងឆ្នាំ ២០១៥។ ប្រព័ន្ធលទ្ធកម្មដែលមានដំណើរការល្អ នឹងធានាថាថវិកាត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងទទួលបាននូវតម្លៃនៃប្រាក់ (Value for Money)។ ដើម្បីសម្រេចបានគោលបំណងនេះ តម្រូវឱ្យមានគោលការណ៍គតិយុត្តស្ដីពីលទ្ធកម្មដែលមានភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងមានតម្លាភាព ហើយវិធីសាស្ត្រនៃកិច្ចលទ្ធកម្មត្រូវអនុវត្តតាមគោលការណ៍ប្រកួតប្រជែងដោយចំហរ, សាធារណជនទូទៅអាចទទួលបានព័ត៌មានស្ដីពីលទ្ធកម្មព្រមទាំងមានយន្តការដោះស្រាយបណ្ដឹងឯករាជ្យ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ជាស្ថាប័នកណ្ដាល ដែលទទួលខុសត្រូវក្នុងកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល។ ចំពោះកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាជំនួយរបស់ដៃគូ ត្រូវប្រើប្រាស់នីតិវិធីលទ្ធកម្មដោយឡែក ដែលកំណត់ដោយដៃគូផ្សេងៗពីគ្នា ហើយមិនស្ថិតនៅក្នុងវិសាលភាពនៃការវាយតម្លៃ PEFA ទេ (សូមពិនិត្យមើល**ផ្នែក ខ.៣** ខាងលើ ស្ដីពីក្របខ័ណ្ឌគតិយុត្ត)។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មិនអនុវត្តកិច្ចលទ្ធកម្មដោយខ្លួនឯងឡើយ។ ការអនុវត្តកិច្ចលទ្ធកម្មត្រូវបានធ្វើវិសហមជ្ឈការទៅឱ្យក្រសួង ស្ថាប័ន និងរាជធានី ខេត្ត នៅឆ្នាំ២០០៥ (ប្រកាសលេខ ៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ)។ ក្រសួង-ស្ថាប័ន មានសិទ្ធិសម្រេច

ពេញលេញ នៅក្នុងកិច្ចលទ្ធកម្មដែលមានកម្រិតទឹកប្រាក់តិចជាង ៥០០ លានរៀល (ប្រហែល ១២៥ ០០០ ដុល្លារអាមេរិក) ដែលពុំទាមទារឱ្យអនុវត្តវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែង។ ចំពោះកិច្ចសន្យាដែលមានទំហំទឹកប្រាក់លើសពី ១២៥ ០០០ ដុល្លារអាមេរិក រហូតដល់ ២៥០ ០០០ ដុល្លារអាមេរិក សម្រាប់ការផ្គត់ផ្គង់ទំនិញ និង ៣០០ ០០០ ដុល្លារអាមេរិក សម្រាប់ការផ្គត់ផ្គង់សេវា គឺតម្រូវឱ្យមានការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក។ កិច្ចសន្យាដែលមានទឹកប្រាក់លើសពីនេះ តម្រូវឱ្យមានការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ។ ក្រសួង-ស្ថាប័នទាំងអស់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលត្រូវទទួលការឯកភាពយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រួតពិនិត្យលើកិច្ចសន្យា ដែលមានទឹកប្រាក់លើសពីទំហំដែលបានកំណត់ ដែលរួមមានការត្រួតពិនិត្យមុននឹងផ្សព្វផ្សាយឯកសារដេញថ្លៃ និងការត្រួតពិនិត្យមុនការប្រគល់កិច្ចសន្យា។ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម ត្រូវបញ្ជូនឯកសារមកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីពិនិត្យភាពត្រឹមត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត និងអនុម័តលើឯកសារទាំងនោះ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មិនចាំបាច់ចុះទៅពិនិត្យដល់ទីកន្លែងទេ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈមិនត្រួតពិនិត្យកិច្ចសន្យា ដែលមានទឹកប្រាក់ក្រោមទំហំដែលបានកំណត់ទេ ប៉ុន្តែតម្រូវឱ្យស្ថាប័នអនុវត្តកិច្ចលទ្ធកម្មនីមួយៗ ផ្ញើរបាយការណ៍ប្រចាំត្រីមាសមកអគ្គនាយកដ្ឋាន។ ទោះបីយ៉ាងណា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មទាំងអស់មិនទាន់អនុវត្តតាមនីតិវិធីជាធរមាននៅឡើយទេ ដោយសារអគ្គ-នាយកដ្ឋានលទ្ធកម្មសាធារណៈមានសិទ្ធិអំណាចតិចតួចក្នុងការបង្ខំឱ្យស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ញើរបាយការណ៍អនុវត្តមកអគ្គនាយកដ្ឋាន។ តាមការប៉ាន់ស្មាន មានស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម ប្រមាណ ៨០%-៩០% បានផ្ញើរបាយ-ការណ៍។ ទោះជាយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មិនអាចពន្យារពេលយល់ព្រមលើឯកសារលទ្ធកម្មរបស់ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មទេ ព្រោះវាអាចប៉ះពាល់ដល់គម្រោង ឬកម្មវិធីដែលជាអាទិភាព។ បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បូកសរុបរបាយការណ៍លទ្ធកម្មដែលស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ញើមកដោយមិនទាន់មានប្រព័ន្ធព័ត៌មានវិទ្យានៅឡើយ ដែលកិច្ចការងារកសាងប្រព័ន្ធគ្រប់គ្រងកិច្ចលទ្ធកម្មតាមព័ត៌មានវិទ្យា កំពុងត្រូវបានរៀបចំដោយទីប្រឹក្សាក្នុងស្រុក។

បច្ចុប្បន្ននេះ កិច្ចលទ្ធកម្មមិនទាន់ត្រូវបានអនុវត្តស្របតាមគោលការណ៍ជំនាញវិជ្ជាជីវៈនៅឡើយទេ។ អគ្គ-នាយកដ្ឋានលទ្ធកម្មសាធារណៈ មិនមានតួលេខមន្ត្រីលទ្ធកម្មសរុបទេ ប៉ុន្តែតាមការប៉ាន់ស្មាន គឺមានប្រមាណ ១ ០០០ នាក់។ ការជ្រើសរើសមន្ត្រីលទ្ធកម្ម ត្រូវគោរពលក្ខខណ្ឌមួយចំនួនពាក់ព័ន្ធនឹងចំណេះដឹងនិងបទពិសោធន៍ ប៉ុន្តែស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមិនបានអនុវត្តទៅតាមលក្ខខណ្ឌនេះទេ និងមិនបានរាយការណ៍មកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អំពីការជ្រើសរើស ឬការផ្លាស់ប្តូរមន្ត្រីលទ្ធកម្ម លើកលែងតែមន្ត្រីដែលត្រូវបានតែងតាំងជាប្រធានការិ-យាល័យលទ្ធកម្ម។ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម អាចផ្លាស់ប្តូរមន្ត្រីលទ្ធកម្មទៅកាន់កន្លែងផ្សេង និងផ្ទេរមន្ត្រីថ្មីមកកាន់ការងារលទ្ធកម្មបាន។ មន្ត្រីលទ្ធកម្មទទួលការបណ្តុះបណ្តាលជាលក្ខណៈចំពោះកិច្ច ដែលរៀបចំដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួន ខ្វះមន្ត្រីលទ្ធកម្ម ដូចជាក្រសួងសាធារណការនិងដឹកជញ្ជូនដែលត្រូវអនុវត្តកិច្ចលទ្ធកម្មក្នុងទឹកប្រាក់ប្រមាណ ២៥១ ពាន់លានរៀល ក្នុងឆ្នាំ២០១៤ មានមន្ត្រីលទ្ធកម្មតែ ១២ នាក់ប៉ុណ្ណោះ។ គោលការណ៍ណែនាំស្តីពីកិច្ចលទ្ធកម្មដែលត្រូវបានរៀបចំ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក

ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៥ ហើយដែលនឹងក្លាយទៅជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលលើកិច្ចលទ្ធកម្ម នាពេលអនាគត។

ក្របខ័ណ្ឌគតិយុត្តសម្រាប់កិច្ចលទ្ធកម្មក្នុងស្រុករួមមាន ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ឆ្នាំ២០១២) និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដែលកំណត់នៅក្នុងច្បាប់នេះ។ បច្ចុប្បន្ននេះ មានអនុក្រឹត្យ ០១ និងប្រកាស ០៥ កំពុងតែត្រូវបានពិនិត្យ និងពិភាក្សា ហើយដែលនឹងត្រូវដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០១៥នេះ។

នៅក្នុងឆ្នាំ២០១១ ការវាយតម្លៃលើកិច្ចលទ្ធកម្មមានការផ្លាស់ប្តូរ។ ដូចនេះ ការប្រៀបធៀបពិន្ទុវាយតម្លៃនៅឆ្នាំ ២០១០ និង ២០១៥ មិនអាចធ្វើទៅបានទេ។

វិធីសាស្ត្រក្នុងការវាយតម្លៃ PEFA នៅឆ្នាំ២០១១ រួមមាន ៤ សមាសធាតុ ដែលវិធីសាស្ត្រ លើកមុនមានតែ ៣ សមាសធាតុប៉ុណ្ណោះ។

### (១) អត្ថិភាពនៃក្របខ័ណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម

សមាសធាតុគន្លឹះនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ឆ្នាំ២០១២) ត្រូវបានវាយតម្លៃ ដូចមានក្នុងតារាង គ.២៩ ខាងក្រោម។ គេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈត្រូវបានបង្កើតនៅឆ្នាំ២០១០ ដើម្បីផ្សព្វផ្សាយព័ត៌មាននានាស្តីពីកិច្ចលទ្ធកម្ម។

**តារាង គ.២៩÷ សមាសធាតុគន្លឹះនៃក្របខ័ណ្ឌនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់លទ្ធកម្ម**

| ក្របខ័ណ្ឌនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់លទ្ធកម្ម÷ | |
|---|---|
| មានការរៀបចំទៅតាមលំដាប់ថានានុក្រម និង មានភាពច្បាស់លាស់ | មាន |
| សាធារណជនអាចទទួលបានព័ត៌មានដោយងាយស្រួលតាមមធ្យោបាយសមស្រប | មាន |
| គ្រប់កិច្ចលទ្ធកម្មទាំងអស់ដែលប្រើប្រាស់ថវិការដ្ឋ ត្រូវអនុវត្តទៅតាមនីតិវិធីលទ្ធកម្មដែលមានចែង | មាន |
| ត្រូវប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងជាចំបាច់។ ប្រសិនបើប្រើប្រាស់វិធីសាស្ត្រផ្សេងពីនេះ ត្រូវមានការពន្យល់ ឱ្យបានសមស្រប | មាន |
| សាធារណជនអាចទទួលបានព័ត៌មានស្តីពី (ក) ផែនការលទ្ធកម្ម (ខ) សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ (គ) លទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា និង (ឃ) ការប្រគល់កិច្ចសន្យា | គ្មាន។ មានតែសេចក្តីជូន ដំណឹងស្តីពីការដេញថ្លៃប៉ុណ្ណោះ |
| មានរៀបចំនីតិវិធីត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្មដោយស្ថាប័នឯករាជ្យមុននឹងចុះហត្ថលេខាលើកិច្ចសន្យា | គ្មាន |

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ឆ្នាំ២០១២) ឆ្លើយតបបានតាមលក្ខខណ្ឌតម្រូវ ចំនួន៤ ក្នុងចំណោម៦។ សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ B ដោយសារឆ្លើយតបបានតាមលក្ខខណ្ឌតម្រូវ៤ ក្នុងចំណោម៦។ ពិន្ទុអាចទទួលបានពិន្ទុខ្ពស់ជាងនេះ ប្រសិនបើលក្ខខណ្ឌទាំង៦ ត្រូវបានបំពេញ។

### (២) ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម

ចាប់តាំងពីឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយបែងចែកគម្រោងក្នុងស្រុក ដោយឈរលើមូលដ្ឋាននៃការដេញថ្លៃ។ គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ត្រូវបានអនុវត្តប្រកបដោយតម្លាភាពជាងគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល។ ផ្អែកលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ការដេញថ្លៃដែលមានលក្ខណៈជាការប្រកួតប្រជែងកម្រិតទាប ត្រូវបានអនុវត្តនៅពេលដែល (១) កិច្ចលទ្ធកម្មមានលក្ខណៈបន្ទាន់ (២) ការផ្គត់ផ្គង់ទំនិញ ឬសេវា មានប្រភពតែ ១ ឬ(៣) អ្នកដែលឈ្នះការដេញថ្លៃ បានបំពានកិច្ចសន្យា ដោយមិនបានផ្គត់ផ្គង់ទំនិញ ឬសេវា តាមការឯកភាពគ្នានៅក្នុងកិច្ចសន្យា។ ចំពោះវិស័យឯកជន ការប្រកួតប្រជែងពិតប្រាកដនៅក្នុងកិច្ចដំណើរការលទ្ធកម្មនៅមានកម្រិតនៅឡើយ។

នៅឆ្នាំ២០១២ ក្នុងចំណោមកិច្ចសន្យាទាំង ២ ៣៥១ ដែលកិច្ចសន្យានីមួយៗមានទឹកប្រាក់លើសពី ១០០ លានរៀល មានកិច្ចសន្យា ១ ៥៧៧ (៦៧%) ត្រូវបានអនុវត្តតាមវិធីសាស្ត្រការប្រកួតប្រជែងពេញលេញ និងកិច្ចសន្យា ៧៧៤ (៣៣%) ត្រូវបានអនុវត្តវិធីសាស្ត្រការប្រកួតប្រជែងកម្រិតទាប។ ក្រុមការងារវាយតម្លៃមិនទទួលបានព័ត៌មានអំពីចំនួនកិច្ចសន្យាតាមវិធីសាស្ត្រប្រកួតប្រជែងកម្រិតទាប ដែលត្រូវបានអនុវត្តតាមនីតិវិធីច្បាប់នោះទេ។ សវនកម្មលើកិច្ចលទ្ធកម្ម ត្រូវបានធ្វើឡើងដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ចំពោះកិច្ចសន្យាដែលមានទឹកប្រាក់ដែលស្ថិតក្រោមទំហំកំណត់។ ប៉ុន្តែការធ្វើសវនកម្មនេះ មិនទាន់មានលទ្ធផលជាដុំកំភួនដែលឈានទៅដល់ការកែលម្អកិច្ចលទ្ធកម្មនៅឡើយទេ។ អង្គភាពអនុវត្តកិច្ចលទ្ធកម្មចំនួន ៦០ ត្រូវរងការធ្វើសវនកម្មក្នុងឆ្នាំ២០១៤។ ក្រុមការងារវាយតម្លៃមិនបានទទួលកិច្ចសន្យា ដែលអនុវត្តវិធីសាស្ត្រប្រកួតប្រជែងនៅក្នុងឆ្នាំ ២០១៤ ទេ (ឆ្នាំ២០១៤ ជាឆ្នាំដែលត្រូវវាយតម្លៃសម្រាប់សូចនាករនេះ) ហើយក៏គ្មានតួលេខសមាមាត្រនៃចំនួនកិច្ចសន្យានេះដែរ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ D ដោយសារគ្មានទិន្នន័យទាក់ទិនទៅនឹងការអនុវត្តវិធីសាស្ត្រមិនប្រកួតប្រជែង។

### (៣) សាធារណជនអាចទទួលបានព័ត៌មានស្តីពីកិច្ចលទ្ធកម្មបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន

សមាសធាតុគន្លឹះអំពីការផ្សព្វផ្សាយព័ត៌មានស្តីពីកិច្ចលទ្ធកម្ម មានកំណត់ក្នុងតារាង គ.៣០ ខាងក្រោមដែលត្រូវវាយតម្លៃដោយ PEFA។

**តារាង គ.៣០÷ សមាសធាតុគន្លឹះនៃកិច្ចលទ្ធកម្មដែលត្រូវផ្សព្វផ្សាយជាសាធារណៈ**

| តើសមាសធាតុគន្លឹះៗ នៃព័ត៌មានស្តីពីកិច្ចលទ្ធកម្មត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមមធ្យោបាយសមស្របដែរឬទេ? | |
|---|---|
| ផែនការលទ្ធកម្ម | មិនបានផ្សព្វផ្សាយ |
| សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ | ផ្សព្វផ្សាយ |
| ការប្រគល់កិច្ចសន្យា | មិនបានផ្សព្វផ្សាយ |
| តួលេខស្តីពីដំណោះស្រាយទៅលើបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម | មិនបានផ្សព្វផ្សាយ |

ក្នុងចំណោមសមាសធាតុទាំង០៤ខាងលើនេះ មានតែសមាសធាតុតែ០១ ប៉ុណ្ណោះគឺសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ផែនការលទ្ធកម្ម ការប្រគល់កិច្ចសន្យា និងតួលេខស្តីពីដំណោះស្រាយទៅលើបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ D ដោយហេតុថា មានតែសមាសធាតុតែមួយប៉ុណ្ណោះក្នុងចំណោមសមាសធាតុទាំង០៤ ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ពិន្ទុអាចទទួលបានខ្ពស់ជាងនេះ ប្រសិនបើមានសមាស-ធាតុ២ ត្រូវបានធ្វើការផ្សព្វផ្សាយជាសាធារណៈ។

**(៤) មានយន្តការឯករាជ្យសម្រាប់ដោះស្រាយរាល់បណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម**

មាត្រា៦២ និងមាត្រា៦៣ ជំពូកទី១០ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ បានកំណត់ពីការដោះស្រាយជម្លោះ និងបណ្តឹងតវ៉ា ប៉ុន្តែមិនបានតម្រូវឱ្យបង្កើតស្ថាប័នឯករាជ្យសម្រាប់ដោះស្រាយជម្លោះនិងបណ្តឹងតវ៉ាទេ។ ក្នុងករណីដែលមានជម្លោះកើតឡើង ដំណោះស្រាយត្រូវបានធ្វើឡើងរវាងអង្គភាពដែលពាក់ព័ន្ធក្នុងកិច្ចលទ្ធកម្មនោះ។ ប្រសិនបើមិនយល់ព្រមចំពោះដំណោះស្រាយ អ្នកតវ៉ាអាចបន្តប្តឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រសិនបើនៅតែមិនពេញចិត្តចំពោះដំណោះស្រាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកតវ៉ាអាចបន្តប្តឹងទៅតុលាការតែម្តង។ ដូច្នេះ គ្មានយន្តការដោះស្រាយបណ្តឹងតវ៉ាឯករាជ្យលើកិច្ចលទ្ធកម្មទេ ហើយក៏មិនទាន់កើតមានបណ្តឹងតវ៉ាលើកិច្ចលទ្ធ-កម្មនៅឡើយដែរ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ D ដោយសារគ្មានយន្តការឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម។

**តារាង គ.៣១÷ សមាសធាតុគន្លឹះសម្រាប់យន្តការដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម**

| តើបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្មត្រូវបានដោះស្រាយដោយស្ថាប័ន ដែល÷ | |
|---|---|
| មានអ្នកជំនាញប្រកបដោយបទពិសោធន៍ និងមានចំណេះដឹងផ្នែកលទ្ធកម្ម ដែលមកពីវិស័យឯកជន អង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល | ទេ |
| មិនទាក់ទិននឹងដំណើរការនៃកិច្ចលទ្ធកម្ម ឬដំណើរការនៃការធ្វើសេចក្តីសម្រេចលើការចុះកិច្ចសន្យា | ទេ |
| មិនគិតថ្លៃសេវា ដែលនាំឱ្យអ្នកពាក់ព័ន្ធមិនអាចចូលរួមបាន | មាន |
| មាននីតិវិធីច្បាស់លាស់ក្នុងកិច្ចដំណើរការដាក់ពាក្យបណ្តឹង និង ការដោះស្រាយបណ្តឹង ហើយសាធារណជនទូទៅ អាចទទួលបានព័ត៌មានទាំងនេះ | មាន |
| មានសិទ្ធិអំណាចក្នុងការបញ្ឈប់កិច្ចដំណើរការលទ្ធកម្ម | មាន |
| ចេញសេចក្តីសម្រេចក្នុងក្របខ័ណ្ឌពេលវេលាដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត | ទេ |
| ចេញសេចក្តីសម្រេចដែលតម្រូវឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់ត្រូវគោរពតាម | មាន |

**តារាង គ.៣២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី១៩**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-19 | **តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** | NA | D | វិធីសាស្ត្រវាយតម្លៃ M2 |
| (១) | មានក្របខ័ណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | NA | B | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (២០១២) ឆ្លើយតបបានតាមលក្ខខណ្ឌតម្រូវ៤ ក្នុងចំណោម ៦ |
| (២) | ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | NA | D | គ្មានព័ត៌មានគ្រប់គ្រាន់ សម្រាប់កំណត់ថាតើកិច្ចសន្យាក្នុងឆ្នាំ២០១៤ ត្រូវបានរៀបចំនិងអនុវត្ត ស្របតាមលិខិតបទដ្ឋានគតិយុត្តដែរឬទេ |
| (៣) | សាធារណជនអាចទទួលបានព័ត៌មានស្តីពីកិច្ចលទ្ធកម្មបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន | NA | D | គ្មានប្រព័ន្ធសម្រាប់ការផ្តល់ព័ត៌មានជាក់លាក់ស្តីពីកិច្ចលទ្ធកម្មដល់សាធារណជនទេ |
| (៤) | មានយន្តការឯករាជ្យសម្រាប់ដោះស្រាយរាល់បណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម | NA | D | គ្មានស្ថាប័នឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្មទេ |

**ប្រអប់ គ.១៨ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

រាជរដ្ឋាភិបាលកម្ពុជាកំពុងកែលម្អតម្លាភាព និងលើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីកិច្ចលទ្ធកម្មក្នុងពេលអនាគតឆាប់ៗនេះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនូវការទទួលបានកិច្ចសន្យា នៅឆ្នាំ២០១៦។

## គ.៤.៨ ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស (PI-20)

សូចនាករសមិទ្ធកម្មនេះមានគោលបំណងវាយតម្លៃប្រសិទ្ធភាព នៃប្រព័ន្ធ និងយន្តការត្រួតពិនិត្យនីតិវិធីធានាចំណាយ និងការទូទាត់។ ការវាយតម្លៃនេះផ្តោតលើការធានាចំណាយ និងការទូទាត់ទំនិញនិងសេវាកម្ម, ព្រមទាំងប្រាក់បំណាច់នានា។ ចំណែកឯការគ្រប់គ្រងបំណុល ការគ្រប់គ្រងបញ្ជីបៀវត្ស និងការគ្រប់គ្រងបុរេប្រទានត្រូវបានវាយតម្លៃក្នុងសូចនាករសមិទ្ធកម្មផ្សេងៗទៀត។

ក្នុងឆ្នាំ២០១៣ ចំណាយបៀវត្សមានចំនួន ៤២% នៃចំណាយថវិកាជាតិទាំងមូល ដូចនេះចំណាយមិនមែនបៀវត្ស មានប្រមាណជិត ៥០% នៃចំណាយថវិកាជាតិទាំងមូល។

### (១) ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យលើការធានាចំណាយ

សមាសធាតុនេះមានគោលបំណងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យលើការធានាចំណាយ ដែលជាកត្តាសំខាន់នៅក្នុងវិន័យថវិកា ដើម្បីធានាថាការចំណាយមានកម្រិតមិនលើសពីកញ្ចប់ថវិកាដែលបានអនុម័ត។ ការធានាចំណាយ

ត្រូវបានកំណត់និយមន័យនៅក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់ ថាគឺជា “កាតព្វកិច្ចដែលរាជរដ្ឋាភិបាលធានាចំណាយសម្រាប់ការទូទាត់នាពេលអនាគត”។ ការធានាចំណាយកើតឡើង នៅពេលមានការស្នើសុំជ្រើសរើសបុគ្គលិកនិងការស្នើសុំរៀបចំកិច្ចលទ្ធកម្មទំនិញនិងសេវា។ ការធានាចំណាយចែកចេញជាពីរប្រភេទ គឺការធានាចំណាយចរន្ត ដូចជាប្រាក់បៀវត្ស ការទូទាត់ទឹក-ភ្លើង និងសេវាបំណុលសាធារណៈនានា ដែលមិនតម្រូវឱ្យមានជាកិច្ចសន្យាជាក់លាក់ និងការធានាចំណាយវិនិយោគ ដែលតម្រូវឱ្យមានកិច្ចសន្យាជាក់លាក់សម្រាប់ទំនិញ និងសេវាកម្ម។

នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកាគឺជាអង្គភាពទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការធានាចំណាយចរន្ត ចំណែកឯនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា ទទួលបន្ទុកត្រួតពិនិត្យលើការធានាចំណាយមូលធន។ ការត្រួតពិនិត្យលើការធានាចំណាយ ធ្វើឡើងដោយមិនទាន់មានប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើប្រតិភូកម្មដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលប្រចាំការនៅតាមក្រសួង-ស្ថាប័ននូវសិទ្ធិពិនិត្យសម្រេចចំពោះចំណាយដែលមិនឆ្លងកាត់កិច្ចលទ្ធកម្ម ដូចជាប្រាក់បៀវត្សជាដើម។ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៦ បានផ្តល់សិទ្ធិក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុ លើការអនុញ្ញាតចំពោះចំណាយប្រាក់បៀវត្សរបស់មន្ត្រីរាជការ, បុគ្គលិកជាប់កិច្ចសន្យា, មន្ត្រីចូលនិវត្តន៍ និងមន្ត្រីដែលលាឈប់ពីការងារ ព្រមទាំងមន្ត្រីទទួលបានអាហារូបករណ៍ផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយនិងបែបបទត្រួតពិនិត្យហិរញ្ញវត្ថុ ព្រមទាំងបានផ្សព្វផ្សាយអនុវត្តទៅគ្រប់ក្រសួង-ស្ថាប័ននៅឆ្នាំ២០១៣។ ប៉ុន្តែនីតិវិធីនេះ ចែងអំពីនីតិវិធីធានាចំណាយចរន្តតែមួយប៉ុណ្ណោះ។

ក្នុងករណីដែលការស្នើសុំធានាចំណាយមានលក្ខណៈបន្ទាន់ ឬក៏ត្រូវបានចាត់ទុកជាករណីពិសេស ការត្រួតពិនិត្យការធានាចំណាយមិនត្រូវបានអនុវត្តតាមនីតិវិធីនោះទេ។ គោលការណ៍និងនីតិវិធីដែលកំពុងអនុវត្តជាធរមាននៅមិនទាន់គ្របដណ្តប់គ្រប់ជ្រុងជ្រោយលើការចំណាយទាំងអស់ប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ការត្រួតពិនិត្យធានាចំណាយ ត្រូវបានអនុវត្តដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស។ សៀវភៅណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់ កំណត់ថាក្រសួង-ស្ថាប័នត្រូវធានាថាគ្មានចំណាយណាមួយលើសពីដែនកំណត់សាច់ប្រាក់ដែលមានសម្រាប់ខែនីមួយៗឡើយ។ ប៉ុន្តែ ការផ្តល់ធានាចំណាយនូវគម្រោងសាងសង់ធំៗ ដែលប្រើប្រាស់រយៈពេលច្រើនខែ ឬឆ្នាំ ត្រូវបានរៀបចំជាកាលវិភាគទូទាត់ និងរក្សាពិដានសាច់ប្រាក់ក្នុងខែ។ ការគ្រប់គ្រងធានាចំណាយនីមួយៗ គឺមិនផ្អែកលើស្ថានភាពសាច់ប្រាក់ដែលនៅសល់នៅអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ C ដោយសារតែមាននីតិវិធីត្រួតពិនិត្យការធានាចំណាយ និងមានប្រសិទ្ធភាពក្នុងការរក្សាការធានាចំណាយស្របតាមការព្យាករណ៍សាច់ប្រាក់ដែលមាន បើទោះបីជាមិនរាប់បញ្ចូលចំណាយមូលធន និងមិនទាន់អនុលោមទៅតាមការធានាចំណាយឥតគ្រោងទុកនិងបន្ទាន់។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ត្រូវកាត់បន្ថយលើការធានាចំណាយលើករណីបន្ទាន់ ឬករណីពិសេស ឧទាហរណ៍ ការធានាចំណាយសម្រាប់ចំណាយមូលធន។

### (២) ភាពគ្រប់ជ្រុងជ្រោយ, ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យ ប្រកាស និងសារាចរ ដោយគ្របដណ្តប់លើទិដ្ឋភាពភាគច្រើនពាក់ព័ន្ធនឹងការត្រួតពិនិត្យហិរញ្ញវត្ថុ ព្រមទាំងការត្រួតពិនិត្យមិនមែនហិរញ្ញវត្ថុមួយចំនួនទៀត។ ទោះយ៉ាងណា គោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយនិងការត្រួតពិនិត្យហិរញ្ញវត្ថុគ្របដណ្តប់តែលើចំណាយចរន្តតែប៉ុណ្ណោះ។ ចំពោះចំណាយមូលធន នៅមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់នៅឡើយ ក្នុងពេលដែលចំណាយមូលធនក្នុងស្រុកមានប្រមាណ ២៤% នៃចំណាយមិនមែនប្រាក់បៀវត្ស។ ប្រព័ន្ធត្រួតពិនិត្យតាមដាននិងគ្រប់គ្រងចំណាយផ្សេងទៀតនៅតែមានដែនកំណត់ក្នុងការអនុវត្ត។ ឧទាហរណ៍ ប្រព័ន្ធត្រួតពិនិត្យ នៅមិនទាន់មានប្រព័ន្ធកុំព្យូទ័រដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

នីតិវិធីនៃការត្រួតពិនិត្យមានភាពស្មុគស្មាញ និងចំណាយពេលវេលាច្រើន ទាំងនៅកម្រិតក្រសួង-ស្ថាប័នដែលស្នើសុំធានាចំណាយ និងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលត្រូវផ្តល់ការអនុម័តលើសំណើសុំធានាចំណាយ[35]។ រាល់ការធានាចំណាយត្រូវឆ្លងកាត់ដំណាក់កាលច្រើន ពីមន្ត្រីជំនាញរហូតដល់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ដែលធ្វើឱ្យខាតបង់ពេលវេលា និងធនធានបន្ថែម។ ទន្ទឹមនេះ ការត្រួតពិនិត្យក្រោយចំណាយមានការត្រួតគ្នារវាងការត្រួតពិនិត្យដោយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន។

ដោយហេតុថាគោលការណ៍ណែនាំចាំបាច់នានានៅមានកង្វះចន្លោះ សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ C ពីព្រោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានតែចំពោះការចំណាយមិនមែនប្រាក់បៀវត្សតែប៉ុណ្ណោះ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ តម្រូវឱ្យមានប្រព័ន្ធត្រួតពិនិត្យដែលមានភាពគ្រប់ជ្រុងជ្រោយ ដែលគ្របដណ្តប់ទាំងលើចំណាយមូលធន។

### (៣) កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការនិងការកត់ត្រាកិច្ចប្រតិបត្តិការ

ភាគច្រើននៃនីតិវិធីអនុវត្ត និងការកត់ត្រានូវរាល់ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានអនុវត្ត ប៉ុន្តែក៏មានករណីជាច្រើនទៀតដែលមិនអនុលោមតាមនីតិវិធីអនុវត្ត។ របាយការណ៍របស់អាជ្ញាធរសវនកម្មជាតិលើការអនុវត្តថវិកាឆ្នាំ ២០១៣ បានបង្ហាញថា÷ ១-អាណត្តិចំនួន ១ ២០៧ ដែលស្មើនឹងទឹកប្រាក់ប្រមាណ ៧១០ពាន់លានរៀល ត្រូវបានដាក់ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ (GDNT) បន្ទាប់ពីការបិទបញ្ជីចុងឆ្នាំ (ខែមករា-កុម្ភៈ ឆ្នាំ២០១៤) និង ២-ទឹកប្រាក់បុរេប្រទានប្រមាណ ២១៥ ពាន់លានរៀល មិនទាន់ជំរះត្រឹមដំណាច់ឆ្នាំ ២០១៣។ ការផ្ទៀងផ្ទាត់គណនីនៅតាមក្រសួង-ស្ថាប័នមានការយឺតយ៉ាវពី ០១ ខែ ទៅ ០៥ ខែ, ការផ្ទៀងផ្ទាត់គណនីចំណូលទៅលើក្រសួង-ស្ថាប័ន ១៩ មានការយឺតយ៉ាវពី ០១ ខែ ដល់ ០៤ ខែ។

[35] មានការកែលម្អមួយចំនួននៅក្នុងវិមជ្ឈការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ នៅក្នុងដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបញ្ជូនទៅគ្រប់ក្រសួង-ស្ថាប័ន

សមាសធាតុនេះត្រូវបានដាក់ពិន្ទុ C ដោយសារតែគោលការណ៍សំខាន់ៗភាគច្រើនមិនត្រូវបានអនុវត្ត ដូចដែលបានបង្ហាញក្នុងរបាយការណ៍អាជ្ញាធរសវនកម្មជាតិ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺទាមទារឱ្យមានអនុលោមភាពច្រើនជាងមុនទៅនឹងគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា។

**តារាង គ.៣៣÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២០**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-20 | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស** | C | D+ | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនៃការធានាចំណាយ | C | C | គោលការណ៍ណែនាំបានណែនាំតែអំពីនីតិវិធីសម្រាប់ធានាចំណាយចរន្តប៉ុណ្ណោះ។ លើសពីនេះទៅទៀត សំណើធានាចំណាយបន្ទាន់ ឬ សំណើធានាចំណាយពិសេស មិនត្រូវបានអនុវត្តតាមនីតិវិធីទាំងស្រុងទេ។ |
| (២) | ភាពគ្រប់ជ្រុងជ្រោយ ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង | C | C | មានគោលការណ៍ណែនាំអំពីការត្រួតពិនិត្យជាទូទៅ ក៏ប៉ុន្តែករណីមួយចំនួន ដូចជា ចំណាយវិនិយោគនិងការគ្រប់គ្រងទ្រព្យសកម្ម នៅមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់នៅឡើយ។ |
| (៣) | កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការនិងការកត់ត្រាកិច្ចប្រតិបត្តិការ | C | C | អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ បានបង្ហាញថា ការមិនអនុលោមទៅតាមច្បាប់មានការកើតឡើងជាញឹកញាប់។ |

**ប្រអប់ គ.១៩ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

ដើម្បីអនុវត្តការធានាចំណាយស្របតាមការអនុវត្តថវិកាកម្មវិធី នៅដើមឆ្នាំ២០១៥ គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី ត្រូវបានអនុម័ត និងផ្សព្វផ្សាយដល់គ្រប់ក្រសួង-ស្ថាប័ន ។ លើសពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងដាក់ឱ្យអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យានៅខែកក្កដា ឆ្នាំ២០១៥ និង នៅក្នុងឆ្នាំ២០១៥ នេះដែរ អគ្គនាយកដ្ឋានថវិកា នឹងបញ្ចប់ការរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិសម្រាប់គម្រោងវិនិយោគ និងចំណាយសម្រាប់ការថែទាំ។ ដូចនេះ សូចនាករនេះនឹងមានការប្រែប្រួល សម្រាប់ការវាយតម្លៃលើកក្រោយ ប្រសិនបើវិធានការខាងលើត្រូវបានអនុវត្តពេញលេញ។

## គ.៤.៩ ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង (PI-21)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើប្រសិទ្ធភាពនៃប្រព័ន្ធសវនកម្មផ្ទៃក្នុង (ដែលផ្ទុយពីការត្រួតពិនិត្យផ្ទៃក្នុង) ដោយផ្អែកលើព័ត៌មានប្រតិបត្តិការ និងហិរញ្ញវត្ថុចុងក្រោយបំផុតដែលមាន។

មុខងារសវនកម្មផ្ទៃក្នុង (IA) ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ និងមានចេញផ្សាយនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (www.gdia.mef.gov.kh)។ មាត្រា ៤១ ដល់ ៤៣ នៃច្បាប់ស្តីពីសវនកម្ម តម្រូវឱ្យបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅក្នុងគ្រប់ក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ។ រីឯរបាយការណ៍សវនកម្ម ត្រូវរាយការណ៍ទៅប្រធានស្ថាប័នសាមី និងច្បាប់ចម្លងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ។ គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីពិនិត្យនិងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ និងអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៤០ ឆ្នាំ២០០៥។

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីពីរ គឺ÷ (១) ធ្វើសវនកម្មលើអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២) ផ្តល់ជំនួយបច្ចេកទេស, គម្រូរបាយការណ៍ និងការបណ្តុះបណ្តាលនានាដល់នាយកដ្ឋានសវនកម្មរបស់ក្រសួង-ស្ថាប័នដទៃទៀត។ ទោះយ៉ាងណាក៏ដោយ អនុលោមតាមច្បាប់ អគ្គនាយកដ្ឋាន មិនមានសិទ្ធិអំណាចគ្រប់គ្រងលើក្រសួងដទៃទៀត និងមិនមានសិទ្ធិអនុម័តលើផែនការសវនកម្ម ឬទទួលបានច្បាប់ចម្លងនៃរបាយការណ៍របស់នាយកដ្ឋានសវនកម្មនៃក្រសួង-ស្ថាប័នឡើយ។ កាលពីពេលថ្មីៗនេះ អគ្គនាយកដ្ឋាន បានរៀបចំសេចក្តីព្រាងសៀវភៅណែនាំសវនកម្ម ស្របតាមស្តង់ដារសវនកម្មអន្តរជាតិ។ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាសមាជិកនៃវិទ្យាស្ថានសវនករផ្ទៃក្នុង (IIA)។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានបុគ្គលិក២៣នាក់ ក្នុងនោះមានបុគ្គលិកតែម្នាក់ប៉ុណ្ណោះ ដែលមានគុណវុឌ្ឍិបញ្ចប់សញ្ញាបត្រគណនេយ្យករជំនាញ ACCA (បុគ្គលិកផ្សេងទៀតកំពុងទទួលបានការបណ្តុះបណ្តាល)។

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ជួយពិនិត្យនិងផ្តល់អនុសាសន៍កែលម្អលើការងារសវនកម្មរបស់ក្រសួង-ស្ថាប័ន។ ដោយឡែក អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រួតពិនិត្យលើដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន។ តួនាទីនិងភារកិច្ចរបស់អគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅក្នុងក្រសួងទាំងនោះ នៅមិនទាន់ត្រូវបានកំណត់ច្បាស់លាស់នៅឡើយ និងអាចជាន់ការងារគ្នា។

សូចនាករនេះមានគោលបំណងវាយតម្លៃលទ្ធភាពរបស់សវនកម្មផ្ទៃក្នុង ដោយពិនិត្យទៅលើវិសាលភាពនិងប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង និងការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង តាមរយៈសមាសធាតុចំនួន បី គឺ (១) វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង (២) ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង និង (៣) ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង។

### (១) វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង

ក្នុងចំណោមក្រសួង-ស្ថាប័នទាំង៤០ មានក្រសួង-ស្ថាប័នចំនួន២៩ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង។ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការធ្វើសវនកម្មផ្ទៃក្នុង ផ្តោតជាសំខាន់ចំពោះអង្គភាពថ្នាក់មូលដ្ឋាន (រាជធានីខេត្ត)។ ការពិនិត្យលើផែនការសវនកម្មប្រចាំឆ្នាំ បានបង្ហាញថា ៨០% នៃអង្គភាពនៅមូលដ្ឋានត្រូវរងការចុះធ្វើសវនកម្មផ្ទៃក្នុង ហើយនៅរដ្ឋបាលថ្នាក់ជាតិ មានអង្គភាពប្រមាណពី ៣០ ទៅ ៤០%ប៉ុណ្ណោះ ដែលត្រូវរងសវនកម្មផ្ទៃក្នុង។ ដោយឡែក ក្រសួង-ស្ថាប័ន ប្រមាណ ៥៧% សម្រេចបានផែនការសវនកម្មផ្ទៃក្នុងរបស់ខ្លួន បានប្រមាណ៥០%។ ជារួម ការធ្វើសវនកម្មផ្ទៃក្នុង គឺពិនិត្យទៅលើតែការអនុវត្តជាក់ស្តែង ថាតើអនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែរឬទេ និងពិនិត្យទៅលើការងាររបស់មន្ត្រី ដោយមិនបានផ្តោតទៅលើបញ្ហាប្រព័ន្ធនោះទេ។

ចាប់ពីឆ្នាំ២០១៤ សមត្ថភាពប្រព័ន្ធសវនកម្មត្រូវបានរៀបចំឡើង ដែលត្រូវបានប៉ាន់ប្រមាណថា អាចកាត់បន្ថយពេលវេលារបស់មន្ត្រី ពី២០% ទៅ ៥០% ប៉ុន្តែនៅតែមិនទាន់បានបំពេញតាមស្តង់ដារ IIA ដែលត្រូវបានរៀបចំតាមរយៈការផ្តល់ជំនួយបច្ចេកទេសក្នុងឆ្នាំ២០១៤។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ C ដោយហេតុថាមុខងារសវនកម្មផ្ទៃក្នុង បានគ្របដណ្តប់លើគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពរបស់រាជរដ្ឋាភិបាល និងបានត្រួតពិនិត្យកែលម្អលើចំណុចមួយចំនួននៃប្រព័ន្ធ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺតម្រូវឱ្យការធ្វើសវនកម្មផ្ទៃក្នុង ត្រូវផ្តោតលើបញ្ហាជាប្រព័ន្ធឱ្យបានកម្រិតខ្ពស់ និងការប្រកាន់ខ្ជាប់ទៅនឹងស្តង់ដារអន្តរជាតិនៃសវនកម្មផ្ទៃក្នុង។

### (២) ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង

របាយការណ៍សវនកម្មដែលរៀបចំដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើទៅអង្គភាពដែលរងសវនកម្ម ដើម្បីពិនិត្យបញ្ជាក់បន្ថែមសំដៅធានាភាពត្រឹមត្រូវនៃរបាយការណ៍។ បន្ទាប់មក របាយការណ៍នោះត្រូវផ្ញើទៅកាន់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ។ ដោយឡែក ក្រសួង-ស្ថាប័ន ត្រូវផ្ញើរបាយការណ៍សវនកម្មរបស់ខ្លួនទៅកាន់រដ្ឋមន្ត្រីរបស់ក្រសួង-ស្ថាប័នសាមី និងអាជ្ញាធរសវនកម្មជាតិ ដោយមិនតម្រូវឱ្យផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើយ។ ទោះយ៉ាងណាក៏ដោយ សារាចរលេខ ០០៣ សហវ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ បានណែនាំឱ្យក្រសួង-ស្ថាប័ន ផ្ញើរបាយការណ៍សវនកម្មរបស់ខ្លួនទៅកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជារៀងរាល់ខែ និងទៅកាន់អាជ្ញាធរសវនកម្មជាតិ ជារៀងរាល់ត្រីមាស។ បច្ចុប្បន្ន ក្រសួង-ស្ថាប័ន នៅមិនទាន់បានផ្ញើច្បាប់ចម្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឡើយទេ។ ក្រសួងសាធារណការនិងដឹកជញ្ជូន រាយការណ៍ពីការបញ្ចប់សវនកម្មនីមួយៗ ទៅកាន់អង្គភាពរងសវនកម្ម និងបូកសរុបរបាយការណ៍ខ្លួនប្រចាំត្រីមាស និងប្រចាំឆ្នាំ។ ក្រសួងនេះ ក៏បញ្ជូនរបាយការណ៍ពិសេសទៅកាន់អាជ្ញាធរសវនកម្មជាតិ ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ។ យោងតាមរបាយការណ៍ដែលទទួលបាន ក្រសួង-ស្ថាប័ន ប្រមាណ ៧៣% បានបញ្ជូនរបាយការណ៍សវនកម្មទៅកាន់រដ្ឋមន្ត្រីរបស់ខ្លួន និងក្នុងចំណោមនោះ មានប្រមាណ ២២% បានបញ្ជូនរបាយការណ៍ទៅកាន់អាជ្ញាធរសវនកម្មជាតិ។

សមាសធាតុនេះត្រូវបានដាក់ពិន្ទុ C ដោយសារអង្គភាពសវនកម្មផ្ទៃក្នុង បានរៀបចំនិងដាក់ជូនរបាយការណ៍សវនកម្មរបស់ខ្លួនទៅរដ្ឋមន្ត្រីសាមី និងអាជ្ញាធរសវនកម្មជាតិ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះគឺតម្រូវឱ្យអង្គភាពសវនកម្មផ្ទៃក្នុងត្រូវផ្ញើរបាយការណ៍សវនកម្មទៅអាជ្ញាធរសវនកម្មជាតិជាប្រចាំ។

**(៣) ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង**

យោងតាមរបាយការណ៍ និងការជួបជាមួយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍ ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ ដែលជាហេតុនាំឱ្យចំណុចខ្វះខាតដែលបានលើកឡើងនៅក្នុងរបាយការណ៍សវនកម្ម មានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ។ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរាយការណ៍ថា ប្រមាណ ៦០% ទៅ ៧០% នៃអនុសាសន៍ ត្រូវបានទទួលការឆ្លើយតបជាវិជ្ជមាន ក្នុងរយៈពេលមួយឆ្នាំ (អនុសាសន៍មួយចំនួន បានប្រើប្រាស់ពេលយូរក្នុងការអនុវត្ត ឬមានការពាក់ព័ន្ធនឹងក្រសួង-ស្ថាប័នផ្សេងទៀត)។ ដោយឡែកសម្រាប់ក្រសួង-ស្ថាប័នទាំងអស់ មានតែអង្គភាពសវនកម្មតែ ២៥% ប៉ុណ្ណោះបានរាយការណ៍ថា អនុសាសន៍ដែលបានលើកឡើងត្រូវបានចាត់វិធានការដើម្បីកែលម្អ។ ក្នុងនោះ អង្គភាពសវនកម្មក្នុងក្រសួង-ស្ថាប័នតំរូវមួយចំនួន បានរាយការណ៍ថាមានការឆ្លើយតបពីថ្នាក់ដឹកនាំខ្ពស់ជាងមុន (ឧទាហរណ៍ ក្នុងចំណោមអនុសាសន៍ប្រមាណពី ១០ ទៅ ២០ ចំណុច សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា, ការអនុវត្តតាមអនុសាសន៍ គឺមានប្រមាណ ៩០% ទៅហើយ)។

សមាសធាតុនេះ បានទទួលពិន្ទុ C ពីព្រោះអនុសាសន៍របស់សវនករត្រូវបានយកទៅអនុវត្តតាមនៅក្រសួង-ស្ថាប័នមួយចំនួន ជាពិសេសអនុសាសន៍សំខាន់ៗ បើទោះបីជាការកែលម្អតាមអនុសាសន៍នោះមានការយឺតយ៉ាវក៏ដោយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ក្រសួង-ស្ថាប័ន ត្រូវចាត់វិធានការឆ្លើយតបអនុសាសន៍របស់សវនករដោយមិនឱ្យមានភាពយឺតយ៉ាវ។

**តារាង គ.៣៤÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២១**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-21 | **ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង** | D+ | C | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង | D | C | មុខងារជាសវនកម្មផ្ទៃក្នុង គ្របដណ្តប់ក្រសួង-ស្ថាប័ននិងអង្គភាពរបស់រាជរដ្ឋាភិបាលនិងការពិនិត្យជាប្រព័ន្ធ (ជាង 20% នៃពេលវេលាសវនករ) |
| (២) | ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង | C | C | សវនកម្មផ្ទៃក្នុងដាក់របាយការណ៍ជូនប្រធានស្ថាប័នសាមី និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ប៉ុន្តែនៅមិនទាន់ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| (៣) | ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង | C | C | អនុសាសន៍របស់សវនករត្រូវបានយកទៅអនុវត្តតាម នៅក្រសួង-ស្ថាប័នមួយចំនួនប៉ុណ្ណោះ ពិសេសបញ្ហាប្រឈមចំបង ប៉ុន្តែជាញឹកញាប់មានការពន្យារពេលអនុវត្ត។ |

**ប្រអប់ គ.២០ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

ពុំមានរបាយការណ៍

# គ.៥ គណនេយ្យ ការកត់ត្រា និងរបាយការណ៍

## គ.៥.១ ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី (PI-22)

របាយការណ៍ព័ត៌មានហិរញ្ញវត្ថុដែលគួរឱ្យជឿទុកចិត្តបាន តម្រូវឱ្យមានការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ការកត់ត្រាជាក់ស្តែងរបស់គណនេយ្យករ ដែលនេះជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង និងជាមូលដ្ឋានមួយសម្រាប់ព័ត៌មានប្រកបដោយគុណភាពល្អ សម្រាប់ការគ្រប់គ្រង និងសម្រាប់របាយការណ៍ផ្ទៃក្រៅ។ ការផ្ទៀងផ្ទាត់ក្នុងពេលវេលាសមស្របនិងញឹកញាប់ នូវទិន្នន័យចេញពីប្រភពផ្សេងៗគ្នា ធ្វើឱ្យទិន្នន័យគួរឱ្យទុកចិត្តបាន។ ការផ្ទៀងផ្ទាត់ មានពីរប្រភេទសំខាន់ៗ រួមមាន÷ (១) ការផ្ទៀងផ្ទាត់ទិន្នន័យគណនេយ្យ ដែលមាននៅក្នុងសៀវភៅរបស់រដ្ឋាភិបាល ជាមួយនឹងទិន្នន័យគណនីធនាគាររបស់រដ្ឋាភិបាល នៅធនាគារកណ្តាលនិងធនាគារពាណិជ្ជ, និង (២) ការទូទាត់និងការផ្ទៀងផ្ទាត់គណនីរង់ចាំ (suspense accounts) និងគណនីបុរេប្រទាន (advances accounts)។

សូចនាករនេះធ្វើការវាយតម្លៃលើភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនីធនាគារ និង ភាពទៀងទាត់និងការទូទាត់គណនីរង់ចាំ និងគណនីសាច់ប្រាក់ (imprest accounts)។ សមាសធាតុនានា ដែលនឹងត្រូវបានវាយតម្លៃរួមមាន÷ (១) ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ និង (២) ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់និងការទូទាត់គណនីរង់ចាំ និងគណនីបុរេប្រទាន។ សូចនាករនេះ វាយតម្លៃស្ថានភាពដែលកើតមាននៅក្នុងអំឡុងពេលនៃការវាយតម្លៃ។

### (១) ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ

នៅក្នុងការវាយតម្លៃនេះ ឃើញថា គណនីធនាគាររបស់រដ្ឋាភិបាលមានចំនួន ១ ០៣៧ (សូមមើលសូចនាករសមិទ្ធកម្មទី១៧ សមាសធាតុ ២)។ អគ្គនាយកដ្ឋានរតនាគារជាតិ ធ្វើការផ្ទៀងផ្ទាត់គណនីទោលរតនាគារជាតិ (TSA) ចំនួនពីរ (មួយជាប្រាក់រៀល និងមួយទៀតជាប្រាក់ដុល្លារអាមេរិក) និងគណនីគម្រោងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាច្រើនទៀត។ នៅឆ្នាំ២០១៣ មានគណនីគម្រោងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន៦៥។ រាល់គណនីទាំងអស់នេះ និង TSA ត្រូវបានធ្វើការផ្ទៀងផ្ទាត់ជាប្រចាំខែ ជាមួយនឹងរបាយការណ៍នានាមកពីធនាគារជាតិនៃកម្ពុជា។ អគ្គនាយកដ្ឋានរតនាគារជាតិ ទទួលរបាយការណ៍ជាក្រដាស និងជា Soft ដោយធ្វើការប្រៀបធៀបដោយហត្ថកម្មទៅនឹងការបញ្ចូលទិន្នន័យឥណពន្ធ និងឥណទាន ជាមួយនឹងទិន្នន័យដែលអគ្គនាយកដ្ឋានរតនាគារជាតិបានកត់ត្រាទុក, ក្នុងនោះដែរ អគ្គនាយកដ្ឋានរតនាគារជាតិកំណត់ភាពខុសគ្នា, ស្វែងរកការបាត់បង់នូវសលាកបត្រចុះឥណទាន និងឥណពន្ធ, វិក័យបត្រចំណាយ និងវិក័យបត្រដកសាច់ប្រាក់ពីធនាគារជាតិនៃកម្ពុជា និងកត់ត្រាបន្ថែមនូវរាល់ចំណុចខុសគ្នា ដើម្បីអាចឱ្យទិន្នន័យចំណូល/ចំណាយនៃរបាយការណ៍របស់អគ្គនាយកដ្ឋានរតនាគារជាតិ និង

ធនាគារជាតិនៃកម្ពុជាឆ្លុះបញ្ចាំងគ្នាទៅវិញទៅមក។ ការផ្ទៀងផ្ទាត់ធនាគាររបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានបញ្ចប់នៅក្នុងរយៈពេល ២ សប្តាហ៍ដំបូង នៃខែបន្ទាប់។

គណនីធនាគារផ្សេងទៀត ពោលគឺគណនីគម្រោងរបស់ក្រសួង-ស្ថាប័ន ត្រូវបានធ្វើការផ្ទៀងផ្ទាត់ដោយអង្គភាពអនុវត្តគម្រោងផ្សេងៗគ្នា ដែលស្ថិតនៅក្នុងនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ដោយមិនមានការពាក់ព័ន្ធនឹងអគ្គនាយកដ្ឋានរតនាគារជាតិទេ។

សមាសធាតុនេះទទួលបានពិន្ទុ B ពីព្រោះការផ្ទៀងផ្ទាត់គណនីធនាគារទាំងអស់ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានបញ្ចប់ជាប្រចាំខែ នៅក្នុងរយៈពេល៤ សប្តាហ៍។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺតម្រូវឱ្យការផ្ទៀងផ្ទាត់ ត្រូវបានធ្វើផងដែរទៅលើគ្រប់គណនីរបស់រដ្ឋបាលកណ្តាលទាំងអស់ ទាំងគណនីដែលមិនគ្រប់គ្រងដោយរតនាគារជាតិ។

### (២) ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ និងទូទាត់គណនីរង់ចាំ និងគណនីបុរេប្រទាន

គណនីរង់ចាំ ត្រូវបានប្រើប្រាស់ដើម្បីកត់ត្រាវិក័យបត្របណ្តោះអាសន្ន ដែលពុំទាន់ទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ដើម្បីចុះទៅក្នុងគណនីចំណូលជាក់លាក់ណាមួយ។ នៅដំណាច់ឆ្នាំ២០១៤, សមតុល្យនៅគណនីរង់ចាំចំណូល គឺមានចំនួន ៦១ ពាន់លានរៀល (លេខកូដ ៤៧០.៨.១.២ និង ៤៧០.៨.១.៣) ដែលស្មើនឹង ០,៦% នៃចំណូលសរុបសម្រាប់ឆ្នាំនេះ។ ទោះបីជាយ៉ាងណា សមតុល្យចំណូលនៅគណនីរង់ចាំបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័សពី ៨ ពាន់លានរៀល នៅដំណាច់ឆ្នាំ២០១១ ដែលនេះគូសបញ្ជាក់ពីតម្រូវការធ្វើចំណាត់ថ្នាក់ចំណូលឱ្យបានកាន់តែឆាប់រហ័ស និងកាន់តែសុក្រឹត នៅពេលមានវិក្កយបត្រ។

គណនីបុរេប្រទាន ត្រូវបានប្រើប្រាស់ដើម្បីកត់ត្រាបុរេប្រទានដែលត្រូវបានផ្តល់ជូនក្រសួង-ស្ថាប័នសម្រាប់ចំណាយលើការអនុវត្តគម្រោងរបស់ខ្លួន ដែលនឹងត្រូវរ៉ាប់រងដោយអង្គភាពរបស់រដ្ឋាភិបាល ដូចជាការប្រមូលបុរេប្រទានសម្រាប់គម្រោងជាដើម។ បុរេប្រទាន មិនមែនជាចំណាយប្រចាំថ្ងៃនោះទេ ប៉ុន្តែជាចំណាយសម្រាប់តម្រូវការអនុវត្តគម្រោងណាមួយតែប៉ុណ្ណោះ។ គណនីបុរេប្រទានខ្លះត្រូវបានទូទាត់នៅក្នុងរយៈពេលខ្លី ប៉ុន្តែគណនីបុរេប្រទានខ្លះទៀត ចំណាយពេលវេលាយូរក្នុងការទូទាត់។ ការទូទាត់គណនីបុរេប្រទានក្នុងឆ្នាំយឺត នឹងមានផលប៉ះពាល់លើចំណាយជាក់ស្តែង ពីព្រោះអគ្គនាយកដ្ឋានរតនាគារជាតិមិនអាចកត់ត្រាចំណាយទាំងនោះបានទេ រហូតដល់បុរេប្រទានទាំងនោះត្រូវបានទូទាត់រួចរាល់។ ជាមួយគ្នានេះ មាត្រា៥ នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ស្តីពីនីតិវិធីនៃការបើកផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្តនិងចំណាយថវិកាវិនិយោគសាធារណៈ កំណត់ថា÷ "ក្នុងករណីជាយថាហេតុណាមួយដែលប្រាក់បុរេប្រទានឆ្នាំមុនមិនបានទូទាត់ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ជាមុនសិនហើយត្រូវរៀបចំធ្វើការទូទាត់ឱ្យបានជម្រះស្រឡះមុននឹងចាប់ផ្តើមប្រតិបត្តិការថវិកា និងក្នុងករណីការអនុវត្តគម្រោង ឬការបំពេញនីតិវិធីសម្រាប់គម្រោងមានការយឺតយ៉ាវដែលធ្វើឱ្យការទូទាត់បុរេប្រទានមិនអាចធ្វើទាន់ក្នុងឆ្នាំ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ ដើម្បីធ្វើការទូទាត់ស្មើនឹងទឹកប្រាក់មិនទាន់ទូទាត់នៃគម្រោងទាំងមូល។"

គណនីបុរេប្រទានត្រូវបានកត់ត្រាក្នុងឥណពន្ធក្នុងលេខកូដ ៤៧៣ និង៤៧៨។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ សមតុល្យដែលមិនទាន់បានទូទាត់ លើលេខកូដទាំងនេះមានចំនួន ១៩៧ ពាន់លានរៀល។ សមតុល្យសាកល្បង

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ បានបង្ហាញថាមានឥណទានសុទ្ធ (ទូទាត់បុរេប្រទានឆ្នាំមុន) ដែលមានចំនួនដល់ទៅ ១៦ ពាន់លានរៀល (ប្តូរលេខកូដទៅ១៥០៥១ និង ១៥០៥២) ដូច្នេះ ទឹកប្រាក់ចំនួន ១៨១ ពាន់លានរៀលទៀត នៅមិនទាន់ទូទាត់បាន ក្នុងរយៈពេលពីរខែបន្ទាប់ពីដំណាច់ឆ្នាំ (ប្រហែល ១,៣% នៃចំណាយសម្រាប់ឆ្នាំនេះ)។ បុរេប្រទានភាគច្រើនមិនត្រូវបានទូទាត់នៅក្នុងរយៈពេលពីរខែ ដូច្នេះសមាសធាតុនេះ គឺទទួលបានពិន្ទុ D ។

**តារាង គ.៣៥÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២២**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-22 | **ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី** | C | C | វិធីសាស្រ្តដាក់ពិន្ទុ M2 |
| (១) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ | B | B | ការផ្ទៀងផ្ទាត់គណនីធនាគារដែលគ្រប់គ្រងដោយរតនាគារជាតិទាំងអស់ត្រូវបានបញ្ចប់ប្រចាំខែនៅក្នុងរយៈពេល ២ សប្តាហ៍។ |
| (២) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់និងការទូទាត់គណនីរង់ចាំនិងគណនីបុរេប្រទាន | D | D | ការផ្ទៀងផ្ទាត់និងការទូទាត់នៃគណនីបុរេប្រទានភាគច្រើនចំណាយពេលវេលាយូររហូតដល់ ២ ខែ។ |

**ប្រអប់ គ.២១ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី១ នឹងត្រូវដាក់ឱ្យអនុវត្តនៅពាក់កណ្តាលឆ្នាំ២០១៥ ដែលនឹងសម្របសម្រួលការកត់ត្រា និងរបាយការណ៍នៅអគ្គនាយកដ្ឋានរតនាគារជាតិ។

## គ.៥.២ អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា (PI-23)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលគាំទ្រសេវាជួរមុខ ប្រកបដោយប្រសិទ្ធភាព (ឧទាហរណ៍ សាលារៀន និងមណ្ឌលថែទាំសុខភាពបឋម) តាមរយៈការផ្តល់ព័ត៌មានអំពីការផ្ទេរធនធានទៅអង្គភាពទាំងនោះ (ជាសាច់ប្រាក់ ឬសម្ភារៈ) សម្រាប់ការព្យាករណ៍ថវិកា។ ការវាយតម្លៃនេះ ផ្តោតលើលទ្ធផលនៃការអនុវត្តក្នុងឆ្នាំសារពើពន្ធ ៣ឆ្នាំ ចុងក្រោយ ដែលបានបញ្ចប់ពេញលេញ។

ចាប់ពីឆ្នាំ២០១៥មក សាលាបឋមសិក្សាមានប្រព័ន្ធថ្មីមួយ ដែលសាលាទាំងនោះរាយការណ៍ទៅក្រសួងអប់រំ យុវជន និងកីឡា ៣ដង ក្នុងមួយឆ្នាំ អំពីធនធានដែលទទួលបាន ដោយចែកចេញជា ៣ ប្រភេទ គឺ ធនធានដែលទទួលបានពីរដ្ឋាភិបាល ធនធានដែលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល និងធនធានដែលទទួលបានពីសហគមន៍ រីឯប្រភពនីមួយ ត្រូវលម្អិតមុខសញ្ញាជាពីរ គឺ សាច់ប្រាក់ និង សម្ភារៈ។ សាលានីមួយៗ ទទួលបាន ហិរញ្ញប្បទានពង្រឹងសាលា ដោយផ្អែកលើរបាយការណ៍ស្តីពីចំនួនសិស្សចុះឈ្មោះចូលរៀន។ សៀវភៅសិក្សា ត្រូវបានផ្តល់ជូនដោយក្រសួងអប់រំ យុវជន និងកីឡា រីឯតម្លៃសៀវភៅនោះ ត្រូវបានចាត់បញ្ចូលជាចំណាយនៅក្នុងគណនីចំណាយរបស់ក្រសួង។ នៅមុនឆ្នាំ២០១៥ សាលាទាំងនោះតែងតែផ្តល់របាយការណ៍ទៀងទាត់ ប៉ុន្តែនៅមិនទាន់គ្រប់ជ្រុង

ជ្រោយ ដូចជាមិនបានបញ្ចូលព័ត៌មានអំពីធនធានដែលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាលនានា។ សាលាមានក្ការខៀនកត់ត្រាដែលគួរត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាថវិកា និងចំណាយជាក់ស្តែង ជាប្រចាំត្រីមាស ប៉ុន្តែការអនុវត្តជាក់ស្តែង មិនមានដូច្នេះឡើយ។

មណ្ឌលសុខភាពក៏មានប្រព័ន្ធថ្មីមួយផងដែរ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០១៥។ មណ្ឌលសុខភាពរាយការណ៍ទៅស្រុកប្រតិបត្តិរបស់ខ្លួន បន្ទាប់មកស្រុកប្រតិបត្តិ រាយការណ៍ទៅមន្ទីរសុខាភិបាល និងចុងក្រោយមន្ទីរសុខាភិបាលរាយការណ៍បន្តទៅក្រសួងសុខាភិបាល (ការិយាល័យព័ត៌មានសុខាភិបាល) ជាប្រចាំខែ អំពីចំណូល-ចំណាយ។ នៅមុនឆ្នាំ២០១៥ មន្ទីរសុខាភិបាលខេត្តនីមួយៗ តែងតែទទួលបានរបាយការណ៍ប្រចាំត្រីមាស ជាទៀងទាត់ ពីគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ។ ក្រៅពីព័ត៌មានលម្អិតពាក់ព័ន្ធនឹងបុគ្គលិក, ចំនួនអ្នកជម្ងឺ ត្រូវបានចាត់ថ្នាក់បែងចែកទៅតាមប្រភពនៃហិរញ្ញប្បទាន (មូលនិធិសមធម៌សុខភាព “Health Equity Fund”, ប័ណ្ណសុខភាព “Health Card” និងកម្រៃជាដើម) ដែលព័ត៌មានទាំងនោះ ត្រូវបានលម្អិតលើចំណូលចំណាយជាលក្ខណៈសរុប តែមិនមានលម្អិតសម្រាប់មណ្ឌលសុខភាពនីមួយៗទេ។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ D ពីព្រោះពុំមានការប្រមូលជាទៀងទាត់ នូវទិន្នន័យនៃធនធានដែលទទួលបានដោយសាលា ឬ មណ្ឌលសុខភាពនីមួយៗឡើយ ឬ ពុំមានការចុះស្រង់ទិន្នន័យពិសេសណាមួយ អំពីសាច់ប្រាក់ និងធនធានជាសម្ភារៈ នៅក្នុងអំឡុងឆ្នាំ២០១២-២០១៤ ឡើយ។

**តារាង គ.៣៦÷ ពិន្ទុសម្រាប់សូចនាករសមិទ្ធកម្មទី២៣**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | C | D | មិនមានការប្រមូលទិន្នន័យព័ត៌មានគ្រប់ជ្រុងជ្រោយអំពីធនធានដែលទទួលបានដោយសាលាបឋមសិក្សា និងមណ្ឌលសុខភាពនោះទេ។ |

**ប្រអប់ គ.២២÷ ការងារកែទម្រង់កំពុងអនុវត្ត**

ការចាប់ផ្តើមដាក់ឱ្យអនុវត្តប្រព័ន្ធរបាយការណ៍ថ្មីនៅក្នុងវិស័យអប់រំ និងសុខាភិបាល នៅក្នុងឆ្នាំ២០១៥។

### គ.៥.៣ គុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ (PI-24)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើលទ្ធភាពផលិតរបាយការណ៍ដែលសុក្រឹតនិងគ្រប់ជ្រុងជ្រោយ ពីប្រព័ន្ធគណនេយ្យ លើគ្រប់ទិដ្ឋភាពនៃថវិកា ទាំងដំណាក់កាលធានាចំណាយ និងដំណាក់កាលទូទាត់។ ការវាយតម្លៃនេះផ្អែកលើឆ្នាំសារពើពន្ធដែលបានបញ្ចប់កាលពីឆ្នាំ២០១៤ កន្លងទៅ។ សូចនាករនេះមាន ៣ សមាសធាតុ ដើម្បីវាយតម្លៃគុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ដែលរួមមាន (១) វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុង

ន័យវិសាលភាពនិងសមិតភាពជាមួយនឹងការព្យាករណ៍ថវិកា (២) ភាពទាន់ពេលនៃការចេញផ្សាយរបាយការណ៍ និង (៣) គុណភាពនៃព័ត៌មាន។

លទ្ធភាពនៃការអនុវត្តថវិកា ទាមទារនូវការផ្តល់ព័ត៌មានទៀងទាត់និងទាន់ពេលវេលា អំពីលទ្ធផលនៃការអនុវត្តថវិកាជាក់ស្តែង សម្រាប់ឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាគណៈរដ្ឋមន្ត្រី ធ្វើការត្រួតពិនិត្យលើសមិទ្ធកម្ម និងក្នុងករណីចាំបាច់ អាចនឹងឈានទៅកំណត់សកម្មភាពថ្មីៗ ដើម្បីឱ្យការវិភាជថវិកាចំគោលដៅ និងសម្រាប់ក្រសួង-ស្ថាប័ន ដើម្បីរៀបចំសកម្មភាពក្រោមការទទួលខុសត្រូវរបស់ខ្លួន។ សូចនាករនេះផ្តោតលើលទ្ធភាពផលិតរបាយការណ៍ដែលសុក្រឹតនិងគ្រប់ជ្រុងជ្រោយ ពីប្រព័ន្ធគណនេយ្យ លើគ្រប់ទិដ្ឋភាពនៃថវិកា។ វិសាលភាពនៃការវាយតម្លៃដែលគ្របដណ្តប់ទាំងលើដំណាក់កាលធានាចំណាយ និងដំណាក់កាលទូទាត់ មានសារៈសំខាន់សម្រាប់ការត្រួតពិនិត្យតាមដានលើការអនុវត្តថវិកានិងការប្រើប្រាស់មូលនិធិដែលត្រូវបានផ្តល់ឱ្យ។ គណនេយ្យសម្រាប់ការចំណាយ ដែលត្រូវបានធ្វើឡើងសម្រាប់ការផ្ទេរធនធាន ទៅកាន់អង្គភាពវិសហមជ្ឈការរបស់រដ្ឋាភិបាល ដូចជារដ្ឋបាលថ្នាក់ខេត្ត ត្រូវបានរាប់បញ្ចូលផងដែរ។

**(១) វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាពនិងសមិតភាពជាមួយនឹងការព្យាករណ៍ថវិកា**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំរបាយការណ៍ហិរញ្ញវត្ថុជាច្រើន ក្នុងឆ្នាំនីមួយៗ ដែលមានដូចតទៅ÷

របាយការណ៍ក្នុងឆ្នាំដែលសំខាន់ជាងគេគឺ TOFE (តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់រដ្ឋ) ដែលជារបាយការណ៍គ្រប់ជ្រុងជ្រោយប្រចាំខែនិងប្រចាំឆ្នាំ ស្តីពីការអនុវត្តថវិការបស់គ្រប់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល និងរដ្ឋបាលរាជធានី-ខេត្ត។ របាយការណ៍ TOFE នេះ ត្រូវបានទាញយកពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខ្មែរ (KIT) ដែលរៀបចំដោយនាយកដ្ឋានចំណូលនិងចំណាយថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដែលព័ត៌មានត្រូវបានផ្តល់ដោយអង្គភាពដទៃទៀតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជា អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃអគ្គនាយកដ្ឋានថវិកា និងធនាគារជាតិនៃកម្ពុជា។ របាយការណ៍ត្រូវបានដាក់ជូនថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ។

នាយកដ្ឋានហិរញ្ញកិច្ច រៀបចំរបាយការណ៍ប្រចាំខែស្តីពីស្ថានភាពនៃអាណត្តិទូទាត់ ដោយបែងចែកជាជំពូក។ ទោះបីជារបាយការណ៍នេះបង្ហាញពីអាណត្តិបើកប្រាក់ដែលពុំទាន់ទូទាត់រួច ក៏ប៉ុន្តែរបាយការណ៍នេះមិនបានបង្ហាញនូវសំណើធានាចំណាយ ដែលកកស្ទះនៅមុនពេលមានការបោះផ្សាយអាណត្តិទូទាត់ដោយក្រសួង-ស្ថាប័នឡើយ (មើលសូចនាករសមិទ្ធកម្មទី៤ សមាសធាតុ ១)។

លើសពីនេះ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវរៀបចំរបាយការណ៍ប្រចាំខែ អំពីចំណូលនិងចំណាយ ដែលត្រូវបានទូទាត់ដោយរតនាគារខេត្ត។ របាយការណ៍ទាំងនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើអាណត្តិបើកប្រាក់ ដែលត្រូវបានបញ្ជូនទៅរតនាគាររាជធានី-ខេត្ត ហើយត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយរបាយការណ៍នៃចំណាយ និងចំណូលដែលរៀបចំដោយរតនាគារខេត្តនីមួយៗ។

នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃអគ្គនាយកដ្ឋានថវិកា រៀបចំរបាយការណ៍ប្រចាំខែ អំពីចំណាយវិនិយោគសាធារណៈ ដែលបែងចែកទៅតាមជំពូក ដោយបានបង្ហាញចំណាយមូលធនគាំទ្រដោយមូលនិធិក្នុងស្រុក អាណត្តិទូទាត់ដែលត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ និងព័ត៌មានអំពីកម្ចី។

សូចនាករនេះ ត្រូវបានវាយតម្លៃ ដោយផ្អែកលើរបាយការណ៍ TOFE ដែលជារបាយការណ៍ក្នុងឆ្នាំដែលគ្រប់ជ្រុងជ្រោយជាងគេ។ របាយការណ៍នេះ ត្រូវបានរៀបចំតាមមាតិកាថវិកា ជាចំណាត់ថ្នាក់រដ្ឋបាល និងចំណាត់ថ្នាក់សេដ្ឋកិច្ច តែមានតែលើការទូទាត់ប៉ុណ្ណោះ និងមិនមានបញ្ចូលទិន្នន័យអំពីការធានាចំណាយឡើយ។

សូចនាករនេះទទួលបានពិន្ទុ C ពីព្រោះការធ្វើចំណាត់ថ្នាក់ទិន្នន័យនៅក្នុងរបាយការណ៍នានា អាចនាំឱ្យការប្រៀបធៀប ធ្វើទៅបានជាមួយថវិកានៃគ្រប់អង្គភាពរដ្ឋបាលសំខាន់ៗ ប៉ុន្តែនៅត្រឹមតែដំណាក់កាលទូទាត់ប៉ុណ្ណោះ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ តម្រូវឱ្យមានព័ត៌មានបន្ថែមអំពីការធានាចំណាយ។

### (២) ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍

បច្ចុប្បន្ន របាយការណ៍ TOFE ត្រូវបានរៀបចំនិងចេញផ្សាយជាទូទៅ នៅក្នុងរយៈពេល ៤សប្តាហ៍បន្ទាប់ពីដំណាច់ខែនីមួយៗ។ ភាពទាន់ពេលវេលានេះ អាចធ្វើទៅបាន ដោយសារតែការបញ្ជូនរបាយការណ៍ពីរតនាគារខេត្តបានលឿនជាងមុន។

សមាសធាតុនេះទទួលបានពិន្ទុ A ពីព្រោះរបាយការណ៍នានាត្រូវបានរៀបចំប្រចាំខែ និងបានចេញផ្សាយនៅក្នុងរយៈពេលពីរសប្តាហ៍។

### (៣) គុណភាពនៃព័ត៌មាន

របាយការណ៍គណនេយ្យមិនបានបញ្ចូល ចំណាយក្រោមហិរញ្ញប្បទានពីខាងក្រៅទេ (មើលសូចនាករសមិទ្ធកម្មទី៧ សមាសធាតុ ២)។

ដូចដែលបានលើកឡើងនៅក្នុងសូចនាករសមិទ្ធកម្មទី២២ មានការពន្យារពេលខ្លះនៅក្នុងការធ្វើចំណាត់ថ្នាក់ចំណូល ដែលនាំឱ្យចំណូលមួយចំនួនតូចមិនត្រូវបានកត់ត្រា។ រីឯការពន្យារពេលទូទាត់បុរេប្រទាន ក៏នាំឱ្យការកត់ត្រាចំណូលតិចជាងទំហំជាក់ស្តែងផងដែរ។ បញ្ហាទាំងនេះត្រូវបានទទួលស្គាល់ ប៉ុន្តែពុំប៉ះពាល់ទៅលើទំហំចំណាយឬចំណូលសរុប ឬគុណភាពនៃរបាយការណ៍នោះទេ។

សូចនាករនេះទទួលបានពិន្ទុ C ពីព្រោះសារៈសំខាន់ជារួមនៃរបាយការណ៍នានានៅតែរក្សាបាន ទោះបីជាការកត់ត្រាចំណាយនៃគម្រោងក្រោមហិរញ្ញប្បទានពីខាងក្រៅ មានកង្វះចន្លោះក៏ដោយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ តម្រូវឱ្យមានការយកចិត្តទុកដាក់លើបញ្ហាគុណភាពទិន្នន័យ និងដោះស្រាយបញ្ហាកង្វះចន្លោះនៃទិន្នន័យនានា ដូចត្រូវបានគូសបញ្ជាក់ខាងលើ។

### តារាង គ.៣៧÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២៤

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណោះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-24 | **គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |
| (១) | វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាពនិងសមិតភាពជាមួយនឹងការព្យាករណ៍ថវិកា | C | C | ការធ្វើចំណាត់ថ្នាក់ទិន្នន័យនៅក្នុងរបាយការណ៍នានា អាចនាំឱ្យការប្រៀបធៀប ធ្វើទៅបានជាមួយថវិកានៃគ្រប់អង្គភាពរដ្ឋបាលសំខាន់ៗ ប៉ុន្តែនៅត្រឹមតែដំណាក់កាលទូទាត់ប៉ុណ្ណោះ |
| (២) | ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍ | B | A | របាយការណ៍ត្រូវបានរៀបចំប្រចាំខែ និងចេញផ្សាយនៅក្នុងរយៈពេល៤ សប្តាហ៍។ |
| (៣) | គុណភាពនៃព័ត៌មាន | C | C | ចំណាយក្រោមគម្រោងហិរញ្ញប្បទានពីខាងក្រៅ ពុំមានដាក់បញ្ចូលក្នុងរបាយការណ៍ តែបញ្ហាអំពីសុក្រឹតភាព មានតិចតួចប៉ុណ្ណោះ និងមិនប៉ះពាល់ដល់គុណភាពនៃរបាយការណ៍ឡើយ។ |

**ប្រអប់ គ.២៣÷ ការងារកែទម្រង់កំពុងអនុវត្ត**

ប្លង់គណនីថ្មី (COA) នឹងត្រូវបានអនុវត្តនៅក្នុងនាយកដ្ឋានគណនេយ្យទាំងអស់ ដែលនឹងពង្រឹងសុក្រឹតភាពនៃគណនី ការកត់ត្រា និងគណនេយ្យ។ ប្លង់គណនីថ្មីដូចគ្នានឹងត្រូវបានប្រើប្រាស់នៅក្នុងអង្គភាពរដ្ឋបាលសាធារណៈ។

## គ.៥.៤ គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (PI-25)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើលទ្ធភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅដំណាច់ឆ្នាំឱ្យបានទាន់ពេលវេលា។ សូចនាករនេះ វិភាគលើភាពពេញលេញនិងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងបទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍។

ការវាយតម្លៃលើសមាសធាតុទី១ ផ្តោតលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ចុងក្រោយដែលបានផ្តល់។ ការវាយតម្លៃលើសមាសធាតុទី២ ផ្តោតលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ចុងក្រោយដែលត្រូវបានផ្តល់សម្រាប់ការធ្វើសវនកម្ម (លើកលែងតែពិន្ទុ “D” ដែលត្រូវការទិន្នន័យរយៈពេលបីឆ្នាំ)។ ការវាយតម្លៃលើសមាសធាតុទី៣ ផ្តោតលើរបាយ-ការណ៍ហិរញ្ញវត្ថុនៃបីឆ្នាំសារពើពន្ធចុងក្រោយ។

នាយកដ្ឋានគណនេយ្យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ទទួលបន្ទុករៀបចំតុល្យការសាកល្បងប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់រដ្ឋាភិបាល។ តុល្យការសាកល្បងប្រចាំខែ គឺជាប្រភពឬធាតុចូលសម្រាប់ការរៀបចំរបាយការណ៍ TOFE និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

### (១) ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ

មាត្រា ១១៣ នៃអនុក្រឹត្យ៨២ ឆ្នាំ១៩៩៩ កំណត់ថាច្បាប់ស្តីពីការទូទាត់ថវិកា ត្រូវរៀបចំជាប្រចាំឆ្នាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំនេះ អាចចាត់ទុកជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់រដ្ឋាភិបាល។ របាយការណ៍នេះ មានបញ្ចូលនូវតុល្យភាពទូទៅនៃគណនីដែលបានសំយោគគណនីរបស់គណនេយ្យករសាធារណៈ, សេចក្តីលម្អិតអំពីចំណូលថវិកា, សេចក្តីលម្អិតអំពីចំណាយថវិកាបង្ហាញសម្រាប់ក្រសួងនីមួយៗ នូវចំនួនទឹកប្រាក់ចំណាយតាមជំពូក ដែលបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ, សេចក្តីលម្អិតអំពីប្រតិបត្តិការដែលបានពិនិត្យឃើញក្នុងគណនីពិសេសរបស់រតនាគារ និងសេចក្តីលម្អិតអំពីគណនីលទ្ធផល។ របាយការណ៍ហិរញ្ញវត្ថុ មិនបានបង្ហាញទ្រព្យហិរញ្ញវត្ថុ (រួមទាំងសមតុល្យគណនីធនាគារ) ឬ បំណុល។

សមាសធាតុនេះទទួលបានពិន្ទុ D ដោយហេតុថាសមតុល្យធនាគារមិនមានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ពិន្ទុអាចទទួលបានខ្ពស់ជាងនេះ លុះត្រាតែសមតុល្យធនាគារ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

### (២) ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ

ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវបានតម្រូវឱ្យរៀបចំនិងបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ដែលទទួលបន្ទុកបូកសរុបរបាយការណ៍នេះ។ បច្ចុប្បន្ន រដ្ឋបាលរាជធានី-ខេត្តរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ បានទៀងទាត់ពេលវេលា ដែលកាលពីមុន តែងតែមានភាពយឺតយ៉ាវ។ របាយ-ការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានផ្ញើចេញ ក្នុងពេល ១ ខែ នៃដំណាច់ឆ្នាំ។ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវផ្ទៀងផ្ទាត់ផងដែរដោយហត្ថកម្ម នូវរបាយការណ៍ហិរញ្ញវត្ថុពីគ្រប់ក្រសួង-ស្ថាប័ន។

បន្ទាប់មក អគ្គនាយកដ្ឋានរតនាគារជាតិបូកសរុបរបាយការណ៍ហិរញ្ញវត្ថុ ពីក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ដែលនឹងត្រូវបញ្ជូនទៅសវនកម្មផ្ទៃក្នុង ទីស្តីការ-គណៈរដ្ឋមន្ត្រី និងអាជ្ញាធរសវនកម្មជាតិ។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមិនមានកំណត់កាលបរិច្ឆេទជាក់លាក់នៃការបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា ដែលត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ។

ការត្រួតពិនិត្យលើការផ្តល់របាយការណ៍ស្តីពីការទូទាត់ថវិកាសម្រាប់ឆ្នាំ២០១១-២០១៣ បង្ហាញថារយៈពេលផ្តល់របាយការណ៍ មានច្រើនខែ រាប់ចាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ ដែលមានដូចខាងក្រោម÷

**តារាង គ.៣៨÷ ការផ្តល់របាយការណ៍ហិរញ្ញវត្ថុដើម្បីធ្វើសវនកម្ម**

| ឆ្នាំសារពើពន្ធ | កាលបរិច្ឆេទផ្តល់របាយការណ៍ | រយៈពេលរាប់ពីដំណាច់ឆ្នាំនីមួយៗ |
|---|---|---|
| ២០១១ | ខែកញ្ញា ឆ្នាំ២០១២ | ៨-៩ ខែ |
| ២០១២ | ខែសីហា ឆ្នាំ២០១៣ | ៧-៨ ខែ |
| ២០១៣ | ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ | ៩-១០ ខែ |
| ២០១៤ | នៅមិនទាន់បានផ្តល់នៅឡើយ គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ | ? |

ប្រភពពី÷ អគ្គនាយកដ្ឋានរតនាគារជាតិ និង អាជ្ញាធរសវនកម្មជាតិ

សមាសធាតុនេះ ត្រូវបានវាយតម្លៃ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៃបណ្តាឆ្នាំសារពើពន្ធចុងក្រោយបង្អស់ ដែលត្រូវបានបញ្ជូនសម្រាប់ការធ្វើសវនកម្មនៅក្នុងឆ្នាំ២០១៣។ បើតាមអគ្គនាយកដ្ឋានរតនាគារជាតិ របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានបញ្ជូនទៅអាជ្ញាធរសវនកម្មជាតិ នៅក្នុងខែឧសភា ឆ្នាំ២០១៤ ដែលមានន័យថា ក្នុងរយៈពេល ៥ ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ២០១៣។ ក៏ប៉ុន្តែ អាជ្ញាធរសវនកម្មជាតិ បានឱ្យដឹងថា របាយការណ៍នេះត្រូវបានផ្តល់ជូនអាជ្ញាធរសវនកម្មជាតិ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ មានន័យថា ក្នុងរយៈពេល ៩ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនាំឱ្យទទួលបានពិន្ទុ B។

**(៣) បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់**

អគ្គនាយកដ្ឋានរតនាគារជាតិ ប្រើប្រាស់មូលដ្ឋានសាច់ប្រាក់កែសម្រួល (Modified Cash Basis) នៃគណនេយ្យ និងរបាយការណ៍។ គោលបំណងនៃការប្រើប្រាស់នេះ គឺដើម្បីអនុលោមតាមបទដ្ឋានអន្តរជាតិនៃគណនេយ្យសាធារណៈ (Cash-IPSAS) សម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងជំនួយបច្ចេកទេសមួយចំនួនដែលត្រូវបានផ្តល់ដោយធនាគារពិភពលោក។ ក៏ប៉ុន្តែ ជាក់ស្តែង គណនីប្រចាំឆ្នាំចុងក្រោយបំផុត (២០១៣) ដែលអនុលោមទៅតាមទម្រង់នៃបទដ្ឋាន IPSAS នៅមិនទាន់លេចចេញជារូបរាងនៅឡើយទេ ដែលទម្រង់ IPSAS នេះ តម្រូវឱ្យបញ្ចូលនូវរបាយការណ៍សាច់ប្រាក់ និងការទូទាត់ (រួមបញ្ចូលទាំងសមតុល្យដើមគ្រានិងចុងគ្រា) ព្រមទាំងការទូទាត់ចំណាយដោយដៃគូអភិវឌ្ឍន៍ ក្នុងនាមរាជរដ្ឋាភិបាល (ដែលបច្ចុប្បន្នត្រូវបានរៀបចំជាថវិកា ប៉ុន្តែលំហូរជាក់ស្តែងមិនបានកត់ត្រាទៅគណនីនោះទេ), ការបូកសរុបរបាយការណ៍នៃអង្គភាពស្វយ័តទាំងអស់ (autonomous administrative bodies) ដែលស្ថិតក្រោមរដ្ឋាភិបាល តាមនិយមន័យនៃស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS), ឥណទានថវិកាដើមឆ្នាំនិងឥណទានថវិកាបន្ថែម និងរបាយការណ៍នៃគោលនយោបាយគណនេយ្យ និងសេចក្តីពន្យល់ក្បោះក្បាយ[36]។

ទោះបីយ៉ាងណា របាយការណ៍នានាត្រូវបានរៀបចំ ដោយមានសង្គតិភាពខ្លះទៅនឹងទម្រង់នៃបទដ្ឋានគណនេយ្យ (ដែលមូលដ្ឋានសាច់ប្រាក់កែសម្រួលនៃគណនេយ្យ ត្រូវបានប្រើប្រាស់)។ សមាសធាតុនេះទទួលបានពិន្ទុ C។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ តម្រូវឱ្យមានការដាក់ឱ្យអនុវត្តនូវបទដ្ឋានគណនេយ្យដែលឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ។

**តារាង គ.៣៩÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២៥**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-25 | **គុណភាព និងភាពទាន់ពេលវេលានៃ** | D+ | D+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |

[36] មានភាពលំបាកក្នុងការលើកឡើងនូវប្រទេសកំពុងអភិវឌ្ឍន៍ណា ដែលមិនទាន់បានសម្រេចនូវបទដ្ឋានពេញលេញនៅឡើយ ហើយបច្ចុប្បន្ននេះ IFAC កំពុងពិពិនិត្យពិចារណាលើប្រព័ន្ធ IPSAS ដែលកាត់បន្ថយតម្រូវការនៃអនុលោមភាព និងថែមទាំងលើកទឹកចិត្តឱ្យអនុលោមតាមទៀត។ ប្រព័ន្ធ IPSAS ដែលផ្អែកលើគណនីបង្គរ (accrual-based IPSAS) រួមមានការកំណត់បទដ្ឋាននានាដែលផ្អែកលើបទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ហើយដែលតម្រូវឱ្យមានសមត្ថភាពវិជ្ជាជីវៈ និងច្រើនឆ្នាំ ដើម្បីសម្រេចបាន។

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| | **របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | | | |
| (១) | ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ | D | D | ព័ត៌មានសំខាន់ៗ មិនមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ | C | B | របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៣ ត្រូវបានដាក់បញ្ជូនទៅ NAA នៅក្នុងរយៈពេល ១០ ខែ បន្ទាប់ពីដំណាច់ឆ្នាំ។ |
| (៣) | បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ | D | C | របាយការណ៍នានាត្រូវបានរៀបចំ ដោយមានសង្គតិភាពខ្លះទៅនឹងទម្រង់នៃបទដ្ឋានគណនេយ្យ។ |

### ប្រអប់ គ.២៤÷ ការងារកែទម្រង់កំពុងអនុវត្ត

ជាមួយនឹងជំនួយពីខាងក្រៅសម្រាប់ការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធ IPSAS, មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ បានពង្រឹងការយល់ដឹងរបស់ពួកគេ អំពីសារៈសំខាន់នៃប្រព័ន្ធនេះ។

ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ដែលស្ថិតនៅក្នុងការរៀបចំចាប់តាំងពីឆ្នាំ២០០៦ ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តដោយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ក្រោមកិច្ចសន្យាដែលបានចាប់ផ្តើមក្នុងខែធ្នូ ឆ្នាំ២០១៣ ដែលត្រូវបានផ្តល់ជំនួយដោយធនាគារពិភពលោក។ គម្រោងនេះត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅក្រសួង ស្ថាប័ន ចំនួន ១០។ ម៉ូឌុលស្នូលចំនួន ២ គឺ មុខងារសៀវភៅធំ (General Ledger) និងការវិភាជថវិកា (Budget Allocation), ត្រូវបានដំឡើង និងបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ដែលគ្របដណ្តប់ផងដែរ នូវចំណាយនៅរាជធានី-ខេត្ត។ ក្រៅពីនេះ ម៉ូឌុលផ្សេងទៀត ត្រូវបានរៀបចំជាបន្តបន្ទាប់ រួមមានការបញ្ជាទិញ (payment order), គណនីត្រូវសង (accounts payable) , គណនីត្រូវទារ (accounts receivable) និងការគ្រប់គ្រងសាច់ប្រាក់។ ជាដំណាក់កាលអនុវត្តដំបូង នីតិវិធីការងារនឹងមិនមានការផ្លាស់ប្តូរទេ។ រាល់ធាតុចូលទាំងអស់ ត្រូវបញ្ចូលនៅថ្នាក់កណ្តាល (អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ.) ប៉ុន្តែប្រព័ន្ធនេះត្រូវបានរៀបចំឱ្យដំណើរការនៅលើបណ្តាញ ដែលនៅក្នុងដំណាក់កាលទី២ ការដាក់បញ្ចូលទិន្នន័យនឹងត្រូវអនុវត្តដោយក្រសួង-ស្ថាប័នផ្ទាល់តែម្តង។ ប្រព័ន្ធព័ត៌មានវិទ្យាដទៃទៀតនៅក្នុងរដ្ឋបាលសាធារណៈ នឹងត្រូវបានភ្ជាប់ជាមួយគ្នា ក្នុងនោះរួមមានការគ្រប់គ្រងបំណុល និងប្រព័ន្ធវិភាគហិរញ្ញវត្ថុ (DMFAS), ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS), ប្រព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា (NBC) និងប្រព័ន្ធនៃធនាគារពាណិជ្ជចំនួនពីរ។ ឯកសារយុទ្ធសាស្ត្រព័ត៌មានវិទ្យា របស់រាជរដ្ឋាភិបាលកំពុងស្ថិតនៅក្នុងដំណាក់កាលនៃសេចក្តីព្រាងបឋម។

# គ.៦ ការត្រួតពិនិត្យនិងសវនកម្មខាងក្រៅ

## គ.៦.១ វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ (PI-26)

សូចនាករនេះ វាយតម្លៃលើគុណភាពនៃសវនកម្មពីខាងក្រៅ ដែលគ្របដណ្តប់លើវិសាលភាពនិងទិដ្ឋភាពនៃការងារសវនកម្ម, ការប្រកាន់ខ្ជាប់នូវស្តង់ដារសវនកម្ម (រួមទាំងឯករាជ្យភាពនៃស្ថាប័នសវនកម្មពីខាងក្រៅ), ការផ្តោតលើបញ្ហាសំខាន់ៗនិងមានលក្ខណៈជាប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរបាយការណ៍សវនកម្ម និងសមិទ្ធកម្មនៃគ្រប់សវនកម្មហិរញ្ញវត្ថុ ដូចជា ភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ ភាពទៀងទាត់នៃប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃ និងការប្រព្រឹត្តទៅនៃការត្រួតពិនិត្យផ្ទៃក្នុងនិងប្រព័ន្ធលទ្ធកម្ម។ ការវាយតម្លៃគ្របដណ្តប់លើសវនកម្មពីខាងក្រៅលើរដ្ឋបាលថ្នាក់កណ្តាល ដោយរាប់បញ្ចូលគ្រប់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត និងអង្គភាពស្វយ័ត។ ការវាយតម្លៃ ផ្តោតលើរបាយការណ៍ហិរញ្ញវត្ថុនៃឆ្នាំចុងក្រោយបង្អស់ដែលត្រូវបានធ្វើសវនកម្ម។

សម្រាប់ប្រទេសកម្ពុជា ស្ថាប័នសវនកម្មកំពូល គឺអាជ្ញាធរសវនកម្មជាតិ។ ស្ថាប័ននេះ គឺជាស្ថាប័នឯករាជ្យផ្នែកមុខងារពីរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្ម ក្នុងឆ្នាំ២០០០។ ថ្វីត្បិតមានឯករាជ្យភាពតាមផ្លូវច្បាប់ ក៏ប៉ុន្តែអាជ្ញាធរសវនកម្មជាតិត្រូវគោរពគោលការណ៍នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ជាក់ស្តែង អាជ្ញាធរសវនកម្មជាតិ នៅតែត្រូវអនុលោមតាមការត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ចំណាយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រីឯផ្នែកមុខងារសាធារណៈ (ការគ្រប់គ្រងមន្ត្រី) ត្រូវស្ថិតក្រោមការត្រួតពិនិត្យដោយក្រសួងមុខងារសាធារណៈ ទោះបីជាមានគោលការណ៍ និងលក្ខខណ្ឌដោយឡែកសម្រាប់មន្ត្រីសវនករ នៃអាជ្ញាធរសវនកម្មជាតិ ក៏ដោយ។

### (១) វិសាលភាព/ចរិតលក្ខណៈនៃសវនកម្ម (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម)

អាជ្ញាធរសវនកម្មជាតិ មានផែនការ ៥ឆ្នាំ (២០១២-២០១៦) និងផែនការប្រចាំឆ្នាំ ដែលត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋាននៃហានិភ័យនៃប្រតិបត្តិការ។ យោងតាមអគ្គលេខាធិការនៃអាជ្ញាធរសវនកម្មជាតិ, ផែនការប្រចាំឆ្នាំ កំណត់ឱ្យមានការចុះធ្វើសវនកម្មលើប្រមាណ ៥០-៦០% នៃក្រសួង-ស្ថាប័ន ព្រមទាំងមានការចុះពិនិត្យតាមគោលដៅ/ផ្នែកដែលនៅសល់។ កិច្ចសវនកម្ម ត្រូវបានធ្វើឡើងដោយមន្ត្រីសវនករចំនួនប្រមាណ ១៧០ រូប ដោយអនុលោមតាមស្តង់ដារនិងបទប្បញ្ញត្តិណែនាំ នៃអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (International Organization of Supreme Audit Institutions)។ គោលការណ៍ណែនាំស្តីពីសវនកម្មលើសមិទ្ធកម្ម នៅពុំទាន់បានដាក់ឱ្យអនុវត្តសាកល្បងនៅឡើយ នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនេះ សវនកម្មហិរញ្ញវត្ថុសម្រាប់គម្រោង និងសវនកម្មលើសហគ្រាសសាធារណៈមួយចំនួន ត្រូវបានចុះកិច្ចព្រមព្រៀងឱ្យក្រុមហ៊ុនឯកទេសសវនកម្ម ចុះធ្វើសវនកម្ម។ សមាសធាតុនេះ មិនអាចដាក់ពិន្ទុបានឡើយ ដោយហេតុថាពុំមានឯកសារអំណះអំណាងគ្រប់គ្រាន់។

### (២) ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់សភា

របាយការណ៍សវនកម្ម ត្រូវបានរៀបចំសម្រាប់ក្រសួង-ស្ថាប័ន សម្រាប់រដ្ឋបាលរាជធានី-ខេត្ត និងសម្រាប់គម្រោង ចំនួនប្រមាណ ៨០ ក្នុងមួយឆ្នាំ។ កាលបរិច្ឆេទជាក់លាក់ នៃការបញ្ចប់របាយការណ៍ទាំងនេះ ពុំអាចស្វែងរកបានទេ ប៉ុន្តែរបាយការណ៍សវនកម្មគោល មានក្នុងរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំ។ របាយការណ៍សវនកម្ម

ដែលជាដំបូងត្រូវបានរៀបចំជូនស្ថាប័នរងសវនកម្ម ហៅថា "របាយការណ៍បឋម" ក្នុងទម្រង់ជាលិខិតរដ្ឋបាលសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នរងសវនកម្ម។ បន្ទាប់ពីនេះ ស្ថាប័នរងសវនកម្ម ត្រូវឆ្លើយតបទៅលើការសង្កេត និងអនុសាសន៍ មុននឹងអាជ្ញាធរសវនកម្មជាតិបញ្ជូន "របាយការណ៍ចុងក្រោយ" រួមទាំងអនុសាសន៍ ទៅរដ្ឋសភា។ កាលបរិច្ឆេទ នៃការទទួលនូវរបាយការណ៍ទូទាត់ថវិកា ការចេញផ្សាយរបាយការណ៍បឋម និងរបាយការណ៍ចុងក្រោយ មានដូចខាងក្រោម÷

**តារាង គ.៤០÷ ភាពទាន់ពេលវេលានៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០១៣**

| ឆ្នាំ | កាលបរិច្ឆេទទទួលបាន របាយការណ៍ទូទាត់ថវិកា | កាលបរិច្ឆេទចេញផ្សាយ របាយការណ៍បឋម | កាលបរិច្ឆេទបញ្ជូន របាយការណ៍ចុងក្រោយទៅរដ្ឋសភា |
|---|---|---|---|
| ២០១៣ | ២៤ តុលា ២០១៤[37] | ១២ វិច្ឆិកា ២០១៤ | ០៦ ធ្នូ ២០១៥ |

យោងតាមតារាងខាងលើ របាយការណ៍បឋមនៃសវនកម្មចុងក្រោយ (ឆ្នាំ២០១៣) ត្រូវបានរៀបចំចេញផ្សាយជូនស្ថាប័នរងសវនកម្ម ក្នុងអំឡុងពេល ០១ ខែ នៃការទទួលបានរបាយការណ៍ទូទាត់ថវិកា។ ចំណែកឯរបាយ-ការណ៍ចុងក្រោយ ក៏ត្រូវបានបញ្ជូនដល់រដ្ឋសភា ក្នុងអំឡុងពេល ០៤ ខែ នៃការទទួលបានរបាយការណ៍ទូទាត់ថវិកា។ ដូចនេះ សមាសធាតុនេះត្រូវទទួលបានពិន្ទុ A។

**(៣) ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម**

ក្រុមសវនករនៃអាជ្ញាធរសវនកម្មជាតិ បង្ហាញលទ្ធផលរកឃើញនៃសវនកម្មនៅក្នុងកិច្ចប្រជុំបិទវគ្គសវនកម្ម។ លទ្ធផលរកឃើញទាំងនេះ ត្រូវដាក់ជូនដល់ស្ថាប័នរងសវនកម្ម ដើម្បីពិនិត្យនិងផ្តល់យោបល់ក្នុងអំឡុងពេល ២៨ ថ្ងៃ ប្រសិនបើមាន ដោយភ្ជាប់មកជាមួយនូវភស្តុតាងថ្មី។ យោបល់ទាំងនេះ នឹងត្រូវអាជ្ញាធរសវនកម្មជាតិទទួលយក រួចរៀបចំរបាយការណ៍ចុងក្រោយដែលរួមមានទាំងអនុសាសន៍។ របាយការណ៍នេះ ត្រូវបញ្ជូនទៅរដ្ឋសភាដោយចម្លងជូនស្ថាប័នរងសវនកម្ម ដើម្បីអនុវត្តតាមអនុសាសន៍ខាងលើ។

អាជ្ញាធរសវនកម្មជាតិ តាមដានចំណាត់ការរបស់ថ្នាក់ដឹកនាំស្ថាប័នទៅលើអនុសាសន៍ទាំងនេះ នៅក្នុងការចុះធ្វើសវនកម្មនៅឆ្នាំបន្ទាប់។ យោងតាមអាជ្ញាធរសវនកម្មជាតិ អនុសាសន៍ស្ទើរតែទាំងអស់ ត្រូវបានអនុវត្តតាម ប៉ុន្តែពុំមានអំណះអំណាងណាមួយជាលាយលក្ខណ៍អក្សរឡើយ។

[37] យោង PI-25 (២).

### តារាង គ.៤១÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២៦

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-26 | **វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ** | D+ | NR | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | វិសាលភាព/ចរិតលក្ខណៈរបស់សវនកម្មដែលត្រូវបានធ្វើឡើង (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម) | D | NR | ៥០-៦០% នៃចំណាយសរុបត្រូវបានគ្របដណ្តប់ ប៉ុន្តែឯកសារអំណះអំណាងពុំមានគ្រប់គ្រាន់ឡើយ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់សភា | C | A | របាយការណ៍សវនកម្ម ត្រូវបានបញ្ជូនទៅរដ្ឋសភាក្នុងអំឡុងពេល ០៤ ខែ បន្ទាប់ពីទទួលបានរបាយការណ៍ទូទាត់ថវិកា |
| (៣) | ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម | C | C | មានចំណាត់ការអនុវត្តជាផ្លូវការតាមអនុសាសន៍ ប៉ុន្តែមិនមានភស្តុតាងបញ្ជាក់ពីការអនុវត្តជាប្រព័ន្ធ តាមអនុសាសន៍សវនកម្ម។ |

**ប្រអប់ គ.២៥ ÷ ការងារកែទម្រង់កំពុងអនុវត្ត**

នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ឱ្យអាជ្ញាធរសវនកម្មជាតិផ្សព្វផ្សាយរបាយការណ៍សវនកម្ម ដើម្បីបង្កើនតម្លាភាព។

## គ.៦.២ ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ (PI-27)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើការត្រួតពិនិត្យនិងការជជែកពិភាក្សារបស់អង្គនីតិបញ្ញត្តិលើសេចក្តីព្រាងច្បាប់ថវិកា (ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ) ដោយផ្អែកលើវិសាលភាពនៃការត្រួតពិនិត្យ, នីតិវិធីផ្ទៃក្នុងសម្រាប់ការត្រួតពិនិត្យនិងការជជែកពិភាក្សា និងពេលវេលាសម្រាប់កិច្ចដំណើរការទាំងនេះ។ ភាពគ្រប់គ្រាន់នៃឯកសារថវិកា ត្រូវវាយតម្លៃដោយសូចនាករសមិទ្ធកម្មទី៦នេះ (PI-6)។ ការវាយតម្លៃសូចនាករនេះ ផ្អែកលើឆ្នាំសារពើពន្ធចុងក្រោយ។

អង្គនីតិបញ្ញត្តិ រួមមានរដ្ឋសភា និងព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់ថវិកាត្រូវបញ្ជូនទៅរដ្ឋសភា។ បន្ទាប់ពីទទួលបានការអនុម័តពីរដ្ឋសភា សេចក្តីព្រាងច្បាប់ថវិកាត្រូវបញ្ជូនទៅព្រឹទ្ធសភា ដើម្បីស្នើសុំការអនុម័ត។

### (១) វិសាលភាពនៃការត្រួតពិនិត្យដោយអង្គនីតិបញ្ញត្តិ

អង្គនីតិបញ្ញត្តិទទួលសេចក្តីព្រាងច្បាប់ថវិកា ក្រោយពេលដែលព័ត៌មានលម្អិតនៃចំណូល-ចំណាយត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល។ អង្គនីតិបញ្ញត្តិ មិនចូលរួមក្នុងការកំណត់អាទិភាពគោលនយោបាយសារពើពន្ធសម្រាប់រយៈពេលវែង ឬមធ្យមឡើយ។

ក្នុងការត្រួតពិនិត្យសេចក្តីព្រាងច្បាប់ថវិកា រដ្ឋសភាអាចស្នើឱ្យអ្នកជំនាញការដែលបំពេញការងារនៅក្នុងគណៈកម្មការទី២ នៃរដ្ឋសភា និងអ្នកបច្ចេកទេសនៃនាយកដ្ឋានស្រាវជ្រាវច្បាប់ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ពិនិត្យ និងផ្តល់យោបល់។

រដ្ឋសភា មានសិទ្ធិស្នើកែប្រែនិងកែសម្រួលសេចក្តីព្រាងច្បាប់ថវិកា ដែលក្នុងការអនុវត្ត រដ្ឋសភាធ្លាប់បានស្នើឱ្យកែប្រែរួចមកហើយ ក៏ប៉ុន្តែ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ពុំមានការកែសម្រួលធំដុំទៅលើសេចក្តីព្រាងច្បាប់ថវិកាឡើយ។

សមាសធាតុនេះទទួលបានពិន្ទុ C ព្រោះអង្គនីតិប្បញ្ញត្តិចាប់ផ្តើមត្រួតពិនិត្យលើចំណូល-ចំណាយ នៅដំណាក់កាលដែលសេចក្តីព្រាងចំណូល-ចំណាយលម្អិត ត្រូវបានរៀបចំបញ្ចប់ដោយរាជរដ្ឋាភិបាលរួចទៅហើយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ តម្រូវឱ្យអង្គនីតិប្បញ្ញត្តិត្រួតពិនិត្យផងដែរលើគោលនយោបាយសារពើពន្ធ និងការប៉ាន់ស្មានចំណូល-ចំណាយសរុប សម្រាប់ឆ្នាំទៅមុខទៀត មុននឹងសេចក្តីព្រាងច្បាប់ត្រូវបានបញ្ចប់។

### (២) កម្រិតនៃការរៀបចំនីតិវិធីបានល្អនិងការអនុវត្តនីតិវិធីបានត្រឹមត្រូវក្នុងអង្គនីតិប្បញ្ញត្តិ

នៅពេលដែលរដ្ឋសភាទទួលបានសេចក្តីព្រាងច្បាប់ថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខា-ធិការដ្ឋានរដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់នេះ បន្តទៅគណៈកម្មការទី២នៃរដ្ឋសភា គឺគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។ បន្ទាប់មក គណៈកម្មការទី២ បញ្ជូនសេចក្តីព្រាងច្បាប់បន្តទៅគណៈកម្មការពាក់ព័ន្ធដទៃទៀត ដើម្បីពិនិត្យលើផ្នែកមួយចំនួននៃសេចក្តីព្រាងច្បាប់នេះ។ ការសម្រេចលើសេចក្តីព្រាងច្បាប់ នៅក្នុងគណៈកម្មការទាំងឡាយ ត្រូវធ្វើឡើងតាមការបោះឆ្នោតដោយការលើកដៃ ដោយយកសម្លេងភាគច្រើនដាច់ខាត។ គណៈកម្មការទាំងនេះរៀបចំកិច្ចប្រជុំផ្ទៃក្នុង និងសិក្ខាសាលាមួយចំនួន។ បន្ទាប់ពីបានពិនិត្យ និងទទួលបានការបញ្ជាក់នានាពីគណៈកម្មការជំនាញ សេចក្តីព្រាងច្បាប់ថវិកាត្រូវបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដើម្បីពិនិត្យដាក់បញ្ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គនៃរដ្ឋសភា។ ក្រោយពីទទួលបានការអនុម័តពីរដ្ឋសភា សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅព្រឹទ្ធសភា ដែលមាននីតិវិធីដោយឡែក តែមានលក្ខណៈប្រហាក់ប្រហែលនឹងនីតិវិធីនៃរដ្ឋសភាដែរ។ ពុំមានតម្រុយណា បង្ហាញថានីតិវិធីទាំងនេះមិនត្រូវបានគោរពនោះឡើយ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ B ព្រោះនីតិវិធីសាមញ្ញសម្រាប់ការត្រួតពិនិត្យ និងអនុម័តនៃរដ្ឋសភាត្រូវបានរៀបចំ និងអនុវត្ត។ ពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យមានការពង្រឹងនិងពង្រីកនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង។

### (៣) ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិ ក្នុងការឆ្លើយតបទៅនឹងសំណើថវិកា

ផ្អែកលើប្រតិទិនថវិកា (យោង PI-11 សមាសធាតុ ១), អង្គនីតិប្បញ្ញត្តិមានពេលប្រមាណ ៧ សប្តាហ៍ក្រោយពីទទួលបានសេចក្តីព្រាងច្បាប់ថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ពិនិត្យនិងអនុម័ត។ ក្នុងការអនុវត្ត

ជាក់ស្តែង ការពិនិត្យនិងអនុម័តនេះ ត្រូវការពេលប្រមាណពី ៣ ទៅ ៦សប្តាហ៍[38] សម្រាប់ថវិកាឆ្នាំ២០១៤ និងឆ្នាំ២០១៥។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ C ព្រោះអង្គនីតិបញ្ញត្តិមានរយៈពេល ០១ ខែ សម្រាប់ពិនិត្យ និងអនុម័ត។ គួរកត់សម្គាល់ថាលក្ខខណ្ឌវិនិច្ឆ័យ ដើម្បីដាក់ពិន្ទុ B និង C ពុំខុសគ្នាឡើយ [39]។ ពិន្ទុ A ទាមទារឱ្យផ្តល់រយៈពេលយ៉ាងតិច ០២ ខែ សម្រាប់រដ្ឋសភាត្រួតពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ថវិកា។

### (៤) វិធានស្តីពីការកែតម្រូវថវិកាក្នុងឆ្នាំ ដោយពុំចាំបាច់មានការយល់ព្រមជាមុនឬក្រោយពីអង្គនីតិបញ្ញត្តិ

មាត្រា ៥៥ ដល់ ៦២ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៨ បានកំណត់អំពីនីតិវិធីក្នុងការធ្វើវិសោធនកម្មច្បាប់ថវិកាប្រចាំឆ្នាំ។ វិសោធនកម្ម ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការរៀបចំសេចក្តីព្រាងច្បាប់ថវិកាដែរ។ ជាគោលការណ៍ និយ័តកម្មឥណទានថវិកាពីស្ថាប័នមួយទៅស្ថាប័នមួយទៀត ត្រូវជាកម្មវត្ថុនៃការអនុម័តពីអង្គនីតិបញ្ញត្តិ។ ដូចគ្នាដែរ និយ័តកម្មឥណទានថវិកាពីចំណាយមូលធន ទៅចំណាយចរន្តនៅក្នុងស្ថាប័នតែមួយ ត្រូវស្នើសុំការអនុម័តពីអង្គនីតិបញ្ញត្តិ។ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួន សិទ្ធិអំណាចត្រូវបានផ្តល់ជូនរាជរដ្ឋាភិបាលក្នុងការធ្វើនិយ័តកម្មខាងលើ ដូចជាករណីគ្រោះធម្មជាតិ និងការប្រកាសអាសន្ននានា ព្រមទាំងការផ្ទេរឥណទាននៅក្នុងជំពូក និងគណនី ដរាបណាការផ្ទេរនេះត្រូវបានធ្វើឡើងក្នុងគោលបំណងពង្រឹងរចនាសម្ព័ន្ធ ឬអភិបាលកិច្ចនៃរាជរដ្ឋាភិបាល។ ការផ្ទេរឥណទានដទៃទៀត អាចធ្វើឡើងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬដោយអនុក្រឹត្យ រួមទាំងការផ្ទេរឥណទានពីជំពូកចំណាយមិនបានគ្រោងទុក។ ចំណែកឯចំណូលលើសការកំណត់ក្នុងច្បាប់ថវិកា ត្រូវយោងទៅឆ្នាំបន្ទាប់ លើកលែងតែមាននិយ័តកម្មឥណទាន តាមរយៈវិសោធនកម្មច្បាប់ថវិកា (យោង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ មាត្រា ៣៣ វាក្យខ័ណ្ឌទី២)។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ B ព្រោះបទប្បញ្ញត្តិសម្រាប់ការកែសម្រួលឥណទានថវិកានៅក្នុងឆ្នាំអនុវត្តថវិកាដោយពុំចាំបាច់មានការអនុម័តជាមុនពីអង្គនីតិបញ្ញត្តិ ត្រូវបានចែងនិងអនុវត្តតាមច្បាស់លាស់ ព្រមទាំងពុំអនុញ្ញាតឱ្យមានការបង្កើនចំណាយនៅក្នុងឆ្នាំឡើយ (ទោះបីជាការប្រមូលចំណូល ទទួលបានលើសពីការចែងក្នុងច្បាប់ក៏ដោយ)។ ពិន្ទុដែលខ្ពស់ជាងនេះ នឹងតម្រូវឱ្យមានការកំណត់តឹងរ៉ឹង ទៅលើគោលការណ៍ និងជម្រៅនៃការកែសម្រួលកញ្ចប់ថវិកា។

---

[38] រយៈពេលនេះ ត្រូវបានគណនាដោយយកផលដករវាងកាលបរិច្ឆេទបញ្ជូន និងទទួលឯកសារថវិកា ដែលផ្តល់និងទទួលដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋសភា និងព្រឹទ្ធសភា និងព្រះបរមរាជវាំង។

[39] សមាសធាតុ (៣) មានលក្ខខណ្ឌវិនិច្ឆ័យដាក់ពិន្ទុដូចគ្នា រវាងពិន្ទុ B និង C។ ពិន្ទុនៃសមាសធាតុនេះ ត្រូវសម្រេចផ្អែកលើសមាសធាតុដទៃទៀត ដោយយោងទៅលើមគ្គុទេសក៍ណែនាំ ២៧-៦។ ហេតុនេះ ទើបទទួលបានពិន្ទុ C។

## តារាង គ.៤២÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២៧

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-27 | **ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ** | NU | C+ | វិធីសាស្ត្រវាយតម្លៃដាក់ពិន្ទុ M1 |
| (១) | វិសាលភាពនៃការត្រួតពិនិត្យរបស់អង្គនីតិប្បញ្ញត្តិ | NU | C | អង្គនីតិប្បញ្ញត្តិត្រួតពិនិត្យលើសេចក្ដីលម្អិតនៃចំណូល-ចំណាយ នៅដំណាក់កាលដែលសេចក្ដីព្រាងចំណូល-ចំណាយលម្អិត ត្រូវបានរៀបចំបញ្ចប់ដោយរាជរដ្ឋាភិបាលរួចទៅហើយ។ |
| (២) | កម្រិតនៃការរៀបចំនីតិវិធីបានល្អនិងការអនុវត្តនីតិវិធីបានត្រឹមត្រូវក្នុងអង្គនីតិប្បញ្ញត្តិ | NU | B | មាននីតិវិធីសាមញ្ញសម្រាប់ការពិនិត្យនិងអនុម័តដោយអង្គនីតិប្បញ្ញត្តិ ហើយនីតិវិធីនេះត្រូវបានអនុវត្ត។ |
| (៣) | ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិ ក្នុងការឆ្លើយតបទៅនឹងសំណើថវិកា | NU | C | រយៈពេលសម្រាប់ការពិនិត្យ និងអនុម័តដោយអង្គនីតិប្បញ្ញត្តិមានប្រមាណ ៧ សប្ដាហ៍។ ក្នុងការអនុវត្តជាក់ស្ដែង អង្គនីតិប្បញ្ញត្តិត្រូវការពេលវេលាតិចជាងនេះសម្រាប់ពិនិត្យនិងអនុម័តសេចក្ដីព្រាងច្បាប់ថវិកា។ |
| (៤) | វិធានស្ដីពីការកែតម្រូវថវិកាក្នុងឆ្នាំ ដោយពុំចាំបាច់មានការយល់ព្រមជាមុន ឬក្រោយពីអង្គនីតិប្បញ្ញត្តិ | NU | B | បទប្បញ្ញត្តិសម្រាប់ការកែសម្រួលឥណទានថវិកានៅក្នុងឆ្នាំអនុវត្តថវិកាដោយពុំចាំបាច់មានការអនុម័តជាមុនពីអង្គនីតិប្បញ្ញត្តិ ត្រូវបានចែងនិងអនុវត្តតាមច្បាស់លាស់, ព្រមទាំងពុំអនុញ្ញាតឱ្យមានការបង្កើនចំណាយនៅក្នុងឆ្នាំឡើយ )ទោះបីជាការប្រមូលចំណូល ទទួលបានលើសពីការចែងក្នុងច្បាប់ក៏ដោយ( |

**ប្រអប់ គ.២៦÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ពុំមានសកម្មភាពកែទម្រង់ឡើយ។

## គ.៦.៣ ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិប្បញ្ញត្តិ (PI-28)

អង្គនីតិប្បញ្ញត្តិមានតួនាទីគន្លឹះ ក្នុងការត្រួតពិនិត្យលើការអនុវត្តថវិកាដែលត្រូវបានអនុម័តរួចរាល់។ យន្តការតាមដានត្រួតពិនិត្យលើការអនុវត្តថវិកានេះ គឺប្រព្រឹត្តទៅតាមរយៈគណៈកម្មការជំនាញនៃរដ្ឋសភា ឬគណៈកម្មាធិការដែលពិនិត្យលើរបាយការណ៍សវនកម្ម និងលើកសំណួរទៅស្ថាប័នពាក់ព័ន្ធ អំពីលទ្ធផលរកឃើញដែលមានក្នុងរបាយការណ៍សវនកម្ម។ កិច្ចដំណើរការនៃគណៈកម្មការជំនាញ ពឹងផ្អែកលើភាពគ្រប់គ្រាន់នៃធនធានហិរញ្ញវត្ថុ និងបច្ចេកទេស និងពេលវេលាដែលផ្ដល់ជូនគណៈកម្មការក្នុងការតាមដានរបាយការណ៍សវនកម្ម។ ជាមួយនឹងការអនុម័តលើអនុសាសន៍ដែលមានក្នុងរបាយការណ៍សវនកម្ម គណៈកម្មការជំនាញអាចផ្ដល់អនុសាសន៍ និងស្នើទណ្ឌកម្មផ្សេងៗ ដើម្បីឱ្យរាជរដ្ឋាភិបាលអនុវត្តតាម (សូចនាករសមិទ្ធកម្មទី២៦)។

ការវាយតម្លៃក្នុងសូចនាករសមិទ្ធកម្មនេះ ផ្ដោតលើរដ្ឋបាលថ្នាក់កណ្ដាល រួមទាំងអង្គភាពស្វយ័ត ដែលមានលក្ខណៈវិនិច្ឆ័យដូចតទៅ ១-ត្រូវបានតម្រូវដោយច្បាប់ឱ្យផ្ដល់របាយការណ៍សវនកម្ម ទៅអង្គនីតិប្បញ្ញត្តិ ឬ ២-ក្រសួង-ស្ថាប័នអាណាព្យាបាល ត្រូវឆ្លើយសំណួរ និងមានចំណាត់ការនានាលើអង្គភាពស្វយ័តទាំងនេះ។ ការវាយតម្លៃលើសមាសធាតុ (១) ត្រូវបានធ្វើឡើងដោយផ្អែកលើរបាយការណ៍សវនកម្មដែលបញ្ជូនទៅអង្គនីតិប្បញ្ញត្តិ នៅក្នុងអំឡុងពេល ០៣ ឆ្នាំចុងក្រោយ រីឯការវាយតម្លៃនៃសមាសធាតុដទៃទៀត នៃសូចនាករនេះ ត្រូវបានធ្វើឡើងផ្អែកលើរបាយ-ការណ៍ក្នុងអំឡុងពេល ១២ ខែចុងក្រោយ។

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២ នៃរដ្ឋសភា) មានមុខងារត្រួតពិនិត្យថវិកា និងត្រួតពិនិត្យក្រោយសវនកម្ម ដូចដែលបានបរិយាយនៅក្នុងសូចនាករសមិទ្ធកម្មទី២៧ (PI-27)។ កិច្ចពិភាក្សានិងការសម្រេចនានា ភាគច្រើនត្រូវធ្វើឡើងជាឯកច្ឆន្ទ ប៉ុន្តែក្នុងករណីមិនអាចស្វែងរកសម្លេងឯកច្ឆន្ទបាន ប្រធានអាចស្នើឱ្យបោះឆ្នោតដោយលើកដៃ (តាមសម្លេងភាគច្រើនដាច់ខាត)។

### (១) ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្ម ដោយអង្គនីតិប្បញ្ញត្តិ

ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ពុំមានចែងកំណត់កាលបរិច្ឆេទ ដែលអាជ្ញាធរសវនកម្ម-ជាតិត្រូវបញ្ជូនរបាយការណ៍ទៅគណៈកម្មការទី២ ឬរយៈពេលនៃការពិនិត្យលើរបាយការណ៍សវនកម្មនេះដោយគណៈកម្មការទី២ ឡើយ។ គណៈកម្មការទី២ រៀបចំកិច្ចប្រជុំជាប្រចាំ តាមកាលបរិច្ឆេទសមស្រប។ តារាងខាងក្រោមបង្ហាញពីកាលបរិច្ឆេទនៃការទទួលបាននូវរបាយការណ៍សវនកម្ម ក្នុងអំឡុងពេល ០៣ ឆ្នាំចុងក្រោយ និងកាល-បរិច្ឆេទដែលរដ្ឋសភាអនុម័តលើច្បាប់ថវិកាប្រចាំឆ្នាំ។

**តារាង គ.៤៣÷ ភាពទាន់ពេលវេលានៃការពិនិត្យរបាយការណ៍សវនកម្ម**

| ឆ្នាំសារពើពន្ធដែលបានធ្វើសវនកម្ម | កាលបរិច្ឆេទទទួលបានរបាយការណ៍ទូទាត់ថវិកា* | កាលបរិច្ឆេទដែលរដ្ឋសភាអនុម័តច្បាប់ថវិកាប្រចាំឆ្នាំ | រយៈពេលសម្រាប់បញ្ចប់ការត្រួតពិនិត្យ |
|---|---|---|---|
| ២០១១ | ២៧ ធ្នូ ២០១២ | ២៥ មករា ២០១៣ | តិចជាង ១ ខែ |
| ២០១២ | ២១ មករា ២០១៤ | ០១ មេសា ២០១៤ | ២ ខែ កន្លះ |
| ២០១៣ | ១៦ កុម្ភៈ ២០១៥* | ២៩ មិថុនា ២០១៥ | ៤ ខែ កន្លះ |

** កាលបរិច្ឆេទនេះ ខុសពីកាលបរិច្ឆេទ (០៦ កុម្ភៈ ២០១៥) ដែលផ្តល់ដោយអាជ្ញាធរសវនកម្មជាតិ។ ភាពខុសគ្នានេះ ពុំធ្វើឱ្យប៉ះពាល់ដល់ការដាក់ពិន្ទុឡើយ។*

រយៈពេលជាមធ្យមនៃការត្រួតពិនិត្យ ក្នុងអំឡុងពេលពីរឆ្នាំ នៃបីឆ្នាំចុងក្រោយ គឺ ៣ ខែកន្លះ។ លទ្ធផលនេះនាំឱ្យទទួលបានពិន្ទុ B ដោយហេតុថា រយៈពេលត្រួតពិនិត្យតិចជាង ៦ ខែ។ ពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យរយៈពេលត្រួតពិនិត្យ មានក្រោម ៣ ខែ។

**(២) ការរៀបចំសវនាការដោយអង្គនីតិប្បញ្ញត្តិ លើរបកគំហើញគន្លឹះ**

សវនាការនេះ មានការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃក្រសួង-ស្ថាប័នរងសវនកម្ម តំណាងនៃអាជ្ញាធរសវនកម្មជាតិ និងតំណាងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សវនាការមិនចាំបាច់ត្រូវរៀបចំសម្រាប់គ្រប់ស្ថាប័នរងសវនកម្មដែលត្រូវបានផ្តល់អនុសាសន៍ដោយអាជ្ញាធរសវនកម្មជាតិឡើយ។ សវនាការ និងកិច្ចប្រជុំមានលក្ខណៈបិទជិត ប៉ុន្តែសន្និសីទព័ត៌មានអាចត្រូវបានរៀបចំដោយប្រធានសវនាការ/កិច្ចប្រជុំ ក្រោយកិច្ចប្រជុំត្រូវបានបញ្ចប់។ គណៈកម្មការទី២ មានជំនួយផ្នែករដ្ឋបាល-លេខាធិការ ប៉ុន្តែជំនួយបច្ចេកទេសមានតិចតួចប៉ុណ្ណោះ ព្រោះពុំមានអង្គភាពពាក់ព័ន្ធថវិកាជាជំនួយការស្រាវជ្រាវ សម្រាប់សមាជិកគណៈកម្មការឡើយ។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ B ព្រោះសវនាការលម្អិត ត្រូវបានរៀបចំដោយមានការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃស្ថាប័នរងសវនកម្ម។ ពិន្ទុខ្ពស់ជាងនេះ ទាមទារឱ្យសវនាការធ្វើឡើងលើភាគច្រើននៃស្ថាប័នរងសវនកម្មដែលមានបញ្ហាសវនកម្ម។

**(៣) អនុសាសន៍របស់អង្គនីតិប្បញ្ញត្តិ និងការអនុវត្តតាមអនុសាសន៍ដោយអង្គនីតិប្រតិបត្តិ**

គណៈកម្មការទី២ ផ្តល់អនុសាសន៍របស់ខ្លួន ដែលនឹងត្រូវតាមដាននៅក្នុងសវនាការលើកក្រោយជាមួយស្ថាប័នរងសវនកម្មនីមួយៗ។ អនុសាសន៍មួយចំនួនត្រូវបានអនុវត្ត ឯមួយចំនួនទៀតក៏ពុំត្រូវបានអនុវត្ត។ ការវាយតម្លៃជាភាគរយនៃការអនុវត្តតាមអនុសាសន៍ ពុំអាចស្វែងរកបានឡើយ។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ B ដោយហេតុថាអង្គនីតិប្បញ្ញត្តិបានផ្តល់អនុសាសន៍ដល់អង្គនីតិប្រតិបត្តិ ហើយអនុសាសន៍មួយចំនួនត្រូវបានអនុវត្តតាម។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គ្រប់អនុសាសន៍ត្រូវតែមានការឆ្លើយតបនិងត្រូវបានចាត់វិធានការអនុវត្តតាមជាទូទៅ។

**តារាង គ.៤៤÷ ពិន្ទុសូចនាករសមិទ្ធកម្មទី២៨**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| PI-28 | **ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិប្បញ្ញត្តិ** | NR | B | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្ម ដោយអង្គនីតិប្បញ្ញត្តិ | NR | B | របាយការណ៍សវនកម្មត្រូវបានពិនិត្យ ហើយការត្រួតពិនិត្យដោយអង្គនីតិប្បញ្ញត្តិ ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ខែជាមធ្យម ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ |
| (២) | ការរៀបចំសវនាការដោយអង្គនីតិប្បញ្ញត្តិលើរបកគំហើញគន្លឹះ | NR | B | សវនាការលម្អិតត្រូវបានរៀបចំ ដោយមានការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃអង្គភាពរងសវនកម្ម ប៉ុន្តែពុំត្រូវបានរៀបចំសម្រាប់គ្រប់ស្ថាប័នរងសវនកម្មឡើយ។ |
| (៣) | អនុសាសន៍របស់អង្គនីតិប្បញ្ញត្តិ និងការអនុវត្តសកម្មភាពអនុលោមតាមអនុសាសន៍ដោយអង្គនីតិប្រតិបត្តិ | NR | B | អង្គនីតិប្បញ្ញត្តិបានផ្តល់អនុសាសន៍ដល់អង្គ-នីតិប្រតិបត្តិ ហើយអនុសាសន៍មួយចំនួនត្រូវបានអនុវត្តតាម។ |

**ប្រអប់ គ.២៧÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

ពុំមាន។

## គ.៧ ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍

ក្នុងប្រទេសកម្ពុជា ចំណាយមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ ជាផ្នែកមួយដ៏សំខាន់នៃធនធានហិរញ្ញវត្ថុ សម្រាប់ចំណាយសាធារណៈ។ យោងតារាង គ.៤៦ ខាងក្រោម ក្នុងឆ្នាំ២០១២ មូលនិធិដៃគូអភិវឌ្ឍន៍មានប្រមាណ ៥០% នៃចំណាយសរុបរបស់រដ្ឋាភិបាល រីឯបច្ចុប្បន្ន មានប្រមាណ ៤៣%។ ដៃគូអភិវឌ្ឍន៍ដែលកំពុងដំណើរការក្នុងប្រទេសកម្ពុជាមានប្រមាណ ៣៥ ទៅ៤០ រួមបញ្ចូលទាំងស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ, ដៃគូពហុភាគី និងដៃគូទ្វេភាគី ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត (NGOs) ដូចមានក្នុងឧបសម្ព័ន្ធ ៥ ក្នុងតារាង ៥.៤។ ដៃគូអភិវឌ្ឍន៍ធំជាងគេ គឺប្រទេសចិន (២៦% នៃមូលនិធិសរុប), ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី (ពី៩-១០%), សហរដ្ឋអាមេរិក, អូស្ត្រាលី, សហភាពអឺរ៉ុប (ពី៣-៦%) ដែលគណនីរួមរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះបូកបញ្ចូលគ្នា មានច្រើនជាងពាក់កណ្តាលនៃហិរញ្ញប្បទានពីខាងក្រៅសរុប។ ព័ត៌មានទាំងនេះ ត្រូវបានចាត់ទុកថាជាព័ត៌មានពេញលេញ តែ

មានដៃគូអភិវឌ្ឍន៍មួយចំនួន មិនបានរាយការណ៍នូវគ្រប់ព័ត៌មានហិរញ្ញប្បទានដែលបានផ្តល់ជូនឡើយ ជាពិសេសប្រទេសចិន និងសហរដ្ឋអាមេរិក)។

**តារាង គ.៤៥÷ រាជរដ្ឋាភិបាលកម្ពុជា និងការផ្តល់កញ្ចប់ថវិការបស់ដៃគូអភិវឌ្ឍន៍ (គិតជាលានដុល្លារអាមេរិក)**

| ឆ្នាំ | ចំណាយសរុប របស់រដ្ឋាភិបាល (១) | ការផ្តល់កញ្ចប់ថវិកា របស់ដៃគូអភិវឌ្ឍន៍ (២) | ភាគរយនៃកញ្ចប់ថវិការបស់ដៃគូអភិវឌ្ឍន៍ (២) ក្នុងចំណាយសរុបរបស់រដ្ឋាភិបាលកម្ពុជា (១) |
|---|---|---|---|
| ២០១១ | ២ ៣៧៥ | ១ ៤២៣ | ៥៩,៩% |
| ២០១២ | ២ ៦៩០ | ១ ៤៩៩ | ៥៥,៧% |
| ២០១៣ | ២ ៩៨១ | ១ ៤៥១ | ៤៨,៧% |
| ២០១៤ | ៣ ៤១៦ | ១ ៤៧២ | ៤៣,१% |

ប្រភព÷ អគ្គនាយកដ្ឋានថវិកា

## គ.៧.១ ភាពអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាដោយផ្ទាល់ (D-1)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃការប៉ាន់ប្រមាណអំពីលំហូរនៃការគាំទ្រថវិកាដោយផ្ទាល់របស់ដៃគូអភិវឌ្ឍន៍ (Budget Support)។ ការវាយតម្លៃសមាសធាតុទី១ គឺផ្អែកលើការព្យាករណ៍ដែលផ្តល់ដោយភ្នាក់ងារដៃគូអភិវឌ្ឍន៍ ជាងលើថវិកាគាំទ្រដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ រីឯការវាយតម្លៃលើសមាសភាពទី២ គឺផ្អែកលើការបែងចែកជាក់ស្តែងជាប្រចាំត្រីមាស នូវលំហូរនៃ Budget Support ធៀបនឹងផែនការដែលបានឯកភាព។ ការវាយតម្លៃផ្តោតលើឆ្នាំសារពើពន្ធ០៣ឆ្នាំចុងក្រោយ។

**(១) គម្លាតរវាងការអនុវត្តជាក់ស្តែងនៃ** Budget Support **និងការព្យាករណ៍**

ដៃគូអភិវឌ្ឍន៍ផ្តល់ការព្យាករណ៍ Budget Support ប្រចាំឆ្នាំ ក្នុងអំឡុងពេលនៃការវាយតម្លៃ តាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ គម្លាតនៃការផ្តល់ហិរញ្ញប្បទានជាមួយនឹងការព្យាករណ៍មានទំហំធំ និងជាទូទៅ ការផ្តល់ហិរញ្ញប្បទានទាបជាងការប៉ាន់ប្រមាណនាឆ្នាំកន្លងទៅ ដូចបានបង្ហាញក្នុងតារាង គ.៤៥ ខាងក្រោម។ Budget Support ត្រូវផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០១២-២០១៣ ដោយសហភាពអឺរ៉ុប និងធនាគារអភិវឌ្ឍន៍អាស៊ីតែប៉ុណ្ណោះ ដោយហេតុថា ដៃគូអភិវឌ្ឍន៍ផ្សេងទៀត (ដូចជា ធនាគារពិភពលោក) បានបញ្ឈប់ Budget Support ក្នុងឆ្នាំ២០១១។ ហេតុនេះ ទំហំសរុបនៃ Budget Support បានធ្លាក់ចុះយ៉ាងគំហុក ទាំងថវិកាដែលបានគ្រោង ទាំងការផ្តល់ហិរញ្ញប្បទានជាក់ស្តែង។ ការផ្តល់ហិរញ្ញប្បទានតាមរយៈ Budget Support ដោយសហភាពអឺរ៉ុបនិងធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានអនុវត្តសម្រាប់វិស័យជាក់លាក់ណាមួយប៉ុណ្ណោះ ដោយសហភាពអឺរ៉ុប ផ្តោតលើវិស័យអប់រំ រីឯធនាគារអភិវឌ្ឍន៍អាស៊ី គាំទ្រដល់ការកែទម្រង់គោលនយោបាយដែលគ្របដណ្តប់លើវិសាលភាពនៃវិស័យធំៗ។

សមាសធាតុនេះ ត្រូវបានផ្តល់ពិន្ទុ D ដោយសារការផ្តល់ Budget Support ជាក់ស្តែង មានតិចជាងផែនការ លើសពី ១៥% ក្នុងរយៈពេល២ឆ្នាំ នៃ៣ឆ្នាំចុងក្រោយ (២០១២-២០១៤) គឺមាន ៦៧% និង៦៤% នៃឆ្នាំនីមួយៗ។

**តារាង គ.៤៦÷ ការប៉ាន់ប្រមាណ និងការទទួលបានជាក់ស្តែងនូវថវិកាគាំទ្រ (គិតជាលានដុល្លារអាមេរិក)**

| ប្រភេទជំនួយ | ២០១១ | | ២០១២ | | ២០១៣ | | ២០១៤ | |
|---|---|---|---|---|---|---|---|---|
| | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត |
| ហិរញ្ញប្បទាន ឥតសំណង | ៤២,២ | ៤៦,៤ | ១១,៤ | ៨,៩ | ២០,៨ | ០,០ | ៣៨,៨ | ២២,១ |
| កម្ចី | ៣៥,៤ | ៦១,៩ | ៦០,៩ | ១៤,៧ | ៥៩,០ | ៨២,២ | ២២,០ | ០,០ |
| សរុប | ៧៧,៦ | ១០៨,៣ | ៧២,៣ | ២៣,៦ | ៧៩,៨ | ៨២,២ | ៦០,៨ | ២២,១ |
| គម្លាតពីផែនការ | | +៤០% | | -៦៧% | | +៣% | | -៦៤% |

ប្រភព÷ ផ្នែកថវិកា, ឃ្លាំងផ្ទុកទិន្នន័យ *ODA* ខែមេសា ២០១៥ និងព័ត៌មានពី *ADB*[40]

### (២) ភាពទាន់ពេលវេលានៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍មិនបានផ្តល់ការប៉ាន់ស្មានការផ្តល់ហិរញ្ញប្បទានតាមការគាំទ្រថវិកាផ្ទាល់ ប្រចាំត្រីមាសឡើយ។ សមាសធាតុនេះគឺត្រូវបានផ្តល់ពិន្ទុ D។

**តារាង គ.៤៧÷ ពិន្ទុសូចនាករសមិទ្ធកម្ម D-1**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| D-1 | **ការប៉ាន់ប្រមាណ Budget Support** | C | D | ការផ្តល់ពិន្ទុតាមវិធីសាស្ត្រ M1 |
| (១) | គម្លាតការអនុវត្ត Budget Support ប្រចាំឆ្នាំពីការព្យាករណ៍ដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ដោយយ៉ាងហោចណាស់ ៦សប្តាហ៍មុនពេលរដ្ឋាភិបាល | C | D | ការផ្តល់ Budget Support ជាក់ស្តែង មានតិចជាងផែនការ គឺលើសពី ១៥%ក្នុងរយៈពេល២ឆ្នាំ នៃ៣ឆ្នាំសារពើពន្ធចុងក្រោយ (២០១២-២០១៤) គឺមាន ៦៧%និង៦៤%នៃឆ្នាំនីមួយៗ។ |

[40] Budget Support ពីសហភាពអឺរ៉ុបត្រូវចាត់ចំណាត់ថ្នាក់ក្នុងឃ្លាំងទិន្នន័យដោយ CDC រីឯថវិកាគាំទ្រពី ADB រួមជាមួយដំណើរការជំនួយកូនកាត់ដោយបញ្ចូលកម្ចីវិនិយោគ, ជំនួយបច្ចេកទេស និងការគាំទ្រថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ។ ទិន្នន័យ ADB លើការធានាចំណាយ Budget Support និងការផ្តល់ថវិកាត្រូវបានបន្ថែមលើទិន្នន័យ Budget Support ផ្លូវការពីឃ្លាំងទិន្នន័យ ODA ដោយការធានាចំណាយរបស់ ADB ឆ្លុះបញ្ចាំងការព្យាករណ៍ ពីព្រោះជាផ្នែកមួយនៃកិច្ចដំណើរការ Budget Support របស់ ADB។ បើទោះបីជា ការបន្ថែមទិន្នន័យរបស់ ADB មិនបានធ្វើឱ្យពិន្ទុខុសគ្នាក៏ដោយ ដែលក្នុងករណីនេះគឺទទួលពិន្ទុ "D"។

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| | បញ្ជូនសំណើថវិការបស់ខ្លួនទៅស្ថាប័ននីតិប្បញ្ញត្តិ | | | |
| (២) | ភាពទាន់ពេលវេលានៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (អនុលោមភាពជាមួយការប៉ាន់ស្មានប្រចាំត្រីមាសសរុប) | NU | D | មិនបានផ្តល់ការព្យាករណ៍ហិរញ្ញប្បទានប្រចាំត្រីមាស |

**ប្រអប់ គ.២៨÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

មិនមានរបាយការណ៍

## គ.៧.២ ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី (D-2)

សូចនាករនេះវាយតម្លៃលើព័ត៌មានដែលបានផ្តល់ឱ្យដោយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធការគាំទ្រសម្រាប់កម្មវិធីនិងគម្រោង (រួមបញ្ចូលទាំងជំនួយជាសម្ភារៈ) ដែលអនុលោមតាមបទប្បញ្ញត្តិផ្សេងៗ ដែលធានាសុក្រឹតភាពនិងភាពទាន់ពេលវេលានៃការព្យាករណ៍ហិរញ្ញប្បទាន ដើម្បីដាក់បញ្ចូលក្នុងសំណើថវិកា និងការរៀបចំរបាយការណ៍។ ការវាយតម្លៃនេះ គឺផ្អែកលើគុណភាពទិន្នន័យរបស់ដៃគូអភិវឌ្ឍន៍ធំៗទាំង៥ ដែលគាំទ្រគម្រោង និងផ្តោតលើឆ្នាំសារពើពន្ធបញ្ចប់ចុងក្រោយ។

### (១) ភាពពេញលេញ និងភាពទាន់ពេលវេលានៃការប៉ាន់ប្រមាណថវិការបស់ម្ចាស់ជំនួយសម្រាប់ការគាំទ្រគម្រោង

ជាទូទៅ គ្រប់ដៃគូអភិវឌ្ឍន៍ (រួមបញ្ចូលទាំងដៃគូអភិវឌ្ឍន៍ធំៗ) ផ្តល់ការព្យាករណ៍ថវិកាប្រចាំឆ្នាំតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ការរៀបចំរបាយការណ៍ចាប់ផ្តើមនៅខែមីនា-មេសា នៃឆ្នាំនីមួយៗ ជាមួយនឹងការព្យាករណ៍ថវិកាសម្រាប់២ឆ្នាំបន្ទាប់។ ក្នុងន័យនេះ ទិន្នន័យប្រមូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែមីនា-មេសា ឆ្នាំ២០១៤ មានបញ្ចូលការព្យាករណ៍សម្រាប់ឆ្នាំ២០១៤ និងឆ្នាំ២០១៥ (យោងរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ចេញផ្សាយនៅខែកក្កដា ឆ្នាំ២០១៤)។ ទិន្នន័យនេះត្រូវបានញែកចេញជាឈ្មោះគម្រោង និងប្រភេទនៃហិរញ្ញប្បទាន (៦ប្រភេទ) ប៉ុន្តែមិនបានរៀបចំចែកថ្នាក់តាមចំណាត់ថ្នាក់ថវិការបស់រាជរដ្ឋាភិបាលនោះទេ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ C ពីព្រោះតាមការអនុវត្ត គ្រប់ដៃគូអភិវឌ្ឍន៍ផ្តល់ការព្យាករណ៍អំពីការផ្តល់ថវិកាប្រចាំឆ្នាំ បានមុនការរៀបចំថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ព័ត៌មានស្តីពីហិរញ្ញប្បទានដែលមិនត្រូវបានរាយការណ៍ដោយប្រទេសចិន និងសហរដ្ឋអាមេរិក ភាគច្រើនគឺពាក់ព័ន្ធនឹងជំនួយជាសម្ភារៈ ប៉ុន្តែ ការខកខាន

នេះ មិនមានឥទ្ធិពលធំដុំនាំឱ្យធ្លាក់ពិន្ទុទេ។ ដើម្បីបានពិន្ទុខ្ពស់ជាងនេះ ព័ត៌មានពាក់ព័ន្ធទាំងឡាយ ត្រូវរៀបចំតាមប្រព័ន្ធនៃមាតិកាថវិការបស់រាជរដ្ឋាភិបាល។

**(២) អត្រានៃការកើតឡើង និងវិសាលភាពនៃការរាយការណ៍ដោយម្ចាស់ជំនួយ អំពីលំហូរជំនួយជាក់ស្តែងសម្រាប់ការគាំទ្រគម្រោង**

ដៃគូអភិវឌ្ឍន៍ផ្តល់ទិន្នន័យប្រចាំឆ្នាំអំពីការផ្តល់ថវិកាជាក់ស្តែង និងក្នុងអំឡុងពេល ៣-៤ ខែ មុនដំណាច់ឆ្នាំ។ ដៃគូអភិវឌ្ឍន៍ជាច្រើន ផ្តល់ទិន្នន័យរៀងរាល់ ០៦ខែម្តង ស្របតាមនីតិវិធីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ។ ផ្ទុយទៅវិញ របាយការណ៍ប្រចាំត្រីមាសមិនត្រូវបានរៀបចំទេ។ ទិន្នន័យទាំងនេះ ត្រូវបានលម្អិតត្រឹមតែតាមឈ្មោះគម្រោង និងប្រភេទនៃហិរញ្ញប្បទាន (៦ប្រភេទ) ប៉ុន្តែមិនត្រូវបានរៀបចំតាមមាតិកាថវិការបស់រាជរដ្ឋាភិបាលឡើយ។

សមាសធាតុនេះត្រូវបានផ្តល់ពិន្ទុ D ដោយហេតុថាមានដៃគូអភិវឌ្ឍន៍តែមួយចំនួនតូចប៉ុណ្ណោះ ដែលផ្តល់ទិន្នន័យជាប្រចាំត្រីមាសអំពីការផ្តល់ថវិកាជាក់ស្តែង។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ភាគច្រើននៃការផ្តល់ថវិកាសម្រាប់ការផ្តល់ហិរញ្ញប្បទានគម្រោងខាងក្រៅ ត្រូវតែរាយការណ៍ជាប្រចាំត្រីមាស។

**តារាង គ.៤៨÷ ពិន្ទុសូចនាករសមិទ្ធកម្ម D-2**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី | D | D+ | ការផ្តល់ពិន្ទុតាមវិធីសាស្ត្រ M1 |
| (១) | ភាពពេញលេញ និងភាពទាន់ពេលវេលានៃការប៉ាន់ប្រមាណថវិការបស់ម្ចាស់ជំនួយសម្រាប់ការគាំទ្រគម្រោង | D | C | គ្រប់ដៃគូអភិវឌ្ឍន៍ផ្តល់ការព្យាករណ៍អំពីការផ្តល់ថវិកាប្រចាំឆ្នាំ បានមុនការរៀបចំថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល តែព័ត៌មានពាក់ព័ន្ធទាំងឡាយ ត្រូវរៀបចំតាមប្រព័ន្ធនៃមាតិកាថវិការបស់រាជរដ្ឋាភិបាល។ |
| (២) | អត្រានៃការកើតឡើង និងវិសាលភាពនៃការរាយការណ៍ដោយម្ចាស់ជំនួយ អំពីលំហូរជំនួយជាក់ស្តែងសម្រាប់ការគាំទ្រគម្រោង | D | D | គ្រប់ដៃគូអភិវឌ្ឍន៍ បានផ្តល់ទិន្នន័យជាប្រចាំឆ្នាំអំពីការផ្តល់ថវិកាជាក់ស្តែង តែមិនមានរបាយការណ៍ជាប្រចាំត្រីមាសទេ រីឯព័ត៌មានមិនត្រូវបានផ្តល់តាមទម្រង់នៃប្រព័ន្ធមាតិកាថវិការបស់រដ្ឋាភិបាលទេ។ |

**ប្រអប់ គ.២៨÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

មិនមានរបាយការណ៍។

## គ.៧.៣ ទំហំហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ (D-3)

សូចនាករសមិទ្ធកម្មនេះ វាយតម្លៃលើទំហំហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ ដូចជាកិច្ចលទ្ធកម្ម, គណនេយ្យ/ការទូទាត់, សវនកម្ម និងការរៀបចំរបាយការណ៍លើការផ្តល់ថវិកា។ ការគាំទ្រថវិកាដោយផ្ទាល់ (Budget Support) ប្រើប្រាស់តាមនីតិវិធីជាតិ។ ការវាយតម្លៃនេះ គឺផ្តោតលើឆ្នាំសារពើពន្ធបញ្ចប់ចុងក្រោយ។

នីតិវិធីជាតិដែលត្រូវបានប្រើប្រាស់ដោយដៃគូអភិវឌ្ឍន៍ ផ្តល់ការលើកទឹកចិត្តនិងជួយរដ្ឋាភិបាល ក្នុងការកែលម្អនីតិវិធីជាតិជាធរមាន។ សូចនាករនេះ វាយតម្លៃលើទំហំនៃហិរញ្ញប្បទានទាំងអស់ដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ លើការងារដែលរួមមានចំនួន ០៤ គឺ ១-កិច្ចលទ្ធកម្ម, ២-គណនេយ្យ/ការទូទាត់, ៣-សវនកម្ម និង ៤-ការរៀបចំរបាយការណ៍លើការផ្តល់ថវិកា។

ជាធម្មតា ដៃគូអភិវឌ្ឍន៍មិនផ្តល់ហិរញ្ញប្បទានតាមរយៈប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលឡើយ។ ទន្ទឹមនេះ ការផ្តល់ Budget Support ដែលតាមនិយមន័យជាហិរញ្ញប្បទានដែលប្រើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនោះ ត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។ ក៏ប៉ុន្តែ ទន្ទឹមនេះ ដៃគូអភិវឌ្ឍន៍មួយចំនួន ជ្រើសរើស

យកនូវការអនុវត្តដោយអន្លើនូវនីតិវិធីជាតិ សម្រាប់ដំណាក់កាលណាមួយនៃវដ្តថវិកា។ ជាក់ស្តែង ទិន្នន័យពីអគ្គ-នាយកដ្ឋានថវិកា បង្ហាញថាមានការប្រើប្រាស់ប្រព័ន្ធ/នីតិវិធីជាតិ សម្រាប់ទិដ្ឋភាព/ដំណាក់កាលនៃការអនុវត្តថវិកាដូចមានក្នុងតារាង គ.៤៨ ខាងក្រោម។ ព័ត៌មាននេះ បង្ហាញថា ហិរញ្ញប្បទានតិចជាង ៣០% នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០១៤ ត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ ជាមួយនឹងមធ្យមភាគសរុបមានប្រមាណ ២៥% ដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ ដោយយោងតាមទំហំសរុបនៃការផ្តល់ថវិកាដោយដៃគូពហុភាគី។

**តារាង គ.៤៩ ÷ ការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍ (ពហុភាគី) ឆ្នាំ២០១៤**

| %នៃហិរញ្ញប្បទានរបស់គ្រប់ដៃគូដែលប្រើ÷ | ឆ្នាំសារពើពន្ធ ២០១៤ |
|---|---|
| នីតិវិធីលទ្ធកម្មរបស់ជាតិ | ២០% |
| នីតិវិធីគណនេយ្យ/ការទូទាត់របស់ជាតិ | ២៨% |
| នីតិវិធីសវនកម្មរបស់ជាតិ | ២៧% |
| នីតិវិធីនៃការរៀបចំរបាយការណ៍របស់ជាតិ | ២៦% |

ប្រភព÷ អគ្គនាយកដ្ឋានថវិកា

ទិន្នន័យបង្ហាញពីការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍន៍ទាំងអស់ អាចស្វែងរកបាននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ឆ្នាំ២០១៣[41] ដោយយោងតាម "លទ្ធផលអង្កេតតាមដានប៉ូសាន" ដែលបង្ហាញថាជាមធ្យមមានប្រមាណ ៣២% ដែលបានប្រើប្រាស់ប្រព័ន្ធលទ្ធកម្ម និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ពោលគឺខ្ពស់ជាងការប៉ាន់ស្មាន សម្រាប់ដៃគូពហុភាគី ដូចមានក្នុងតារាង គ.៤៩។ ម្យ៉ាងទៀត ការប៉ាន់ប្រមាណជាមធ្យមសម្រាប់ការអនុវត្តតាមនីតិវិធីជាតិក្នុងឆ្នាំ២០១៤ មានប្រមាណ ២៤,៧%[42] ផ្អែកលើប្រព័ន្ធទិន្នន័យ ODA។

សមាសធាតុនេះទទួលបានពិន្ទុ D ដោយហេតុថា ការប្រើប្រាស់ប្រព័ន្ធជាតិទាំងមូល សម្រាប់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ មានក្រោម៥០%។

**តារាង គ.៥០÷ ពិន្ទុសូចនាករសមិទ្ធកម្ម D-3**

| សូចនាករ | សមាសធាតុ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ |
|---|---|---|---|---|
| D-3 | **ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ** | D | D | ការប្រើប្រាស់ប្រព័ន្ធជាតិ ស្ថិតក្នុងចន្លោះពី ២៣%-៣០ %ពោលគឺទាបជាង ៥០%ដែលជាភាគរយចាំបាច់ សម្រាប់ទទួលបានពិន្ទុC។ |

[41] CDC Development Cooperation Trends in Cambodia July 2014 Table 5.

[42] Estimate dated 26th December 2014 and based on extract from the ODA Database.

**ប្រអប់ គ.៣០÷ ការងារកែទម្រង់ដែលកំពុងត្រូវបានអនុវត្ត**

សមិទ្ធកម្មក្នុងស្ទូចនាករនេះ អាចនឹងកែលម្អបានច្រើននៅក្នុងឆ្នាំខាងមុខ ដោយហេតុថាដៃគូអភិវឌ្ឍន៍ អាចបង្ហាញទំនោរក្នុងការប្រើប្រាស់ប្រព័ន្ធ/នីតិវិធីជាតិសម្រាប់ការទូទាត់, គណនេយ្យ និងការរៀបចំរបាយការណ៍ នៅពេលដែលប្រព័ន្ធ FMIS ត្រូវបានរៀបចំរួចរាល់, ដាក់ឱ្យអនុវត្តទាន់ពេលវេលា និងប្រកបដោយគុណភាព។ បច្ចុប្បន្ន ប្រព័ន្ធ FMIS បាននិងកំពុងរៀបចំនិងដាក់ឱ្យដំណើរការ។ ទន្ទឹមនេះ ជំនួយបច្ចេកទេសសម្រាប់ការរៀបចំបទដ្ឋាននិងប្រព័ន្ធកិច្ចលទ្ធកម្ម និងសវនកម្ម អាចទាក់ទាញដៃគូអភិវឌ្ឍន៍ជឿទុកចិត្តនិងងាកមកអនុវត្តតាមនីតិវិធីជាតិ ក៏ប៉ុន្តែនេះជាទស្សនវិស័យរយៈពេលវែង។

# ឃ. បម្រែបម្រួលសមិទ្ធកម្ម ចាប់ពីឆ្នាំ២០១០

## ឃ.១ ទិដ្ឋភាពរួមនៃលទ្ធផលវាយតម្លៃឆ្នាំ២០១០

សេចក្តីសង្ខេបអំពីលទ្ធផលវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឆ្នាំ២០១០ នឹងត្រូវបង្ហាញជាបន្តបន្ទាប់នៅខាងក្រោម ដោយផ្អែកលើសមាសធាតុនៃសូចនាករសមិទ្ធកម្មដែលបានអនុវត្ត និងកំពុងបន្តអនុវត្តនៅក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ ការផ្តល់ពិន្ទុសម្រាប់សូចនាករ និងសមាសធាតុរបស់សូចនាករនីមួយៗ ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី១។

**ភាពជឿទុកចិត្តនៃថវិកា** ត្រូវបានពង្រឹងតាមរយៈភាពអាចប៉ាន់ប្រមាណបាននៃចំណូល (PI-3 បានពិន្ទុ A) ដោយហេតុថា វិធីសាស្ត្រ ឬមធ្យោបាយព្យាករណ៍ចំណូលត្រូវបានអនុវត្តប្រកបដោយភាពប្រាកដនិយម និងចំណាយត្រូវបានគ្រប់គ្រងល្អប្រសើរ (សូចនាករចំណាយសរុប PI-1 ទទួលបានពិន្ទុ B) ដែលកត្តាទាំងនេះនាំឱ្យការលុបបំបាត់បំណុលកកស្ទះ អាចប្រព្រឹត្តទៅបានប្រកបដោយស័ក្តិសិទ្ធភាព (PI-4 សមាសធាតុ ១, ពិន្ទុ A)។ ការលុបបំបាត់បំណុលកកស្ទះ បានធ្វើឱ្យការទូទាត់ចំណាយដល់អ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្ម កាន់តែរលូន និងមានភាពជឿជាក់ ស្របពេលដែលការព្យាករណ៍ថវិការបស់អង្គភាពថវិកាកាន់តែមានសុក្រឹតភាព។ យោងតាមសមាសធាតុនៃចំណាយថវិកា (PI-2), សមត្ថភាពព្យាករណ៍របស់អង្គភាពថវិកានីមួយៗនៅមានកម្រិត ជាក់ស្តែងគម្លាតរវាងការព្យាករណ៍ និងការអនុវត្ត នៃសមាសធាតុចំណាយ មានប្រមាណលើសពី ១០% នៅអំឡុង ០២ ឬ ០៣ឆ្នាំ ចុងក្រោយនេះ ដែលមួយផ្នែកនេះនៃគម្លាតនេះ កើតចេញពីការវិភាជថវិកាឡើងវិញ ពីជំពូកមិនទាន់បែងចែក ឬបម្រុង។ ទោះជាយ៉ាងនេះ ក៏ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានល្អ នៅក្នុងវិស័យអាទិភាព ដូចជា វិស័យអប់រំ និងវិស័យសុខាភិបាល។

**តម្លាភាពនិងភាពគ្រប់ជ្រុងជ្រោយនៃថវិកា** ទទួលបានពិន្ទុ C ក្នុងសូចនាករ PI-17 ដែលបង្ហាញពីទំហំនៃប្រតិបត្តិការថវិកាមិនបានរាយការណ៍។ កត្តាចម្បងដែលនាំឱ្យមានបញ្ហានេះកើតឡើង គឺអាចកើតចេញពីចំណូលមិនមែនសារពើពន្ធមិនត្រូវបានប្រកាស និងការបើកគណនីធនាគារដោយឡែកដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។ ដោយឡែកសម្រាប់តម្លាភាពថវិកា នៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងគម្រោងហិរញ្ញប្បទានឥតសំណង (ពិន្ទុ D នៅក្នុង D2-D3) ក៏អាចជាកត្តានាំឱ្យភាពទុកចិត្តនៃថវិកាធ្លាក់ចុះផងដែរ ព្រោះ (១) ការលើកទឹកចិត្តបុគ្គលិកក្នុងក្រសួង-ស្ថាប័នដែលមានអង្គភាពអនុវត្តគម្រោង (PIUs) នាំឱ្យមានការយល់ឃើញថា ថវិការដ្ឋមិនអាចក្លាយជាធនធានចម្បងសម្រាប់ទ្រទ្រង់ការផ្តល់សេវាសាធារណៈ; (២) បុគ្គលិក ឬមន្ត្រីមានសម្ថភាពត្រូវបានជំរុញឱ្យចូលបម្រើការងារក្នុងអង្គភាពអនុវត្តគម្រោង (PIUs) ដោយហេតុថាប្រព័ន្ធលើកទឹកចិត្តមានភាពប្រសើរជាងក្នុងមុខងារសាធារណៈ ដូច្នេះហើយទើបសមត្ថភាពនៃការរៀបចំថវិកាឱ្យមានភាពជឿទុកចិត្តត្រូវបានកាត់បន្ថយ; និង (៣) ភាពមិនច្បាស់លាស់នៃការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ នាំឱ្យប៉ះពាល់ដល់ចំណាយចរន្តសម្រាប់គម្រោង។

PI-10 បានពិន្ទុ C ដែលបង្ហាញថា សាធារណជនមិនទាន់មានព័ត៌មានគ្រប់គ្រាន់អំពីផែនការ និងការអនុវត្តថវិកា។ គណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈនឹងត្រូវបានលើកកម្ពស់ នៅពេលដែលសាធារណជនមានព័ត៌មានថវិកាទាំងនោះ។

ក្នុងផ្នែក **ថវិកាផ្សារភ្ជាប់គោលនយោបាយ,** នីតិវិធីរៀបចំថវិកាមានភាពច្បាស់លាស់ និងប្រសើរ (PI-11) តាមរយៈការចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) ជាមួយនឹងការយកចិត្តទុកដាក់លើចំណាយរយៈពេលមធ្យម និងយុទ្ធសាស្ត្រចំណាយតាមវិស័យ (PI-12) ដូចជាវិស័យអប់រំ និងវិស័យសុខាភិបាល ដែលអាចជាកត្តាជំរុញឱ្យថវិកាឆ្ពោះទៅរកភាពជឿទុកចិត្តផងដែរ។ ក្របខ័ណ្ឌយន្តការទាំងនេះ បានអនុញ្ញាតឱ្យបន្តផ្តល់វិភាជថវិកាសម្រាប់ទ្រទ្រង់ការផ្តល់សេវាសាធារណៈក្នុងកម្រិតបច្ចុប្បន្ន ព្រមទាំងអនុញ្ញាតឱ្យវិភាជថវិកាបន្ថែម ទៅដល់សេវាសាធារណៈអាទិភាពដទៃទៀតរបស់រដ្ឋាភិបាល (ដែលអាចកែប្រែនៅក្នុងវដ្តថវិកាបន្ទាប់)។ ចំណុចខ្សោយចម្បង គឺនៅត្រង់ភាពមិនគ្រប់គ្រាន់ នៃការធ្វើសមាហរណកម្មថវិកាមូលធនជាមួយនឹងថវិកាចរន្ត ដែលនាំឱ្យ PI-12 (១ និង ៤) បានពិន្ទុ C។ ក្នុងន័យនេះ នៅពេលដែលភាពប្រទាក់ក្រឡាគ្នារវាងថវិកាចរន្ត និងថវិកាមូលធនត្រូវបានរៀបចំឡើង សម្រាប់ឆ្នាំបន្ទាប់ និងសម្រាប់រយៈពេលមធ្យម ភាពជឿទុកនៃថវិកានឹងកាន់តែមានភាពរឹងមាំ មានន័យថា ភាពគ្រប់គ្រាន់ នៃធនធានហិរញ្ញវត្ថុ ដែលត្រូវបានបែងចែកសម្រាប់ទ្រទ្រង់ការផ្តល់សេវាសាធារណៈ ត្រូវបានបង្កើននៅក្នុងរយៈពេលមធ្យម (ឧទាហរណ៍ ការសាងសង់សាលារៀនមានសង្គតិភាពជាមួយនឹងចំនួនសិស្ស និងចំណាយប្រតិបត្តិត្រូវបានគ្រោងសមស្រប)។ ការខកខានមិនបានផ្តល់ថវិកាគ្រប់គ្រាន់ នឹងនាំឱ្យភាពជឿទុកចិត្តនៃថវិកាធ្លាក់ចុះ។

**ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា:** ផ្នែករដ្ឋបាលចំណូល ទោះបីនៅតែត្រូវការអភិវឌ្ឍន៍បន្ថែម (PI-13 ដល់ 15 បានពិន្ទុ C) បានរួមចំណែកធ្វើឱ្យថវិកាកាន់តែមានភាពជឿទុកចិត្តបានតាមរយៈតម្លាភាពកាន់តែប្រសើរ នៃកាតព្វកិច្ច និងបំណុលអ្នកជាប់ពន្ធ, ការបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីសារពើពន្ធ និងការវាយតម្លៃពន្ធ (ឧទាហរណ៍ ការចាប់ផ្តើមរៀបចំ និងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការងារសវនកម្ម) និងការពន្លឿនការផ្ទេរប្រាក់ចូលទៅក្នុងគណនីទោលរតនាគារ។ ក្នុងន័យនេះ កិច្ចប្រឈមចម្បងមាន (១) បញ្ហាអនុលោមភាព នៃការចុះបញ្ជីសារពើពន្ធ ការប្រកាស និងការប្រមូលពន្ធ និង (២) បញ្ហានៃការគ្រប់គ្រងផ្ទៃក្នុង។ ទន្ទឹមនេះ ការមិនបានប្រតិបត្តិតាមច្បាប់ពន្ធដារ និងកាតព្វកិច្ចពន្ធ (ឧទាហរណ៍ ការគេចវេសពន្ធ) ធ្វើឱ្យចំណូលសម្រាប់គាំទ្រដល់ការផ្តល់ថវិកាទៅឱ្យអង្គភាពសេវាសាធារណៈត្រូវបានថយចុះ។ ជាក់ស្តែង ប្រសិនបើគ្មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់គាំទ្រដល់សេវាសាធារណៈទេ កត្តានេះអាចនឹងបណ្តាលឱ្យភាពជឿទុកចិត្តនៃថវិកាជួបប្រទះនូវបញ្ហាប្រឈម។

ដោយឡែក សម្រាប់ផ្នែកចំណាយ ប្រសិទ្ធភាពនៃការគ្រប់គ្រងត្រូវមានភាពរឹងមាំ ដើម្បីកាត់បន្ថយការខាតបង់ក្នុងការបើកប្រាក់បៀវត្ស និងក្នុងចំណាយមិនមែនបៀវត្ស (PI-18 ដល់ 21 ពិន្ទុចន្លោះពី C ទៅ D)។ នៅពេលការទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណាយសាធារណៈត្រូវបានធ្វើប្រតិភូកម្មទៅដល់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន និងគ្រប់អង្គភាពសាធារណៈនោះ តួនាទីសវនកម្មផ្ទៃក្នុងនឹងកាន់តែមានសារៈសំខាន់ក្នុងការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ។ ទន្ទឹមនេះ ទំហំធំនៃចំណាយ

មិនបានគ្រោងទុកក្នុងថវិកាជាតិ (លើសពី ១០% នៃចំណាយសរុប) និងការវិភាជថវិកាក្នុងឆ្នាំក៏បានបង្ហាញពីកង្វះខាតតម្លាភាព (និងភាពមិនអាចប៉ាន់ប្រមាណបាន) ក្នុងថវិកាជាតិ (មានក្នុង PI-16, សមាសធាតុ ៣)។

ប៉ុន្តែភាពអាចប៉ាន់ប្រមាណបាននៃសាច់ប្រាក់ក្នុងឆ្នាំ (PI-16) បានចូលរួមចំណែកធានានូវភាពជឿទុកចិត្តនៃថវិកាផងដែរ តាមរយៈក្របខ័ណ្ឌគ្រប់គ្រងលំហូរសាច់ប្រាក់ប្រចាំត្រីមាស, ស្របពេលដែលប្រសិទ្ធភាពនៃការបង់ប្រាក់ចូលគណនីទោលរតនាគារត្រូវបានបង្កើននិងពង្រីកបន្តិចម្តងៗជាមួយនឹងការបិទគណនីធនាគារដែលបានបើកដោយគ្មានការអនុញ្ញាត (នាំឱ្យធនធានហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំសម្រាប់គាំទ្រដល់ការអនុវត្តថវិកា, PI-17)។

**គណនេយ្យ ការកត់ត្រា និងរបាយការណ៍,** ជាទូទៅសូចនាករ PI-22 ដល់ PI-25 បានពិន្ទុ C និង D ព្រោះក្នុងដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាដំណាក់កាលដែលផ្តោតលើការពង្រឹងភាពអាចប៉ាន់ប្រមាណបាននៃធនធានដែលមាន សម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈ។ ការសម្រេចបាននូវគណនេយ្យភាពហិរញ្ញវត្ថុ (ដែលទទួលបានពិន្ទុខ្ពស់ជាងនេះ) គឺជាគោលដៅចម្បងរបស់ដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ និងនាំមកនូវភាពជឿទុកចិត្តនៃថវិកាផងដែរ ព្រោះសាធារណជនអាចឃើញកាន់តែច្បាស់ ថាតើធនធានហិរញ្ញវត្ថុត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពសម្រាប់គោលបំណងដែលចង់បាន ឬយ៉ាងណានោះ។

**ការត្រួតពិនិត្យនិងសវនកម្មផ្ទៃក្រៅ,** សូចនាករ PI-26 បានពិន្ទុទាប (ពិន្ទុ D+) ដែលបង្ហាញថាសវនកម្មផ្ទៃក្រៅមិនទាន់បានដើរតួនាទីពេញលេញ ក្នុងការពង្រឹងគណនេយ្យភាពនៃអង្គនីតិប្រតិបត្តិនៅឡើយ។ អាជ្ញាធរសវនកម្មជាតិមិនបានផ្សព្វផ្សាយរបាយការណ៍របស់ខ្លួនឱ្យបានទាន់ពេលវេលា ឬតាមកាលបរិច្ឆេទកំណត់នោះទេ ដូច្នេះសាធារណជនមិនអាចមានមធ្យោបាយដឹងថា ហិរញ្ញវត្ថុសាធារណៈត្រូវបានប្រើប្រាស់ទៅតាមគោលដៅដែលបានកំណត់ទុកនោះឡើយ។ ក្រុមការងារវាយតម្លៃ ពុំបានជួបជាមួយគណៈកម្មការទី២ នៃរដ្ឋសភានោះទេ ប៉ុន្តែតួនាទីរបស់គណៈកម្មការនេះ ក្នុងការទាមទារឱ្យអង្គនីតិប្រតិបត្តិមានគណនេយ្យភាពហិរញ្ញវត្ថុ ក៏ហាក់នៅមានកម្រិតដែរ។

**ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍,** ដូចដែលបានបង្ហាញក្នុងសូចនាករ D-2 និង D-3 ត្រូវពិភាក្សាក្នុងតម្លាភាព និងភាពគ្រប់ជ្រុងជ្រោយនៃថវិកាខាងលើ។ សូចនាករ D-1 (ភាពអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាផ្ទាល់) បានពិន្ទុ C ក៏ប៉ុន្តែផលប៉ះពាល់លើភាពជឿទុកចិត្តនៃថវិកាក៏មានកម្រិតទាបដែរ ដោយហេតុថា ការគាំទ្រថវិកាផ្ទាល់របស់ដៃគូអភិវឌ្ឍន៍ មានទំហំតូចបើធៀបនឹងធនធានហិរញ្ញវត្ថុដទៃទៀត។

## ឃ.២ ទិដ្ឋភាពរួមនៃលទ្ធផលវាយតម្លៃឆ្នាំ២០១៥

**ភាពជឿទុកចិត្តនៃថវិកា** (PI-1 ដល់ PI-4) នៅតែអាចធានាបាន តាមរយៈការពង្រឹងនូវក្របខ័ណ្ឌប្រមូលចំណូលក្នុងស្រុក និងចំណាយដែលប្រើប្រាស់ថវិកាជាតិ (PI-1 និង PI-3)។ ជាក់ស្តែង ការអនុវត្តនេះបានល្អប្រសើររួចទៅហើយក្នុងឆ្នាំ២០១០ ប៉ុន្តែត្រូវបានធ្វើឱ្យប្រសើរឡើងបន្ថែមទៀត។ លទ្ធផលទាំងនេះ មិនត្រូវបានប៉ះពាល់ដោយភាពមិនអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាដោយហិរញ្ញប្បទានពីខាងក្រៅនោះទេ ព្រោះហិរញ្ញប្បទានពីខាងក្រៅរួមចំណែកតូចប៉ុណ្ណោះក្នុងចំណាយសាធារណៈ (សូចនាករ D-1)។ ដោយឡែក ភាពជឿទុកចិត្តនៃថវិកា នៅតែជួបប្រទះ

កិច្ចប្រឈមពាក់ព័ន្ធនឹងយុទ្ធសាស្ត្រវិភាជន៍ថវិកា ទៅឱ្យអង្គភាពថវិកា ថ្វីបើចំណុចខ្វះខាតនេះធ្លាប់បានបង្ហាញរួចមកហើយក្នុងឆ្នាំ២០១០ (PI-12)។ ទន្ទឹមនេះ ការកំណត់កាលបរិច្ឆេទនៃការសងបំណុលមានរយៈពេលវែង ប្រព័ន្ធត្រួតពិនិត្យបំណុលក៏មិនទាន់គ្រប់គ្រាន់ ឬគ្រប់ជ្រុងជ្រោយនៅឡើយ ហើយភាពប្រសើរឡើងនានានៃការសងបំណុល ក៏មិនត្រូវបានរាយការណ៍ដែរ។

**តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយនៃថវិកា** (PI-5 ដល់ PI-10) ជារួមផ្នែកនេះទទួលបានពិន្ទុចន្លោះពី C ទៅ D លើកលែងការវាយតម្លៃដែលមានវិសាលភាពគ្របដណ្តប់លើទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ-សង្កាត់) ដែលទទួលបានពិន្ទុខ្ពស់ជាងនេះ។ ភាពគ្រប់ជ្រុងជ្រោយនៃថវិកានៅតែមិនអាចពង្រឹងបានពេញលេញ ដោយសារតែសមាសធាតុសំខាន់ៗនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ចំណូល-ចំណាយនោះទេ ជាពិសេសប្រតិបត្តិការហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងគម្រោងដោយហិរញ្ញប្បទានខាងក្រៅ (PI-7)។ នាពេលបច្ចុប្បន្នប្រព័ន្ធចំណាត់ថ្នាក់ថវិកា និងប្លង់គណនី មានតែការចាត់ថ្នាក់ជាមូលដ្ឋានប៉ុណ្ណោះ ពោលគឺកំណត់តែចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់រដ្ឋបាលប៉ុណ្ណោះ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបន្ថែមក្នុងការដាក់ឱ្យអនុវត្តពេញលេញនូវចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់មុខងារ (PI-5) ព្រោះចំណាត់ថ្នាក់ថវិកាថ្មីនៅមិនទាន់បានរៀបចំពេញលេញ និងដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពសាធារណៈនៅឡើយ។

ដោយឡែក ពិន្ទុនៃតម្លាភាពថវិកា បានធ្លាក់ចុះ។ ក្នុងន័យនេះ ព័ត៌មានថវិកាដែលបានដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ថវិកា និងបានបញ្ជូនទៅអង្គនីតិបញ្ញត្តិ (ត្រូវបានផ្សព្វផ្សាយបន្ទាប់ពីអង្គនីតិបញ្ញត្តិបានពិនិត្យ និងអនុម័ត) ត្រូវបានកាត់បន្ថយ (PI-16, បានពិន្ទុ B ឆ្នាំ២០១០ ទៅ C ឆ្នាំ២០១៥) ហើយលទ្ធភាពសាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ ក៏បានធ្លាក់ចុះ ដោយសារការពន្យារពេល ផ្សព្វផ្សាយ ទោះបីជារបាយការណ៍ផ្ទៃក្នុងត្រូវបានរៀបចំបានទាន់ពេលវេលាក៏ដោយ (PI-10, បានពិន្ទុ C ឆ្នាំ២០១០ ទៅ D ឆ្នាំ២០១៥), យោង PI-24 សមាសធាតុ ២, PI-25 សមាសធាតុ ២, និង PI-26 សមាសធាតុ ២ ដែលនឹងបង្ហាញជាបន្តបន្ទាប់ខាងក្រោម។

តម្លាភាព និងការព្យាករណ៍ទុកជាមុន សម្រាប់ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលឃុំ-សង្កាត់ នៅតែស្ថិតនៅកម្រិតមួយល្អប្រសើរ ព្រោះការផ្ទេរថវិកាទៅឃុំ-សង្កាត់ ត្រូវបានអនុវត្តផ្អែកលើវិធានច្បាស់លាស់ ហើយឥណទានថវិកាប៉ាន់ប្រមាណ ត្រូវបានផ្តល់ទៅឱ្យឃុំ-សង្កាត់ ទាន់ពេលវេលា និងអាចជឿទុកចិត្តបាន (PI-8, ១ និង ២ ទទួលបានពិន្ទុ A)។ ទន្ទឹមនេះ ប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុ ធានាថា រដ្ឋបាលឃុំ-សង្កាត់ នឹងមិនអាចបង្កើតជាហានិភ័យថវិកាដល់រដ្ឋបាលថ្នាក់ជាតិទេ (PI-9, ២ បានពិន្ទុ A)។ ទោះជាយ៉ាងនេះក្តី ក៏ការវិភាជធនធាននៅមិនទាន់អាចផ្សារភ្ជាប់ទៅគោលដៅយុទ្ធសាស្ត្រនៅថ្នាក់ជាតិបាននៅឡើយ ដោយហេតុថា ចំណាត់ថ្នាក់ថវិកានៅមិនទាន់មានសង្គតិភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយចំណាត់ថ្នាក់ពេញលេញតាមមុខងារ និងវិស័យនៅមិនទាន់មានឡើយ (PI-8, ៣ បានពិន្ទុ D)។ ទន្ទឹមនេះ ការត្រួតពិនិត្យហានិភ័យថវិកាពីសហគ្រាសសាធារណៈនៅមានភាពខ្វះចន្លោះ (PI-8, ១ បានពិន្ទុ A ទាំងពីរឆ្នាំ) ដូចជាការមិនបានរៀបចំ និងរាយការណ៍ការវិភាគហានិភ័យហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ ដែលករណីនេះកាន់តែមិនល្អ ដោយសារកង្វះការកំណត់ពិដាននៃការធានារបស់រដ្ឋលើកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ (PI-17, ៣)។

**ថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ** (PI-11 និង 12) បានបង្ហាញនូវសមិទ្ធកម្មល្អប្រសើរ ក្នុងដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលមានភាពគ្រប់ជ្រុងជ្រោយ, បានរៀបចំនៅក្នុងច្រើនកម្រិត ដោយមានការចូលរួមពីភាគីពាក់ព័ន្ធសមស្រប ទាំងក្នុងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសនៃក្រសួង-ស្ថាប័ននីមួយៗ និងបានរៀបចំទាន់ការកំណត់ក្នុងច្បាប់។ សមិទ្ធកម្មល្អនេះត្រូវបានរក្សាតាំងពីឆ្នាំ២០១០ មកម្ល៉េះ (PI-11 បានពិន្ទុ A ទាំងពីរលើក)។ ទោះជាយ៉ាងនេះក៏ដោយ ការរៀបចំថវិការយៈពេលមធ្យមដែលផ្សារភ្ជាប់ទៅនឹងគោលនយោបាយ នៅកំពុងត្រូវបានកែលម្អជាបណ្តើរៗចាប់តាំងពីឆ្នាំ ២០១០ ប៉ុន្តែនៅពុំទាន់បានល្អប្រសើរដូចការរៀបចំថវិកាប្រចាំឆ្នាំនៅឡើយ ដែលកត្តានេះ ធ្វើឱ្យការគាំទ្រដល់គោលនយោបាយអាទិភាពពុំមានចីរភាពឡើយ នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ ការគណនាចំណាយលម្អិតសម្រាប់វិស័យនីមួយៗ នៅមិនទាន់បានរៀបចំពេញលេញ (PI-12, សមាសធាតុ ៣) ហើយការរៀបចំថវិកាចរន្តនិងមូលធន នៅតែស្ថិតនៅក្នុងនីតិវិធីពីរដាច់ដោយឡែកពីគ្នា ហើយមានទំនាក់ទំនងនឹងគ្នាតិចតួច (PI-12, សមាស-ធាតុ ៤ បានពិន្ទុ C ទាំងពីរលើក)។ ទោះបីជាក្របខ័ណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំ ប៉ុន្តែការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយពីឆ្នាំសារពើពន្ធមួយ ទៅឆ្នាំបន្ទាប់ នៅមានកង្វះចន្លោះ (PI-12, សមាសធាតុ ៣ បានពិន្ទុ C ទាំងពីរលើក)។ ក៏ប៉ុន្តែ ការវិភាគអំពីនិរន្តរភាពនៃបំណុល មានភាពល្អប្រសើរ និងច្បាស់លាស់ (PI-12 សមាសធាតុ ២ បានពិន្ទុ A ទាំងពីរលើក) ហើយរាជរដ្ឋាភិបាលបានពង្រឹងសមត្ថភាពផ្ទៃក្នុងបន្ថែម និងបានឈានទៅវិភាគហានិភ័យបំណុលជាប្រចាំឆ្នាំ។

**ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យក្នុងការអនុវត្តថវិកា** (PI-13 ដល់ PI-21), សូចនាករទាំង៩នេះទទួលបានពិន្ទុទាប ក្នុងចន្លោះ C និង D, ទោះបីជាទិដ្ឋភាពរួមភាគច្រើននៃសូចនាករបង្ហាញថាមានភាពប្រសើរឡើងក៏ដោយ (សមាសធាតុមួយចំនួនបានពិន្ទុ B)។ ផ្នែករដ្ឋបាលចំណូល មានការប្រែប្រួលតិចតួចតាំងពីឆ្នាំ២០១០ ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូល។ ទន្ទឹមនេះ ច្បាប់ស្តីពីសារពើពន្ធ ក៏នៅមានកង្វះខាតមួយចំនួន ដែលបានផ្តល់សិទ្ធិអំណាចលើសលុបដល់រដ្ឋបាលសារពើពន្ធ ហើយយន្តការតវ៉ាពន្ធឯករាជ្យនៅពុំទាន់ត្រូវបានរៀបចំនៅឡើយ។ ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកបង់ពន្ធអាចទទួលបានព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងការបង់ពន្ធ ប៉ុន្តែសមត្ថភាព និងបរិមាណធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ អាចធ្វើឱ្យព័ត៌មាននានាមិនមានភាពគ្រប់ជ្រុងជ្រោយ និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំនោះទេ (PI-13)។ ការអនុវត្តការចុះបញ្ជីពន្ធ និងការប្រកាសពន្ធនៅមានការលំបាក ដោយសារកង្វះវិធីសាស្ត្របុរេសកម្មក្នុងការរួមបញ្ចូលអាជីវកម្មទាំងអស់ទៅក្នុងបញ្ជីអ្នកជាប់ពន្ធ, ភាពមិនគ្រប់គ្រាន់នៃការអនុវត្តទោសទណ្ឌដល់អ្នកមិនគោរពតាមគោលការណ៍ច្បាប់ និងការធ្វើសវនកម្មពន្ធ នៅពុំទាន់បានអនុវត្តទៅតាមហានិភ័យពេញលេញនៅឡើយ (PI-14)។ ការប្រមូលចំណូលពន្ធអាចត្រូវបានពង្រឹងបន្ថែម។ បំណុលពន្ធនៅមានទំហំខ្ពស់ បើទោះជាមានភាពប្រសើរឡើងក្នុងការប្រមូល ហើយការតាមដាន និងការផ្ទៀងផ្ទាត់ការប្រមូលពន្ធនិងបំណុលពន្ធត្រូវបានអនុវត្តជាប្រចាំឆ្នាំប៉ុណ្ណោះ។ ទោះយ៉ាងណា ការប្រមូលចំណូលពន្ធ ត្រូវបានផ្ទេរទៅរតនាគារជាតិជាប្រចាំដោយមានការពន្យារពេលតិចតួច (PI-15)។

ការព្យាករណ៍សាច់ប្រាក់មានសមិទ្ធកម្មល្អ និងកាន់តែមានភាពល្អប្រសើរនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និងអង្គភាពថវិកា អាចមានលទ្ធភាពរៀបចំគម្រោងធានាចំណាយដោយខ្លួនឯង យ៉ាងហោច

ណាស់ប្រចាំត្រីមាស (PI-16 សមាសធាតុ ១ និង ២) ប៉ុន្តែនិយ័តភាពថវិកាក្នុងឆ្នាំ កើតមានឡើងជាញឹកញាប់ ក្នុងទំហំធំ (PI-16 សមាសធាតុ ៣) ដោយសារតែសិទ្ធិអំណាចទូលំទូលាយរបស់រដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័ននានា (យោង PI-27 សមាសធាតុ ៤) ដែលអាចនាំឱ្យមានភាពខុសគ្នារវាងថវិកាដែលបានអនុម័ត នឹងការអនុវត្តជាក់ស្តែង (PI-2, ភាពជឿទុកចិត្តនៃថវិកា)។ ប្រព័ន្ធគ្រប់គ្រងបំណុលមានភាពត្រឹមត្រូវនិងច្បាស់លាស់ ដោយហេតុថាបំណុលរបស់រាជរដ្ឋាភិបាលនៅមានកម្រិតទាប។ ការបូកសរុបសមតុល្យសាច់ប្រាក់ មានដំណើរការល្អ ដោយសារតែប្រសិទ្ធភាពនៃការអនុវត្តគណនីទោលរតនាគារ (PI-17) និងនៅតែល្អប្រសើរចាប់តាំងពីឆ្នាំ២០១០ មក។ ដោយឡែក ការងារលទ្ធកម្មមិនទាន់មានតម្លាភាពពេញលេញ ហើយយន្តការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មឯករាជ្យមិនត្រូវបានបង្កើតឡើងនៅឡើយ។ ការតាមដាននៃអនុលោមភាពតាមបទប្បញ្ញត្តិលទ្ធកម្មត្រូវរាំងស្ទះដោយកង្វះខាតទិន្នន័យ (PI-19)។ ការត្រួតពិនិត្យផ្ទៃក្នុងនៅមានភាពខ្វះចន្លោះមួយចំនួន។ ពាក់ព័ន្ធនឹងបៀវត្សបុគ្គលិក (PI-18) ទិន្នន័យបុគ្គលិក និងទិន្នន័យបញ្ជីបើកប្រាក់បៀវត្ស និងមិនមានសង្គតិភាពនឹងគ្នា ហើយបញ្ជីបើកប្រាក់បៀវត្សមិនត្រូវបានធ្វើសវនកម្មឱ្យបានទូលំទូលាយនៅឡើយ។ លើសពីនេះទៅទៀត ការបើកប្រាក់បៀវត្ស ជាញឹកញាប់ ត្រូវបានពន្យារពេលដែលជាលទ្ធផលនាំឱ្យក្លាយជាបំណុលកកស្ទះ (យោង PI-4)។ ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ចំណាយមិនមែនបៀវត្ស មិនមានភាពទូលំទូលាយ និងជាទូទៅរបាយការណ៍សវនកម្មបានបង្ហាញពីការមិនគោរពតាមវិធានជាធរមាន (PI-20)។ មុខងារនៃសវនកម្មផ្ទៃក្នុង នៅមិនទាន់មានភាពរឹងមាំនៅឡើយ ប៉ុន្តែមានការអភិវឌ្ឍជាវិជ្ជមាន ព្រោះសវនកម្មបានផ្តោតលើបញ្ហាជាលក្ខណៈប្រព័ន្ធ ជាជាងការធ្វើសវនកម្មលើប្រតិបត្តិការដាច់ដោយឡែកៗ (PI-21)។

**គណនេយ្យ ការកត់ត្រា និងរបាយការណ,** សមិទ្ធកម្មសូចនាករចំនួនបួន (PI-22 ដល់ 25) ជាទូទៅបានពិន្ទុទាប, ចន្លោះពី C ទៅ D ប៉ុន្តែការអភិវឌ្ឍជាវិជ្ជមានត្រូវបានកត់សម្គាល់ក្នុងទិដ្ឋភាពជាច្រើននៃសូចនាករ។ ការផ្ទៀងផ្ទាត់ធនាគារនៅតែបន្តបានយ៉ាងទូលំទូលាយ និងទាន់ពេលវេលា (PI-22 សមាសធាតុ ១ បានពិន្ទុ B ទាំងពីរលើក) និងពេលវេលានៃការរៀបចំរបាយការណ៍ថវិកាប្រចាំឆ្នាំ (របាយការណ៍ TOFE) មានភាពប្រសើរឡើង (PI-24 សមាសធាតុ ២)។ ជាក់ស្តែង ការរៀបចំរបាយការណ៍ថវិកាប្រចាំឆ្នាំនេះ ត្រូវបានបង្ហាញឱ្យឃើញពីការកែលម្អ ទាំងនៅក្នុងភាពទាន់ពេលវេលា និងក្នុងការបង្ហាញពីបទដ្ឋានគណនេយ្យ។

**ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ,** វិសាលភាពសវនកម្មលើស្ថាប័ន នៃសវនកម្មផ្ទៃក្រៅ និងការប្រកាន់ខ្ជាប់ទៅនឹងស្តង់ដារសវនកម្មអន្តរជាតិនៅតែមានកម្រិតទាប (PI-26 សមាសធាតុ ១ មិនអាចវាយតម្លៃបាន និង សមាសធាតុ ៣ ទទួលបានពិន្ទុ C ទាំងពីរលើក) ប៉ុន្តែតាមពិតទៅ ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍សវនកម្មត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ (PI-26 សមាសធាតុ ២ បានពិន្ទុ C ក្នុងឆ្នាំ២០១០ រហូតទទួលបានពិន្ទុដល់ទៅ A ក្នុងឆ្នាំ២០១៥)។ មុខងារត្រួតពិនិត្យនៃអង្គនីតិបញ្ញត្តិ ជាទូទៅត្រូវបានអនុវត្តបានល្អនៅក្នុងកម្រិតពិន្ទុ B (PI-27 និង PI-28) បើទោះបីជាការចូលរួមរបស់អង្គនីតិបញ្ញត្តិនៅក្នុងដំណើរការថវិកានៅមានកម្រិត ដោយសារតែការពិនិត្យនៃអង្គនីតិបញ្ញត្តិត្រូវបានធ្វើឡើងក្រោយគម្រោងថវិកាត្រូវបានរៀបចំលម្អិតរួចទៅហើយដោយរាជរដ្ឋាភិបាល ទន្ទឹមនឹងទំហំធំធេងនៃសិទ្ធអំណាចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល ក្នុងការវិភាជថវិកាឡើងវិញដោយពុំចាំបាច់ស្នើសុំការអនុម័តពីអង្គនីតិបញ្ញត្តិជាមុន (PI-27 សមាសធាតុ ១ និង ៤)។ ការផ្លាស់ប្តូររវាងឆ្នាំ២០១០ និងឆ្នាំ

២០១៥ មិនអាចបកស្រាយបានឡើយ ខណៈពេលដែលសូចនាករទាំងពីរនៅលើការត្រួតពិនិត្យដោយអង្គនីតិបញ្ញត្តិ មិនត្រូវបានវាយតម្លៃនៅឆ្នាំ២០១០នោះទេ ។

**ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍,** សូចនាករការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍នៅតែបន្តមានពិន្ទុទាប ដោយសារសូចនាករទាំង៣ ទទួលបានពិន្ទុ D ។ ភាពអាចប៉ាន់ប្រមាណបាននៃការគាំទ្រថវិកាផ្ទាល់ កាន់តែមានភាពទន់ខ្សោយ (D-1 បានពិន្ទុ C ក្នុងឆ្នាំ២០១០ ហើយឆ្នាំ២០១៥ បាន D) ប៉ុន្តែសារៈសំខាន់នៃការគាំទ្រថវិកាផ្ទាល់ក៏បានធ្លាក់ចុះធៀបនឹងតម្រូវការចំណាយសាធារណៈសរុប ដូច្នេះផលប៉ះពាល់នៃការធ្លាក់ចុះពិន្ទុនេះគឺតិចតួចណាស់។ ភាពប្រសើរឡើងមាននៅក្នុងការរាយការណ៍ពីការគាំទ្រគម្រោងតាមរយៈមូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC (D-2) ទាំងសម្រាប់ការរៀបចំថវិកា និងការរាយការណ៍សម្រាប់ការធ្វើរបាយការណ៍ចំណាយជាក់ស្តែង។ ទោះជាយ៉ាងណា ការរាយការណ៍ការអនុវត្តថវិកាដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ នៅតែមានភាពបែកខ្ញែក និងមានភាពយឺតយ៉ាវ ដែលមិនអាចបញ្ចូលបានពេញលេញនៅក្នុងរបាយការណ៍អនុវត្តថវិកា។ ការប្រើប្រាស់ប្រព័ន្ធរបស់ជាតិនៅមានកម្រិតទាប (D-3 បានពិន្ទុ D ទាំងពីរលើក) ប៉ុន្តែមានការកែលម្អគួរឱ្យកត់សម្គាល់ គឺការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ ពីកម្រិត ១២-១៥% ក្នុងឆ្នាំ២០១០ ដល់បច្ចុប្បន្ននេះប្រមាណ ២៥% នៃការផ្តល់ជំនួយពីខាងក្រៅទាំងអស់ បើទោះបីជាមិនគ្រប់គ្រាន់ដើម្បីបង្កើនពិន្ទុក៏ដោយ។

## ឃ.៣ សង្ខេបបម្រែបម្រួលសមិទ្ធកម្មពីឆ្នាំ២០១០

ឧបសម្ព័ន្ធ ១ ប្រៀបធៀបសមិទ្ធកម្មរបស់ពិន្ទុសូចនាករក្នុងការវាយតម្លៃបច្ចុប្បន្នទៅនឹងពិន្ទុនៃការវាយតម្លៃឆ្នាំ ២០១០ ដោយប្រៀបធៀបសូចនាករនឹងសូចនាករ និងរវាងសមាសធាតុសូចនាករទៅនឹងសមាសធាតុសូចនាករ។ សូចនាករ និងសមាសធាតុនៅក្នុងកូឡោនខាងស្តាំ បង្ហាញពីលទ្ធភាពនៃការប្រៀបធៀបពិន្ទុវាយតម្លៃទាំងពីរដោយផ្ទាល់ និងប្រៀបធៀបបម្រែបម្រួលសមិទ្ធកម្មក្នុងការវាយតម្លៃឆ្នាំ២០១៥។

ការប្រៀបធៀបមិនមានអត្ថន័យចំពោះសូចនាករចំនួន ១២ ក្នុងចំណោមសូចនាករទាំង ៣១ ដោយហេតុថា (ក) លក្ខណៈវិនិច្ឆ័យរបស់រចនាសម្ព័ន្ធ និង/ឬ ពិន្ទុសូចនាករនៃក្របខ័ណ្ឌវាយតម្លៃ ត្រូវបានផ្លាស់ប្តូរចាប់តាំងពីការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងឆ្នាំ២០១០ (PI-2, PI-3, និង PI-19); ឬ (ខ) ការវាយតម្លៃឆ្នាំ ២០១០ មិនមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់ ឬមានភាពខុសគ្នារវាងការបកស្រាយព័ត៌មានចាំបាច់ ឬកត្តាផ្សេងៗ ដែលមានឥទ្ធិពលដល់ការផ្តល់ពិន្ទុ។ ចំណែកសូចនាករចំនួន ២ ដទៃទៀត (PI-27 និង PI-28) មិនអាចប្រៀបធៀបបានទេ ព្រោះមិនមានក្នុងការវាយតម្លៃកាលពីឆ្នាំ២០១០។

ទោះជាមិនអាចប្រៀបធៀបរវាងពិន្ទុនឹងពិន្ទុសម្រាប់សូចនាករចំនួន ១០ ក្នុងចំណោមសូចនាករទាំង១៤ ខាងលើ គេអាចធ្វើការប្រៀបធៀបបានទៅតាមទិសដៅនៃបម្រែបម្រួល។ គួរឱ្យកត់សម្គាល់ផងដែរថា ការផ្លាស់ប្តូរសមិទ្ធកម្មនៃសមាសធាតុនីមួយៗរបស់សូចនាករប្រហែលជាអាចមាននៅក្នុងការវាយតម្លៃកាលពីឆ្នាំ២០១០ ប៉ុន្តែមិនមានបម្លាស់ប្តូរក្នុងពិន្ទុសរុបឡើយ។ ផ្អែកលើមូលដ្ឋាននេះ ទិសដៅនៃការផ្លាស់ប្តូរត្រូវបានបង្ហាញនៅក្នុងកូឡោនខាងស្តាំក្នុងតារាង

នេះ ហើយមួយចំនួនអាចបញ្ជាក់បានថាភាពទន់ខ្សោយជាមូលដ្ឋាននៅតែមាននៅក្នុងសូចនាករនោះ ទោះជាមានការធ្វើឱ្យប្រសើរក្នុងទិដ្ឋភាពផ្សេងទៀតក៏ដោយ។

ភាពប្រសើរឡើងក្នុងសមិទ្ធកម្មត្រូវបានបង្ហាញក្នុងសូចនាករចំនួន ៧ របស់រាជរដ្ឋាភិបាល ចំណែកឯការធ្លាក់ចុះពិន្ទុនៃសមិទ្ធកម្មត្រូវបានរកឃើញក្នុងសូចនាករចំនួន ៣ ផ្សេងទៀត។ ការវាស់សមិទ្ធកម្មមិនអាចធ្វើទៅបានទេសម្រាប់សូចនាករចំនួន ៤ ផ្សេងទៀត របស់រាជរដ្ឋាភិបាល។ ដោយឡែក សមិទ្ធកម្មរបស់សូចនាករចំនួន ១៤ មិនបានបង្ហាញអំពីការផ្លាស់ប្តូរសំខាន់ណាមួយគួរឱ្យកត់សម្គាល់ក្នុងទិសដៅទាំងពីរ (សូចនាករ និងសមាសធាតុ)។ សូចនាករទាំង២៨ របស់រាជរដ្ឋាភិបាល និងសមាសធាតុនៃសូចនាករទាំងនេះ ត្រូវបានវាស់វែង, សមាសធាតុ ១១ បានបង្ហាញថា សមិទ្ធកម្មមានការប្រសើរឡើង ទោះបីជាការកើនពិន្ទុសូចនាករចំនួន ៣ មិនមានភាពគ្រប់គ្រាន់សម្រាប់ដំឡើងពិន្ទុរួមក៏ដោយ។ សមិទ្ធកម្មសូចនាករចំនួន ៣ ផ្សេងទៀត បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំណែកឯសមាសធាតុ ៣៩ ផ្សេងទៀតមិនមានការផ្លាស់ប្តូរណាមួយគួរឱ្យកត់សម្គាល់នោះឡើយ។ ការប្រៀបធៀបសមិទ្ធកម្មមិនអាចធ្វើទៅបានសម្រាប់សមាសធាតុនៃសូចនាករចំនួន ១៨ ផ្សេងទៀត។

ភាពប្រសើរឡើងនៃសមិទ្ធកម្មត្រូវបានគេរកឃើញថា ភាគច្រើនជាសូចនាករដែលជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វិន័យថវិកា (PI-1, PI-3, និង PI-16) និងសូចនាករដែលពាក់ព័ន្ធនឹងការតាមដាន និងរបាយការណ៍ប្រតិបត្តិការថវិកា (PI-21, PI-24, PI-25, និង PI-26)។

ការធ្លាក់ចុះរបស់សមិទ្ធកម្មត្រូវបានរកឃើញជាចម្បង ក្នុងសូចនាករដែលជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់យុទ្ធសាស្ត្រវិភាជន៍ធនធាន និងតម្លាភាព (PI-2, PI-6, PI-10)។ ការធ្លាក់ចុះមួយចំនួននៅក្នុងចំណាត់ថ្នាក់សមិទ្ធកម្ម កើតឡើងដោយសារការធ្លាក់ចុះបន្តិចបន្តួចនៃប្រសិទ្ធភាពនៃការអនុវត្ត ដែលពិន្ទុទាំងនេះអាចកើនឡើងវិញប្រសិនបើមានការកែលម្អការអនុវត្ត, ឧទាហរណ៍ ភាពទាន់ពេលវេលានៃការផ្សព្វផ្សាយរបាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ (PI-10)។

# ៦. ការវិវត្តនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល

## ៦.១ វឌ្ឍនភាព និងជំហានបន្ទាប់នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ភាពជឿទុកចិត្តនៃថវិកា គឺជាលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអាចសម្រេចបានលុះត្រាតែសមាសធាតុសំខាន់ចំនួន៥ ត្រូវបានពង្រឹង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពដូចជា÷

(១) ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពថវិកា÷ ការព្យាករណ៍ហានិភ័យនៃថវិកា (ចំណូល-ចំណាយ) មានភាពគ្រប់ជ្រុងជ្រោយ និងសាធារណជនអាចទទួលបាននូវព័ត៌មានសំខាន់ៗស្តីពីថវិកា។

(២) ថវិកាផ្សារភ្ជាប់គោលនយោបាយ÷ ការគោរពតាមប្រតិទិននៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំថវិកា, ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល ត្រូវកំណត់គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពឱ្យមានសង្គតិភាពជាមួយចក្ខុវិស័យរបស់ក្រសួង-ស្ថាប័ន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

(៣) ភាពអាចប៉ាន់ប្រមាណបាន និងការគ្រប់គ្រងការអនុវត្តថវិកា÷ ការអនុវត្តថវិកាអនុលោមតាមគោលការណ៍ត្រឹមត្រូវ និងអាចប៉ាន់ប្រមាណបាន និងមានយន្តការសម្រាប់គ្រប់គ្រងការអនុវត្តថវិកា។

(៤) គណនេយ្យ ការកត់ត្រា និងរបាយការណ៍÷ ការកត់ត្រាបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ តាមប្លង់គណនីដែលអនុវត្តតាមប្រព័ន្ធគណនេយ្យស្តង់ដារអន្តរជាតិ (IPSAS), របាយការណ៍ហិរញ្ញវត្ថុត្រូវបានរក្សាទុកនិងជូនជារបាយការណ៍ដល់ថ្នាក់ដឹកនាំសម្រាប់ការត្រួតពិនិត្យ គ្រប់គ្រង និងការសម្រេចនានា។

(៥) ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ÷ មានយន្តការក្នុងការត្រួតពិនិត្យ និងតាមដានការអនុវត្តអនុសាសន៍ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ, តួនាទីរបស់ស្ថាប័នត្រួតពិនិត្យ និងសវនកម្មខាងក្រៅមានប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាពលើការអនុវត្តថវិកានិងសមិទ្ធកម្មរបស់អង្គភាពអនុវត្តថវិកា។

ទន្ទឹមនេះ ការអនុវត្តកម្មវិធីកែទម្រង់រយៈពេល ១០ឆ្នាំកន្លងទៅ សម្រេចបានលទ្ធផលជាសារវន្តដូចតទៅ÷

**១. ដំណាក់កាលទី១ (២០០៤-២០០៨)**

- លទ្ធផលនៃការអនុវត្តផែនការប្រមូលចំណូលខិតទៅរកថវិកាដែលបានអនុម័ត
- បានលុបបំបាត់កង្វះសាច់ប្រាក់ភ្ញៀរ៉ៃ
- លុបបំបាត់បំណុលកកស្ទះដែលមានរយៈពេលលើសពី៩០ថ្ងៃចាប់ពីឆ្នាំ២០០៧មក

- បានប្រមូលផ្ដុំគណនីរបស់រាជរដ្ឋាភិបាលនិងអនុវត្តគណនីទោលរតនាគារ (TSA)
- ការកែលម្អការរៀបចំថវិកា
- ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី (ឆ្នាំ២០០៨)
- មាតិកាសេដ្ឋកិច្ចថ្មី
- អនុវត្តផែនការយុទ្ធសាស្ត្រថវិកានៅឆ្នាំ២០០៨
- ថវិកាកម្មវិធី (ក្រសួងចំនួន៧ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០០៨)
- ការគ្រប់គ្រងបំណុល
- វិមជ្ឈការហិរញ្ញវត្ថុ។

**២. ដំណាក់កាលទី២ (២០០៩-២០១៥)**

- បានប្រមូលផ្ដុំគណនីទោលរតនាគារ (គ្មានគណនីរដ្ឋាភិបាលត្រូវបានបើកដោយគ្មានការអនុញ្ញាត)
- មន្ត្រីរាជការក្រសួង-ស្ថាប័នចំនួន៣៦ បានបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- បានកែលម្អនីតិវិធីលទ្ធកម្ម (ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១២, អនុក្រឹត្យនិងប្រកាសនានាត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត ឯលិខិតបទដ្ឋានដទៃទៀតកំពុងត្រូវបានរៀបចំ)
- អង្គភាពប្រមូលចំណូលបានបង់ចំណូលថវិកាតាមប្រព័ន្ធធនាគារ
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានដាក់ឱ្យអនុវត្ត
- បានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងអនុវត្តប្រព័ន្ធគ្រប់គ្រងបំណុលនិងវិភាគហិរញ្ញវត្ថុ (DMFAS) ព្រមទាំងបានរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងបំណុល។
- ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យអនុវត្តនៅខែកក្កដា ឆ្នាំ២០១៥
- បានរៀបចំប្លង់គណនីថ្មីពីលេខកូដ ៤ខ្ទង់ មក ៥ខ្ទង់
- បានផ្សព្វផ្សាយព័ត៌មានសំខាន់ៗទៅសាធារណជន ដូចជា TOFE និងថវិកាសង្ខេបជាដើមតាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការរៀបចំវេទិកាសាធារណៈ
- ក្រសួងចំនួន១០ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- ក្រសួង-ស្ថាប័នបានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង។

**៣. ការងារត្រូវធ្វើបន្តក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយ
- រៀបចំចំណាត់ថ្នាក់មុខងាររដ្ឋាភិបាល (COFOG) ឱ្យបានពេញលេញ
- រៀបចំនិងអនុវត្តផែនការសកម្មភាពនៃការដាក់ឱ្យអនុវត្ត FMIS ដំណាក់កាលទី២

- ពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ គឺរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត មានដូចជាអនុក្រឹត្យលេខ៨១ និងអនុក្រឹត្យលេខ៨២
- ពង្រឹងសមត្ថភាពវិភាគ និងព្យាករម៉ាក្រូសេដ្ឋកិច្ច
- ពង្រឹងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- ក្របខ័ណ្ឌថវិការយៈពេលមធ្យមត្រូវបានដាក់ឱ្យអនុម័តដោយគណៈរដ្ឋមន្ត្រី
- សមាហរណកម្មចំណាយចរន្ត និងចំណាយមូលធន ព្រមទាំងហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍
- រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា និងរៀបចំប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម
- លើកកម្ពស់គណនេយ្យភាពនៃក្រសួង-ស្ថាប័ន តាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ។

## ខ.២ កម្មវិធីកែទម្រង់វិស័យរដ្ឋបាល

### ខ.២.១ ការកែទម្រង់រដ្ឋបាលសាធារណៈ

អភិបាលកិច្ចល្អ ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដូចនេះកម្មវិធីកំណែទម្រង់រដ្ឋបាល-សាធារណៈ ជាការងារស្នូលក្នុងការឈានទៅសម្រេចបាននូវគោលបំណង និងគោលដៅរបស់រាជរដ្ឋាភិបាល ដើម្បីបម្រើ និងលើកកម្ពស់ជីវភាពប្រជាជន ក៏ដូចជាភាពរុងរឿងរបស់ប្រជាជាតិទាំងមូល។ ទន្ទឹមនេះកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ក៏សំដៅផ្តោតការយកចិត្តទុកដាក់ទៅលើការកែលម្អ និងពង្រឹងគុណភាពនិងភាពទាន់ពេលវេលានៃការផ្តល់សេវាសាធារណៈជូនប្រជាជន។ កំណែទម្រង់រដ្ឋបាលសាធារណៈ គឺជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់អនាគតនៃការអភិវឌ្ឍប្រទេស តាមរយៈការរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ យុត្តិធម៌សង្គម និងនិរន្តភាពនៃការអភិវឌ្ឍ និងភាពសម្បូរសប្បាយសម្រាប់ប្រជាជន និងប្រទេសជាតិ។ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃរដ្ឋបាលសាធារណៈ គឺត្រូវផ្តើមចេញពីភក្តីភាព ឆន្ទៈខ្ពស់ ជំនាញវិជ្ជាជីវៈ ជាពិសេស ភាពរឹងមាំ និងជឿជាក់នៃស្ថាប័ន។ មួយផ្នែកនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ក៏បានផ្តោតលើវិមជ្ឈការ និងវិសហមជ្ឈការក្នុងបរិបទនៃការផ្តល់សេវា-សាធារណៈផងដែរ។

### ខ.២.២ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈយ៉ាងមោះមុតចំពោះកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងមានជំនឿជឿជាក់ចំពោះតួនាទីដ៏មានសារៈសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ ផ្តើមចេញពីឆន្ទៈនេះ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញ និងគាំទ្រយ៉ាងសកម្មដល់ការរៀបចំ និងការអនុវត្ត

កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយចាប់ផ្តើមចេញពីការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ-សង្កាត់ នាឆ្នាំ ២០០២ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត រួមមាននៅថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ នាឆ្នាំ២០១០ ឱ្យមានការវិវត្តទៅមុខជាលំដាប់ និងទទួលបាននូវសមិទ្ធផលគន្លឹះៗជាច្រើន។

កិច្ចដំណើការកំណែទម្រង់ គឺការផ្ទេរជាជំហានៗនូវការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមួយចំនួនរបស់ថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដោយមានការសម្រេចចិត្តយ៉ាងច្បាស់លាស់ ស្របគ្នាជាមួយនឹងការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់រាជធានី-ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ការសម្របសម្រួល ការគាំទ្រ និងការត្រួតពិនិត្យមើលពីលើ។ នៅក្នុងឆ្នាំ ២០១០ រាជរដ្ឋាភិបាល បានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល ១០ឆ្នាំ (២០១០-២០១៩) ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការអនុវត្តកម្មវិធីជាតិត្រូវបានបែងចែកជា ៣ ដំណាក់កាល និងត្រូវគ្រប់គ្រង និងសម្របសម្រួលដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។ ក្នុងដំណាក់កាលទី១ ផែនការអនុវត្តរយៈពេល ៣ ឆ្នាំ (ផអ៣-ទី១) ដែលត្រូវបានពន្យារពេលមួយឆ្នាំបន្ថែមទៀត (២០១១-២០១៤) ផ្តោតលើការអភិវឌ្ឍប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៤ និងបន្តអនុវត្តដំណាក់ទី២ ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ដោយផ្តោតជាសំខាន់ទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែប្រសើរ កាន់តែមានលក្ខណៈឆ្លើយតប ចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន តាមរយៈ ÷ ការធ្វើវិមជ្ឈការមុខងារក្នុងការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានចាំបាច់នានា(ពីក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ឱ្យទៅក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់) ការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើននូវគំនិតផ្តួចផ្តើមនិងស្វ័យភាពមូលដ្ឋាន និងការបង្កើនធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ.៣ ការគាំទ្រផ្នែកនយោបាយ និងស្ថាប័ន

ពិតណាស់ដូចបានអះអាង និងបរិយាយខាងដើមរួចមកហើយ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាជំហានៗ ឆ្ពោះទៅរកស្តង់ដារអន្តរជាតិ នោះគឺការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលវែង គ្រប់ជ្រុងជ្រោយ និងអនុវត្តយុទ្ធសាស្ត្រ ៤ ជំហាន ឬ/និង ៤ដំណាក់កាលគឺ (១) ការបង្កើនភាពជឿទុកចិត្តនៃថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤) ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។ ដើម្បីសម្រេចបានការងារទាំង៤ ដំណាក់កាលខាងលើ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ត្រូវបានបង្កើតឡើងជាសេនាធិការ នៃគណៈកម្មា-

ធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបំពេញមុខងារក្នុងការដឹកនាំ រៀបចំសម្របសម្រួល ការអនុវត្ត ការតាមដាននិងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ព្រមទាំងក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។

ការធានាបានថាថវិកាពិតជាឧបករណ៍នៃគោលនយោបាយ គឺជាគោលបំណងចម្បងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលនឹងទាមទារការប្តេជ្ញាប្រកបដោយឆន្ទៈមោះមុតឥតរាថយរបស់រាជរដ្ឋាភិបាល ក្នុងការបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់នេះ។ ជាការដកស្រង់បទពិសោធន៍ ចំណុចខ្លាំងដែលនាំឱ្យសម្រេចបាន ជោគជ័យក្នុងពេលកន្លងមកនោះគឺរាជរដ្ឋាភិបាលមានភាពជាម្ចាស់ខ្ពស់ និងមាន÷ (១)-ចក្ខុវិស័យត្រឹមត្រូវ (២)-ឆន្ទៈនយោបាយមុតស្រួចឥតរាថយ (៣)-ការដឹកនាំឈ្លាសវៃរស់រវើកនិងបុរេសកម្ម (៤)-ការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ (៥)-ការចូលរួមឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ដៃគូអភិវឌ្ឍន៍និង (៦)-យន្តការគ្រប់គ្រងតាមដានត្រួតពិនិត្យប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

ជាក់ស្តែងដូចអ្វីដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា÷ បើគិតអំពីអត្ថប្រយោជន៍ដែលយើងទទួលបាន ហើយនឹងបន្តទទួលបានពីការអនុវត្តការកែទម្រង់ទាំងនេះ ធៀបទៅនឹងថ្លៃដែលយើងត្រូវបង់ យើងច្បាស់ជាទទួលស្គាល់ថាវាពិតជាមានតម្លៃដ៏លើសលប់ដូចពាក្យថា "គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានកំណែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ"។ ហេតុនេះហើយទើបជារឿយៗ ម្តងហើយម្តងទៀត សម្តេចបានបញ្ជាក់ថា **កែទម្រង់ គឺរស់ មិនកែទម្រង់ គឺស្លាប់** ដែលចាំបាច់តម្រូវឱ្យមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយហួសពីព្រំសីមារបស់ខ្លួនក្នុងការវិភាគ និងការធ្វើសេចក្តីសម្រេចចិត្តទៀតផងដែរ ទើបអាចធានាបាននូវភាពប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងស្មារតីនេះ ការសម្រេចបាននូវចក្ខុវិស័យចុងក្រោយនៃកម្មវិធីកែទម្រង់នៅឆ្នាំ២០២៥ នឹងនាំកម្ពុជាឱ្យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទំនើបមួយ ដែលនឹងលើកកម្ពស់ការប្រើប្រាស់ប្រភពធនធានសាធារណៈដ៏កម្រប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ ហើយអាចឱ្យរាជរដ្ឋាភិបាលកែលម្អការផ្តល់សេវាសាធារណៈជាមូលដ្ឋានជូនប្រជាពលរដ្ឋបានកាន់តែល្អប្រសើរឡើង។ ទន្ទឹមនេះប្រព័ន្ធទាំងមូលនឹងមានសមត្ថភាពប្រើប្រាស់ធនធានទៅតាមគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល, រាល់ចំណូល និងចំណាយសាធារណៈ នឹងត្រូវបានប្រមូលផ្តុំនិងកត់ត្រាប្រកបដោយតម្លាភាព ទោះជាបានមកពីប្រភពណាក៏ដោយ ហើយមានការត្រួតពិនិត្យសមិទ្ធកម្ម ដើម្បីធានាសម្រេចបានលទ្ធផលចុងក្រោយស្របតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុ។

## ៦.៤ យុទ្ធសាស្ត្រ ការដឹកនាំ និង យន្តការតាមដាននិងត្រួតពិនិត្យ

យុទ្ធសាស្ត្រ ការដឹកនាំ និងយន្តការតាមដាន និងត្រួតពិនិត្យក្នុងអំឡុងពេលជាង១០ឆ្នាំកន្លងមកនេះ កម្ពុជាបានសម្រេចលទ្ធផលជាច្រើនក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ប៉ុន្តែក៏នៅសល់កិច្ចការជាច្រើនដែលចាំបាច់ត្រូវបន្តធ្វើ។ អភិក្រមជាដំណាក់ៗ (Platform Approach) ត្រូវបានជ្រើសរើសជាយុទ្ធសាស្ត្រក្នុងការអនុវត្តការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងតាមមធ្យោបាយ

របស់ខ្លួន។ ជោគជ័យនៃការអនុវត្តជំហានទី១នៅឆ្នាំ២០០៨ គឺនៅពេលដែលប្រព័ន្ធគោលការណ៍ជាមូលដ្ឋាន និងការពង្រឹងកិច្ចការរដ្ឋបាលត្រូវបានអនុវត្ត ភាពជឿទុកចិត្តបាននៃថវិកាត្រូវបានបង្កើននិងត្រូវបានឆ្លុះបញ្ចាំង តាមរយៈការកែលម្អលើការប្រមូលចំណូល, ការបញ្ចេញថវិកា និងការគ្រប់គ្រងសាច់ប្រាក់។ ជាលទ្ធផលភាពអាចប៉ាន់ស្មានបាន និងការត្រួតពិនិត្យការអនុវត្តថវិកាត្រូវបានកែលម្អអាស្រ័យដោយការលុបបំបាត់ចោលនូវបំណុលកកស្ទះ និងបញ្ហាខ្វះសាច់ប្រាក់ ការអនុវត្តចំណាយថវិកាកាន់តែរលូន និងការប្រមូលចំណូលត្រូវបានកែលម្អ។ លើសពីនេះទៅទៀត សមត្ថភាពរបស់រាជរដ្ឋាភិបាលត្រូវបានបង្ហាញតាមរយៈ ជោគជ័យក្នុងការទប់ទល់ទៅនឹងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលក្នុងអំឡុងឆ្នាំ២០០៩ ដល់២០១១ ដោយសារតែប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលដែលត្រូវបានសន្សំពីឆ្នាំ២០០៤ ដល់២០០៨។ ឥឡូវនេះ ជាចំណុចរបត់ដ៏សំខាន់មួយនៃជំហានទី២ ដែលសមាសធាតុថ្មីៗនឹងត្រូវដាក់បញ្ចូល រួមមានប្លង់គណនីថ្មី, មាតិកាថវិកាថ្មី និងកិច្ចប្រតិបត្តិការការងារថ្មី ចូលទៅក្នុងប្រព័ន្ធបច្ចុប្បន្ន ជាមួយនឹងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។ សមាសធាតុ និងប្រព័ន្ធថ្មីនេះ ពិតណាស់នឹងទាមទារនូវជំនាញថ្មី និងវិធីសាស្ត្រថ្មី ក្នុងការប្រតិបត្តិ និងគ្រប់គ្រង។ ទន្ទឹមនេះ ដើម្បីពង្រឹងការងារដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសធាតុផ្សេងទៀតក៏ត្រូវបានត្រៀម និងដាក់បញ្ចូលជាដំណាក់កាលសាកល្បងផងដែរ ដើម្បីឈានទៅរកការបង្កើនការផ្សារភ្ជាប់ថវិកា នឹងគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពវិភាជន៍ និងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ដែលរួមមានផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និងអង្គភាពថវិកា។ ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់តាំងពីឆ្នាំ២០០៨មក ដែលជាដំណាក់កាលដំបូងនៃការកែទម្រង់ប្រព័ន្ធថវិកា។ ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រសម្រាប់ការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០ ក៏ត្រូវបានរៀបចំ ដើម្បីបង្ហាញឱ្យបានច្បាស់លាស់នូវទិសដៅ ក៏ដូចជាការធានានូវភាពស៊ីសង្វាក់គ្នា និងសង្គតិភាពជាមួយនឹងគោលបំណងរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរវាងបណ្តាកម្មវិធីកែទម្រង់ជាគន្លឹះផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងត្រូវបានអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាយន្តការតាមដាន និងត្រួតពិនិត្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានយន្តការ៣ គឺការតាមដាន និងត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ ការតាមដាន និងត្រួតពិនិត្យត្រូវបានធ្វើឡើងជាប្រចាំខែ មានលក្ខណៈផ្ទៃក្នុងសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង (MEF PFM Reform Committee), ជាប្រចាំខែ និងប្រចាំត្រីមាសសម្រាប់គ្រប់ក្រសួង-ស្ថាប័ន តាមរយៈក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន (PFM Working Groups) និងតាមរយៈកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Steering Committee) និងជាប្រចាំត្រីមាស និងប្រចាំឆ្នាំសម្រាប់គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ (PFM Development Partners Committee) តាមរយៈកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM-TWG)។ របាយការណ៍ប្រចាំខែ និងលទ្ធផលនៃកិច្ចប្រជុំប្រចាំខែទាំងនេះ ថ្វីត្បិតតែធ្វើឡើងជាលក្ខណៈផ្ទៃក្នុង តែត្រូវបានចែកផ្សាយយ៉ាងទូលាយ និងជាមូលដ្ឋានសម្រាប់ការរៀបចំរបាយការណ៍ប្រចាំត្រីមាស ព្រមទាំងជាកម្មវត្ថុសម្រាប់ការកោះប្រជុំ

វិសាមញ្ញ របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Steering Committee) ឬ/និងក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Technical Working Group) ក្នុងករណីចាំបាច់។ ការតាមដាននិងត្រួតពិនិត្យប្រចាំត្រីមាស គឺជាការអនុវត្តរួមគ្នាដែលរបាយការណ៍ប្រចាំត្រីមាស ត្រូវបានរៀបចំឡើង ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ដោយផ្អែកលើរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរបស់គ្រប់ក្រសួង-ស្ថាប័ន។ របាយការណ៍ប្រចាំត្រីមាស គឺជារបាយការណ៍ផ្លូវការ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្រោយពីមានការឯកភាពតាមរយៈកិច្ចប្រជុំនៃគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការតាមដាន និងត្រួតពិនិត្យប្រចាំឆ្នាំ គឺជាការអនុវត្តរួមគ្នាដែលរបាយការណ៍ប្រចាំឆ្នាំ នឹងត្រូវបានរៀបចំឡើងដោយ អ.គ.ហ ដោយផ្អែកលើរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរបស់គ្រប់ក្រសួង-ស្ថាប័នជំនាញ។ របាយការណ៍ប្រចាំឆ្នាំ គឺជារបាយការណ៍ផ្លូវការ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្រោយពីមានការឯកភាពតាមរយៈកិច្ចប្រជុំនៃគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ របាយការណ៍ប្រចាំឆ្នាំគឺជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យប្រចាំឆ្នាំ (វិបស្សនា) ដែលការត្រួតពិនិត្យប្រចាំឆ្នាំមានលក្ខណៈទូលាយ និងស៊ីជម្រៅដោយមានទាំងរបាយការណ៍វាយតម្លៃរបស់ក្រុមវាយតម្លៃឯករាជ្យ និងមិនត្រឹមតែជាការត្រួតពិនិត្យវឌ្ឍនភាពនៃផែនការសកម្មភាពប៉ុណ្ណោះទេ តែក៏ជាវេទិកាសម្រាប់ការវាយតម្លៃប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ទាំងមូល ព្រមទាំងជាយន្តការសម្រាប់ការកែលម្អសកម្មភាព ឬ/និងទិសដៅយុទ្ធសាស្ត្រ ថែមទាំងអាចឈានដល់ការកែសម្រួលទិសដៅនៃកំណែទម្រង់ទៀតផងក្នុងករណីចាំបាច់។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១÷ សេចក្ដីសង្ខេបសូចនាករនៃក្របខ័ណ្ឌវាស់សមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ឧបសម្ព័ន្ធ ២÷ សមាសភាពក្រុមការងារវាយតម្លៃ
ឧបសម្ព័ន្ធ ៣÷ បញ្ជីរាយនាមភាគីពាក់ព័ន្ធដែលត្រូវបានសម្ភាសន៍
ឧបសម្ព័ន្ធ ៤÷ បញ្ជីឯកសារយោង
ឧបសម្ព័ន្ធ ៥÷ តារាងទិន្នន័យ
ឧបសម្ព័ន្ធ ៥.១÷ បញ្ជីគ្រឹះស្ថានសាធារណៈរដ្ឋបាល
ឧបសម្ព័ន្ធ ៥.២÷ បញ្ជីសហគ្រាសសាធារណៈ
ឧបសម្ព័ន្ធ ៥.៣÷ ទិន្នន័យលម្អិតសម្រាប់គណនាគម្លាតនៃ PI-2 សមាសធាតុ (១)
ឧបសម្ព័ន្ធ ៥.៤÷ កម្ចី និងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ២០១២-២០១៤
ឧបសម្ព័ន្ធ ៦÷ អនុសាសន៍កែលម្អកង្វះខាតនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ឧបសម្ព័ន្ធ ៧÷ អង្គការលេខនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ឧបសម្ព័ន្ធ ១÷ សេចក្ដីសង្ខេបសូចនាករនៃក្របខ័ណ្ឌវាស់សមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| **១** | **លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ ភាពជឿទុកចិត្តនៃថវិកា** | | | | |
| PI-1 | **ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | B | A | គម្លាតនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកា ដែលជាតម្លៃដាច់ខាត គឺ ឆ្នាំ២០១១ (២,៤%), ឆ្នាំ២០១២ (៣,១%), និងឆ្នាំ២០១៣ (៦,១%) | ពិន្ទុទាំងនេះ មិនអាចប្រៀបធៀបគ្នាបានទាំងស្រុងទេ ដោយហេតុថាមូលដ្ឋាននៃការវាយតម្លៃចំណាយសរុបក្នុងរបាយការណ៍វាយតម្លៃ PEFA ឆ្នាំ២០១០ មិនមានចំណាយមូលធន។<br>ការដកចំណាយមូលធនចេញពីការវាយតម្លៃនេះ គឺដោយសារចំណាយមូលធនទាំងនោះ មិនត្រូវបានវិភាជតាមក្រសួង-ស្ថាប័នទេ តែចំណាយមូលធន គឺស្ថិតក្នុងបន្ទាត់នៃមាតិកាថវិកាមួយដោយឡែក។ ទោះយ៉ាងណាហេតុផលនេះ មិនត្រូវបានចាត់ទុកថាត្រឹមត្រូវ។ ក៏ប៉ុន្តែបើសិនជាមូលដ្ឋាននៃការវាយតម្លៃឆ្នាំ ២០១០ ត្រូវបានប្រើក្នុងការវាយតម្លៃ ឆ្នាំ២០១៥ ដែរនោះ ពិន្ទុ ដែលត្រូវទទួលបាន នៅតែ A ដដែល។ |
| PI-2 | **សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | D | D+ | វិធីសាស្ត្រផ្ដល់ពិន្ទុ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ សម្រាប់ការវាយតម្លៃឆ្នាំ២០១០ សូចនាករនេះ មានតែ ១ សមាសធាតុប៉ុណ្ណោះ។ |
| (១) | កម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយ នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក | D | D | គម្លាតនៃសមាសធាតុក្នុងការអនុវត្តចំណាយមានលើសពី១៥% ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ គឺឆ្នាំ២០១១ (៣៧,៩%) ឆ្នាំ២០១២ (២៥,៤%) និងឆ្នាំ២០១៣ (៣០,៤%)។ | គម្លាតសម្រាប់ PI-2 (១) ក្នុងរបាយការណ៍ឆ្នាំ២០១០ មានមូលដ្ឋានផ្សេង ដែលនាំឱ្យមិនអាចប្រៀបធៀបបាន។ នៅពេលដែលតួលេខត្រូវបានគណនាឡើងវិញ ដោយប្រើប្រាស់វិធីសាស្ត្រ PEFA ឆ្នាំ២០១១ គម្លាតនៅក្នុង |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | សមាសភាគចំណាយមានកម្រិតលើស ១៥% តែនៅក្នុងឆ្នាំ២០០៨ គឺត្រឹម ១៦,១%។ ការប្រៀបធៀបនេះបញ្ជាក់ថា គម្លាតមានទំហំធំ នៅក្នុងឆ្នាំ២០១១, ២០១២ និងឆ្នាំ២០១៣។ |
| (២) | ចំនួនជាមធ្យមនៃការចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុកនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ | - | B | ចំណាយមិនបានគ្រោងទុកជាក់ស្តែងជាមធ្យមសម្រាប់ឆ្នាំ២០១១ ឆ្នាំ២០១២ និង២០១៣ មានស្មើនឹង ៥,៣ %នៃច្បាប់ថវិកា។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ សមាសធាតុ នៃសូចនាករនេះ មិនមាននៅក្នុងការវាយតម្លៃឆ្នាំ២០១០ ឡើយ។ |
| PI-3 | **ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | A | A | ចំណូលក្នុងស្រុកសរុបធៀបនឹងច្បាប់ថវិកាក្នុងឆ្នាំ២០១១ (១០០.៦%) និង ២០១៣ (១០៣.៥%) ដោយឡែកការ អនុវត្តគឺស្ថិតចន្លោះ៩៧%- ១០៦% សម្រាប់២ឆ្នាំ នៃរយៈពេល៣ ឆ្នាំចុងក្រោយនេះ។ | លក្ខណៈវិនិច្ឆ័យនៃការផ្តល់ពិន្ទុសម្រាប់ PI-3 បានប្តូរនៅឆ្នាំ២០១១។ តាមរយៈវិធីសាស្ត្រលើកមុន (ប្រើនៅឆ្នាំ២០១០) រាជរដ្ឋាភិបាលកម្ពុជា បានទទួលពិន្ទុ A ដោយសារលទ្ធផលចំណូលក្នុងឆ្នាំ២០០៦ ប្រមូលបាន ១០៥,១%, ឆ្នាំ២០០៧ ប្រមូលបាន ១២៤,៣% និងឆ្នាំ២០០៨ ប្រមូលបាន ១៣៤, ស្មើ ៧% នៃច្បាប់ថវិកា។ និយាយម្យ៉ាងទៀត លក្ខខណ្ឌ “ការប្រមូលចំណូលក្នុងស្រុកជាក់ស្តែង មានក្រោម ៩៧% នៃចំណូលក្នុងស្រុកដែលគ្រោងទុកក្នុងថវិកា មិនមានច្រើនជាងមួយឆ្នាំ ក្នុង៣ឆ្នាំចុងក្រោយ” ត្រូវបានសម្រេច ដើម្បីទទួលបានពិន្ទុ A។ បើសិនជាវិធីសាស្ត្របច្ចុប្បន្ន ត្រូវបានប្រើប្រាស់នោះពិន្ទុនឹងធ្លាក់ទៅកម្រិត D វិញ ដោយហេតុថាការប្រមូលចំណូលក្នុងស្រុកជាក់ស្តែង មានលើសពី ១១៦% នៃចំណូលក្នុងស្រុកដែលគ្រោងទុកក្នុងថវិកា |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | មាន២ឆ្នាំ គឺឆ្នាំ២០០៧ និង ឆ្នាំ២០០៨។ ដូចនេះ សមិទ្ធកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹងក្នុងឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ២០១០។ |
| PI-4 | **សន្និធិបំណុលកកស្ទះនិងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ** | C+ | D+ | វិធីសាស្រ្តផ្តល់ពិន្ទុ M1 | ការប្រៀបធៀប មិនអាចធ្វើទៅរួច រីឯការផ្លាស់ប្តូរតាំងពីឆ្នាំ២០១០ មិនអាចវាយតម្លៃបាន។ |
| (១) | កម្រិតស្តុកនៃចំណាយដែលនៅជំពាក់ (គិតជាភាគរយនៃចំណាយសរុបជាក់ស្តែងសម្រាប់ឆ្នាំថវិកាដែលពាក់ព័ន្ធ) និងការប្រែប្រួលថ្មីៗនៅក្នុងស្តុកចំណាយដែលនៅជំពាក់នេះ | A | D | ចំនួនប៉ាន់ស្មាននៃបំណុលដែលមិនទាន់សង ដែលលើសពី៦០ថ្ងៃ សម្រាប់ទំនិញនិងសេវា ព្រមទាំងបំណុលកកស្ទះនៃបៀវត្ស និង បំណុលកកស្ទះនៃអត្រាការប្រាក់បំណុល រួមទាំងការពិន័យ បញ្ជាក់ថា សន្និធិសរុបនៃបំណុលកកស្ទះ មានទំហំធំជាង ១០% នៃចំណាយសរុប។ ការប៉ាន់ស្មាននេះប្រហែលច្រើនជាងនេះទៀត ប្រសិនបើទិន្នន័យអាចរកបានក្នុងវិក្កយបត្រសម្រាប់អាណត្តិទូទាត់ដែលមិនទាន់ត្រូវបានបោះផ្សាយ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ ពិន្ទុ ឆ្នាំ២០១០ ផ្អែកលើការពិនិត្យចំពោះកិច្ច លើអាណត្តិដែលមិនទាន់បានទូទាត់ តែមិនបានបញ្ចូលបំណុលកកស្ទះនៃបៀវត្ស ឬ សេវាបំណុលឡើយ។ |
| (២) | ទិន្នន័យដែលអាចស្វែងរកបានសម្រាប់ការត្រួតពិនិត្យតាមដាននៃចំណាយដែលនៅជំពាក់ | C | C | ទោះបីជាទិន្នន័យដែលរក្សាទុកក្នុងប្រព័ន្ធកត់ត្រាអាចទាញយកដាក់ក្នុងប្រព័ន្ធ Excel ដើម្បីរៀបចំជារបាយការណ៍ និងត្រូវបានប្រើប្រាស់ដើម្បីផ្តល់ទិន្នន័យសម្រាប់ PEFA ២០១៥នេះ, ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ មិនមែនជាមុខងារប្រចាំថ្ងៃឡើយ រីឯប្រព័ន្ធក៏មិនទាន់មានមុខងារពេញលេញនៅឡើយ។ | នៅឆ្នាំ២០១០ ក្រុម PEFA បានបញ្ជាក់អំពីស្ថានភាពនៃអាណត្តិបើកប្រាក់ តាមរយៈការពិនិត្យ (ដោយមិនស្វ័យប្រវត្តិ) គំនរនៃអាណត្តិបើកប្រាក់ ដែលមិនត្រូវបានទូទាត់នៅអគ្គនាយកដ្ឋានរតនាគារជាតិ។ ចាប់តាំងពីពេលនោះមក ប្រព័ន្ធ KIT ត្រូវបានបង្កើតឡើង។ ទោះយ៉ាងណា ប្រព័ន្ធស្វ័យប្រវត្តិនេះ ត្រូវបានបង្កើតឡើងដើម្បីតាមដានការបញ្ជាការទូទាត់ ចាប់ពីការទទួលវិក្កយបត្រនៅអគ្គនាយកដ្ឋានរតនាគារជាតិ តែមិនមែនប្រើដើម្បីត្រួតពិនិត្យស្តុកនៃបំណុលកកស្ទះទាំងអស់នោះទេ។ ពិន្ទុមិនអាចប្រៀបធៀបបាន ដោយសារ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | បំណុលកកស្ទះ ជាបៀវត្ស និង សេវាបំណុល មិនត្រូវបានចាត់បញ្ចូលនៅក្នុងការវាយតម្លៃ ឆ្នាំ២០១០ ។ |
| ២ | **ការទារត្រួតស៊ីគ្នាសំខាន់ៗ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា** | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | មាតិកាដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកានិងគណនេយ្យ ក្នុងឆ្នាំសារពើពន្ធ២០១៤ មានតែចំណាត់ថ្នាក់រដ្ឋបាលនិងចំណាត់ថ្នាក់សេដ្ឋកិច្ចប៉ុណ្ណោះ។ | ប្រព័ន្ធចំណាត់ថ្នាក់ ដែលត្រូវបានប្រើសម្រាប់កិច្ចដំណើរការនៃការរៀបចំថវិកា និង គណនេយ្យ មិនខុសគ្នាពីការវាយតម្លៃលើកមុនទេ។ ការកែលម្អលើចំណាត់ថ្នាក់តាមមុខងារនិងកម្មវិធី មិនទាន់គ្រប់ជ្រុងជ្រោយ ដើម្បីបានពិន្ទុល្អជាងនេះនៅឡើយ។ |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃពត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | B | C | ឯកសារថវិកាចំនួន ៣ ក្នុងចំណោមឯកសារថវិកាសរុបចំនួន ៩ (១, ៣, ៨) មានក្នុងឯកសារសំណើថវិកា ដែលត្រូវបានបញ្ជូនទៅអង្គនីតិបញ្ញត្តិ ក្នុងឆ្នាំ២០១៥។ | ចំនួនសមាសធាតុសំខាន់ៗ ដែលជាលក្ខខណ្ឌសម្រាប់ការវាយតម្លៃនិងដាក់ពិន្ទុ បានធ្លាក់ចុះពីចំនួន ៥ នៅឆ្នាំ ២០១០ មក ចំនួន ៣ នៅឆ្នាំ២០១៥ ដោយសារតែសមាសធាតុទី២ និងទី៩ មិនត្រូវបានរៀបចំសមស្របតាមលក្ខខណ្ឌ។ ឱនភាពថវិកា មិនត្រូវបានកំណត់តាមទម្រង់ GFS ទេ រីឯការប៉ាន់ប្រមាណអំពីផលប៉ះពាល់ផ្នែកថវិកា ដោយសារការផ្លាស់ប្តូរគោលនយោបាយ មិនត្រូវបានពន្យល់នៅក្នុងឯកសារថវិកាឡើយ។ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានការផ្លាស់ប្តូរតាំងពីឆ្នាំ២០១០។ |
| (១) | ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍ | C | C | ផ្អែកលើគំរូរបស់នាយកដ្ឋាន ការព្យាករណ៍ចំណូលមិនមែនសារពើពន្ធ បញ្ជាក់ថាកម្រិតនៃចំណាយបន្ថែមដែលមិនត្រូវបានរាយការណ៍មានច្រើនជាង ៥% ប៉ុន្តែទាបជាង ១០% នៃចំណាយថវិកាសរុបរបស់រដ្ឋ។ | គ្មានការផ្លាស់ប្តូរពិន្ទុ តាំងពីឆ្នាំ២០១០ ក៏ប៉ុន្តែវិធីសាស្ត្រនៃការប៉ាន់ប្រមាណ សម្រាប់ឆ្នាំ២០១០ និង ឆ្នាំ២០១៥ គឺខុសគ្នាទាំងស្រុង។ ទោះយ៉ាងណា ខ្ទង់ចំណាយប្រហាក់ប្រហែល ដែលមិនត្រូវបានរាយការណ៍ មាន |

| លេខ.វ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួល ពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | ទំហំដូចគ្នា សម្រាប់ទាំង ២ ឆ្នាំនេះ។ ដូចគ្នា សម្រាប់ការប្រមូលនិងការរាយការណ៍អំពីចំណូលមិនមែនសារពើពន្ធ មិនមានការផ្លាស់ប្តូរ គួរឱ្យកត់សម្គាល់ រវាងឆ្នាំ២០១០ និង ឆ្នាំ២០១៥ ទេ។ |
| (២) | ព័ត៌មានស្តីពីចំណូល-ចំណាយ សម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ | C | C | គ្រប់ថវិកាគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ខាងក្រៅ (ការព្យាករណ៍) មានបង្ហាញនៅក្នុងឯកសារថវិកា ផ្នែកលើកម្មវិធីវិនិយោគសាធារណៈ។ ការអនុវត្តចំណាយ ជាក់ស្តែង មានបង្ហាញក្នុងរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ ប៉ុន្តែមានភាពពេញលេញ ចំពោះតែគម្រោងដែលប្រើប្រាស់កម្ចី។ ការព្យាករណ៍ឱ្យបានសុក្រឹតពីទំហំគម្រោងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានកត់ត្រានៅក្នុងរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំមិនអាចធ្វើទៅរួចឡើយ ប៉ុន្តែតាមការប៉ាន់ស្មានមានទំហំតិចជាង ៥០%។ | គ្មានការផ្លាស់ប្តូរ ចាប់ពីឆ្នាំ២០១០។ ប្រព័ន្ធ មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទេ។ |
| **PI-8** | **តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិនិងក្រោមជាតិ)** | **C+** | **B** | វិធីសាស្រ្តផ្តល់ពិន្ទុ M2 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ដោយសារសមាសធាតុ (១)។ គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ |
| (១) | តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ | C | A | ឃុំសង្កាត់ ជាទូទៅពឹងផ្អែកទាំងស្រុងលើ ឧបត្ថម្ភធនពីមូលនិធិឃុំ-សង្កាត់។ ការវិភាជ តាមខ្សែបណ្តោយ (Vertical) ទៅមូលនិធិ និងការវិភាជតាមខ្សែទទឹង (Horizontal) ទៅគ្រប់ឃុំ-សង្កាត់ ផ្អែកលើប្រព័ន្ធដែលមានតម្លាភាពនិងមានរូបមន្តច្បាស់លាស់។ | មានការផ្លាស់ប្តូរតិចតួចនៅក្នុងប្រព័ន្ធសមិទ្ធកម្ម។ ភាពខុសគ្នានៃការផ្តល់ពិន្ទុ ប្រហែលជាដោយសារអ្នកវាយតម្លៃនៅឆ្នាំ២០១០ មានការបកស្រាយផ្សេង អំពីតម្លាភាព ដោយផ្សារភ្ជាប់ជាមួយការគណនាអំពីអត្រានៃភាពក្រីក្រនិងអត្រាប្រជាជន សម្រាប់ឃុំ-សង្កាត់នីមួយៗ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (២) | ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបានស្តីពីការវិភាជថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំ-សង្កាត់ត្រូវបានផ្តល់ព័ត៌មាន អំពីឧបត្ថម្ភធនដែលនឹងត្រូវទទួលបាន ក្នុងរវាងប៉ុន្មានខែ មុននឹងបញ្ចប់ការរៀបចំថវិការបស់ខ្លួន រីឯការផ្តល់ថវិកាធ្វើឡើងតាមកាលវិភាគច្បាស់លាស់ ដោយមានការពន្យារពេលតែចំពោះ ឃុំ-សង្កាត់ណាដែលមិនបានផ្តល់របាយការណ៍ត្រីមាសទាន់ពេលវេលា | គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ |
| (៣) | កម្រិតនៃការប្រមូលសរុបទិន្នន័យសារពើពន្ធរបស់រដ្ឋាភិបាលដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ | D | D | ចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់វិស័យនៃ ចំណាយ មិនត្រូវបានបញ្ចូលទាំងក្នុងប្លង់គណនីរបស់រដ្ឋបាលថ្នាក់ជាតិ និងរបស់រដ្ឋបាលឃុំ-សង្កាត់។ | គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ |
| **PI-9** | **ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ** | C+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ចាប់ពីឆ្នាំ២០១០។ |
| (១) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់កណ្តាលទៅលើអង្គភាពស្វ័យតនិងសហគ្រាសរដ្ឋ | C | C | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធទទួលបានរបាយការណ៍ប្រចាំឆ្នាំពីគ្រប់សហគ្រាសសាធារណៈនិងភាគច្រើននៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ការប្រមូលសរុបរួមនៃរបាយការណ៍ថវិកាត្រូវបានរៀបចំ (មិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា) ប៉ុន្តែមិនបានកំណត់ និងវិភាគពីហានិភ័យហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ជាតិឡើយ ហើយគ្របដណ្តប់តែ ៦០%នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលប៉ុណ្ណោះ។ | មានការរីកចម្រើនតិចតួច។ បច្ចុប្បន្ន អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ រៀបចំការប្រមូលសរុប ព័ត៌មានហិរញ្ញវត្ថុនៃសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។ ក៏ប៉ុន្តែ នៅតែមិនគ្រប់គ្រាន់ សម្រាប់បានពិន្ទុខ្ពស់ជាងមុន។ |
| (២) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ស្ថានភាពហិរញ្ញវត្ថុនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានតាមដានជាត្រីមាស និងរៀបចំជារបាយការណ៍ដាច់ដោយឡែកពីគ្នា សម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង របាយការណ៍នេះមិនបានកំណត់ ឬ វិភាគពីបញ្ហាហានិ | មិនមានការផ្លាស់ប្តូរក្នុងលទ្ធផល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ភ័យហិរញ្ញវត្ថុទេ តាមការអនុវត្ត ឃុំ-សង្កាត់មិនអាចបង្កើតជាហានិភ័យទៅលើរដ្ឋបាលថ្នាក់ជាតិបានទេ។ | |
| PI-10 | **លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ** | C | D | ពុំមានលក្ខខណ្ឌណាមួយ ក្នុងចំណោម ៦ ត្រូវបានបំពេញឡើយ។ ទោះបីជាមានឯកសារចំនួន ៤ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក៏មានការយឺតយ៉ាវក្នុងការផ្សព្វផ្សាយដែរ។ | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ ភាពយឺតយ៉ាវ នៃការផ្សព្វផ្សាយរបាយការណ៍ក្នុងឆ្នាំ នាំឱ្យពិន្ទុធ្លាក់ចុះ។ ក្រៅពីនេះ មានការរីកចម្រើន នៅលើចំណុចផ្សេងទៀត ក៏ប៉ុន្តែ នៅតែមិនគ្រប់គ្រាន់ ដើម្បីបានពិន្ទុខ្ពស់ជាងមុន ដែលមានដូចជាលក្ខខណ្ឌ [iii], [iv] និង [vi]។ សម្រាប់លក្ខខណ្ឌ [i] លទ្ធភាពរបស់សាធារណជនដើម្បីស្តាប់សុន្ទរកថារបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាឱកាសពិនិត្យសេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០១៥ គឺជាការរីកចម្រើនមួយ។ |
| **៣** | **ទដ្ឋថវិកា** | | | | |
| **៣.១** | **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | | |
| PI-11 | **កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ** | A | A | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ចាប់ពីឆ្នាំ២០១០។ |
| (១) | អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា | A | A | ក្រសួង-ស្ថាប័នមានរយៈពេល ៤ ទៅ ៥សប្តាហ៍ ក្នុងមួយដំណាក់កាល ដើម្បីរៀបចំថវិកាទាំងពីរដំណាក់កាល ពោលគឺសរុបប្រហែល ៩ សប្តាហ៍។ ដំណាក់កាលទាំង២ មានពិដានថវិកា (ទន់ភ្លន់) ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះ មានការពន្យាររយៈពេលខ្លីដោយក្រសួង-ស្ថាប័នមួយចំនួន តែមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ និងមិនមានអ្វីប៉ះពាល់ដល់ការអនុវត្តតាមកាលវិភាគឡើយ។ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ ប្រព័ន្ធ និងការអនុវត្តប្រព័ន្ធ នៅតែដដែល ក៏ប៉ុន្តែ ការវាយតម្លៃឆ្នាំ២០១០ បានផ្តល់ពិន្ទុ A ទោះបីមានការពន្យារការផ្តល់គម្រោងថវិកា នៅក្នុងខែកក្កដា ដោយក្រសួង-ស្ថាប័ន មួយចំនួនក៏ដោយ ដែលបញ្ហានេះ កើតឡើងក្នុងឆ្នាំ២០០៨ និងឆ្នាំ២០១៤ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (២) | ភាពច្បាស់លាស់/ភាពគ្រប់ជ្រុងជ្រោយ និងការចូលរួមផ្នែកនយោបាយ ក្នុងការណែនាំអំពីការរៀបចំដាក់សំណើថវិកា | A | A | សារាចរផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដោយផ្អែកលើការអនុម័តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការសើរើ និងការធ្វើអាទិភាវូបនីយកម្មឡើងវិញនូវគោលនយោបាយ។ សារាចររៀបចំកញ្ចប់ថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល និងផ្ញើជូនគ្រប់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត។ ការកំណត់ពិដានពីលើចុះក្រោម គឺកំណត់សម្រាប់ចំណាយសរុប (ថវិកាចរន្ត និងថវិកាមូលធន ត្រូវកំណត់ដាច់ពីគ្នា) និងសម្រាប់វិស័យទាំង ៤ (សង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាលទូទៅ និងការពារជាតិ និងសន្តិសុខសាធារណៈ) ជាភាគរយ នៃ ផ.ស.ស (ជាការចង្អុលបង្ហាញ)។ ការរៀបចំគម្រោងថវិកាលម្អិត ដោយក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ត្រូវផ្អែកលើ កម្រិតកំណើនធៀបនឹងឆ្នាំចាស់ដែលអនុញ្ញាត សម្រាប់ចំណាត់ថ្នាក់សេដ្ឋកិច្ច នីមួយៗ។ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ ប្រព័ន្ធ និង ការអនុវត្តប្រព័ន្ធ នៅតែដដែល។ |
| (៣) | ការអនុម័តថវិកាទាន់ពេលវេលា ដោយអង្គនីតិប្បញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល | A | A | ច្បាប់ថវិកាត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់៣ឆ្នាំសារពើពន្ធចុងក្រោយនេះ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ ប្រព័ន្ធ និង ការអនុវត្តប្រព័ន្ធ នៅតែដដែល |
| PI-12 | **ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា គោលនយោបាយចំណាយនិងការរៀបចំថវិកា** | B | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល ចាប់ពីឆ្នាំ២០១០ ព្រោះការផ្លាស់ប្តូរពិន្ទុ គឺដោយសារមានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងលទ្ធផលនៃសមាសធាតុ (៣)។ |
| (១) | ការរៀបចំនូវការព្យាករណ៍ថវិកាពហុឆ្នាំ និងការវិភាជតាមមុខងារ | C | C | ការព្យាករណ៍ថវិកាសរុបរយៈពេល៣ឆ្នាំ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយផ្អែកលើសមាសធាតុធំៗនៃសេដ្ឋកិច្ច។ ប៉ុន្តែមិនមានការញែកចេញជាចំណាត់ថ្នាក់វិស័យ មុខងារ ឬរដ្ឋបាល ហើយប | មានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងលទ្ធផលនៃសមាសធាតុនេះ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំទៀតក៏មិនត្រូវបានពន្យល់លម្អិតឡើយ។ | |
| (២) | វិសាលភាពនិងភាពញឹកញាប់នៃការវិភាគនិរន្តរភាពបំណុល | A | A | ការវិភាគចីរភាពបំណុលដែលគ្របដណ្តប់បំណុលបរទេស និង ក្នុងស្រុក ត្រូវបានគ្រប់គ្រងនិងពិនិត្យជាប្រចាំឆ្នាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | “ការវិភាគចីរភាពបំណុល” នៅតែត្រូវបានបន្តធ្វើបច្ចុប្បន្នកម្មជាប្រចាំឆ្នាំ (មិនមានការផ្លាស់ប្តូរពិន្ទុ)។ ទោះយ៉ាងណា សមត្ថភាពក្នុងការរៀបចំ “ការវិភាគ ចីរភាពបំណុល” ត្រូវបានបង្កើននៅក្នុង កសហវ ដែលកំពុងរ៉ាប់រងមុខងារនេះដោយខ្លួនឯង ដែលកាលពីក្នុងការវាយតម្លៃលើកមុន មុខងារនេះ គឺរ៉ាប់រងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក។ |
| (៣) | យុទ្ធសាស្ត្រតាមវិស័យដែលមានការគណនាចំណាយចរន្តនិងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ | B | C | វិស័យអប់រំ និងវិស័យសុខាភិបាលបានធ្វើការកំណត់ចំណាយយ៉ាងពេញលេញក្នុងផែនការយុទ្ធសាស្ត្រដោយបានតម្រឹមជាមួយនឹងថវិកាសរុប។ វិស័យទាំងពីរនេះ ស្មើនឹងប្រមាណ ២៣%នៃចំណាយអាទិភាពសរុប។ ដោយឡែក សម្រាប់វិស័យផ្សេងទៀតក៏មានផែនការយុទ្ធសាស្ត្រដែរ ប៉ុន្តែមិនមានការព្យាករណ៍ចំណាយច្បាស់លាស់ និងនៅមិនទាន់មានសង្គតិភាព។ | សមិទ្ធកម្ម មានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ។ វិស័យអប់រំ និង សុខាភិបាល នៅតែជាវិស័យដែលមានការរៀបចំចំណាយក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ឱ្យមានសង្គតិភាពទៅនឹងការព្យាករណ៍ណ៍ថវិកា។ ទោះយ៉ាងណា សារៈសំខាន់នៃវិស័យទាំងនេះ បានធ្លាក់ចុះពី ២៦% មក ២៣% នៃចំណាយថវិកា ដែលធ្វើឱ្យពិន្ទុធ្លាក់មក C វិញ ដោយសារកម្រិតចំណាយថវិកាក្នុងវិស័យទាំងនេះត្រូវមានយ៉ាងតិច ២៥% នៃចំណាយថវិកាសរុប ដើម្បីបានពិន្ទុលើសពីនេះ។ |
| (៤) | ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគ និងការព្យាករណ៍ចំណាយរំកិល | C | C | ការសម្រេចចិត្តវិនិយោគ គឺធ្វើឡើងដោយផ្អែកលើប្រភពធនធានខាងក្រៅច្បាស់លាស់ ជាជាងការយកយុទ្ធសាស្ត្រវិស័យជាមូលដ្ឋាន។ បច្ច័យជាចំណាយចរន្តសម្រាប់អាទិភាពគម្រោងមិន | សមិទ្ធកម្មមានភាពខុសគ្នាតិចតួចប៉ុណ្ណោះ ព្រោះការរៀបចំថវិកាចរន្ត និង វិនិយោគ នៅតែរៀបចំតាមដំណើរការដាច់ដោយឡែកពីគ្នាដដែល រីឯការផ្សារភ្ជាប់រវាង |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | បានដាក់បញ្ចូលធាតុផ្សំសំខាន់សម្រាប់ការជ្រើសរើស និងមានតែនៅក្នុងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ អមដោយថវិកាចរន្តសម្រាប់ប្រតិបត្តិការ និងការថែទាំ | សេចក្តីសម្រេចវិនិយោគ និងយុទ្ធសាស្ត្រសម្រាប់វិស័យនៅមិនទាន់ល្អនៅឡើយ។ |
| **៣.២** | **ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា** | | | | |
| PI-13 | **តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ** | B | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ សមិទ្ធកម្មទាំងមូល មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទេ។ |
| (១) | ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយ នៃគោលការណ៍ច្បាប់ និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ | B | C | នៅមានកង្វះខាត÷ (១) លិខិតបទដ្ឋានគតិយុត្តពន្ធ ត្រូវរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ និង (២) ការប្រើប្រាស់សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលចំណូលក្នុងការសម្រេច ឬការបកស្រាយភាពមិនច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្តត្រូវមានការថយចុះ ដើម្បីឱ្យក្របខ័ណ្ឌច្បាប់មានតម្លាភាពនិងយុត្តិធម៌ (ឧទាហរណ៍ ពន្ធលើប្រាក់ចំណេញ, អាករលើតម្លៃបន្ថែម និងពន្ធគយ)។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍ PEFA ឆ្នាំ២០១០ មិនបានកំណត់ឱ្យច្បាស់នូវចន្លោះប្រហោង និងបញ្ហាដែលមាននៅក្នុងច្បាប់ស្តីពីសារពើពន្ធទេ។ ទោះបីនេះជាចំណុចដ៏មានសារៈសំខាន់ តែនៅតែមិនមានការប្រែប្រួលពីលើកមុន។ ទោះយ៉ាងណាការពិនិត្យកែសម្រួលលើបទប្បញ្ញត្តិពាក់ព័ន្ធ កំពុងត្រូវបានរៀបចំបន្ត។ |
| (២) | លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល | B | B | មានព័ត៌មានជាច្រើន ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានវេទិកាដែលជំរុញការជជែកពិភាក្សា រវាងរដ្ឋាភិបាលនិងវិស័យឯកជន។ ប៉ុន្តែត្រូវពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលចំណូល និងធានាឱ្យមានធនធានថវិកា ដើម្បីពង្រឹងសេវាពន្ធ និងអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយនិងងាយស្រួល, ទាន់ពេលវេលា (ឧទាហរណ៍ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយជាបន្តបន្ទាប់) | ព័ត៌មានកាន់តែមានច្រើនជាងមុន នៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ, កិច្ចសន្ទនា និងការអប់រំសម្រាប់អ្នកបង់ពន្ធ។ យ៉ាងនេះក៏ដោយ បញ្ហាកង្វះធនធាន ជាឧបសគ្គនៃការពង្រីកវិសាលភាពសេវាសម្រាប់អ្នកបង់ពន្ធ ដែលនាំឱ្យសមិទ្ធកម្មទាំងមូល មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ពីការវាយតម្លៃលើកមុន។ |
| (៣) | ដំណើរការនៃយន្តការតវ៉ាពន្ធ | C | C | ប្រព័ន្ធនិងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធមានចែង | មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ |

| លរ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ច្បាស់លាស់រួចហើយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ប្រព័ន្ធនេះ ដំណើរការ មិនបានពេញលេញតាមច្បាប់ជាធរមានទេ។ | |
| PI-14 | **ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ** | C | D+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ មិនមានការផ្លាស់ប្តូរ គួរឱ្យកត់សម្គាល់ នៅក្នុងលទ្ធផល។ |
| (១) | ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ | C | D | ប្រព័ន្ធចុះបញ្ជីពន្ធនៅមានកង្វះខាត ជាពិសេស ព័ត៌មានអ្នកជាប់ពន្ធនៅមិនទាន់ភាពសុក្រឹតឬភាពពេញលេញ ព្រមទាំងដំណើរការដាក់បញ្ចូលអ្នកជាប់ពន្ធថ្មីមិនទាន់ស៊ីសង្វាក់គ្នារវាងស្ថាប័ន និងស្ថាប័ន និងផ្ទៃក្នុងស្ថាប័ន។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍ PEFA ឆ្នាំ២០១០ ផ្តល់ពិន្ទុ C សម្រាប់ PI-14 (១) ដោយហេតុថាលេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) ត្រូវបានរៀបចំ សម្រាប់គ្រប់ប្រភេទសារពើពន្ធធំៗ។ ទោះយ៉ាងណា របាយការណ៍វាយតម្លៃឆ្នាំ២០១០ មិនបានលើកឡើងនូវ ចំណុចខ្សោយដ៏ចម្បង នៃការត្រួតពិនិត្យ នៅក្នុងប្រព័ន្ធចុះបញ្ជីទេ។ សម្រាប់ការវាយតម្លៃលើកនេះ ពិន្ទុ C អាចទទួលបាន លុះត្រាតែការចុះអង្កេតអំពីអ្នកបង់ពន្ធ ដែលមានសក្តានុពល ត្រូវបានធ្វើតែជាក់ស្តែង សកម្មភាព មិនត្រូវបានរៀបចំទេ។ គ្មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ នៅក្នុងលទ្ធផល។ |
| (២) | ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ | C | C | និតិវិធីច្បាប់នៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធមិនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដោយហេតុថា (១) ការផាកពិន័យនៅមានកម្រិតទាប (២) មានបញ្ហាប្រឈមច្រើន ក្នុងការតាមដាន និងការចាប់បង្ខំឱ្យអនុវត្តតាមច្បាប់។ | គ្មានការផ្លាស់ប្តូរ។ ទំហំនៃការផាកពិន័យ មិនមានការផ្លាស់ប្តូរ។ ការពង្រឹងការអនុវត្ត នៅតែជាបញ្ហា។ |
| (៣) | ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និង | C | C | នៅពេលដែលការអនុវត្តសវនកម្មពន្ធត្រូវបានកែលម្អនឹងពង្រឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យនៃការគេចវេសពន្ធ មិនទាន់ | គ្មានបម្រែបម្រួលពិន្ទុ គួរឱ្យកត់សម្គាល់។ ចាប់តាំងពីមានវឌ្ឍនភាពល្អ ក្រោយឆ្នាំ២០១០ ការធ្វើសវនកម្ម |

| លរ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | កម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ | | | ត្រូវបានរៀបចំបានពេញលេញ និងតាមស្តង់ដារ។ លើសពីនេះទៅទៀត វិសាលភាពនៃការអនុវត្តសវនកម្មនៅមានកម្រិត គឺត្រូវបានអនុវត្តទៅលើតែទំនិញនាំចូលនិងនាំចេញ (ចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) និងគ្របដណ្តប់លើអ្នកជាប់ពន្ធធំតាមរបបពិត តិចតួចប៉ុណ្ណោះ (ចំពោះអគ្គនាយកដ្ឋានពន្ធដារ) | នៅក្នុង អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានកំណត់តែសម្រាប់អ្នកបង់ពន្ធមួយចំនួន។ |
| PI-15 | **ប្រសិទ្ធភាពនៃការប្រមូលពន្ធ** | D+ | D+ | វិធីសាស្ត្រនៃការផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានបម្រែបម្រួលគួរឱ្យកត់សម្គាល់ នៅក្នុង សមិទ្ធកម្ម។ |
| (១) | អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធដុល ដែលជាភាគរយនៃបំណុលពន្ធនៅដើមឆ្នាំសារពើពន្ធ និងដែលត្រូវបានប្រមូលក្នុងឆ្នាំសារពើពន្ធនោះ | D | D | បំណុលពន្ធសរុបមានទំហំធំ ហើយអនុបាតប្រមូលពន្ធក្នុងឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ស្ថិតក្រោម ៦០% (១៧,៨% ក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣) | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ ទោះយ៉ាងណា បំណុលពន្ធ ដែលត្រូវបានប្រមូល គិតជាភាគរយ នៃស្តុកបំណុលពន្ធនៅដើមឆ្នាំ មានកំណើន នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ រហូតដល់១៧,៨% ធៀបនឹងឆ្នាំ២០០៨ ដែលប្រមូលបានតែ ៤,៥%។ ទោះយ៉ាងណា លទ្ធផលវិជ្ជមាននេះ មិនទាន់គ្រប់គ្រាន់ដើម្បីបានពិន្ទុខ្ពស់ជាងលើកមុនទេ។ |
| (២) | ប្រសិទ្ធភាពនៃការផ្ទេរប្រាក់ពន្ធដែលប្រមូលបានទៅរតនាគារ ដោយរដ្ឋបាលចំណូល | B | B | ចំណូលភាគច្រើនត្រូវបានផ្ទេរទៅកាន់ រតនាគារជាតិជារៀងរាល់ថ្ងៃ។ ចំណូលពន្ធមួយចំនួនត្រូវបានប្រមូលដោយការិយាល័យគយនិងរដ្ឋាករ កម្ពុជា និងសាខាពន្ធដារខេត្ត-ខណ្ឌ និងត្រូវបានរក្សាទុកនៅធនាគារ។ ប្រាក់ទាំងនេះមិនត្រូវបានផ្ទេរជារៀងរាល់ថ្ងៃទេ ប៉ុន្តែយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍។ | គ្មានបម្រែបម្រួលពិន្ទុ។ ប្រព័ន្ធនៃការផ្ទេរចំណូល សារពើពន្ធ មិនមានការប្រែប្រួល។ |
| (៣) | ពេលវេលា នៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគាររវាងការវាយតម្លៃពន្ធ, ការប្រមូលពន្ធ, | C | C | ពន្ធដែលប្រមូលបានត្រូវបានផ្ទៀងផ្ទាត់ជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារទទួលបានភស្តុតាងដែលបញ្ជាក់ថាអ្វីផ្សេងៗទៀតត្រូវបានកត់ត្រាជារៀងរាល់ឆ្នាំ | គ្មានបម្រែបម្រួល។ របាយការណ៍ PEFA ឆ្នាំ២០១០ ផ្អែកលើព័ត៌មាន ដែលផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវបានផ្ទៀងផ្ទាត់ ជាប្រចាំខែ សម្រាប់ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | កំណត់ត្រាបំណុលពន្ធ និង វិក្កយបត្រ | | | | ការប្រមូលនិងការវាយតម្លៃពន្ធ និងជាប្រចាំឆ្នាំ សម្រាប់បំណុលពន្ធ។ នៅក្នុងរបាយការណ៍ PEFA ឆ្នាំ២០១៥ មានតែការផ្ទៀងផ្ទាត់ជាប្រចាំឆ្នាំប៉ុណ្ណោះ ដែលត្រូវបានសង្កេតឃើញ និងត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការវាយតម្លៃ។ |
| PI-16 | **ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ** | C+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ ការរីកចម្រើន មាននៅក្នុងសមាសធាតុ (១)។ |
| (១) | វិសាលភាពដែលលំហូរសាច់ប្រាក់អាចព្យាករណ៍បាន និងត្រូវបានត្រួតពិនិត្យ | C | B | ការព្យាករណ៍សាច់ប្រាក់ត្រូវបានធ្វើបច្ចុប្បន្ន-កម្មប្រចាំត្រីមាស ដោយផ្អែកលើលំហូរសាច់ប្រាក់ជាក់ស្តែងត្រីមាសមុន និងព្យាករណ៍ឡើងវិញចំពោះពេលវេលាដែលនៅសល់ក្នុងឆ្នាំ។ | សមាសធាតុ (១) ៖ ការកើនពិន្ទុលើសពិន្ទុកាលពីឆ្នាំ២០១០ ដោយសារលំហូរព័ត៌មាន ពីក្រសួង-ស្ថាប័ន មកអង្គភាពគ្រប់គ្រងសាច់ប្រាក់ ត្រូវបានពង្រឹងឱ្យកាន់តែប្រសើរជាងមុន រីឯការព្យាករណ៍សាច់ប្រាក់របស់គណៈកម្មាធិការបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ កាន់តែគួរឱ្យជឿជាក់។ |
| (២) | សុក្រឹតភាព និងការផ្តល់ថវិកាគ្រប់គ្រាន់ ទាន់ពេលវេលាសម្រាប់ការគ្រោងចំណាយដោយក្រសួង-ស្ថាប័ន | B | B | ក្រសួង ស្ថាប័ន អាចរៀបចំកម្មវិធីចំណូល និងចំណាយរបស់ខ្លួនជារៀងរាល់ត្រីមាស | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| (៣) | អត្រានៃការកើតឡើង (frequency) និង តម្លាភាពនៃការផ្ទេរថវិកាដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន | C | C | ការផ្ទេរថវិកាក្នុងឆ្នាំ មានចំនួនច្រើននិងកើតឡើងច្រើនដង ប៉ុន្តែមានតម្លាភាព។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| PI-17 | **ការកត់ត្រានិងការគ្រប់គ្រង សម** | C+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានបម្រែបម្រួលគួរ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | **តុល្យសាច់ប្រាក់, បំណុល និងការធានា** | | | | ឱ្យកត់សម្គាល់ នៅក្នុងលទ្ធផល។ |
| (១) | គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល | C | C | កំណត់ត្រាបំណុលក្នុងស្រុក និងក្រៅស្រុក មានភាពពេញលេញ និងត្រូវបានធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍ឥណទាយីជាទៀងរាល់ឆ្នាំ | មានការរីកចម្រើន នៅក្នុងការរាយការណ៍អំពីបំណុល ក៏ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់ ដើម្បីបានពិន្ទុខ្ពស់ជាងមុន។ |
| (២) | វិសាលភាពនៃការប្រមូលសរុបសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល | B | B | តុល្យភាពសាច់ប្រាក់ភាគច្រើនត្រូវបានគណនា និងប្រមូលសរុបយ៉ាងហោចណាស់មួយសប្តាហ៍ម្តង។ | គ្មានបម្រែបម្រួល។ |
| (៣) | ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការចេញផ្សាយការធានា | C | C | ការចុះកិច្ចសន្យាកម្ចី និងប័ណ្ណធានា សុទ្ធសឹងត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងដែនកំណត់សម្រាប់បំណុលសរុប ប៉ុន្តែមិនមែនពុំទាន់មានប័ណ្ណធានាទេ។ | គ្មានបម្រែបម្រួល។ |
| **PI-18** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស** | **D+** | **D+** | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល។ |
| (១) | ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | គ្មានការភ្ជាប់គ្នាដោយផ្ទាល់រវាងបញ្ជីបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស។ ប៉ុន្តែបញ្ជីប្រាក់បៀវត្ស ប្រចាំខែនីមួយៗ មានភ្ជាប់មកជាមួយឯកសារយោងគ្រប់គ្រាន់ ហើយក្រសួង ស្ថាប័នបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ទៅលើបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ។ | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល ចាប់ពីឆ្នាំ២០១០។ |
| (២) | ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិកនិងបញ្ជីប្រាក់បៀវត្ស | C | C | មានការយឺតយ៉ាវរហូតដល់ទៅ៣ខែ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស ព្រមទាំងមាននិយ័តកម្មច្រើនលើបញ្ជីទាំងនោះ (ប្រហែល ៣០%) | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល ចាប់ពីឆ្នាំ២០១០។ |
| (៣) | ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់ | B | B | សិទ្ធអំណាចនៃការសម្រេចលើការផ្លាស់ប្តូរស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្ស មានចែងច្បាស់លាស់ ទោះបីជាគ្មានការធ្វើសវនកម្ម | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល ចាប់ពីឆ្នាំ២០១០។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | បៀវត្ស | | | ទៅលើការអនុវត្តសិទ្ធអំណាចនេះក៏ដោយ។ | |
| (៤) | ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្ស ដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច | D | D | គ្មានការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល ចាប់ពីឆ្នាំ២០១០។ |
| **PI-19** | **តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** | **NA** | **D** | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M2 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ បម្រែបម្រួល នៅក្នុងលទ្ធផល មិនអាចវាយតម្លៃបាន។ |
| (១) | មានក្របខ័ណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | NA | B | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (២០១២) ឆ្លើយតបបានតាមលក្ខខណ្ឌតម្រូវ៤ ក្នុងចំណោម ៦ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ដោយហេតុថាការវាយតម្លៃ ទាំងពីរលើក អនុលោមតាមវិធីសាស្ត្រដោយឡែកពីគ្នា។ |
| (២) | ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | NA | D | គ្មានព័ត៌មានគ្រប់គ្រាន់ សម្រាប់កំណត់ថាតើកិច្ចសន្យាក្នុងឆ្នាំ២០១៤ ត្រូវបានរៀបចំនិងអនុវត្ត ស្របតាមលិខិតបទដ្ឋានគតិយុត្តដែរឬទេ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ដោយហេតុថាការវាយតម្លៃ ទាំងពីរលើក អនុលោមតាមវិធីសាស្ត្រដោយឡែកពីគ្នា។ |
| (៣) | សាធារណជនអាចទទួលបានព័ត៌មានស្តីពីកិច្ចលទ្ធកម្មបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន | NA | D | គ្មានប្រព័ន្ធសម្រាប់ការផ្តល់ព័ត៌មានជាក់លាក់ស្តីពីកិច្ចលទ្ធកម្មដល់សាធារណជនទេ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ដោយហេតុថាការវាយតម្លៃ ទាំងពីរលើក អនុលោមតាមវិធីសាស្ត្រដោយឡែកពីគ្នា។ |
| (៤) | មានយន្តការឯករាជ្យសម្រាប់ដោះស្រាយរាល់បណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម | NA | D | គ្មានស្ថាប័នឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្មទេ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ដោយហេតុថាការវាយតម្លៃ ទាំងពីរលើក អនុលោមតាមវិធីសាស្ត្រដោយឡែកពីគ្នា។ |
| **PI-20** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស** | C | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ទាំងស្រុង។ ទោះយ៉ាងណា គ្មានបម្រែបម្រួលគួរឱ្យកត់សម្គាល់ នៅក្នុង |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | លទ្ធផលឡើយ។ |
| (១) | ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនៃការធានាចំណាយ | C | C | គោលការណ៍ណែនាំបានណែនាំតែអំពីនីតិវិធីសម្រាប់ធានាចំណាយចរន្តប៉ុណ្ណោះ។ លើសពីនេះទៅទៀត សំណើធានាចំណាយបន្ទាន់ ឬ សំណើធានាចំណាយពិសេស មិនត្រូវបានអនុវត្តតាមនីតិវិធីទាំងស្រុងទេ។ | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផលចាប់ពីឆ្នាំ២០១០។ |
| (២) | ភាពគ្រប់ជ្រុងជ្រោយ ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង | C | C | មានគោលការណ៍ណែនាំអំពីការត្រួតពិនិត្យជាទូទៅ ក៏ប៉ុន្តែករណីមួយចំនួន ដូចជា ចំណាយវិនិយោគនិងការគ្រប់គ្រងទ្រព្យសកម្ម នៅមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់នៅឡើយ។ | មានការលំបាក ក្នុងការប្រៀបធៀបពិន្ទុទាំងពីរលើក ដោយហេតុថា ការវាយតម្លៃឆ្នាំ២០១០ មិនបានលើកឡើងអំពីគម្លាតនិងភាពមិនច្បាស់លាស់ នៃវិធាននៃការត្រួតពិនិត្យផ្ទៃក្នុង។ ទោះយ៉ាងណា មានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ នៅក្នុងអំឡុងពេល ៥ ឆ្នាំនេះ។ |
| (៣) | កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការនិងការកត់ត្រាកិច្ចប្រតិបត្តិការ (Transaction) | C | C | អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ បានបង្ហាញថា ការមិនអនុលោមទៅតាមច្បាប់មានការកើតឡើងជាញឹកញាប់។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| **PI-21** | **ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង** | **D+** | **C** | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ ការរីកចម្រើន មាននៅក្នុង សមាសធាតុ (១)។ |
| (១) | វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង | D | C | មុខងារជាសវនកម្មផ្ទៃក្នុង គ្របដណ្តប់ក្រសួង-ស្ថាប័ននិងអង្គភាពរបស់រាជរដ្ឋាភិបាលនិងការពិនិត្យជាប្រព័ន្ធ (ជាង 20% នៃពេលវេលាសវនករ) | ពិន្ទុ បានកើនឡើងលើសពីឆ្នាំ២០១០ ដែលបានត្រឹម D ដោយហេតុថា កាលពីលើកមុនមិនមានការផ្តោតទៅលើបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធ។ |
| (២) | ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង | C | C | សវនកម្មផ្ទៃក្នុងដាក់របាយការណ៍ជូនប្រធានស្ថាប័នសាមី និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ប៉ុន្តែនៅមិនទាន់ផ្ញើមកក្រសួងសេដ្ឋកិច្ច | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | និងហិរញ្ញវត្ថុ | |
| (៣) | ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង | C | C | អនុសាសន៍របស់សវនករត្រូវបានយកទៅអនុវត្តតាម នៅក្រសួង-ស្ថាប័នមួយចំនួនប៉ុណ្ណោះ<br>ពិសេសបញ្ហាប្រឈមចំបង ប៉ុន្តែជាញឹកញាប់មានការពន្យារពេលអនុវត្ត។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| ៣.៣ | **គណនេយ្យ, ការកត់ត្រា និងរបាយការណ៍** | | | | |
| **PI-22** | **ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី** | C | C | វិធីសាស្ត្រដាក់ពិន្ទុ M2 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ គ្មានបម្រែបម្រួលគួរឱ្យកត់សម្គាល់ នៅក្នុងលទ្ធផល។ |
| (១) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ | B | B | ការផ្ទៀងផ្ទាត់គណនីធនាគារដែលគ្រប់គ្រងដោយរតនាគារជាតិទាំងអស់ត្រូវបានបញ្ចប់ប្រចាំខែនៅក្នុងរយៈពេល ២ សប្តាហ៍។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| (២) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់និងការទូទាត់គណនីរង់ចាំនិងគណនីបុរេប្រទាន | D | D | ការផ្ទៀងផ្ទាត់និងការទូទាត់នៃគណនីបុរេប្រទានភាគច្រើនចំណាយពេលវេលាយូររហូតដល់ ២ ខែ។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| **PI-23** | **អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា** | C | D | មិនមានការប្រមូលទិន្នន័យព័ត៌មានគ្រប់ជ្រុងជ្រោយអំពីធនធានដែលទទួលបានដោយសាលាបឋមសិក្សា និងមណ្ឌលសុខភាពនោះទេ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ ការវាយតម្លៃក្នុងឆ្នាំ២០១០ បានផ្តល់ពិន្ទុ C ដោយមិនបានសំអាងលើការទទួលធនធាន។ គ្មានបម្រែបម្រួល បានកើតឡើងមុនឆ្នាំ២០១៥ ទេ។ |
| **PI-24** | **គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ ការរីកចម្រើន មាននៅក្នុង សមាសធាតុ (១)។ |
| (១) | វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាពនិង | C | C | ការធ្វើចំណាត់ថ្នាក់ទិន្នន័យនៅក្នុងរបាយការណ៍នានា អាចនាំឱ្យការប្រៀបធៀប ធ្វើទៅបានជាមួយថវិកានៃគ្រប់អង្គភាពរដ្ឋបាលសំ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | សមិតភាពជាមួយនឹងការព្យាករណ៍ថវិកា | | | ខាន់ៗ ប៉ុន្តែនៅត្រឹមតែដំណាក់កាលទូទាត់ប៉ុណ្ណោះ | |
| (២) | ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍ | B | A | របាយការណ៍ត្រូវបានរៀបចំប្រចាំខែ និងចេញផ្សាយនៅក្នុងរយៈពេល៤ សប្តាហ៍។ | ភាពទាន់ពេលវេលានៃរបាយការណ៍អនុវត្តថវិកា ពីថ្នាក់ខេត្ត មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ |
| (៣) | គុណភាពនៃព័ត៌មាន | C | C | ចំណាយក្រោមគម្រោងហិរញ្ញប្បទានពីខាងក្រៅ ពុំមានដាក់បញ្ចូលក្នុងរបាយការណ៍ តែបញ្ហាអំពីសុក្រឹតភាព មានតិចតួចប៉ុណ្ណោះ និងមិនប៉ះពាល់ដល់គុណភាពនៃរបាយការណ៍ឡើយ។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| **PI-25** | **គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | D+ | D+ | វិធីសាស្ត្រដាក់ពិន្ទុ M1 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ ការរីកចម្រើន មាននៅក្នុង សមាសធាតុ (១) និង (៣) ។ |
| (១) | ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ | D | D | ព័ត៌មានសំខាន់ៗ មិនមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ | គ្មានបម្រែបម្រួល ចាប់ពីឆ្នាំ២០១០។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ | C | B | របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៣ ត្រូវបានដាក់បញ្ជូនទៅ NAA នៅក្នុងរយៈពេល ១០ ខែបន្ទាប់ពីដំណាច់ឆ្នាំ។ | ភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានបញ្ជូនមក លឿនជាងមុន ពី៣ ទៅ ៥ខែ។ |
| (៣) | បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ | D | C | របាយការណ៍នានាត្រូវបានរៀបចំ ដោយមានសង្គតិភាពខ្លះទៅនឹងទម្រង់នៃបទដ្ឋានគណនេយ្យ។ | វឌ្ឍនភាព រួមមាន ការរៀបចំរបាយការណ៍ក្នុងទម្រង់តែមួយ ដោយបានបង្ហាញជាអន្លើពីបទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់។ |
| ៣.៤ | **ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ** | | | | |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| PI-26 | **វិសាលភាព ចរិតលក្ខណៈ និង ការតាមដានបន្តនៃសវនកម្មពីខាងក្រៅ** | D+ | NR | វិធីសាស្ត្រវាយតម្លៃ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ សមាសធាតុ (១) និង (២) មានវឌ្ឍនភាពរីកចម្រើនគួរឱ្យកត់សម្គាល់។ |
| (១) | វិសាលភាព/ចរិតលក្ខណៈរបស់សវនកម្មដែលត្រូវបានធ្វើឡើង (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម) | D | NR | ៩០-១០០% នៃចំណាយសរុបត្រូវបានគ្របដណ្តប់ ប៉ុន្តែឯកសារអំណះអំណាងពុំមានគ្រប់គ្រាន់ឡើយ | វឌ្ឍនភាពប្រសើរជាងមុន ដោយហេតុថា វិសាលភាពនៃសវនកម្ម ត្រូវបានពង្រីក តាំងពីឆ្នាំ២០១០។ មិនអាចប្រៀបធៀបបានដោយសារខ្វះឯកសារអំណះអំណាង។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់សភា | C | A | របាយការណ៍សវនកម្ម ត្រូវបានបញ្ជូនទៅរដ្ឋសភាក្នុងអំឡុងពេល ០៤ ខែ បន្ទាប់ពីទទួលបានរបាយការណ៍ទូទាត់ថវិកា | វឌ្ឍនភាពប្រសើរជាងមុន។ លទ្ធផល ដ៏គួរឱ្យកត់សម្គាល់ គឺ ភាពទាន់ពេលវេលានៃរបាយការណ៍សវនកម្ម។ |
| (៣) | ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម | C | C | មានចំណាត់ការអនុវត្តជាផ្លូវការតាមអនុសាសន៍ ប៉ុន្តែមិនមានភស្តុតាងបញ្ជាក់ពីការអនុវត្តជាប្រព័ន្ធ តាមអនុសាសន៍សវនកម្ម។ | គ្មានបម្រែបម្រួល គួរឱ្យកត់សម្គាល់ តាំងពីឆ្នាំ២០១០។ |
| PI-27 | **ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ** | NU | C+ | វិធីសាស្ត្រវាយតម្លៃដាក់ពិន្ទុ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ បម្រែបម្រួលនៃលទ្ធផល មិនអាចវាយតម្លៃបាន។ |
| (១) | វិសាលភាពនៃការត្រួតពិនិត្យរបស់អង្គនីតិប្បញ្ញត្តិ | NU | C | អង្គនីតិប្បញ្ញត្តិត្រួតពិនិត្យលើសេចក្តីលម្អិតនៃចំណូល-ចំណាយនៅដំណាក់កាលដែលសេចក្តីព្រាងចំណូល-ចំណាយលម្អិត ត្រូវបានរៀបចំបញ្ចប់ដោយរាជរដ្ឋាភិបាលរួចទៅហើយ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| (២) | កម្រិតនៃការរៀបចំនីតិវិធីបានល្អ និងការអនុវត្តនីតិវិធីបានត្រឹមត្រូវក្នុងអង្គនីតិប្បញ្ញត្តិ | NU | B | មាននីតិវិធីសាមញ្ញសម្រាប់ការពិនិត្យនិងអនុម័តដោយអង្គនីតិប្បញ្ញត្តិ ហើយនីតិវិធីនេះត្រូវបានអនុវត្ត។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| (៣) | ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិ ក្នុងការឆ្លើយតបទៅ | NU | C | រយៈពេលសម្រាប់ការពិនិត្យ និងអនុម័តដោយ អង្គនីតិប្បញ្ញត្តិមានប្រមាណ ៧ សប្តាហ៍។ ក្នុងការអនុវត្តជាក់ស្តែង អង្គនីតិ- | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | នឹងសំណើថវិកា | | | ប្បញ្ញត្តិ ត្រូវការពេលវេលាតិចជាងនេះសម្រាប់ពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ថវិកា។ | មិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| (៤) | វិធានស្តីពីការកែតម្រូវថវិកាក្នុងឆ្នាំ ដោយពុំចាំបាច់មានការយល់ព្រមជាមុនឬក្រោយពីអង្គនីតិប្បញ្ញត្តិ | NU | B | បទប្បញ្ញត្តិសម្រាប់ការកែសម្រួលឥណទានថវិកានៅក្នុងឆ្នាំអនុវត្តថវិកាដោយពុំចាំបាច់មានការអនុម័តជាមុនពីអង្គនីតិប្បញ្ញត្តិ ត្រូវបានចែងនិងអនុវត្តតាមច្បាស់លាស់, ព្រមទាំងពុំអនុញ្ញាតឱ្យមានការបង្កើនចំណាយនៅក្នុងឆ្នាំឡើយ (ទោះបីជាការប្រមូលចំណូលទទួលបានលើសពីការចែងក្នុងច្បាប់ក៏ដោយ) | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| PI-28 | **ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិប្បញ្ញត្តិ** | NU | B | វិធីសាស្ត្រវាយតម្លៃ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ បម្រែបម្រួល នៅក្នុងលទ្ធផល មិនអាចវាយតម្លៃបាន។ |
| (១) | ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្ម ដោយអង្គនីតិប្បញ្ញត្តិ | NU | B | របាយការណ៍សវនកម្មត្រូវបានពិនិត្យ ហើយការត្រួតពិនិត្យដោយអង្គនីតិប្បញ្ញត្តិ ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ខែជាមធ្យម ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| (២) | ការរៀបចំសវនាការដោយអង្គនីតិ-ប្បញ្ញត្តិ លើរបកគំហើញគន្លឹះ | NU | B | សវនាការលម្អិតត្រូវបានរៀបចំ ដោយមាន ការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃអង្គភាពរង សវនកម្ម ប៉ុន្តែពុំត្រូវបានរៀបចំសម្រាប់គ្រប់ស្ថាប័នរងសវនកម្មឡើយ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| (៣) | អនុសាសន៍របស់អង្គនីតិប្បញ្ញត្តិ និងការអនុវត្តសកម្មភាពអនុលោមតាមអនុសាសន៍ដោយអង្គនីតិប្រតិបត្តិ | NU | B | អង្គនីតិប្បញ្ញត្តិបានផ្តល់អនុសាសន៍ដល់អង្គនីតិប្រតិបត្តិ ហើយអនុសាសន៍មួយចំនួនត្រូវបានអនុវត្តតាម។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ មិនបានដាក់ពិន្ទុសូចនាករនេះ ព្រោះមិនមានលទ្ធភាពក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| ៤ | **ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍** | | | | |

| លរ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| D-1 | **ការប៉ាន់ប្រមាណ Budget Support** | C | D | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាដោយផ្ទាល់បាន។ សមិទ្ធកម្ម មានការធ្លាក់ចុះ គឺជាអំណះអំណាង។ |
| (១) | តម្លាតការអនុវត្ត Budget Support ប្រចាំឆ្នាំពីការព្យាករណ៍ដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ដោយយ៉ាងហោចណាស់៦សប្តាហ៍មុនពេលរដ្ឋាភិបាលបញ្ជូនសំណើថវិការបស់ខ្លួនទៅស្ថាប័ននីតិប្បញ្ញត្តិ | C | D | ការផ្តល់ Budget Support ជាក់ស្តែង មានតិចជាងផែនការ គឺលើសពី ១៥ %ក្នុងរយៈពេល២ឆ្នាំ នៃ៣ឆ្នាំសារពើពន្ធចុងក្រោយ (២០១២-២០១៤) គឺមាន ៦៧ %និង៦៤ %នៃឆ្នាំនីមួយៗ។ | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន។ ការធ្លាក់ចុះនៃការអនុវត្តជាក់ស្តែងនូវការគាំទ្រថវិកាផ្ទាល់ធៀបនឹងកិច្ចព្រមព្រៀង/គម្រោង កាន់តែមានភាពមិនល្អ គិតចាប់ពីឆ្នាំ២០១០។ ទោះជាយ៉ាងណា អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១០ គួរតែត្រូវបានពិន្ទុ A ដូចនេះនៅតែជាការធ្លាក់ចុះនៃពិន្ទុ។ |
| (២) | ភាពទាន់ពេលវេលានៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (អនុលោមភាពជាមួយការប៉ាន់ស្មានប្រចាំត្រីមាសសរុប) | NU | D | មិនបានផ្តល់ការព្យាករណ៍ហិរញ្ញប្បទានប្រចាំត្រីមាស | គ្មានបម្រែបម្រួលនៅក្នុងលទ្ធផល ដោយហេតុថា ម្ចាស់ជំនួយ មិនបានបែងចែកផ្តល់ថវិកា ជាប្រចាំត្រីមាសក្នុងរយៈពេល ៣ ឆ្នាំ មុនឆ្នាំ២០១០។ |
| D-2 | **ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី** | D | D+ | ការផ្តល់ពិន្ទុតាមវិធីសាស្ត្រ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ លទ្ធផលវាយតម្លៃប្រសើរជាងមុន។ |
| (១) | ភាពពេញលេញ និងភាពទាន់ពេលវេលានៃការប៉ាន់ប្រមាណថវិការបស់ម្ចាស់ជំនួយសម្រាប់ការគាំទ្រគម្រោង | D | C | គ្រប់ដៃគូអភិវឌ្ឍន៍ផ្តល់ការព្យាករណ៍អំពីការផ្តល់ថវិកាប្រចាំឆ្នាំបានមុនការរៀបចំថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល តែព័ត៌មានពាក់ព័ន្ធទាំងឡាយ ត្រូវរៀបចំតាមប្រព័ន្ធនៃមាតិកាថវិការបស់រាជរដ្ឋាភិបាល។ | ការបញ្ជូនរបាយការណ៍ ទៅក្នុងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានពង្រឹងនិងបានផ្តល់សឹងគ្រប់គម្រោងជំនួយរបស់ដៃគូ សម្រាប់ឆ្នាំបន្ទាប់។ |
| (២) | អត្រានៃការកើតឡើង និងវិសាលភាពនៃការរាយការណ៍ដោយម្ចាស់ | D | D | គ្រប់ដៃគូអភិវឌ្ឍន៍ បានផ្តល់ទិន្នន័យជាប្រចាំឆ្នាំអំពីការផ្តល់ថវិកាជាក់ស្តែង តែមិនមានរបាយការណ៍ជាប្រចាំត្រីមាសទេ រីឯព័ត៌មាន | ការផ្តល់របាយការណ៍ អំពីការផ្តល់ថវិកាបច្ចុប្បន្ន ត្រូវបានពង្រឹងឱ្យកាន់តែប្រសើរជាងមុន តាំងពីឆ្នាំ២០១០ |

| លស.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៥ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | ជំនួយ អំពីលំហូរជំនួយជាក់ស្តែងសម្រាប់ការគាំទ្រគម្រោង | | | មិនត្រូវបានផ្តល់តាមទម្រង់នៃប្រព័ន្ធមាតិកាថវិការបស់រដ្ឋាភិបាលទេ។ | ប៉ុន្តែ នៅតែមិនទាន់គ្រប់លក្ខខណ្ឌ ដើម្បីទទួលបាននូវពិន្ទុខ្ពស់ជាងមុន។ ព័ត៌មាន កាន់តែមានភាពពេញលេញ។ |
| D-3 | **ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ** | D | D | ការប្រើប្រាស់ប្រព័ន្ធជាតិ ស្ថិតក្នុងចន្លោះពី ២៣%- ៣០ % ពោលគឺទាបជាង ៥០%ដែលជាភាគរយចាំបាច់ សម្រាប់ទទួលបានពិន្ទុ C។ | ទោះបីពិន្ទុ មិនមានការប្រែប្រួល តែលទ្ធផលនៃសូចនាករនេះ មានភាពល្អប្រសើរជាងមុន គួរឱ្យកត់សម្គាល់។ របាយការណ៍វាយតម្លៃ ឆ្នាំ២០១០ បានបង្ហាញថា មានពី ១២-១៦% នៃជំនួយអភិវឌ្ឍន៍ បានប្រើប្រាស់នូវប្រព័ន្ធក្នុងប្រទេស នាពេលនោះ។ |

## ឧបសម្ព័ន្ធ ២÷ សមាសភាពក្រុមការងារវាយតម្លៃ

| ឈ្មោះ | ស្ថាប័ន | មុខតំណែង |
|---|---|---|
| **អ្នកគ្រប់គ្រងការវាយតម្លៃ នៃ អ.គ.ហ** | | |
| **ឯកឧត្តមបណ្ឌិត សុខ សារាវុឌ្ឍ** | កសហវ | អនុរដ្ឋលេខាធិការ កសហវ និងជាអគ្គលេខាធិការ នៃ អ.គ.ហ រហូតមកដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ |
| **ឯកឧត្តម រស់ សីលវ៉ា** | កសហវ | អនុរដ្ឋលេខាធិការ កសហវ និងជាអគ្គលេខាធិការ នៃ អ.គ.ហ ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ |
| **អ្នកសម្របសម្រួលនិងផ្តល់ការណែនាំលើកិច្ចដំណើរការវាយតម្លៃ** | | |
| Mr. Joshi Suhas | IMF | ទីប្រឹក្សា IMF ប្រចាំតំបន់ |
| **ក្រុមទទួលបន្ទុកការវាយតម្លៃ នៃ អ.គ.ហ** | | |
| **ឯកឧត្តមបណ្ឌិត ម៉េង ចំរើន** | កសហវ | អគ្គលេខាធិការ នៃ កសហវ និងជាអគ្គលេខាធិការរង នៃ អ.គ.ហ |
| **លោក យ៉េត វីណែល** | កសហវ | អគ្គលេខាធិការរង នៃ កសហវ និងជាអគ្គលេខាធិការរង នៃ អ.គ.ហ |
